ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការផ្តល់ប្រឹក្សាអាជីព

# និង

# ព័ត៌មានស្តីពីការសិក្សាជំនាញ

ក្រសួងអប់រំ យុវជន និងកីឡា

២០១៦

# មាតិកា


| | | ទំព័រ |
|---|---|---|
| បុព្វកថា | | ០២ |
| សេចក្តីផ្តើម | | ០៣ |
| **ផ្នែកទី១** | **មេរៀនអនុវត្តផ្នែកប្រឹក្សាអាជីព** | ០៥ |
| ១. | ការស្គាល់ខ្លួនឯង | ០៦ |
| ២. | ជីវិត និងក្តីសុបិននៃអាជីព | ១២ |
| ៣. | ការសិក្សា | ១៨ |
| ៤. | ជំនាញ និងភាពខ្លាំង | ២៨ |
| ៥. | ការអប់រំ និងជម្រើសនៃអាជីព | ៤០ |
| ៦. | កម្មវិធីសិក្សាផ្នែកប្រឹក្សាអាជីពនៅមធ្យមសិក្សា | ៨២ |
| ៧. | ការប្រឹក្សាយោបល់ពីការសិក្សា និងបញ្ហាផ្ទាល់ខ្លួន | ៩៦ |
| **ផ្នែកទី២** | **ការវាយតម្លៃបុគ្គលិកលក្ខណៈដើម្បីតម្រង់ទិសជំនាញ** | ១៤២ |
| ១. | វិធីស្វែងយល់ពីខ្លួនឯង | ១៤៣ |
| ២. | ការស្វែងរកព័ត៌មានបន្ថែម | ១៥៨ |
| ៣. | ការបង្កើតគម្រោងឆ្ពោះទៅរកអាជីព | ១៦៤ |
| ៤. | ការបន្តអភិវឌ្ឍជំនាញ និងចំណេះដឹង | ១៧១ |
| **ផ្នែកទី៣** | **ព័ត៌មានស្តីពីការសិក្សា គ្រឹះស្ថានសិក្សា និងមុខរបរ** | ១៧៤ |
| ក. | ព័ត៌មានស្តីពីគ្រឹះស្ថានឧត្តមសិក្សា | ១៧៥ |
| ខ. | ព័ត៌មានស្តីពីវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | ២១១ |
| គ. | ព័ត៌មានទាក់ទងនឹងការសិក្សាមុខជំនាញនៅឧត្តមសិក្សា | ២១២ |
| ឃ. | មុខរបរពេញនិយម និងមុខវិជ្ជាត្រូវសិក្សាតាមវិស័យ | ២៤០ |
| ង. | ព័ត៌មានស្តីពីគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ | ២៤៩ |


f facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# បុព្វកថា

ក្នុងបរិការណ៍នៃសហគមន៍អាស៊ានក្រោយឆ្នាំ២០១៥នេះ គឺជារបត់ថ្មីមួយដែលការយកចិត្តទុកដាក់លើការអភិវឌ្ឍធនធានមនុស្សគឺជាកត្តាសំខាន់បំផុត ដើម្បីអនុញ្ញាតឱ្យប្រទេសកម្ពុជាអាចប្រកួតប្រជែងស្មើមុខស្មើមាត់គ្នានឹងប្រទេសដទៃទៀតនៅក្នុងតំបន់។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការលើវិស័យអប់រំ បានដាក់ចេញនូវយុទ្ធសាស្ត្រដ៏ទូលំទូលាយ ដើម្បីបង្កើនសក្ដានុពលធនធានមនុស្សឱ្យមានជំនាញបច្ចេកទេសគ្រប់កម្រិត ដែលអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការនៃទីផ្សារពលកម្មបានពេញលេញ មានគំនិតច្នៃប្រឌិតខ្ពស់ មានស្មារតីទទួលខុសត្រូវ សំដៅលើកកម្ពស់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ។

ស្ថានភាពនៃការផ្ដល់សេវាអប់រំកម្ពុជាមានការរីកចំរើនគួរឱ្យកត់សម្គាល់ ប៉ុន្តែនៅមានការប្រឈមដែលកើតឡើងដោយសារគម្លាតពីរគឺ គម្លាតជំនាញ និងគម្លាតនៃការបណ្ដុះបណ្ដាល ដែលមិនទាន់ឆ្លើយតបទៅនឹងតម្រូវការបុគ្គល និងទីផ្សារពលកម្ម។ ជាការឆ្លើយតប ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឲ្យមានកម្មវិធីផ្ដល់ប្រឹក្សាអាជីពនៅតាមគ្រឹះស្ថានមធ្យមសិក្សា និងចងក្រងឯកសារស្ដីពី«**ការផ្ដល់ប្រឹក្សាអាជីពនិងព័ត៌មានស្ដីពីការសិក្សាជំនាញ**» ដើម្បីជួយសិស្សឱ្យចេះរៀបចំផែនការអាជីព ផែនការសិក្សា ចេះដោះស្រាយបញ្ហាផ្ទាល់ខ្លួន និងចូលរួមចំណែកកាត់បន្ថយការបោះបង់ការសិក្សាផងដែរ។

ឯកសារ«**ការផ្ដល់ប្រឹក្សាអាជីព និងព័ត៌មានស្ដីពីការសិក្សាជំនាញ**» នេះ គឺជាឯកសារដែលបានចងក្រងឡើង ដើម្បីជួយសម្រួលដល់ដំណើរការអនុវត្តរបស់ក្រុមគ្រូផ្ដល់ប្រឹក្សាអាជីពនៅតាមគ្រឹះស្ថានមធ្យមសិក្សា។ ខ្លឹមសារសំខាន់ក្នុងឯកសារនេះ ត្រូវបានបែងចែកជា ៥ ផ្នែកគឺ ទី១: ការស្គាល់ខ្លួនឯង ទី២: ជីវិតនិងក្ដីសុបិននៃអាជីព ទី៣: ការសិក្សា ទី៤: ជំនាញនិងភាពខ្លាំង ទី៥: ការអប់រំនិងជម្រើសនៃអាជីព និងផ្នែកខាងក្រោយនៃឯកសារនេះ គឺជាតេស្ដវាយតម្លៃផ្ទាល់ខ្លួន ព័ត៌មានស្ដីពីគ្រឹះស្ថានសិក្សាជំនាញ តម្រូវការជំនាញតាមប្រភេទមុខរបរ និងព័ត៌មានស្ដីពីការសិក្សាជំនាញ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា លោកគ្រូ អ្នកគ្រូផ្ដល់ប្រឹក្សាអាជីពទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃឯកសារនេះ តាមរយៈការបង្កើតបណ្ដាញដើម្បីសហការ ព្រមទាំងសិក្សាស្រាវជ្រាវបន្ថែម ដើម្បីពង្រឹងសមត្ថភាពជាអ្នកផ្ដល់ប្រឹក្សាអាជីព នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនប្រកបដោយភាពប៉ិនប្រសប់ និងប្រសិទ្ធភាពខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡា ជឿជាក់ថាបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ជាពិសេស នាយកនាយិកាសាលា និងគណៈកម្មការពាក់ព័ន្ធ នឹងផ្ដល់ការគាំទ្រដល់ដំណើរការអនុវត្តការងារប្រឹក្សាអាជីពរបស់គ្រូផ្ដល់ប្រឹក្សាយោបល់នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវ និងយកចិត្តទុកដាក់ខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណចំពោះក្រុមមន្ត្រីជំនាញនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ ជាពិសេសអង្គការជំនួយព្រះវិហារនៃប្រទេសហ្វាំងឡង់និងអ្នកស្ម័គ្រចិត្ត ដែលបានអនុវត្តសាកល្បងកម្មវិធីផ្ដល់ប្រឹក្សាអាជីពនេះដោយជោគជ័យ និងយកអស់កម្លាំងកាយចិត្ត ដើម្បីរៀបចំចងក្រងឯកសារនេះឡើង។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

www.moeys.gov.kh YouTube youtube.com/moeyscambodia facebook.com/moeyscambodia

# សេចក្តីផ្តើម

មគ្គុទ្ទេសក៍នៃការអប់រំនិងវិជ្ជាជីវៈ ជាដំណើរការដែលបន្តពេញ ១ ឆ្នាំសិក្សា នៅមធ្យមសិក្សា។ ដោយបានរួមបញ្ចូលនូវចំណុចសំខាន់ៗមួយចំនួនដូចជា ការសិក្សាជំនាញ ការធ្វើការងារនៅសហគមន៍របស់សាលារៀន ចំណេះដឹងផ្ទាល់ខ្លួន ជម្រើសសម្រាប់ការសិក្សា ការបន្តមុខរបរ និងវិស័យមុខរបរ ព្រមទាំងជីវិតការងារ។

នៅឆ្នាំចុងក្រោយនៃការសិក្សា សិស្សនឹងត្រូវទទួលបានការណែនាំឲ្យស្គាល់ពីផែនការបន្ទាប់ពីបញ្ចប់ការសិក្សា។ តួនាទីរបស់មគ្គុទ្ទេសក៍នៃការអប់រំនិងវិជ្ជាជីវៈ គឺគាំទ្រការសិក្សារបស់ពួកគេ និងផ្តល់នូវជំនាញ និងចំណេះដឹងគ្រាប់គ្រាន់ដើម្បីបន្តការសិក្សា និងចូលបម្រើការងារ។

សៀវភៅវិធីសាស្ត្រអនុវត្តការប្រឹក្សាអាជីព មានលំហាត់អនុវត្តនិងសកម្មភាពដែលមានប្រយោជន៍ជាច្រើនសម្រាប់ការប្រឹក្សាយោបល់ផ្ទាល់ខ្លួន ការប្រឹក្សាយោបល់ជាក្រុម និងក្នុងថ្នាក់រៀន ហើយអាចយកទៅប្រើប្រាស់តាមកម្រិតថ្នាក់មធ្យមសិក្សាបឋមភូមិ ចាប់ពីថ្នាក់ទី៧ ដល់ទី៩ និង កម្រិតថ្នាក់មធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី១០ ដល់ទី១២ ទៅតាមដំណាក់កាលផ្សេងៗនៃដំណើរការប្រឹក្សាអាជីព។ សៀវភៅនេះផ្តល់ឲ្យគ្រូប្រឹក្សាអាជីពនូវវិធីសាស្ត្រដើម្បីៈ

- ជួយសម្រួលដល់ការផ្លាស់ប្តូររបស់សិស្ស មកទទួលការអប់រំនៅវិទ្យាល័យ និងការលើកកំពស់ជំនាញសិក្សារបស់ពួកគេ។
- ជួយសិស្សបង្កើនចំណេះដឹងខ្លួនឯង បុគ្គលិកលក្ខណៈ អារម្មណ៍ ចំណង់ចំណូលចិត្ត និងការចាប់អារម្មណ៍ ព្រមទាំងទទួលស្គាល់នូវបណ្តាញនៃមនុស្សដែលអាចគាំទ្រពួកគេក្នុងជីវិតប្រចាំថ្ងៃនៅក្នុងសាលារៀន នៅផ្ទះ ឬអាចជួយកសាងអនាគតរបស់ពួកគេ។
- លើកទឹកចិត្តឲ្យសិស្សបញ្ចេញបំណងប្រាថ្នា និងក្តីសុបិន្តសម្រាប់អនាគតរបស់ពួកគេ ទាំងក្នុងជីវិត និងក្នុងអាជីព។ តើទិដ្ឋភាពបែបណាដែលមានសារៈប្រយោជន៍សម្រាប់ពួកគេក្នុងជិវិតការងារ និងអាជីព? តើអ្វីអាចជួយឲ្យពួកគេសម្រេចបាននូវក្តីសុបិន ហើយពួកគេត្រូវការសិក្សាដើម្បីសម្រេចគោលបំណងទាំងនេះ?

**វដ្តនៃប្រឹក្សាអាជីព**

- ការស្គាល់ខ្លួនឯង
- ជីវិត និងក្តីសុបិននៃអាជីព
- ការសិក្សា
- ជំនាញ និងភាពខ្លាំង
- ការអប់រំ និងជម្រើសអាជីព

facebook.com/moeyscambodia youtube.com/moeys.gov.kh YouTube youtube.com/moeyscambodia

- ដឹកនាំសិស្សឲ្យយល់ថា ការសិក្សាជាដំណើរការពេញមួយជីវិត ហើយកំណត់ខ្លួនឯងថាជាអ្នកសិក្សា។ លើកទឹកចិត្តឲ្យពួកគេយកចិត្តទុកដាក់ចំពោះជំនាញគ្រប់គ្រងជីវិតដែលអាចគាំទ្រដល់ការសិក្សា។
- ជំរុញសិស្សឲ្យស្វែងយល់ពីចំណុចខ្លាំង ចំណុចខ្សោយ ជំនាញ បុគ្គលិកលក្ខណៈល្អៗ និងរកឲ្យឃើញ នូវរបៀបនៃការអភិវឌ្ឍចំណុចខ្សោយ តាមរយៈការសិក្សា និងការអនុវត្ត។
- ណែនាំសិស្សឲ្យស្គាល់ពីទិដ្ឋភាពពាក់ព័ន្ធ ដែលមានឥទ្ធិពលដល់ផែនការ បន្ទាប់ពីបញ្ចប់ការសិក្សារបស់ពួកគេ។ រកឲ្យឃើញនូវចំណាប់អារម្មណ៍ថ្មីៗ និងបង្ហាញជម្រើសនៃអាជីពដែលបានគ្រោងទុកសម្រាប់អាជីពអនាគត ប្រមូលព័ត៌មានពីការអប់រំនិងការបណ្តុះបណ្តាលដែលត្រូវការសម្រាប់អនាគត និងចង្អុលបង្ហាញពីជំហានបន្ទាប់ដែលពួកគេត្រូវការដើម្បីបន្តការសិក្សា និងដើរតាមផ្លូវអាជីពរបស់ពួកគេបន្ទាប់ពីបញ្ចប់ការសិក្សានៅសាលារៀន។
- ប្រឹក្សាយោបល់ក្នុងថ្នាក់រៀនប្រកបដោយភាពរីកចម្រើនជាប្រចាំ ដើម្បីផ្តល់ឱកាសដល់សិស្សឲ្យទទួលបាននូវជំនាញ និងចំណេះដឹងមូលដ្ឋានដែលអាចជួយពួកគេឲ្យរៀបចំផែនការសម្រាប់បន្តការសិក្សា និងធ្វើការជ្រើសរើសអាជីព។ លើសពីនេះទៀត សិស្សត្រូវទទួលការណែនាំក្នុងការប្រើប្រភពផ្សេងៗដើម្បីស្វែងរកព័ត៌មានគាំទ្រ ហើយព័ត៌មាននេះផ្តល់ដោយស្ថាប័នរបស់រដ្ឋ ឯកជន និងភ្នាក់ងារសាធារណៈផ្សេងៗ។
- សិស្សក៏ត្រូវបានជួយលើកទឹកចិត្តឲ្យស្វែងរកការប្រឹក្សាអាជីព ស្ថានភាពបច្ចុប្បន្នក្នុងជីវិតរបស់ពួកគេ និងផែនការអនាគត។ នៅក្នុងក្រុមតូចៗ សិស្សអាចពិភាក្សាបញ្ហាទាំងនោះ ដែលគេចាត់ទុកថាជាប្រធានបទប្រកបដោយអត្ថន័យសម្រាប់កិច្ចពិភាក្សាជាក្រុម ហើយជាលទ្ធផលទទួលបានការគាំទ្រពីសមាជិក។
- គាំទ្រសិស្សដែលមានបញ្ហាផ្ទាល់ខ្លួន ដូចជាការគ្រប់គ្រងអារម្មណ៍ ការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការខកចិត្ត ការរងសម្ពាធ និងការដោះស្រាយជម្លោះ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ១
# មេរៀនអនុវត្តផ្នែកប្រឹក្សាអាជីព

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី១

# ការស្គាល់ខ្លួនឯង

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ១. ការស្គាល់ខ្លួនឯង

## ១.១ គោលបំណង

គោលបំណងនៅក្នុងដំណាក់កាលដំបូងនៃវដ្តប្រឹក្សាអាជីពនេះ គឺជួយឲ្យសិស្សបង្កើនចំណេះដឹងអំពីខ្លួនឯង បុគ្គលិកលក្ខណៈ អារម្មណ៍ ចំណង់ចំណូលចិត្ត និងចំណាប់អារម្មណ៍។ លើសពីនេះ គោលបំណង គឺចង់ជួយសិស្សឲ្យស្គាល់បណ្តាញមនុស្សដែលអាចជួយគាំទ្រដល់ពួកគេ ក្នុងជីវិតរស់នៅប្រចាំថ្ងៃទាំងក្នុងសាលារៀន និងក្នុងផ្ទះ ឬជួយគាំទ្រក្នុងការកសាងអនាគតរបស់ពួកគេ។ ជារឿងសំខាន់ផងដែរ ការស្គាល់ខ្លួនឯងអាចឲ្យសិស្សសង្កេតមើលនូវ ឱកាសទាំងឡាយ ដែលបរិស្ថានរស់នៅរបស់ពួកគេអាចផ្តល់ឲ្យគេបាន។ ការស្គាល់ខ្លួនឯង និងការបង្កើនចំណេះដឹងអំពីខ្លួនឯង និងបណ្តាញជាប្រចាំរបស់ពួកគេ គឺជាជំហានដំបូងនិងសំខាន់បំផុតក្នុងការប្រឹក្សាអាជីព។

## ១.២ វិធីសាស្ត្រក្នុងការអនុវត្តដើម្បីឲ្យសិស្សស្គាល់ខ្លួនឯង

### ១.២.១ ការពិពណ៌នាអំពីខ្លួនឯង (ផែនទីពាក្យ)៖

គោលបំណងនៃការអនុវត្តលំហាត់នេះ គឺដើម្បីជួយសិស្សឲ្យមានភាពងាយស្រួលក្នុងការបង្កើនចំណេះដឹងអំពីខ្លួនគេ ដឹងពីលក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈ អារម្មណ៍ ចំណង់ចំណូលចិត្ត និងចំណាប់អារម្មណ៍។ ការស្គាល់ខ្លួនឯង គឺជំហានដំបូងហើយសំខាន់បំផុតក្នុងការប្រឹក្សាអាជីព។ លំហាត់នេះក៏អាចប្រើប្រាស់សម្រាប់ការប្រឹក្សាយោបល់ក្នុងថ្នាក់រៀនផងដែរ។ គេអាចប្រើធ្វើជាសកម្មភាពសម្រាប់សិស្សមួយក្រុមថ្មីដើម្បីស្គាល់គ្នា។ ដើម្បីអនុវត្ត លំហាត់នេះ គ្រូត្រូវអនុវត្តទៅតាមជំហានទាំង ៦ តាមលំដាប់លំដោយដូចខាងក្រោម៖

**ជំហានទី១៖** សិស្សម្នាក់ៗក្នុងក្រុមណែនាំខ្លួនដោយប្រាប់ឈ្មោះ បន្ទាប់មករៀបរាប់ពីខ្លួនឯងដោយប្រើពាក្យមួយម៉ាត់។ ពាក្យនេះអាចជាគុណនាមដែលបញ្ជាក់ពីអារម្មណ៍ ឬបុគ្គលិកលក្ខណៈ (សប្បាយ ឧស្សាហ៍...) ល្បែងកំសាន្ត ចំណាប់អារម្មណ៍។ល។

ឧទាហរណ៍៖




facebook.com/moeyscambodia YouTube youtube.com/moeyscambodia

**ជំហានទី២៖** យកក្រដាសមួយសន្លឹក ហើយសរសេរឈ្មោះនៅចំកណ្តាល។ ចូរសរសេរពាក្យដែលអ្នកបានប្រើដើម្បីរៀបរាប់ពីខ្លួនឯងនៅក្បែរឈ្មោះរបស់អ្នក។

**សារី** (អាន)

**ជំហានទី៣៖** ចូរបន្ថែមពាក្យដែលរៀបរាប់អំពីអ្នក (គុណនាមរៀបរាប់ពីអារម្មណ៍ និងបុគ្គលិកលក្ខណៈ ល្បែងកំសាន្ត ចំណាប់អារម្មណ៍ ចំណង់ចំណូលចិត្ត) នៅជុំវិញឈ្មោះរបស់អ្នក។ សម្រាប់ជំហាននេះ ចូរកំណត់ពេលវេលាជាក់លាក់ណាមួយឧទាហរណ៍ ១០ នាទី។



ទុក្ខព្រួយ

ធុញថប់ **សារី** ចូលចិត្ត

សប្បាយ

**ជំហានទី ៤៖** ចូរគូសរង្វង់ពាក្យបីដែលសំខាន់បំផុតសម្រាប់ពិពណ៌នាពីរូបអ្នក។

ទុក្ខព្រួយ

ធុញថប់ **សារី** ចូលចិត្ត

សប្បាយ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**ជំហានទី ៥៖** បង្កើតក្រុមដែលមានសិស្ស៣ ទៅ៤នាក់។ ចូរបង្ហាញ និងចែកក្រដាសសន្លឹកកិច្ចការជាមួយសមាជិកក្រុមដទៃ រួចផ្តល់យោបល់និងប្រៀបធៀបលទ្ធផល។

**ជំហានទី ៦៖** គ្រូប្រឹក្សាយោបល់បន្តសួរនូវសំណួរដូចខាងក្រោម៖

- តើពាក្យដំបូងដែលអ្នកបានជ្រើសរើសសម្រាប់រៀបរាប់ពីខ្លួនអ្នកស្ថិតក្នុងចំណោមពាក្យទាំងបីដែលបានគូសរង្វង់ដែរឬទេ? បើមិនមាន ហេតុអ្វី?
- ហេតុអ្វីបានជា អ្នកជ្រើសរើសយក ពាក្យពិសេសទាំងនេះមកដើម្បីពិពណ៌នាពីខ្លួនឯង?

**១.២.២ ការស្គាល់ខ្លួនឯង** (ផែនទីគំនិតអំពីភាពខ្លាំង ក្តីសុបិន្ត មនុស្សសំខាន់ ការបន្តប្រយោគ អំពីខ្លួនឯង)

គោលបំណងនៃលំហាត់នេះគឺ ជួយសម្របសម្រួលឲ្យសិស្សបង្កើនចំណេះដឹងអំពីខ្លួនឯង។ លើសពីនេះ គឺចង់ជួយសិស្សឲ្យស្គាល់បណ្តាញមនុស្សដែលអាចជួយគាំទ្រពួកគេក្នុងជីវិតរស់នៅប្រចាំថ្ងៃទាំងក្នុងសាលារៀន និងក្នុងផ្ទះ ឬជួយគាំទ្រក្នុងការកសាងអនាគតរបស់ពួកគេ។ ជារឿងសំខាន់ផងដែរក្នុងការសង្កេតមើលនូវឱកាសណាមួយ ដែលបរិស្ថានរស់នៅរបស់ពួកគេអាចផ្តល់ឲ្យបាន។ ការស្គាល់ខ្លួនឯង និងការបង្កើនចំណេះដឹងអំពីខ្លួនឯង និង បណ្តាញជាប្រចាំរបស់ពួកគេ គឺជាជំហានដំបូង និងសំខាន់បំផុតក្នុងការប្រឹក្សាអាជីព។

លំហាត់នេះ **អាចយកមកប្រើប្រាស់**សម្រាប់ការប្រឹក្សាយោបល់មុខទល់មុខ (Face to Face) និងក្នុងថ្នាក់រៀន (Classroom Guidance) ហើយក៏អាចយកមកប្រើប្រាស់ជាកិច្ចការផ្ទះបានដែរ។

**ដំណាក់កាលទី១**

ផ្តល់ពេលវេលាជាក់លាក់ដល់សិស្សដើម្បីបំពេញផែនទីគំនិត ប៉ុន្តែត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ឲ្យពួកគេបានគិតគ្រប់ជ្រុងជ្រោយ។ បង្កើតក្រុមដែលមានសិស្សចំនួន២ ទៅ ៣នាក់ ហើយឲ្យពួកគេបង្ហាញ និងចែករំលែកផែនទីគំនិតជាមួយសមាជិកក្រុមដទៃទៀត បន្ទាប់មកសួរសំណួរមួយចំនួនដូចខាងក្រោម៖

- តើអ្នកមានអារម្មណ៍ដូចម្តេចចំពោះផែនទីគំនិតនេះ? តើវាងាយស្រួល ឬលំបាក?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- តើផែនទីនេះជួយអ្នកឲ្យស្គាល់ខ្លួនឯងប្រសើរជាងមុនដែរឬទេ?
- តើអ្នកបានរៀនអ្វីថ្មីអំពីខ្លួនឯងទេនៅពេលកំពុងគូរផែនទីនេះ?

ប្រសិនបើសិស្សខ្លះចាត់ទុកផែនទីគំនិតនេះជាឯកសារដែលមានព័ត៌មានផ្ទាល់ខ្លួន អ្នកអាចប្រមូលផែនទីគំនិតទុកជាព័ត៌មាន ហើយប្រគល់ឲ្យសិស្សនៅពេលក្រោយ។

**ដំណាក់កាលទី២**

ប្រាប់សិស្សឲ្យធ្វើលំហាត់ទី២ លើកទឹកចិត្តសិស្សឲ្យមានគំនិតវិជ្ជមាន និងមានមោទនភាពចំពោះជំនាញរបស់ពួកគេ។

**ប្រតិបត្តិ**

១.ចូរបំពេញផែនទីគំនិត (គ្រូប្រឹក្សាអាជីពអាចជួយសិស្សប្រសិនសិស្សមានសំណួរ)។




facebook.com/moeyscambodia YouTube youtube.com/moeyscambodia

២. ចូរបន្តបំពេញប្រយោគខាងក្រោមនេះ៖

ខ្ញុំពូកែខាង.............................

គ្រួសារ និងមិត្តភ័ក្តរបស់ខ្ញុំពេញចិត្តនឹងខ្ញុំព្រោះ...................

មុខវិជ្ជាដែលខ្ញុំពេញចិត្តនៅសាលារៀន គឺ..................

ខ្ញុំចង់រៀនបន្ថែមទៀតពី..............................

លក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈរបស់ខ្ញុំ គឺ.....................

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី២
# ជីវិត និងក្តីសុបិននៃអាជីព

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ២. ជីវិត និងក្តីសុបិននៃអាជីព

## ២.១ គោលបំណង

នៅក្នុងដំណាក់កាលនៃវគ្គការប្រឹក្សាអាជីពនេះ គឺជំរុញឲ្យសិស្សបញ្ជាក់ពីក្តីប្រាថ្នា និងក្តីសុបិនសម្រាប់អនាគត ទាំងជីវិត និងការងារ។ ក្តីសុបិនអាចជារឿងតូចតាច គ្មានក្តីសុបិនណាធំពេកទេ។ គោលបំណងនេះ ក៏ជំរុញឲ្យសិស្សគិតអំពីការងារក្នុងក្តីសុបិនរបស់គេឲ្យ ស៊ីជម្រៅថែមទៀតក្នុងជីវិតការងារ និងអាជីព។ តើទិដ្ឋភាពបែបណាដែលមានសារៈសំខាន់ចំពោះពួកគេ? តើអ្វីជួយឲ្យទទួលបានការងារក្នុងក្តីសុបិន ហើយគេត្រូវរៀនសូត្រអ្វីខ្លះ ដើម្បីសម្រេចគោលដៅ?

## ២.២ វិធីសាស្ត្រអនុវត្ត

សន្លឹកកិច្ចការ និង/ឬលំហាត់

**២.២.១ ផែនទីគំនិត** (ចូរមើលខាងលើ ការស្គាល់ខ្លួនឯង)

**២.២.២ រូបភាពការងារ**

ភ្ជាប់ការងារជាមួយកិច្ចការ រូបភាព អារម្មណ៍ គំនិត សញ្ញាណ ការគិតទុកមុន។ល។

**២.២.៣ ការងារក្នុងក្តីសុបិន** (តើការងារក្នុងក្តីសុបិនរបស់អ្នកយ៉ាងដូចម្តេច?)

គោលបំណងនៃលំហាត់នេះ គឺ ជួយសម្រួលឲ្យសិស្សបង្ហាញពីក្តីប្រាថ្នាសម្រាប់ការងារក្នុងក្តីសុបិនរបស់ពួកគេ។ តើទិដ្ឋភាពនៃការងារបែបណាដែលសំខាន់សម្រាប់ពួកគេ? ជំនួសឲ្យការកំណត់ឈ្មោះការងារក្នុងក្តីសុបិនពិសេសណាមួយដែលសិស្សចង់បាន គ្រូត្រូវដឹកនាំសិស្សឲ្យគិតពីសំណួរដូចខាងក្រោមនេះវិញ៖






**សម្គាល់** ៖ លំហាត់នេះអាចយកទៅប្រើសម្រាប់ការប្រឹក្សាទល់មុខ និងក្នុងថ្នាក់រៀន។ វាក៏អាចប្រើជាកិច្ចការផ្ទះ និងការពិភាក្សាជាក្រុមផងដែរ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ២.៣ ប្រតិបត្តិ 

**ដំណាក់កាលទី១**

កំណត់ពេលវេលាជាក់លាក់ដើម្បីឲ្យសិស្សសរសេរក្តីប្រាថ្នាសម្រាប់ការងារក្នុងក្តីសុបិន របស់ពួកគេ។ បន្ទាប់មកប្រមូលក្តីប្រាថ្នាមួយចំនួនពីសិស្សម្នាក់ៗមកដាក់លើក្តារខៀន រួច ពិភាក្សាទាំងអស់គ្នាថាតើក្តីប្រាថ្នាដូចគ្នា ឬខុសគ្នាដូចម្តេច?

**ឧទាហរណ៍៖**



- ខ្ញុំចង់ក្លាយជាអ្នកបើកយន្តហោះ
- ខ្ញុំចង់ក្លាយជាមេចុងភៅ
- ខ្ញុំចង់ក្លាយជានាយកសាលា
- ខ្ញុំចង់ក្លាយជាប៉ូលីស
- ខ្ញុំចង់ក្លាយជាវិស្វករ
- ខ្ញុំចង់ក្លាយជាអ្នកច្បាប់
- ខ្ញុំចង់ធ្វើជារដ្ឋមន្ត្រី
- ខ្ញុំចង់ធ្វើជាអ្នកផ្តល់ប្រឹក្សា
- ខ្ញុំចង់ធ្វើជាវេជ្ជបណ្ឌិត
- ខ្ញុំចង់ក្លាយជាអាវកាសយានិក...

បន្ទាប់មក ឲ្យសិស្សដាក់ឈ្មោះការងារ ឬកន្លែងការងារមួយចំនួនដែលក្តីប្រាថ្នារបស់ ពួកគេភាគច្រើនត្រូវបានបំពេញ។

**ដំណាក់កាលទី២**

សំណួរបន្ថែម (ការពិភាក្សាដឹកនាំដោយគ្រូបង្គោល ឬការងារជាបុគ្គល)

គ្រូប្រឹក្សាអាជីព ត្រូវសួរសំណួរបន្ថែមដើម្បីសិក្សាស្វែងយល់ពីការគិត ការត្រៀមខ្លួន របស់សិស្ស ដើម្បីជួយជំរុញឲ្យសម្រេចនូវក្តីសុបិនរបស់ពួកគេ។

**ឧទាហរណ៍ ៖**

- តើអ្វីដែលជាទិដ្ឋភាពសំខាន់បំផុតសម្រាប់អ្នកចំពោះការងារក្នុងក្តីសុបិន?
- តើអ្វីដែលជួយឲ្យអ្នកសម្រេចបាននូវក្តីសុបិន?
- តើអ្នកត្រូវការសិក្សាអ្វីខ្លះ?
- តើអ្វីដែលលើកទឹកចិត្ត ឬជំរុញចិត្តអ្នក?...

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**លំហាត់អនុវត្តបន្ថែម** (តើការងារក្នុងក្តីសុបិនរបស់ខ្ញុំដូចម្តេច?)

ដើម្បីអនុវត្តលំហាត់នេះ គ្រូប្រឹក្សាអាជីពត្រូវដឹកនាំសកម្មភាព ជាបុគ្គល ជាដៃគូ ឬជាក្រុមតូច ដើម្បីឲ្យសិស្សសរសេរ ឬរៀបរាប់ ឬពិភាក្សា និងរាយការណ៍ពីចំណង់ចំណូលចិត្ត ចំណាប់អារម្មណ៍ ព្រមទាំងឆ្លុះបញ្ចាំងការងារណាមួយដែលជាក្តីសុបិនរបស់គេ ដោយប្រើប្រាស់សំណួរដូចខាងក្រោម៖

- ចូរសរសេរក្តីប្រាថ្នាសម្រាប់ការងារក្នុងក្តីសុបិនរបស់អ្នក
- តើអ្វីដែលមានសារៈសំខាន់សម្រាប់អ្នក?
- តើអ្វីដែលអ្នកចូលចិត្តធ្វើ?
- តើអ្នកមានចំណាប់អារម្មណ៍លើអ្វី? (ឧទា. ខ្ញុំចូលចិត្តធ្វើការជាមួយមនុស្ស ខ្ញុំចង់បានការងារណាដែលងាយស្រួលផ្លាស់ប្តូរ ខ្ញុំចាប់អារម្មណ៍លើប្រវត្តិសាស្ត្រ ខ្ញុំចង់បានការងារដែលមានម៉ោងបត់បែន ប្រាក់ខែល្អ។ល។)

ការពិភាក្សាជាដៃគូ



ការពិភាក្សាជាក្រុម



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ២.៣.១ កិច្ចសន្យានៃក្តីសុបិន

គោលបំណងនៃលំហាត់នេះ គឺ លើកទឹកចិត្តសិស្សឲ្យរៀបចំគោលដៅសម្រាប់ជីវិតអាជីព និងអនាគតរបស់គេ ព្រមទាំងជួយឲ្យពួកគេមានសុទិដ្ឋិនិយមថាគោលដៅទាំងនេះអាចសម្រេចបាន។ លំហាត់នេះអាចប្រើបានចំពោះការប្រឹក្សាយោបល់ទល់មុខគ្នា ការប្រឹក្សាក្នុងថ្នាក់រៀន និងអាចប្រើជាកិច្ចការផ្ទះក៏បាន។

### គោលការណ៍ណែនាំអនុវត្ត

កំណត់ពេលវេលាពិតប្រាកដណាមួយដល់សិស្ស ដើម្បីបំពេញកិច្ចសន្យានៃក្តីសុបិន ប៉ុន្តែទុកពេលឲ្យបានគ្រប់គ្រាន់ដើម្បីគិតអំពីទិដ្ឋភាពទាំងអស់។ បន្ទាប់មកឲ្យសិស្សបង្ហាញ និងចែករំលែក នូវកិច្ចសន្យានៃក្តីសុបិនរបស់គេជាមួយសិស្សដទៃ។ ការធ្វើកិច្ចសន្យាជាសាធារណៈ នឹងបង្កើនកម្រិតនៃការប្តេជ្ញាចិត្តចំពោះគោលដៅរបស់គេ។

បើសិនជាសិស្សចាត់ទុកកិច្ចសន្យានៃក្តីសុបិនរបស់គេ ជាឯកសារផ្ទាល់ខ្លួនដែលមានព័ត៌មានសម្ងាត់ អ្នកអាចប្រមូលកិច្ចសន្យានៃក្តីសុបិនទាំងនោះទុកជាព័ត៌មានរបស់អ្នក ហើយប្រគល់ឲ្យពួកគេវិញនៅពេលក្រោយ។ ប្រាប់សិស្សឲ្យរក្សាទុកនូវកិច្ចសន្យានៃក្តីសុបិនរបស់គេ។ ក្នុងអំឡុងឆ្នាំសិក្សា កិច្ចសន្យាអាចពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពបាន។

សូមប្រើប្រាស់គម្រូកិច្ចសន្យានៃក្តីសុបិនដូចខាងក្រោម ៖






facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ក្តីសុបិនរបស់ខ្ញុំ

តើខ្ញុំចង់ធ្វើ ជួប និងឃើញអ្វី?

## ជំនាញ និងចំណេះដឹង

តើជំនាញ និងចំណេះដឹងបែបណាដែលខ្ញុំត្រូវការ ដើម្បីសម្រេចបាននូវក្តីសុបិនរបស់ខ្ញុំ?

## សកម្មភាព

តើជំហានបីដំបូងឆ្ពោះទៅកាន់ក្តីសុបិនរបស់ខ្ញុំមានអ្វីខ្លះ?

1.

2.

3.

## ខ្ញុំត្រូវធ្វើ

ថ្ងៃនេះខ្ញុំចាប់ផ្តើមធ្វើឲ្យក្តីសុបិនរបស់ខ្ញុំក្លាយជាការពិត!

ពេលវេលា និងទីកន្លែង

ហត្ថលេខា

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី៣
# ការសិក្សា

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ៣. ការសិក្សា

## ៣.១ គោលបំណង

ការសិក្សា គឺជាដំណាក់កាលមួយនៃវដ្តការប្រឹក្សាអាជីព។ ក្នុងដំណាក់កាលនេះ គ្រូត្រូវជួយឲ្យសិស្សយល់ឃើញថា ការសិក្សាជាដំណើរការពេញមួយជីវិត ហើយការសិក្សាកើតមានគ្រប់ទីកន្លែង ជាផ្លូវការ ការសិក្សាកើតឡើងតាមរយៈការអប់រំនិងការងារ និងក្រៅផ្លូវការ ការសិក្សាក៏អាចធ្វើឡើងនៅពេលយើងទំនេរ។ គោលបំណងមួយទៀត គឺជួយជំរុញឲ្យសិស្សយកចិត្តទុកដាក់ចំពោះកត្តាគាំទ្រការសិក្សា និងធ្វើឲ្យការសិក្សាអាចទទួលបានជោគជ័យ។ ទោះបីជាយ៉ាងណាក៏ដោយ គោលដៅដ៏សំខាន់បំផុតនោះ គឺជួយសិស្សកំណត់ខ្លួនឯងថាជាអ្នកសិក្សា ស្វែងយល់ពីចំណុចខ្លាំងនិងចំណុចខ្សោយ រៀបរាប់ពីបទពិសោធន៍នៃការសិក្សារបស់គេ និងការយល់ពីរបៀបផ្សេងៗនៃការសិក្សា ដូចជា ការស្តាប់ ការសង្កេត ការពិភាក្សា ការ អនុវត្តផ្ទាល់ និងការបង្រៀនអ្នកដទៃ។ល។

## ៣.២ វិធីសាស្ត្រអនុវត្ត

### ៣.២.១ ការដឹកនាំពិភាក្សាក្រុម

**ប្រតិបត្តិ** 

ដើម្បីឈ្វេងយល់ពីនិយមន័យការសិក្សា ការប្រតិបត្តិក្នុងការសិក្សា ការរៀបចំពេលវេលាសិក្សា ក្នុងគោលបំណងឲ្យសិស្សស្រឡាញ់ការសិក្សា គ្រូប្រឹក្សាអាជីពអាចអនុវត្តវិធីសាស្ត្រ ដោយឲ្យសិស្សពិភាក្សាជាបុគ្គល ជាក្រុមតូច ឬជាក្រុមធំ ទៅលើសំណួរដូចខាងក្រោម រួចឲ្យក្រុមនីមួយៗ បង្ហាញ និងប្រៀបធៀបពីការយល់ឃើញរបស់សិស្សម្នាក់ៗ ឬក្រុមនីមួយៗ។ ការអនុវត្តត្រូវមានភាពបត់បែន ទៅតាមស្ថានភាពរបស់សិស្ស ថ្នាក់រៀន និងប្រភេទរបស់សិស្ស។ គ្រូប្រឹក្សាអាជីព ក៏អាចប្រើប្រាស់សំណួរទាំងនេះក្នុងការផ្តល់ប្រឹក្សាទល់មុខ ដើម្បីសិក្សាស្វែងយល់ពីទស្សនៈ និងការយល់ឃើញរបស់សិស្សម្នាក់ៗអំពីការសិក្សា។ គម្រូសំណួរសម្រាប់អនុវត្តមានដូចខាងក្រោម៖

- តើការសិក្សាជាអ្វី?
- តើមានការសិក្សាបែបណាខ្លះ?
- តើការសិក្សាងាយស្រួលដែរ ឬទេ?
- តើយើងសិក្សា នៅឯណា ពេលណា និងរបៀបណា?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- ជានិច្ចកាល តើយើងអាចទទួលស្គាល់ការសិក្សាភ្លាមទេ (ឬក៏ការសិក្សាជាដំណើរការ)?

មនុស្សគ្រប់រូបសិក្សារៀនសូត្ររៀងរាល់ថ្ងៃ ក្នុងអំឡុងពេលមានជីវិតរស់នៅ ហើយមនុស្សក៏តែងតែទទួលបានព័ត៌មាន ជំនាញ និងបទពិសោធន៍ថ្មីៗ ជារៀងរាល់ថ្ងៃ ហើយដំណើរការនេះបន្តពេញមួយជីវិត។

ចំពោះមនុស្សមួយចំនួន ការសិក្សាអ្វីដែលថ្មីអាចមានភាពងាយស្រួល ប៉ុន្តែចំពោះមនុស្សមួយក្រុមផ្សេងទៀតអាចមានការពិបាក។ ចំពោះការសិក្សាខ្លះ យើងអាចទទួលបានចំណេះដឹង និងព័ត៌មានភ្លាមៗ ប៉ុន្តែការសិក្សាខ្លះត្រូវការរយៈពេលយូរទើបស្តែងចេញជា លទ្ធផល និងខ្លះទៀតស្តែងចេញជាលទ្ធផលបន្តិចម្តងៗ។

## សំណួរបន្ថែមអំពីបទពិសោធន៍នៃការសិក្សាថ្មីៗ

### តើខ្ញុំជានរណាក្នុងនាមជាអ្នកសិក្សា?

គ្រូប្រឹក្សាអាជីពអាចឲ្យសិស្សពិភាក្សាជាបុគ្គល ជាក្រុមតូច ឬជាក្រុមធំ ទៅលើសំណួរដូចខាងក្រោម រួចឲ្យក្រុមនីមួយៗ បង្ហាញ និងប្រៀបធៀបពីការយល់ឃើញរបស់សិស្សម្នាក់ៗ ឬក្រុមនីមួយៗ។ ការអនុវត្តត្រូវមានភាពបត់បែន ទៅតាមស្ថានភាពរបស់សិស្ស ថ្នាក់រៀន និងប្រភេទរបស់សិស្ស។ គ្រូអាចបន្ថែមសំណួរបំផុសងាយៗបន្ថែមទៀត ដើម្បីឲ្យសិស្សងាយយល់ និងអាចបន្តការពិភាក្សាបាន៖

- ក្នុងនាមជាសិស្សតើប្អូនត្រូវធ្វើអ្វីខ្លះ ដើម្បីគាំទ្រការសិក្សារបស់ខ្លួន?
- តើធ្វើដូចម្តេចដើម្បីរៀនឲ្យពូកែ?
- តើសប្តាហ៍នេះ អ្នកបានរៀនអ្វីខ្លះ?
- ក្នុងសប្តាហ៍នេះ អ្នកបានរៀនអ្វីខ្លះនៅពេលទំនេរ?
- សម្រាប់អ្នក តើអ្វីខ្លះជាភាពងាយស្រួលក្នុងការរៀនសូត្រ?
- តើអ្វីខ្លះជាការលំបាកក្នុងការរៀនសូត្រ?...

### ការកំណត់ខ្លួនឯងក្នុងនាមជាអ្នកសិក្សា

គ្រូប្រឹក្សាអាជីព ឲ្យសិស្សបំពេញកម្រងសំណួរគម្រូខាងក្រោម ដើម្បីឲ្យសិស្សអាចកំណត់សកម្មភាព រៀបចំសកម្មភាព ដែលទាក់ទងនឹងការសិក្សា ការពេញចិត្តចំពោះការរៀនសូត្រ ការគាំទ្រ និងប្តេជ្ញាសម្រេចផែនការសិក្សារបស់ពួកគេ។

១. នៅសាលាយើងសិក្សាមុខវិជ្ជាដូចខាងក្រោម:

____________ ____________ ____________
____________ ____________ ____________
____________ ____________ ____________
____________ ____________ ____________



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

________________ ________________ ________________

២. មុខវិជ្ជាដែលខ្ញុំពេញចិត្ត គឺ (ចូររៀបរាប់ឲ្យបានបី)

ទី១______________ ទី២______________ ទី៣______________

៣. ចូរគូស (x) ដើម្បីពន្យល់ពីមូលហេតុដែលអ្នកពេញចិត្តនឹងមុខវិជ្ជាទាំងបីនេះ

- ☐ ខ្ញុំចាប់អារម្មណ៍មុខវិជ្ជានោះ
- ☐ មិត្តភ័ក្តខ្ញុំក៏ចូលចិត្តមុខវិជ្ជានោះដែរ
- ☐ ខ្ញុំរំភើបនឹងមុខវិជ្ជានោះដែរនៅពេលទំនេរ ហើយស្រាវជ្រាវរកព័ត៌មានបន្ថែម
- ☐ ខ្ញុំចូលចិត្តគ្រូ
- ☐ ខ្ញុំទទួលបានពិន្ទុល្អ
- ☐ ខ្ញុំយល់ឃើញថាមុខវិជ្ជានោះស្រួលរៀន
- ☐ ឪពុកម្ដាយខ្ញុំផ្ដល់ដំបូន្មានឲ្យខ្ញុំរៀនមុខវិជ្ជានោះ
- ☐ មុខវិជ្ជានោះទាក់ទងនឹងផែនការអនាគតរបស់ខ្ញុំ។

ហេតុផលផ្សេងទៀតគឺ:______________________________




facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

៤. តើមុខវិជ្ជាអ្វីដែលលំបាកសម្រាប់អ្នកនៅសាលារៀន? អ្វីដែលធ្វើឲ្យមុខវិជ្ជានោះលំបាក និងមិនគួរឲ្យចាប់អារម្មណ៍?

___

___

___

៥. តើអ្នកអាចធ្វើដូចម្តេច ដើម្បីឲ្យមុខវិជ្ជាលំបាកទាំងនោះក្លាយជាមុខវិជ្ជាងាយស្រួល ឬគួរឲ្យចាប់អារម្មណ៍ជាងមុន សម្រាប់ការសិក្សារបស់អ្នក?

___

___

___

៦. តើគោលបំណងបែបណាដែលអ្នកបានកំណត់សម្រាប់ខ្លួនឯងចំពោះការសិក្សា (ពិន្ទុ ថ្នាក់ ការសិក្សាបន្ត ជំនាញ ។ល។)?

___

___

___

៧. តើអ្វីដែលជាការជំរុញឲ្យអ្នកទទួលបានលទ្ធផល និងទង្វើល្អនៅសាលារៀន (ការលើកទឹកចិត្តពីឪពុកម្តាយ គ្រូ អ្នកដទៃ ពិន្ទុ ក្តីសុបិន ផែនការអនាគត...)?

___

___

___

៨. ហេតុអ្វីបានជាគ្រូដាក់ពិន្ទុនៅសាលារៀន?

___

___

___

៩. តើអ្នកមានប្រតិកម្មយ៉ាងណាដែរ បើសិនជាអ្នកមិនបានទទួលពិន្ទុល្អនៅពេលប្រឡង?

___

___

___

១០. ហេតុអ្វីបានជាវង្វាយតម្លៃលើទង្វើ និងការប្រឹងប្រែងរបស់អ្នកនៅសាលារៀនមានសារៈសំខាន់?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

១១. តើអ្នកមានអារម្មណ៍ដូចម្តេច នៅពេលគ្រូរបស់អ្នកផ្តល់ព័ត៌មានត្រឡប់បែបវិជ្ជមានដល់អ្នក?

១២. ហេតុអ្វីបានជាការធ្វើកិច្ចការផ្ទះមានសារៈសំខាន់?

១៣. ហេតុអ្វីបានជាការសួរនៅក្នុងថ្នាក់រៀនមានសារៈសំខាន់?

១៤. តើអ្នកមានចំណុចខ្លាំងលើការសិក្សាបែបណា?

☐ ស្តាប់ ☐ ពិភាក្សា ☐ ប្រតិបត្តិ ☐ បង្រៀនអ្នកដទៃ

### ៣.២.២ លំហាត់ផ្កា

គ្រូប្រឹក្សាអាជីព ដឹកនាំសិស្សអោយពិភាក្សាអំពីសកម្មភាព និងកត្តាដែលគាំទ្រដល់ការសិក្សា និងជួយជំរុញការសិក្សាអោយទទួលបានជោគជ័យ។

**ជំហានទី១ ៖** ដើម្បីដឹកនាំសកម្មភាព គ្រូត្រូវបង្ហាញអំពីការលូតលាស់របស់ផ្កា ចាប់តាំងពីការដាំគ្រាប់រហូតដល់ចេញផ្កា។



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**ជំហានទី២ ៖** ហេតុអ្វីបានជាផ្កាលូតលាស់ហើយរីកស្គុសស្គាយ? តើកត្តាអ្វីខ្លះដែលអាចធ្វើអោយផ្កាលូតលាស់ ហើយរីកស្គុសស្គាយ?



### ៣.២.៣ ដំណើរនៃការសិក្សារបស់ខ្ញុំ

គោលបំណងនៃលំហាត់នេះ គឺជួយសម្របសម្រួលឲ្យសិស្សរៀបរាប់ពីបទពិសោធន៍នៃការសិក្សាដ៏សំខាន់របស់គេក្នុងអំឡុងពេលនៃឆ្នាំសិក្សា ជីវិត និងបន្ទាប់មកទៀត អាជីព។ គោលបំណងនៃលំហាត់នេះក៏ជួយឲ្យសិស្សមើលឃើញមនុស្សសំខាន់ៗនៅជុំវិញខ្លួន ដែលមានឥទ្ធិពលលើជីវិត និងក្តីសុបិន ហើយផែនការពាក់ព័ន្ធនឹងអាជីពអនាគតនឹងអាចមានការផ្លាស់ប្តូរដោយវិធីណា ពីមួយឆ្នាំទៅមួយឆ្នាំ។ លើសពីនេះដំណើរនៃការសិក្សាធ្វើឲ្យយើងអាចមើលឃើញពីផែនការ និងគោលដៅអនាគតយ៉ាងជាក់ច្បាស់។

ដំណើរនៃការសិក្សាអាចជាតារាងពេលវេលា ផ្លូវ ផែនទីគំនិត ឬរបាយការណ៍/សំបុត្រ។ គ្រូប្រឹក្សាអាជីព ត្រូវលើកទឹកចិត្តឲ្យសិស្សប្រើអត្ថបទ រូបភាព ដ្យាក្រាម និងពណ៌ ដើម្បីធ្វើឲ្យដំណើរនៃការសិក្សារបស់ពួកគេ រស់រវើកនិងអាចរៀបរាប់បាន។

ដំណើរនៃការសិក្សាគឺជាលំហាត់ដ៏ទូលំទូលាយមួយ ហើយអាចប្រើប្រាស់ក្នុងការប្រឹក្សាបែបទល់មុខ និងក្នុងថ្នាក់រៀន។ វាក៏អាចប្រើប្រាស់ (មួយផ្នែក) ជាកិច្ចការផ្ទះផងដែរ ពីព្រោះវាត្រូវការពេលវេលាមួយចំនួនដើម្បីបញ្ចប់កិច្ចការនោះ។ អាយុរបស់សិស្សកំណត់ពីដំណើរ នៃការសិក្សាបានយ៉ាងជ្រាលជ្រៅ ។

### គោលការណ៍ណែនាំអនុវត្ត

ចូរពន្យល់ពីគោលបំណង និងគោលដៅនៃការគូរដំណើរនៃការសិក្សាដល់សិស្ស។ ចូរបង្ហាញនូវឧទាហរណ៍នៃដំណើរការសិក្សា ពោលគឺ ដំណើរនៃកាសិក្សារបស់ពួកគេផ្ទាល់ ហើយប្រាប់ពីអ្វីដែលអាចរៀបរាប់បានទៅតាមដំណាក់កាលផ្សេងៗគ្នានៃដំណើរនោះ ។ ផ្តល់ពេលកំណត់ណាមួយដើម្បីសិស្សបានគូរដំណើរនៃកាសិក្សារបស់ពួកគេ និងផ្តល់ពេលវេលាគ្រប់គ្រាន់ជ្រោយ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

បង្កើតក្រុមដែលមានសិស្ស ២ ទៅ ៣នាក់ អនុញ្ញាតឲ្យពួកគេចែករំលែកនូវដំណើរការនៃការសិក្សារបស់ពួកគេជាមួយសមាជិកនៃក្រុមផ្សេងៗទៀត។ បន្ទាប់មកអ្នកអាចសួរសំណួរបន្ថែមដូចខាងក្រោម៖

- តើអ្នកមានអារម្មណ៍ដូចម្តេចចំពោះការគូរដំណើរការនៃការសិក្សារបស់អ្នក?
- តើការគូរនេះជួយឲ្យអ្នកស្គាល់ច្បាស់ជាងមុន អំពីដំណាក់កាលផ្សេងៗនៃជីវិត និងបទពិសោធន៍របស់អ្នកដែរឬទេ?
- តើអ្វីជាកំណត់សំគាល់សំខាន់ៗរបស់ដំណើរនៃការសិក្សារបស់អ្នក?

អ្នកអាចប្រមូលដំណើរនៃការសិក្សាសម្រាប់ជាព័ត៌មាន ហើយប្រគល់ឲ្យសិស្សវិញនៅពេលក្រោយ។ ប្រាប់សិស្សឲ្យរក្សាទុកនូវដំណើរនៃការសិក្សារបស់គេ។ ក្នុងអំឡុងពេលសិក្សា អ្នកអាចពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើដំណើរការសិក្សានេះបាន។

## ប្រតិបត្តិ



ចូរគូរដំណើរនៃការសិក្សារបស់អ្នក។ វាជាតារាងពេលវេលា ផែនការគំនិត ឬរបាយការណ៍/សំបុត្រ។ អ្នកអាចប្រើអត្ថបទ រូបភាព និងពណ៌ ដើម្បីឲ្យដំណើរការរបស់អ្នក រស់រវើក និងអាចរៀបរាប់បាន។

ចូររៀបរាប់អំពី៖

- ឆ្នាំសិក្សារបស់អ្នក និងបទពិសោធន៍នៃការសិក្សាដ៏សំខាន់ៗ
- ខ្លួនឯង គ្រួសារ និងមិត្តភ័ក្តិ
- មុខវិជ្ជាពេញចិត្ត និងបញ្ហាប្រឈមនៅសាលារៀន
- ការកំសាន្ត និងចំណាប់អារម្មណ៍
- ការងារក្នុងក្តីសុបិន្តទៅតាមដំណាក់កាលផ្សេងៗរបស់ដំណើរនៃការសិក្សា
- មនុស្សសំខាន់នៅក្នុងជីវិត ដែលអាចមានឥទ្ធិពលលើជីវិត និងជម្រើសអាជីពរបស់អ្នក

ចូររៀបរាប់ផងដែរអំពី៖

- ឱកាសដ៏សំខាន់ក្នុងជីវិតរបស់អ្នក
- តើក្តីរំពឹងនៃអនាគតរបស់អ្នកមានអ្វីខ្លះ?
- ផែនការ និងគោលបំណងដែលបានរៀបចំអនាគត (ការអប់រំ អាជីពផ្សេងៗ)
- ក្តីសុបិន្តរបស់អ្នក

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**ឧទាហរណ៍ទី១ ៖** សរសេរជាអត្ថបទអំពីដំណើរនៃការសិក្សា

My Learning Journey



ដំណើរនៃការសិក្សារបស់ខ្ញុំ

ចាប់ផ្តើមពី............................

..............................................

..............................................

........................................

**ឧទាហរណ៍ទី២៖** ប្រើប្រាស់តារាងពេលវេលា




ខ្ញុំនឹងប្រឡងសិស្សពូកែ

ខ្ញុំនឹងរៀនឲ្យបានលេខ១

ខ្ញុំនឹងរៀនឲ្យបានលេខ១ភាសាខ្មែរ

ខ្ញុំនឹងទៅទស្សនកិច្ចនៅក្រុមហ៊ុន

ខ្ញុំនឹងរៀនឲ្យបានលេខ១ភាសាខ្មែរ

ខ្ញុំនឹងរៀនឲ្យបានលេខ១គណិតវិទ្យា

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**ឧទាហរណ៍ទី៣ ៖** ប្រើប្រាស់ផែនទីដំណើរនៃការសិក្សា




**ឧទាហរណ៍ទី៤៖** ប្រើប្រាស់ដ្យាក្រាមដំណើរនៃការសិក្សា




facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី៤
# ជំនាញ និងភាពខ្លាំង

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ៤. ជំនាញ និងភាពខ្លាំង

## ៤.១. និយមន័យ «ជំនាញ និងភាពខ្លាំង»

**ជំនាញ** គឺលទ្ធភាព និងសមត្ថភាពរបស់បុគ្គលមានលក្ខណៈជាប្រព័ន្ធចេតនា ដែលទទួលបានតាមរយៈការសិក្សា ពិភាក្សា ពិនិត្យ សង្កេត អនុវត្ត... ហើយត្រូវបានប្រើប្រាស់ទៅតាមស្ថានភាពដើម្បីដោះស្រាយបញ្ហា ឬអនុវត្តការងារ ។ កាលណាគេនិយាយពី**ភាពខ្លាំង**របស់បុគ្គល មានន័យថាប្រមូលផ្តុំនូវសម្បទាសំខាន់ៗបី គឺជំនាញក្នុងការគិត (ចំណេះដឹង) ជំនាញបច្ចេកទេស (ចំណេះធ្វើ) និងទំនាក់ទំនងអន្តរបុគ្គល (ឥរិយាបថ)។ ដែលភាពខ្លាំងនេះអាចកើតមានតាមរយៈការសិក្សា ចំណូលចិត្ត និងសម្បទាពីកំណើតរបស់បុគ្គល។

## ៤.២. គោលបំណង

គោលបំណងនៅក្នុងដំណាក់កាលនៃវដ្តការប្រឹក្សាអាជីពនេះគឺ ជួយឲ្យសិស្សកំណត់នូវភាពខ្លាំង ជំនាញ គុណតម្លៃ សមត្ថភាព និងបុគ្គលិកលក្ខណៈល្អៗរបស់គេ និងមើលឃើញទាំងអស់នេះជារូបភាពរួម និងជួយពង្រីកការគិតអំពីភាពខ្សោយ ដើម្បីអភិវឌ្ឍតាមរយៈការសិក្សានិងការអនុវត្ត ហើយប្រែក្លាយវាទៅជាភាពខ្លាំងវិញ។ តាមរយៈសកម្មភាពដឹកនាំ និងការសម្របសម្រួលរបស់គ្រូប្រឹក្សាអាជីព នឹងជួយឲ្យសិស្សគិតអំពីទំនាក់ទំនងរវាងរូបភាពខ្លួនឯង និងជម្រើសនៃអាជីពដែរ ព្រមទាំងផ្សារភ្ជាប់រវាងអ្វីដែលខ្លួនគេមានទៅនឹងអ្វីដែលពួកគេកំពុងស្រមៃក្នុងពេលអនាគត។

**គោលការណ៍ណែនាំអនុវត្ត**

១. ការពិភាក្សាជាក្រុមអំពីការកំណត់នូវភាពខ្លាំង

២. ការស្វែងយល់ពីជំនាញរបស់ខ្ញុំ

៣. ការមើលឃើញពីភាពខ្លាំងរបស់ខ្ញុំតាមក្រសែភ្នែកអ្នកដទៃ

៤. ជំនាញ និងបុគ្គលិកលក្ខណៈជាសញ្ញាឆ្ពោះទៅកាន់ផ្លូវអាជីព

៥. តេស្តពហុសញ្ញា (ហ្គាដនើ ហាវើដ)

៦. តេស្តវាស់របៀបសិក្សា (Test of Learning Style)

៧. កាតនៃភាពខ្លាំងរបស់ខ្ញុំ

ជាការលំបាកណាស់សម្រាប់ពួកយើងម្នាក់ៗក្នុងការដឹងថាខ្លួនពូកែខាងអ្វី។ ផ្ទុយទៅវិញ នៅពេលដែលគេឲ្យនិយាយពីចំណុចខ្លាំងយើងហាក់បីដូចជាលើកឡើងពីចំណុចខ្សោយមុនគេ។ យើងក៏នឹងជាមានការដាក់ខ្លួន និងមានភាពអៀនខ្មាសចំពោះជំនាញរបស់យើង។ គោលដៅនៃលំហាត់ទាំងនេះ គឺជួយសិស្សឲ្យមើលឃើញខ្លួនឯង តាមក្រសែភ្នែកអ្នកដទៃ និងទទួលបាននូវចំណេះដឹងដ៏មានតម្លៃ និងសមរម្យពាក់ព័ន្ធនឹងភាពខ្លាំងរបស់ពួកគេ។

លំហាត់នេះអាចយកទៅប្រើប្រាស់ដោយបត់បែនទៅតាមស្ថានភាព ៖

**ការស្វែងយល់ពីជំនាញរបស់ខ្ញុំ**

–កិច្ចការផ្ទះ

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

– កម្រិតបឋម និងមធ្យមសិក្សា

– ការពិភាក្សាអំពីព័ត៌មានត្រឡប់ ជាសកម្មភាពក្នុងថ្នាក់រៀន (សំណួរបន្ថែម)

**ការមើលឃើញពីចំណុចខ្លាំងរបស់ខ្ញុំតាមក្រសែភ្នែកអ្នកដទៃ**

– សកម្មភាពក្នុងថ្នាក់ និង/ឬកិច្ចការផ្ទះ (វិធីសាស្ត្រសន្ទនាផ្ទាល់មាត់ ឬតាមទូរស័ព្ទ)

– កម្រិតមធ្យមសិក្សា

– ការពិភាក្សាអំពីព័ត៌មានត្រឡប់ដែលជាសកម្មភាពក្នុងថ្នាក់រៀន (សំណួរបន្ថែម)

**ជំនាញ និងបុគ្គលិកលក្ខណៈជាសញ្ញាសម្រាប់ផ្លូវអាជីព**

– ការពិគ្រោះយោបល់ក្នុងថ្នាក់រៀន និង/ឬកិច្ចការផ្ទះ

– កម្រិតបឋម និងមធ្យមសិក្សា

– ពិនិត្យលំហាត់ដែលជាសកម្មភាពក្នុងថ្នាក់រៀន ចែករំលែក និងផ្លាស់ប្តូរគំនិតគ្នា

### ៤.៣ ប្រតិបត្តិ



#### ៤.៣.១ ការស្វែងយល់ពីជំនាញរបស់ខ្ញុំ

ចូរសម្ភាសន៍ឪពុកម្តាយ ជីដូនជីតា និងមិត្តភ័ក្តរបស់អ្នក ដោយសំណួរសំខាន់ៗខាងក្រោម៖

១. តើខ្ញុំជាមនុស្សប្រភេទណា? ខ. តើខ្ញុំពូកែខាងអ្វី? គ. តើខ្ញុំមានមុខរបរ ឬអាជីពអ្វីនាពេលអនាគត?

ឪពុកម្តាយ

Parents

ជីដូនជីតា

Grandparents

មិត្តភ័ក្ត

Friends

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

២. តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចចំពោះការសម្ភាសន៍សមាជិកគ្រួសារ និងមិត្តភក្តិរបស់អ្នក?

..............................................................................................................................

..............................................................................................................................

៣. តើអ្នកយល់ថាចម្លើយរបស់ពួកគេ គួរឲ្យភ្ញាក់ផ្អើលដែរឬទេ?

..............................................................................................................................

..............................................................................................................................

៤. តើអ្នកបានរៀនអ្វីថ្មី? ចំណុចខ្លាំងរបស់អ្នកទេ?

..............................................................................................................................

..............................................................................................................................

### ៤.៣.២ ការមើលឃើញពីភាពខ្លាំងរបស់ខ្ញុំតាមក្រសែភ្នែកអ្នកដទៃ

និយាយទៅកាន់មនុស្សពីរនាក់ដែលអ្នកស្គាល់ច្បាស់ (ម្តាយ ឪពុក អ្នកធ្វើការជាមួយ ថៅហ្វាយ មិត្តភ័ក្ត។ល។) ចូរសួរពួកគាត់នូវសំណួរខាងក្រោម៖

១. តើខ្ញុំជោគជ័យនៅពេលណា? តើខ្ញុំបានធ្វើអ្វីល្អ?

២. ហេតុអ្វីបានខ្ញុំទទួលបានជោគជ័យ? តើជំនាញ និងបុគ្គលិកលក្ខណៈបែបណាជួយឲ្យខ្ញុំជាគជ័យ?

៣. តើអ្នកចង់ផ្តល់ព័ត៌មានត្រឡប់បែបវិជ្ជមានផ្សេងទៀតទេ?





៤. តើអ្នកមានអារម្មណ៍យ៉ាងណាដែរចំពោះការទូរស័ព្ទទៅកាន់មនុស្សទាំងនេះ?

៥. តើអ្នកយល់ថាចម្លើយរបស់គាត់គួរឲ្យភ្ញាក់ផ្អើលដែរឬទេ?

៦. តើអ្នកបានរៀនអ្វីថ្មីពីខ្លួនឯងទេ?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

### ៤.៣.៣ ជំនាញ និងបុគ្គលិកលក្ខណ:ជាសញ្ញាដំបូងឆ្ពោះទៅកាន់ផ្លូវអាជីព

ខាងក្រោមនេះជាបញ្ជីនៃជំនាញ និងបុគ្គលិកលក្ខណ:។ ចូរស្វែងរកយ៉ាងហោចណាស់ការងារពីរដែលត្រូវការបំពេញ ឬបុគ្គលិកលក្ខណ:ដូចបានរៀបរាប់ បន្ទាប់មកគូសរង្វង់ជុំវិញបុគ្គលិកលក្ខណ: និងជំនាញដែលអ្នកមាន។

| ជំនាញ/បុគ្គលិកលក្ខណ: | ការងារ ១ | ការងារ ២ |
|---|---|---|
| ពូកែខាងសរសេរ | | |
| ពូកែខាងគូរ | | |
| រៀនភាសាបរទេសងាយស្រួល | | |
| ជំនាញប្រើដៃ | | |
| ការងារជាក្រុម | | |
| ចាប់អារម្មណ៍ខាងគីមី | | |
| ពូកែគណិតវិទ្យា | | |
| ចាប់អារម្មណ៍ខាងកីឡា | | |
| ចាប់អារម្មណ៍ខាងបច្ចេកវិទ្យា | | |
| រំភើបរីករាយនឹងតូរ្យតន្ត្រី | | |
| អ្នកសំដែងដ៏ចំណាន | | |
| ចូលចិត្តសត្វ | | |
| ខ្លាំងផ្នែករាងកាយ | | |
| **ជំនាញ/បុគ្គលិកលក្ខណ:** | **ការងារ ១** | **ការងារ ២** |
| អំណត់ | | |
| ចេះជួយយកអាសារគេ | | |
| ក្លាហាន និងមិនខ្លាច | | |
| ចាប់អារម្មណ៍ខាងម៉ូដ | | |
| ចាប់អារម្មណ៍ខាងយន្តហោះ | | |
| មានគំនិតច្នៃប្រឌិត | | |
| ចាប់អារម្មណ៍ខាងធម្មជាតិ | | |

### ៤.៣.៤ ភាពខ្លាំងទាក់ទងនឹងរបៀបនៃការសិក្សា និងវិធីសាស្ត្រនៃការសិក្សា

យើងគួរតែរៀនទទួលស្គាល់ពីភាពខ្លាំងរបស់យើង។ ជារឿងសំខាន់ណាស់ក្នុងការស្វែងរកនូវភាពខ្លាំងជាមុនសិន មុននឹងជ្រើសរើសយកអាជីពណាមួយ។ ភាពខ្លាំងអាចចាត់ទុកថាជាវិញ្ញាផងដែរ។ សិស្សម្នាក់ៗ អាចសិក្សា ចងចាំ សម្តែង និងយល់ ដោយមធ្យោបាយផ្សេងៗគ្នា។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

តាមរយៈការកំណត់នូវរបៀបនៃការសិក្សាដែលគេពេញចិត្ត។ មានវិធីសាស្ត្រជាច្រើនដែលសិស្សអាចជ្រើសរើស ដើម្បីពង្រឹងការសិក្សាប្រកបដោយលទ្ធផលល្អ ដូចជា ស្តាប់ សង្កេត អាន ប្រតិបត្តិ ពិភាក្សា ចោទសួរ ដោះស្រាយបញ្ហា បង្រៀនអ្នកដទៃ ជាដើម។

ដើម្បីគាំទ្រដល់ការវាយតម្លៃលើបញ្ញា ភាពខ្លាំង និងរបៀបនៃការសិក្សា គ្រូប្រឹក្សាអាជីព អាចប្រើប្រាស់តេស្តពហុបញ្ញាដើម្បីវាស់ស្ទង់។ គ្រូត្រូវបកស្រាយពីលទ្ធផលតេស្តដោយប្រុងប្រយ័ត្ន និងមិនអាចពឹងផ្អែកទាំងស្រុងទៅលើលទ្ធផលតេស្តតែមួយមុខនោះទេ។

**តេស្តពហុបញ្ញា** (តាមម៉ូដែល Multiple Intelligences របស់ហាវើដ ហ្គាដនើ 1991)

១. ធ្វើតេស្តនៃទម្រង់បញ្ញារបស់អ្នក។ ចូរដាក់ពិន្ទុលើប្រយោគខាងក្រោម។ (ដាក់ពិន្ទុនៅក្នុងប្រអប់ពណ៌ស)

1 =មិនយល់ព្រមច្រើន 2 = មិនយល់ព្រមតិច 3 = យល់ព្រមតិច 4 = យល់ព្រមច្រើន

| ល.រ | ប្រយោគ | ពិន្ទុ | | | | | | |
|---|---|---|---|---|---|---|---|---|
| 1 | ខ្ញុំចេះលេងភ្លេង | | | | | | | |
| 2 | ជាញឹកញាប់ខ្ញុំមានចម្រៀង ឬតូរតន្ត្រីនៅក្នុងចិត្ត | | | | | | | |
| 3 | ខ្ញុំយល់ថាការសរសេររឿងមានភាពងាយស្រួល | | | | | | | |
| 4 | ខ្ញុំតែងតែមានទំនាក់ទំនងផ្នែករាងកាយល្អ (រត់ លោត តុល្យភាព...) | | | | | | | |
| 5 | តូរតន្ត្រីមានសារៈសំខាន់សម្រាប់ខ្ញុំ | | | | | | | |
| 6 | ខ្ញុំពូកែកុហក (បើសិនជាខ្ញុំចង់) | | | | | | | |
| 7 | ខ្ញុំលេងកីឡា ឬរាំ | | | | | | | |
| 8 | ខ្ញុំជាមនុស្សរួសរាយ និងចូលចិត្តនៅក្បែរមនុស្ស | | | | | | | |
| 9 | ខ្ញុំងាយយល់ក្រាហ្វ តារាង និងដ្យាក្រាម | | | | | | | |
| 10 | ខ្ញុំងាយចងចាំ សម្រង់ ឃ្លា កំណាព្យ ឬពាក្យពេចន៍នៃចម្រៀង | | | | | | | |
| 11 | ខ្ញុំតែងតែអាចចាំបាននូវកន្លែងដែលខ្ញុំធ្លាប់ទៅដល់ | | | | | | | |
| 12 | នៅពេលខ្ញុំផ្ចង់អារម្មណ៍ ខ្ញុំទំនោរទៅខាងគូររូប | | | | | | | |
| 13 | ខ្ញុំពូកែគិតលេខ (គណនា នៅក្នុងខួរក្បាល) | | | | | | | |
| 14 | នៅសាលារៀន មុខវិជ្ជាដែលខ្ញុំពេញចិត្ត គឺភាសាខ្មែរ | | | | | | | |
| 15 | ខ្ញុំគិតពីបញ្ហាដោយមានការប្រុងប្រយ័ត្ន និងមើលឃើញពីលទ្ធផលរបស់វា | | | | | | | |
| | ពិន្ទុសរុបទី ១ | | | | | | | |
| 16 | ខ្ញុំចូលចិត្តកីឡាដែលជួយបំបាត់ភាពតានតឹង និងការជិះតូរឲ្យរន្ធត់ | | | | | | | |
| 17 | ខ្ញុំចូលចិត្តកីឡាបែបបុគ្គលច្រើនជាង | | | | | | | |
| 18 | ខ្ញុំយល់ថាលេខទូរស័ព្ទងាយស្រួលចាំ | | | | | | | |
| 19 | ខ្ញុំបានរៀបចំគោលដៅ និងផែនការសម្រាប់អនាគត | | | | | | | |

facebook.com/moeyscambodia YouTube youtube.com/moeyscambodia www.moeys.gov.kh

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 20 | ខ្ញុំអាចប្រាប់យ៉ាងងាយថាមាននរណាចូលចិត្ត ឬមិនចូលចិត្តខ្ញុំ | | | | | | | |
| 21 | ដើម្បីសិក្សាអ្វីដែលថ្មី ខ្ញុំត្រូវការសាកល្បងវាសិន | | | | | | | |
| 22 | ជាញឹកញាប់ ខ្ញុំឃើញរូបភាពខ្លួនឯងនៅពេលបិទភ្នែក | | | | | | | |
| 23 | ខ្ញុំមិនប្រើម្រាមដៃទេនៅពេលខ្ញុំរាប់ | | | | | | | |
| 24 | នៅសាលារៀន/កាលខ្ញុំនៅរៀន ខ្ញុំចូលចិត្តមេរៀនតន្ត្រី | | | | | | | |
| 25 | ខ្ញុំយល់ថាហ្គេមស្រួលលេង និងសប្បាយ | | | | | | | |
| 26 | មុខវិជ្ជាដែលខ្ញុំពេញចិត្តនៅសាលា គឺគណិតវិទ្យា | | | | | | | |
| 27 | ខ្ញុំតែងតែដឹងថាខ្ញុំកំពុងមានអារម្មណ៍យ៉ាងណា | | | | | | | |
| 28 | ខ្ញុំតែងតែសរសេរកំណត់ហេតុ | | | | | | | |
| 29 | មុខវិជ្ជាដែលខ្ញុំពេញចិត្ត គឺសិល្បៈ | | | | | | | |
| 30 | ខ្ញុំចូលចិត្តអាន | | | | | | | |
| 31 | ខ្ញុំមិនសប្បាយចិត្តពេលឃើញនរណាម្នាក់យំ ហើយមិនអាចជួយបាន | | | | | | | |
| 32 | ខ្ញុំចូលចិត្តកីឡាជាក្រុម | | | | | | | |
| 33 | ការច្រៀងធ្វើឲ្យខ្ញុំសប្បាយចិត្ត | | | | | | | |
| 34 | ខ្ញុំសប្បាយចិត្តក្នុងការចំណាយពេលម្នាក់ឯង | | | | | | | |
| 35 | មិត្តរបស់ខ្ញុំតែងមករកការគាំទ្រ និងដំបូន្មានផ្នែកអារម្មណ៍ពីខ្ញុំ | | | | | | | |
| | ពិន្ទុសរុបទី២ | | | | | | | |

៦) ចូរបូកពិន្ទុសរុប (ពិន្ទុសរុបទី ១ + ពិន្ទុសរុបទី២) សម្រាប់កូឡោននិមួយៗ។

| ទម្រង់បញ្ញា «របៀបនៃការសិក្សា» | ពិន្ទុសរុប | | | | | | |
|---|---|---|---|---|---|---|---|
| ផ្នែកខាងភាសា | | | | | | | |
| ផ្នែកតក្កនិងគណិតវិទ្យា | | | | | | | |
| ផ្នែកខាងតូរ្យតន្ត្រី | | | | | | | |
| ផ្នែកខាងកាយសម្បទា | | | | | | | |
| ផ្នែកមើល ទស្សនីយភាព និងលំហរ | | | | | | | |
| ផ្នែកទំនាក់ទំនង | | | | | | | |
| ផ្នែកចិត្តសាស្ត្រ និងអារម្មណ៍ | | | | | | | |

*(www.businessballs.com)*

ន្ទុខ្ពស់បង្ហាញពីភាពខ្លាំង និងសក្តានុពលពីកំណើត ពោលគឺបញ្ញាពីកំណើត!

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**សម្គាល់៖** កាលណាពិន្ទុកាន់តែខ្ពស់ វាបង្ហាញថា អ្នកមានភាពខ្លាំង និងសក្តានុពលពីកំណើត ពោលគឺ បញ្ញាពីកំណើត។ បន្ទាប់ពីតេស្តភាពខ្លាំង និងទំនាក់ទំនងនៃការសិក្សា គ្រូប្រឹក្សាអាជីព អាចណែនាំសិស្ស ឬផ្តល់យោបល់ដល់គ្រូផ្សេងទៀត ពីភាពខ្លាំងរបស់សិស្សនោះ និងពីរបៀបនៃការរៀនរបស់គេ ដើម្បីអោយពួកគេអាចរៀនបានដោយជោគជ័យ តាមរយៈការពិភាក្សា ឬការស្វែងយល់ពីទម្រង់នៃបញ្ញា និងរបៀបនៃការសិក្សា។

### ៤.៣.៥ ទម្រង់នៃបញ្ញា និងរបៀបនៃការសិក្សា

**ផ្នែកភាសា៖** អ្នកសិក្សាដែលពូកែពាក្យពេចន៍ និងមានភាពរីកចម្រើនខាងជំនាញស្តាប់។ អ្នកដែលមានជំនាញភាសាប្រើពាក្យប្រកបដោយប្រសិទ្ធភាព ហើយតែងតែគិតអំពីអ្វីជាពាក្យច្រើនជាងរូបភាព។ មនុស្សជំនាញខាងភាសាមានភាពស្ញប់ស្ញាត់ មានហេតុផលសមរម្យ និងជាមនុស្សដែលពូកែស្តាប់ផងដែរ។ មនុស្សប្រភេទនេះចូលចិត្តគិតច្រើន និងចូលចិត្តលេងផ្គុំរូប។ អ្នកសិក្សាផ្នែកភាសាពូកែរៀបរាប់ និងពន្យល់។ គេចូលចិត្តអាន លេងហ្គេម និពន្ធ និងប្រឌិតរឿង។ វិធីសាស្ត្រនិងឧបករណ៍សិក្សាដែលល្អសម្រាប់មនុស្សក្រុមនេះគឺ៖ *ការអាន (ម្នាក់ឯងឬជុំគ្នា) ការពិភាក្សា ធ្វើអត្ថាធិប្បាយ ប្រើប្រាស់កុំព្យូទ័រ ហ្គេម ការសួរព័ត៌មាន និងការបង្រៀន* ជាដើម។ អាជីពដែលស័ក្តិសមបម្រាប់អ្នកដែលមានទម្រង់បញ្ញាខាងភាសាគឺ៖ *អ្នកសារព័ត៌មាន បណ្ណារក្ស អ្នកអត្ថាធិប្បាយបុគ្គលិករដ្ឋបាល អ្នកប្រឹក្សាយោបល់ មេធាវី កវី អ្នកបកប្រែភាសា អ្នកធ្វើបទបង្ហាញតាមវិទ្យុ/ទូរទស្សន៍ អ្នកសរសេរអត្ថបទផ្សាយពាណិជ្ជកម្ម អ្នកលក់ អ្នកប្រឹក្សាព័ត៌មាន និងគ្រូបង្រៀន*។

**ផ្នែកតក្ក និងគណិតវិទ្យា៖** អ្នកសិក្សាដែលពូកែខាងតក្ក និងលេខ មានហេតុផលបែបអនុមាន និងគិតបែបអរូបី ហើយអាចយល់ពីគម្រូ និងទំនាក់ទំនង។ បញ្ញានេះមានភាពពាក់ព័ន្ធនឹងការគិតបែបវិទ្យាសាស្ត្រនិងគណិតវិទ្យា។ ពួកគេចូលចិត្តរក្សារបស់របរ សម្ភារ ឲ្យបានស្អាតនិងមានលំដាប់ផ្ទាប់ ហើយសរសេរក្នុងបញ្ជី មុននឹងធ្វើអ្វីមួយទៅតាមលំដាប់លំដោយ។ ពួកគេពិចារណាពីគ្រប់លទ្ធផលនិងហេតុផលទាំងអស់ មុននឹងសម្រេចចិត្តធ្វើអ្វីមួយ។ មនុស្សប្រភេទតក្ក ចូលចិត្តស្វែងយល់ពីលក្ខណៈនៃដំណើរការការងារ ហើយយល់ច្បាស់ពីការងារលម្អិត។ អ្នកសិក្សាបែបតក្កចូលចិត្តសួរសំណួរច្រើន ហើយក៏ជាអ្នកដែលពូកែបកស្រាយចម្ងល់ផងដែរ។ ពួកគេអាចរៀនសូត្រតាមរយៈ *ហ្គេមតក្ក ការស៊ើបអង្កេត និងអាថ៌កំបាំង*។ មនុស្សប្រភេទនេះត្រូវការការរៀនដែលមានលក្ខណៈបង្កើតគំនិតថ្មី មុននឹងដោះស្រាយបញ្ហា។ អាជីពដែលស័ក្តិសមគឺ៖ *គណនេយ្យករ អ្នកស្ថិតិប៉ូលីស អាកាសចរ អាវកាសយានិក អ្នកស្រាវជ្រាវ អ្នកបង្កើតកម្មវិធីកុំព្យូទ័រ អ្នកបង្កើតហ្គេម វិស្វករអ្នកស៊ើបអង្កេត ធនាគារិក និងអ្នកវិទ្យាសាស្ត្រ* ជាដើម។

**ផ្នែកតន្ត្រី៖** ចូលចិត្តតូរ្យតន្ត្រី និងឆាប់ដឹងពីសម្លេងដែលនៅជុះវិញខ្លួន។ ពួកគេចូលចិត្តតន្ត្រីខុសៗគ្នា និងជ្រើសរើសស្តាប់ទៅតាមអារម្មណ៍។ ជាញឹកញាប់គេចូលចិត្តច្រៀងតិចៗម្នាក់ឯង ឬ



facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

តាមទំនុកច្រៀងផ្សេងៗ។ ជួនកាលគេអាចនិពន្ធបទភ្លេងដោយខ្លួនឯងបាន។ អ្នកសិក្សាផ្នែកតូរ្យ តន្ត្រី អាចសិក្សាបានល្អជាមួយភ្លេង ការបន្ទរតាម និងអាចចងចាំបានល្អ ដោយបន្ទរ ឬថាដដែលៗ។ យើងអាចបង្រៀនពួកគេដោយប្តូរមេរៀនទៅជា *កាព្យខ្លីៗ និយាយបែបចង្វាក់ភ្លេង និងគោះដៃជើង បណ្តើរ*។ ពួកគេអាចរៀនបានល្អតាមរយៈ *ឧបករណ៍តន្ត្រី ភ្លេង វិទ្យុ ម៉ាញ៉េ សោតទស្សន៍ និងពហុសារព័ត៌មាន*។ អាជីពដែលស័ក្តិសមសម្រាប់ពួកគេគឺៈ *តន្ត្រីករ អ្នកចម្រៀង អ្នកនិពន្ធបទភ្លេងនិងបទចម្រៀង អ្នកសម្តែង គ្រូតន្ត្រី អ្នកបង្កើតឧបករណ៍ភ្លេង អ្នកដឹកនាំវង់ភ្លេង DJ អ្នកលំហែរ អ្នករៀបចំ វីដេអូ និងភាពយន្ត និងអ្នករៀបចំពិធីជប់លៀង* ផ្សេងៗ។

**ផ្នែកកាយសម្បទា៖** អ្នកពូកែខាងកាយសម្បទាអាចប្រើប្រាស់រាងកាយ វិញ្ញាណទាំងប្រាំ និងអវៈយវៈរបស់គេបានយ៉ាងមានប្រសិទ្ធិភាពដូចជា អ្នករាំ ឬគ្រូពេទ្យវះកាត់។ អ្នកសិក្សាទាំងនេះអាចទទួលបានប្រយោជន៍ពីបទពិសោធន៍ផ្នែករាងកាយដូចជា *ការប៉ះ ស្ទាប កាន់ ហិតក្លិន និងបទពិសោធន៍ដោយមានការចូលរួមសកម្ម*។ ពួកគេពូកែខាងកីឡា សម្តែង រាំ ទំនាក់ទំនងរវាងដៃ និង ភ្នែក។ អ្នកសិក្សាដែលពូកែខាងកាយសម្បទា អាចមានការលំបាកក្នុងការផ្ចង់អារម្មណ៍នៅពេលរៀន ហេតុនេះ ពួកគេអាចចាត់ទុកថាជាអ្នកមានសកម្មភាពរស់រវើក។ វិធីសាស្ត្រដ៏ល្អបំផុតសម្រាប់បង្រៀនពួកគេគឺ *បញ្ចូលសកម្មភាពដោយប្រើសកម្មភាពរាងកាយ ការសិក្សាផ្សារភ្ជាប់នឹងការអនុវត្ត និងការសម្តែងតួ* ជាដើម។ អាជីពដែលស័ក្តិសមសម្រាប់ពួកគេគឺ៖ *យន្តការី សិប្បករ គ្រូបង្វឹក អត្ត ពលិក អ្នកវិភាគកីឡា កីឡាករ អ្នករបាំ នាដករ អ្នកម៉ាស្សា ជាងសំណង់ អ្នកធ្វើសក់ អ្នកសង្គ្រោះបន្ទាន់ពេទ្យ គ្រូពេទ្យវះកាត់ អ្នកសម្តែងភាពយន្ត ទាហាន អ្នកពន្លត់អគ្គីភ័យ អ្នកបើកបរ អ្នកថែរសួនច្បារ ក្រៅ និងជាងជួសជុល* ផ្សេងៗ។

**ផ្នែកមើល ទស្សនីយភាព និងលំហរ៖** អ្នកសិក្សាដែលពូកែមើលរូបភាព គិតលំហរចេញជារូបភាព ដូចជានាវិក និងអ្នកដើរកប៉ាល់ជាដើម។ ពួកគេស្គាល់ពីបរិស្ថានច្បាស់លាស់ ចូលចិត្តគូររូប មើលផែនទី និងមានភាពរវើរវាយដោយរស់រវើក មានការចងចាំដោយស្រមៃឃើញរូបភាព ឬគូរផែនទីគំនិត ពួកគេចូលចិត្តមើលរូបភាព ដ្យាក្រាមនៅក្នុងសៀវភៅមុននឹងអាន។ ពួកគេក៏ពូកែស្រមៃជារូបភាពលំហរបី (3D)។ មនុស្សប្រភេទនេះងាយរៀនដោយប្រើប្រាស់ភ្នែក លំហរ និង ការសង្កេត។ វិធីសាស្ត្របង្រៀន និងសម្ភារបង្រៀនដែលសមស្របសម្រាប់ពួកគេគឺ៖ *ការធ្វើគំរូ ការសម្តែង ការបង្ហាញ ការថត ការគូរ ភាពយន្ត វីដេអូ ពហុសារព័ត៌មាន អត្ថបទជារូបភាព ដ្យាក្រាម* និងតារាងជាដើម។ អាជីពដែលស័ក្តិសមសម្រាប់ពួកគេគឺ៖ *អ្នកគូប្លង់ អ្នកDesign អ្នករៀបចំគេហទំព័រ វិចិត្រករ អ្នកទេសចរណ៍ អ្នកគូរផែនទី អ្នកថតរូប ចាងហ្វាងខ្សែភាពយន្ត អ្នករៀបចំផ្ទះ អ្នកលាបថ្នាំ អ្នកសាងសង់ អ្នកដើរកប៉ាល់ និម្មាបនិក (ស្ថាបត្យករ) គ្រូពេទ្យវះកាត់ អ្នកបើកយន្តហោះ វិស្វករ អ្នករៀបចំក្រុង*។

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

**ផ្នែកទំនាក់ទំនង៖** អ្នកពូកែទំនាក់ទំនងចូលចិត្តធ្វើការ សិក្សារៀនសូត្រ និងជួយអ្នកដទៃនៅជុំវិញខ្លួន។ ពួកគេមានមិត្តច្រើន និងមានការយល់ចិត្តអ្នកដទៃ។ បញ្ញាខាងទំនាក់ទំនងមានការពាក់ព័ន្ធទៅនឹងសមត្ថភាពក្នុងការស្វែងយល់ពីបំណង ការលើកទឹកចិត្ត និងក្តីប្រាថ្នារបស់អ្នកដទៃ។ មនុស្សជំពូកនេះ មានការបារម្ភចំពោះអ្នកដទៃ ហើយមនុស្សទូទៅតែងតែទទួលការទូន្មានពីគេ។ ពួកគេយល់ថាការស្វែងរកមធ្យោបាយដោះស្រាយបញ្ហា និងជម្លោះរវាងមិត្តភក្តិជាការងាយស្រួល។ គេចូលចិត្តការងារជាក្រុម ការចែករំលែក និងពូកែយល់ភាសាកាយវិការ។ ពួកគេអាចរៀនបានល្អតាមរយៈ*ការប្រាស្រ័យទាក់ទង ការធ្វើការងារជាក្រុម ការសន្ទនាសិក្ខាសាលា*។ អាជីពដែលសមស្របសម្រាប់ពួកគេគឺ៖ *គ្រូបង្រៀន តួសម្តែង ពេទ្យផ្លូវចិត្ត អ្នកលក់ អ្នកគ្រប់គ្រង អ្នកសម្ភាសន៍ អ្នកនយោបាយ អ្នកការងារសង្គម វេជ្ជបណ្ឌិត អ្នកផ្តល់ប្រឹក្សា អ្នកជំនួញ ភ្នាក់ងារទេសចរណ៍ អ្នកជំនួញ អ្នកគ្រប់គ្រងសណ្ឋាគារ អ្នកផ្សព្វផ្សាយ និងគ្រូបង្វឹក* ជាដើម។

**ផ្នែកចិត្តសាស្ត្រ និងអារម្មណ៍៖** គឺជាអ្នកដែលមានភាពឆ្លាតវៃផ្នែកខាងក្នុង និងអារម្មណ៍។ ពួកគេមានគតិបណ្ឌិត អព្ភន្តរញាណ ការលើកទឹកចិត្ត ឆន្ទៈមោះមុត មានទំនុកកចិត្ត និងឧត្តមគតិ។ ជាមនុស្សដែលឆ្លាតដោយខ្លួនឯង មានការតាំងចិត្ត ឯករាជ្យ ធ្វើការដោយមានពេលកំណត់ និងកំណត់វត្ថុបំណងនិងគោលដៅច្បាស់លាស់សម្រាប់ខ្លួនឯង។ ជួនកាលគេចូលចិត្តធ្វើការដោយខ្លួនឯង គេចវេះពីអ្នកដទៃ។ ពួកគេក៏អាចមានចំណាប់អារម្មណ៍ខាងសាសនា សិល្បៈ ល្ខោន និងតែងតែសរសេរកំណត់ហេតុពីអារម្មណ៍របស់គេ។ ពួកគេជាអ្នកសិក្សាដែលឯករាជ្យបំផុត។ ពួកគេអាចរៀនបានល្អតាមរយៈវិធីសាស្ត្រ និងឧបករណ៍ ដូចជា *សៀវភៅ សម្ភារច្នៃប្រឌិត កំណត់ហេតុ*។ អាជីពដែលសមស្របសម្រាប់ពួកគេមាន៖ *សិល្បៈករ ម្ចាស់ជំនួញខ្នាតតូច អ្នកស៊ើបអង្កេត ចាង ហ្វាងខ្សែភាពយន្ត អ្នកប្រឹក្សា អ្នកធ្វើការផ្នែកសង្គម អ្នកធ្វើផែនការ អ្នកស្រាវជ្រាវ ចិត្តវិទូ ទស្សនវិទូ អ្នកបណ្តុះបណ្តាល ឬអ្នកនិពន្ធ* ជាដើម។

### ៤.៣.៦ កាតនៃភាពខ្លាំងរបស់ខ្ញុំ

គោលបំណងនៃលំហាត់នេះ គឺ ប្រមូលដាក់ចូលគ្នានូវផ្នែកជំនាញ និងភាពខ្លាំង (ការស្វែងយល់នូវជំនាញ ការយល់ពីភាពខ្លាំងតាមក្រសែភ្នែកអ្នកដទៃ ជំនាញ និងបុគ្គលិកលក្ខណៈជាសញ្ញាបំប៉ូងឆ្ពោះទៅកាន់ផ្លូវអាជីព និង/ឬ តេស្តនៃទម្រង់ពហុបញ្ញា) ដោយប្រើកាតនៃភាពខ្លាំងរបស់ខ្ញុំ។ គោលដៅ គឺជួយឲ្យសិស្សមើលឃើញពីភាពខ្លាំងរបស់គេ ជំនាញ និងបុគ្គលិកលក្ខណៈល្អៗ ជាមួយសភាពរួម។ គោលបំណងនេះ ក៏ជួយពង្រីកការគិតចំពោះការអភិវឌ្ឍភាពខ្សោយតាមរយៈការសិក្សា និងការអនុវត្ត ពោលគឺរបៀបផ្លាស់ប្តូរភាពខ្សោយឲ្យទៅជាភាពខ្លាំង។

លំហាត់នេះអាចប្រើប្រាស់សម្រាប់សកម្មភាពជាបុគ្គលក្នុងការពិគ្រោះយោបល់ទល់មុខ ឬការពិគ្រោះយោបល់នៅក្នុងថ្នាក់រៀន។ គ្រូក៏អាចដាក់ជាកិច្ចការផ្ទះបានដែរ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## គោលការណ៍ណែនាំ

ជំបូងស្នើសុំឲ្យសិស្សប្រមូល និងសរសេរនៅលើក្រដាសនូវជំនាញទាំងអស់របស់គេ ភាពខ្លាំង បុគ្គលិកលក្ខណៈល្អៗ ដែលបានកត់ទុកនៅក្នុងលំហាត់មុន។ បន្ទាប់មក ប្រាប់សិស្សជ្រើសយកភាពខ្លាំងសំខាន់ចំនួន៥។ បន្តដូចខាងក្រោម៖

ជំហានទី១ ៖ ប្រាប់ឲ្យសិស្សជ្រើសយកចំណុចខ្លាំងតែមួយពីភាពខ្លាំងទាំង៥ ដែលជាចំណុចពិសេស ឬខ្លាំង ហើយសរសេរនៅលើសន្លឹកបៀរ "Joker"

ជំហានទី២ ៖ ប្រាប់ឲ្យសិស្សសរសេរចំណុចខ្លាំង៤ ទៀតនៅលើសន្លឹក "A" ពោលគឺចំណុចខ្លាំងមួយនៅលើកាតនិមួយៗ

ជំហានទី៣ ៖ បន្តការពិភាក្សាពីភាពខ្លាំងទៅដល់ជំនាញ និងបុគ្គលិកលក្ខណៈល្អ ដែលសិស្សគិតថា ត្រូវការដើម្បីអភិវឌ្ឍបន្ថែមទៀត។

ជំហានទី៤ ៖ ស្នើសុំឲ្យ សិស្សជ្រើសយកជំនាញ ឬបុគ្គលិកលក្ខណៈចំនួន៣ ដែលគេយល់ថាជាចំនុចខ្សោយ នាពេលបច្ចុប្បន្ន ហើយសរសេរនៅលើសន្លឹក "10" ពោលគឺចំណុចខ្សោយមួយនៅលើកាតនីមួយៗ ហើយប្រាប់ឲ្យសិស្សពិពណ៌នាដោយសង្ខេបពីលក្ខណៈដែលគេត្រូវអភិវឌ្ឍជំនាញរបស់គេ ដើម្បីឲ្យប្រសើរឡើង។

## ប្រតិបត្តិ



### ដល់ពេលលេងកាតនៃភាពខ្លាំងរបស់អ្នកហើយ!

ជំបូងប្រមូលដាក់ចូលគ្នានៅលើក្រដាសនូវជំនាញ ភាពខ្លាំង និងបុគ្គលិកលក្ខណៈល្អៗ ទាំងអស់ដែលបាន កត់ទុកនៅក្នុងលំហាត់មុន។ បន្ទាប់មកជ្រើសយកចំណុចខ្លាំង៥ ដែលសំខាន់ ហើយបន្តដូចខាងក្រោម៖

១. ជ្រើសយកតែមួយចេញពីចំណុចខ្លាំងទាំង៥ ដែលជាចំណុចពិសេស ឬអស្ចារ្យ ហើយសរសេរនៅ លើកាត "Joker"

២. សរសេរចំណុចខ្លាំង៤ ទៀតនៅលើសន្លឹក "A" ពោលគឺចំណុចខ្លាំងមួយនៅលើកាតនីមួយៗ

៣. ចូរយើងបន្តការគិតទាំងអស់គ្នា! តើជំនាញនិងបុគ្គលិកលក្ខណៈណាខ្លះដែលអ្នកត្រូវអភិវឌ្ឍបន្ថែម? តើចំណុចខ្សោយរបស់អ្នកមានអ្វីខ្លះ?

៤. ជ្រើសយកពីរចំណុចហើយសរសេរវានៅលើកាត "10" និងរៀបរាប់សង្ខេបអំពីគោលនយោបាយដែលអ្នកនឹងត្រូវអភិវឌ្ឍជំនាញទាំងនេះ ដើម្បីប្តូរភាពខ្សោយឲ្យទៅជាភាពខ្លាំង ពោលគឺ ឧទា. អនុវត្ត សិក្សាបន្ថែម...)។

facebook.com/moeyscambodia YouTube youtube.com/moeyscambodia






















facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៥

# ការអប់រំ និងជម្រើសនៃអាជីព

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ៥. ការអប់រំ និងជម្រើសនៃអាជីព

## ៥.១ គោលបំណង

គោលបំណងនៅក្នុងដំណាក់កាលនៃវដ្ដការប្រឹក្សាអាជីពនេះគឺ ជួយឲ្យសិស្ស៖

- យល់ដឹងនូវទិដ្ឋភាពពាក់ព័ន្ធទាំងអស់ដែលមានឥទ្ធិពលដល់ជម្រើសនៃអាជីព និង ផែនការបន្ទាប់ពីបញ្ចប់ការសិក្សារបស់គេ
- ស្វែងយល់ពីចំណាប់អារម្មណ៍បច្ចុប្បន្ន ក្ដីរំពឹងទុក និងក្ដីប្រាថ្នាសម្រាប់អនាគត
- ស្វែងរកការងារផ្សេងៗ និងបង្ហាញការងារមួយចំនួនដែលសិស្សចាត់ទុកថាជា ជម្រើសអាជីពដែលបានប៉ងប្រាថ្នាទុកនៅថ្ងៃអនាគត
- ប្រមូលព័ត៌មានអំពីការអប់រំ និងការបណ្ដុះបណ្ដាលដែលត្រូវការសម្រាប់អាជីពដែល បានគ្រោងទុករបស់ពួកគេ និងជួយគាំទ្រការរៀបចំផែនការសម្រាប់ផ្លូវនៃការសិក្សា របស់គេ
- ចង្អុលបង្ហាញជំហានបន្ទាប់ដែលគេត្រូវដើរទៅមុខ ដើម្បីឈានជើងចូលសិក្សា និង ផ្លូវអាជីពបន្ទាប់ពីបញ្ចប់ការសិក្សា
- គិតពីជម្រើសផ្សេងៗក្នុងវិស័យដែលពាក់ព័ន្ធ
- រៀបចំផែនការដែលជួយឲ្យពួកគេសម្រេចបានគោលដៅ

## ៥.២ វិធីសាស្ត្រអនុវត្ត

### សន្លឹកកិច្ចការ និងលំហាត់

១. ការប្រកួតការងារ + សំណួរបាទ/ចា+

២. ឆ្ពោះទៅកាន់ជម្រើសអាជីព១ ផ្នែក១-៥

៣. ឆ្ពោះទៅកាន់ជម្រើសអាជីព២
- ការងារដែលប្រកបដោយអត្ថន័យ និងភាពរីករាយ
- ថ្ងៃធ្វើការងារធម្មតា

៤. ដំណើររុករកការសិក្សា

៥. ការស្វែងរកអាជីព
- លំហាត់ផ្គុំការងារ
- បញ្ជីស្វែងរកអាជីព (លំហាត់ពាក់ព័ន្ធ៖ ការងារដែលប្រកបដោយអត្ថន័យ និង ភាពរីករាយថ្ងៃធ្វើការងារធម្មតា ឆ្ពោះទៅកាន់ជម្រើសអាជីព២)
- បទសម្ភាសន៍ស្វែងរកព័ត៌មាន

៦. តេស្តហូឡែនកូដ (RIASEC)

៧. ផែនការអាជីព និងការអប់រំសង្ខេប

៨. កិច្ចសន្យានៃក្ដីសុបិន (សូមមើលផងដែរ ២. ក្ដីសុបិននៃអាជីព និងជីវិត)

៩. ផែនទីកំណប់ទ្រព្យ/ក្ដារទស្សនៈវិស័យ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ៥.៣ ប្រតិបត្តិ



### ៥.៣.១ ដំណើរឆ្ពោះទៅកាន់ជម្រើសអាជីព ១

ការអប់រំ និង ជម្រើសអាជីព គឺទទួលឥទ្ធិពលពីកត្តាជាច្រើនដូចជា មុខវិជ្ជាជាទីពេញចិត្តនៅសាលារៀន ចំណាប់អារម្មណ៍នាពេលបច្ចុប្បន្ន និង ល្បែងកំសាន្ត ចរិយាសម្បត្តិ ក្តីសុបិន្តកាលនៅកុមារ វប្បធម៌ មនុស្សដែលគេយកធ្វើជាគំរូ ការរំពឹងទុកនៃការងារ និងបំលាស់ប្តូរនៃទីផ្សារការងារ ហើយជួនកាលជម្រើសនេះទទួលបានពីក្តីរំពឹងទុករបស់អ្នកដទៃ។ ទោះជាយ៉ាងណាក្តី ជារឿងសំខាន់ក្នុងការទទួលការអប់រំ និងបណ្តុះបណ្តាលដែលផ្តល់ឱកាសដើម្បីអភិវឌ្ឍជំនាញ និងសមត្ថភាព ហើយរកការងារដែលគួរឲ្យចាប់អារម្មណ៍។ គោលបំណងនៃលំហាត់នេះ រៀបចំដើម្បីជួយសិស្សឲ្យស្វែងយល់ពីចំណាប់អារម្មណ៍ ក្តីរំពឹងទុក និងក្តីប្រាថ្នារបស់គេ។ ក្រោយមកពេលសិស្សរបស់អ្នកមានព័ត៌មានច្រើនអំពីការអប់រំ និងជម្រើសអាជីពផ្សេងៗ គេអាចវាយតម្លៃបានថាចំណាប់អារម្មណ៍របស់គេមានការផ្លាស់ប្តូរយ៉ាងណា។

លំហាត់ដែលបានរៀបចំឡើងនេះអាចយកមក ប្រើប្រាស់សម្រាប់ការប្រឹក្សាយោបល់ទល់មុខ និងនៅក្នុងថ្នាក់រៀនបាន។ លំហាត់ខ្លះ ក៏អាចដាក់ជាកិច្ចការផ្ទះបានដែរ ដើម្បីឲ្យសិស្សមានពេលគ្រប់គ្រាន់ក្នុងការពិចារណា នូវគំនិតរបស់គេ។

### ៥.៣.២ គោលការណ៍ណែនាំសម្រាប់អ្នកប្រឹក្សាយោបល់

លំហាត់នេះរៀបចំឡើងជាបន្តបន្ទាប់ (ចាប់ពីផ្នែក១-៥) ហើយអាចតម្រូវឲ្យមានមេរៀនប្រឹក្សាយោបល់មួយចំនួនដើម្បីបញ្ចប់។ ជាជម្រើស គេអាចជ្រើសយកលំហាត់ដែលមានលក្ខណៈផ្ទាល់ខ្លួន ដោយមិនត្រៀមទុក ទៅតាមតម្រូវការ និងសមត្ថភាពរបស់សិស្សដើម្បីបញ្ចប់លំហាត់។

មុននឹងបន្តផ្នែកទី១ (**ឥទ្ធិពលលើជម្រើសអាជីព**) គួរតែពិភាក្សាអំពីកត្តាសក្តានុពលណាដែលមានផលប៉ះពាល់ដល់ជម្រើសអាជីព។ ចូរផ្តល់ឧទាហរណ៍ឲ្យបានច្បាស់លាស់ដល់សិស្ស ដូចជាការនិយាយអំពីកត្តាផ្សេងៗ និងមនុស្សដែលមានឥទ្ធិពលដល់ការអប់រំ និងជម្រើសអាជីពរបស់ពួកគេ។

មុននឹងបន្តផ្នែកទី២ (**លក្ខណៈនៃការងារ**) ជាការសំខាន់ក្នុងការពិភាក្សាអំពីលក្ខណៈនៃការងារជាមួយសិស្ស ដើម្បីបើកចំហរអត្ថន័យនៃការបញ្ចេញមតិ តាមរយៈការសាកសួរ និងផ្តល់ជាឧទាហរណ៍ និងតាមការរៀបរាប់ថា លក្ខណៈនៃការងារ គឺ ស្ថិតក្នុងក្តីសុបិននៃការពិត សេចក្តីប្រាថ្នាការរំពឹងទុក ដែលសិស្សមានចំពោះការងារ និងលក្ខខណ្ឌនៃការងារសម្រាប់អាជីពនាពេលអនាគតរបស់គេ។ យ៉ាងហោចណាស់ សិស្សក្មេងៗ អាចពិបាកយល់នូវការបញ្ចេញមតិនេះ។ ជាជម្រើសបញ្ជីនៃលក្ខណៈការងារនៅលើសន្លឹកកិច្ចការ អាចធ្វើការកែប្រែបាន ដោយមានប្រយោគងាយ

facebook.com/moeyscambodia YouTube youtube.com/moeyscambodia www.moeys.gov.kh

ស្រួលយល់ដូចជា *ខ្ញុំចូលចិត្តនិយាយភាសាបរទេស ខ្ញុំចូលចិត្តធ្វើការម្នាក់ឯង ខ្ញុំចង់បានប្រាក់ខែច្រើន ខ្ញុំមិនចូលចិត្តធ្វើការក្រៅការិយាល័យទេ* ។

ជារឿងសំខាន់ផងដែរក្នុងការបញ្ចប់លំហាត់ដែលបានរៀបចំនេះ ហើយធ្វើការប្រៀបធៀបលទ្ធផល៖ តើលទ្ធផលចង្អុលបង្ហាញនូវទិសដៅដូចគ្នានឹងផ្លូវអាជីពរបស់គេដែរទេ?

## លំហាត់អំពីដំណើរឆ្ពោះទៅកាន់ជម្រើសអាជីព

លំហាត់ខាងក្រោមនេះជួយសិស្សឲ្យស្វែងយល់ពីចំណាប់អារម្មណ៍នាពេលបច្ចុប្បន្ន ក្តីរំពឹងទុក និងក្តីប្រាថ្នារបស់គេ។ ក្រោយមក ពេលសិស្សមានព័ត៌មានច្រើនអំពីការអប់រំ និងជម្រើសអាជីពផ្សេងៗ គេអាចវាយតម្លៃបានថាចំណាប់អារម្មណ៍របស់គេមានការផ្លាស់ប្តូរយ៉ាងណា។

### ផ្នែកទី១ ឥទ្ធិពលលើជម្រើសអាជីព

១. តើអ្វីខ្លះជះឥទ្ធិពលដល់ការអប់រំ និងជម្រើសអាជីពរបស់អ្នក? ចូរបំពេញប្រអប់គំនិត៖



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

២. តើនរណាជួយគាំទ្រដល់ជម្រើសអាជីពរបស់អ្នក? ចូរសរសេរនៅលើប័ណ្ណប្រកាស។



៣. តើអ្នកចង់ដើរតាមជំហានអ្នកណា? តើការងាររបស់អ្នកណាដែលអ្នកសរសើរ? តើពួកគេធ្វើអ្វី?



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

៤. តើអ្នកបានឮយោបល់បែបណាខ្លះ អំពីផែនការអនាគតរបស់អ្នក?



៥. តើយោបល់ទាំងនេះមានឥទ្ធិពលដល់ការអប់រំ និងជម្រើសនៃអាជីពរបស់អ្នកដែរឬទេ? ូរគូសសញ្ញានៅលើបន្ទាត់បង្ហាញពីឥទ្ធិពលដែលបានពីយោបល់ទាំងនេះ។

ំនមានទេ ខ្ញុំដឹងនូវអ្វីដែលខ្ញុំចង់បាន មានមនុស្សដទៃដឹងនូវអ្វីដែលល្អបំផុតសម្រាប់ខ្ញុំ

**ផ្នែកទី២ លក្ខណៈនៃការងារ**



នៅពេលដែលយើងកំពុងឆ្ងល់ថា *"តើអាជីពអ្វីដែលសាកសមនឹងខ្ញុំ"* អ្នកអាចមានការភ្ញាក់ផ្អើលដោយដឹងថាអ្នកមានចម្លើយអស់ទាំងនេះនៅក្នុងចិត្តអ្នក។ អ្នកមានសេចក្តីប្រាថ្នាពិតប្រាកដ ឬ ាការរំពឹងទុក ចំពោះការងារក្នុងក្តីសុបិនរបស់អ្នក ហើយអ្នកចង់ដាក់ឈ្មោះលក្ខណៈនៃការងារមួយ ំនួន ដែលអ្នកយល់ថាសំខាន់បំផុតចំពោះការងារក្នុងក្តីសុបិន។ តាមការស្វែងយល់នូវ លក្ខណៈបំខាន់ទាំងនោះ អ្នកក៏អាចរកឃើញចម្លើយចំពោះសំណួរដូចខាងក្រោមៈ

- តើអាជីពអ្វីខ្ញុំគួរជ្រើសយក?
- តើការងារបែបណាដែលខ្ញុំពេញចិត្ត?
- តើការងារបែបណាដែលស័ក្តិសមនឹងចរិយាសម្បត្តិរបស់ខ្ញុំ?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

១. តើអ្វីខ្លះសំខាន់សម្រាប់ការងារក្នុងក្តីសុបិនរបស់អ្នក? ចូរគូស(✓)

| | |
|---|---|
| លក្ខណៈនៃការងារ | |
| ឋានៈ | |
| ប្រាក់ចំណូលទៀងទាត់ | |
| ការងារគួរឲ្យចាប់អារម្មណ៍ ទោះជាប្រាក់ខែតិចក្តី | |
| ម៉ោងការងារទៀងទាត់ | |
| ម៉ោងការងារបត់បែន | |
| ការងារមានភាពច្បាស់លាស់ | |
| ការងារឯករាជ្យ និងមានភាពច្នៃប្រឌិត | |
| ប្រាក់ខែខ្ពស់ | |
| ធ្វើការម្នាក់ឯង | |
| ធ្វើការជាក្រុម/ជាមួយមនុស្ស | |
| មានទំនួលខុសត្រូវច្រើន | |
| មានឱកាសទទួលបានការបណ្តុះបណ្តាលបន្ថែម | |
| គ្មានហានិភ័យ | |
| ទទួលបានឱកាសនៃការអភិវឌ្ឍការងារ | |
| អាចធ្វើការនៅក្នុងការិយាល័យ | |
| ជួយអ្នកធ្វើការក្រៅការិយាល័យ | |
| ជួយអ្នកដទៃ | |
| សន្តិសុខការងារ | |
| ជួយសង្គម | |
| អាចធ្វើដំណើរទៅបរទេស | |
| អាចធ្វើការនៅក្នុងមាតុភូមិរបស់ខ្ញុំ | |
| បរិស្ថានការងារស្អាត | |
| ធ្វើការសម្រេចចិត្ត | |
| ការប្រកួតប្រជែងនៅកន្លែងការងារ | |
| មិត្តភាពជាមួយបុគ្គលិកដទៃ | |

២. ចំពោះលក្ខណៈនៃការងារដែលបានរៀបរាប់ខាងលើ តើអ្វីខ្លះដែលសំខាន់សម្រាប់អ្នក?ចូរជ្រើសយកបី៖

1) ______________________________

2) ______________________________

3) ______________________________

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ផ្នែកទី៣ ក្រុមការងារ និងបុគ្គលិកលក្ខណៈរបស់អ្នក



១. ខាងក្រោមនេះអ្នកអាចមើលឃើញក្រុមនៃការងារចំនួន៦ (R, I, A, S, E និង C)ចូរអាន បញ្ជីនៃក្រុមនីមួយៗ ហើយគូសសញ្ញា (✓) លើការងារដែលអ្នកចាប់អារម្មណ៍

| | R | | I | | A |
|---|---|---|---|---|---|
| | វិស្វករ | | ជាងមេកានិច | | អ្នកឌីសាញម៉ូដ |
| | ជាងឡាន | | អ្នកជីវសាស្ត្រ | | ស្ថាបត្យករ |
| | ជាងផ្សារ | | អ្នកប្រវត្តិសាស្ត្រ | | តន្ត្រីករ |
| | ជាងសំណង់ | | ជំនួយការបណ្ណាល័យ | | តួកុន |
| | អ្នកដុតនំ | | ជំនួយការបណ្ណាល័យ (បកប្រែ) | | អ្នករបាំ |
| | ប៉ូលិស | | អ្នករូបវិទ្យា | | ជាងថតរូប |
| | ជាងឈើ | | ឱសថការី | | អ្នកកាសែត |
| | អ្នកថែសួន | | អ្នកឌីសាញផ្នែកអាយធី | | អ្នកឌីសាយផ្នែកអាយធី |
| | ជាងកាត់ដេរ | | អ្នកបើកយន្តហោះ | | អ្នកតុបតែងផ្ទះ |
| | កសិករ | | អ្នកគណិតវិទ្យា | | ជាងគំនូរ |

| | S | | E | | C |
|---|---|---|---|---|---|
| | គ្រូ | | នាយកគ្រប់គ្រង | | លេខា |
| | អ្នកកីឡា | | អ្នករាយការណ៍តាមទូរទស្សន៍ | | អ្នកទទួលភ្ញៀវ |
| | អ្នកម៉ាស្សា | | អ្នកធនាគារ | | គណនេយ្យករ |
| | ចិត្តវិទូ | | ជំនួយការហាង | | ស្មៀនការិយាល័យ |
| | អ្នកទេសចរណ៍ | | អ្នកលក់ឬទិញឡាន | | អ្នកត្រួតពិនិត្យ |
| | អ្នកបម្រើប្រុស/អ្នកបម្រើស្រី | | អ្នកគ្រប់គ្រងផ្នែកលក់ | | សកម្មជន |
| | ពេទ្យ | | ភ្នាក់ងារសូរិយោដី | | បេឡាករនៅធនាគារ |
| | អ្នកប្រឹក្សាយោបល់ | | អ្នកលក់ | | ជំនួយការផ្នែកអាយធី |
| | ជាងកាត់សក់/អ្នកធ្វើសក់ | | អ្នកគ្រប់គ្រងសណ្ឋាគារ | | បេឡាធិការ |
| | វេជ្ជបណ្ឌិត | | អ្នកលក់ដូរ | | អ្នកស្ថិតិ |

២. តើមានការងារប៉ុន្មានដែលអ្នកបានគូសនៅក្រុមនីមួយៗ?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

R— I — A — S — E — C —

ក្រុមនៃការងារដែលមានសញ្ញា✓ច្រើនគឺ៖ —

៣. ចូរអានការពន្យល់សម្រាប់ក្រុមនៃការងារ វាផ្តល់ជាគំនិតខ្លះៗចំពោះវិស័យនៃអាជីពដែលអ្នកមានចំណាប់អារម្មណ៍៖

R = វិស័យដែលមានការអនុវត្តជាក់ស្តែង ការងារក្រៅការិយាល័យ

I = វិស័យខាងវិទ្យាសាស្ត្រ ការស្រាវជ្រាវវិទ្យាសាស្ត្រសង្គម និងធម្មជាតិ

A = វិស័យសិល្បៈ

S = វិស័យទំនាក់ទំនង ការថែទាំសុខភាព និងសង្គម ការអប់រំ

E = ការគ្រប់គ្រង ការប្រើឥទ្ធិពលលើអ្នកដទៃតាមរយៈការដឹកនាំ សហគ្រិនភាព

C = ការងារការិយាល័យ ការបញ្ចូលទិន្នន័យ (ផ្នែកលេខ)

៤. យោងតាមលទ្ធផល តើវិស័យនៃអាជីពអ្វីដែលស័ក្តិសមនឹងអ្នក?

___

___

___

៥. នៅលំហាត់មុន (ផ្នែកទី២) អ្នកបានជ្រើសរើសយកលក្ខណៈការងារបី ដែលអ្នកយល់ថាបំខាន់បំផុត សម្រាប់ការងារក្នុងក្តីសុបិន្តរបស់អ្នក។ តើលក្ខណៈនៃការងារ ឬក្តីប្រាថ្នាទាំងនេះ ស័ក្តិបមនឹងវិស័យអាជីព ដែលមានសញ្ញាគូស✓ច្រើនដែរទេ?

___

___

៦. តើអ្វីជាក្តីសុបិន្តរបស់អ្នកនាពេលបច្ចុប្បន្ន? តើក្រុមនៃការងារណាខ្លះ (R, I, A, S, E, ឬ C) ដលស្ថិតក្នុងការងារនៃក្តីសុបិន្ត?

**ផ្នែកទី៤ ចំណាប់អារម្មណ៍ និងសមត្ថភាពចំពោះការងារមួយ**



១. ចូរស្រមៃថាអ្នកធ្វើការឲ្យក្រុមហ៊ុន Future Career ដែលជាក្រុមហ៊ុនធំមួយដែលមានប្រតិបត្តិការផ្សេងៗគ្នា។ ក្រុមហ៊ុន Future Career ពិសេសលើសគេ ព្រោះបុគ្គលិកអាចជ្រើសប្រភេទនការងារដែលគេចង់ធ្វើ។ តារាងខាងក្រោមនេះរៀបរាប់ពីការងារផ្សេងៗចំនួន២១។ ចូរជ្រើសយកការងារទាំងឡាយណាដែលអ្នកចាប់អារម្មណ៍ ដោយគូសរង្វង់ជុំវិញអក្សរខាងមុខ នៃការងារនោះ។

| ខ្ញុំចង់... | |
|---|---|
| A | លក់ផលិតផល |
| B | ទទួលខុសត្រូវផ្នែកធនធានមនុស្ស |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | |
|---|---|
| C | រៀបចំផែនការឃោសនាផ្នែកលក់ |
| D | ធ្វើខាងTyping ឬការងារនៅតុទទួលភ្ញៀវ |
| E | ធ្វើយ៉ាងណាឲ្យកុំព្យូទ័រមានដំណើរការល្អ |
| F | ជួសជុលម៉ាស៊ីននៅក្នុងរោងផលិតកម្ម |
| G | សិក្សាផលប៉ះពាល់សុខភាពរបស់វត្ថុធាតុដើម |
| H | ធ្វើការជានាយកក្រុមហ៊ុន |
| I | ធ្វើជាពេទ្យប្រចាំក្រុមហ៊ុន |
| J | គ្រប់គ្រងហាងអនឡាញ |
| K | ផ្សព្វផ្សាយ |
| L | បង្កើតសុវត្ថិភាពដល់កន្លែងការងារ |
| M | គ្រប់គ្រងវិក័យប័ត្រ និងគណនេយ្យ |
| N | ធ្វើឲ្យបច្ចេកវិទ្យា និងម៉ាស៊ីនថ្មី |
| O | ពិនិត្យផលិតផលនៅក្នុងបន្ទប់ពិសោធន៍ |
| P | ស្ទង់មតិ និងវាយតម្លៃ ភាពពេញចិត្តនៃការងារ |
| Q | គ្រប់គ្រងអាហារដ្ឋានសម្រាប់បុគ្គលិក |
| R | ផ្តល់ការណែនាំពាក់ព័ន្ធនឹងបញ្ហាសង្គម |
| S | ធ្វើបទបង្ហាញពីក្រុមហ៊ុនដល់ភ្ញៀវ |
| T | ទាក់ទងជាមួយមនុស្សនៅបរទេស |
| U | កែសម្រួលព្រឹត្តិបត្ររបស់ក្រុមហ៊ុន និងទំព័របណ្តាញ |

២. ចូរគូសអក្សរដែលជាចម្លើយនូវក្នុងតារាងខាងក្រោម

| អក្សរ | | | វិស័យការងារ |
|---|---|---|---|
| B | H | Q | តំណែងខាងផ្នែកគ្រប់គ្រង និងរដ្ឋបាល |
| I | L | R | ការថែទាំសុខភាព និងសង្គម |
| A | C | J | ការលក់ |
| K | S | U | ការប្រាស្រ័យទាក់ទងនិងសិល្បៈ |
| D | M | T | ការងារការិយាល័យ |
| E | F | N | ការងារបច្ចេកទេស |
| G | O | P | ការស្រាវជ្រាវ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**ការបកស្រាយលទ្ធផល៖** អក្សរដែលបានគូសកាន់តែច្រើន មានន័យថាការចាប់អារម្មណ៍ និងសមត្ថភាព របស់អ្នកក៏មានកាន់តែច្រើនចំពោះវិស័យការងារដ៏ពិសេសនោះដែរ។

៣. ចូរត្រឡប់មកកាន់តារាងដែលពិពណ៌នាការងារទាំង២១ នៅក្នុងក្រុមហ៊ុន Future Career ហើយជ្រើសរើសយកការងារ ដែលអ្នកចាប់អារម្មណ៍ចំនួនបីក្នុងចំណោមការងារទាំងអស់។

1.________________________________________

2.________________________________________

3.________________________________________

*(សកម្មភាពនេះ គឺជាទម្រង់លំហាត់ណែនាំដោយ ហោគីណិន ២០១៥)*

**ផ្នែកទី៥** 

ចូរប្រៀបធៀបលទ្ធផលនៃលំហាត់ទាំងបីមុន (លក្ខណៈនៃការងារ ក្រុមការងារនៃRIASEC វិស័យការងារគួរឲ្យចាប់អារម្មណ៍)។ តើលទ្ធផលចង្អុលបង្ហាញនូវទិសដៅគ្នានឹងផ្លូវនៃអាជីពរបស់អ្នកឬទេ?

| លក្ខណៈនៃការងារ | RIASEC | វិស័យការងារគួរឲ្យចាប់អារម្មណ៍ | ការប្រៀបធៀប |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

### ៥.៣.៣ ដំណើរឆ្ពោះទៅកាន់ជម្រើសអាជីព ២

គោលបំណងនៃលំហាត់ទាំងពីរខាងក្រោមនេះ គឺសង្ខេបនូវលំហាត់មុនៗ (ផ្នែកទី១-ទី៥) នៅក្នុងលំហាត់ឆ្ពោះទៅកាន់ (អាជីពទី១) សិស្សបានមើលលក្ខណៈនៃការងារ វិស័យការងារដែលគួរឲ្យចាប់អារម្មណ៍ និងការងារនៃក្នុងសុបិនដែលបានប៉ងទុក ជាទម្រង់សន្លឹកកិច្ចការដែលរៀបចំទុក។ ឥឡូវនេះពួកគេអាចធ្វើការដោយគ្មានភាពតានតឹង ហើយទុកឲ្យការស្រមៃរបស់គេហោះហើរ ពួកគេអាចសរសេរ និងគូរជាសាច់រឿងអំពីក្ដីសុបិន និងទស្សនវិស័យរបស់គេបាន។

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

**ការងារប្រកបដោយអត្ថន័យ និងភាពរីករាយ** និង **ថ្ងៃធ្វើការងារធម្មតា** លំហាត់ទាំងពីរនេះអាចយកប្រើសម្រាប់ការប្រឹក្សាយោបល់ក្នុងថ្នាក់ ឬជាកិច្ចការផ្ទះក៏បាន។ បើរៀបចំសកម្មភាពនៅក្នុងថ្នាក់រៀន វាអាចធ្វើឲ្យសិស្សពេញចិត្តនិងគាំទ្រពីមិត្ត និងមានការណែនាំជិតដល់ពីគ្រូ។ ផ្ទុយទៅវិញ បើធ្វើនៅផ្ទះ សិស្សមានពេលវេលាគ្រប់គ្រាន់ក្នុងការពិចារណានូវទិដ្ឋភាពផ្សេងៗ និងចងក្រងរឿងរបស់គេប្រកបដោយការគិតស៊ីជម្រៅ។ ទោះជាអ្នកជ្រើសរើសវិធីអនុវត្តមួយណាក៏ដោយ កិច្ចការដែលសំខាន់នោះ គឺការចែករំលែករឿង ឧទាហរណ៍បិទរឿងនៅលើជញ្ជាំងថ្នាក់រៀន ដើម្បីឲ្យសិស្សទាំងអស់បានមើល និងស្វែងយល់។ រឿងនីមួយៗ អាចតម្រូវឲ្យមានការបញ្ចប់យ៉ាងហោចណាស់មួយ ឬពីរមេរៀនដែរ។

### ក. ការងារប្រកបដោយអត្ថន័យ និងភាពរីករាយ

តើអ្នកចង់មានការងារបែបណាធ្វើនៅពេលអនាគត? ចូរសរសេរ និងគូរការងារប្រកបដោយអត្ថន័យ និងភាពរីករាយ។ សំណួរនៅលើវត្ថុស៊ិកក្នុងសៀវភៅជួយអ្នកឲ្យចាប់ផ្តើមសរសេរ ហើយអ្នកអាចបន្ថែម ឬបន្ថយគំនិត និងទស្សនៈរបស់អ្នកដើម្បីឲ្យសាច់រឿងនេះកាន់តែគួរឲ្យចាប់អារម្មណ៍ថមទៀត។

**ការងារប្រកបដោយអត្ថន័យ និងភាពរីករាយ**



ខ្ញុំធ្វើការនៅ....ដែលមានទីតាំង....នៅទីនោះបរិស្ថានការងារ.....។ អ្វីដែលសំខាន់ចំពោះខ្ញុំគឺ..............

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

តើអ្នកធ្វើការនៅកន្លែងណា?
តើបរិស្ថានការងារបែបណា?
តើអ្នកស្លៀកពាក់បែបណា?
តើអ្នកមានការងារបែបណា?
តើអ្វីដែលសំខាន់សម្រាប់អ្នកនៅក្នុងការងារ?
តើអ្នកមានជំនាញអ្វីខ្លះដើម្បីធ្វើការងារ?
តើអ្នកអាចធ្វើអ្វីបាន?
តើអ្នកមានផែនការអ្វីខ្លះសម្រាប់អនាគត?

ការងារប្រកបដោយអត្ថន័យនិងភាពរីករាយ



**ខ. ការធ្វើការងារធម្មតា**

ចូរស្រមៃដល់ថ្ងៃធ្វើការងារធម្មតាក្នុងការងារក្នុងក្តីសុបិន្តរបស់អ្នក។ តើអ្នកទៅធ្វើការដោយរបៀបណា? តើអ្នកចាប់ផ្តើមធ្វើការនៅម៉ោងប៉ុន្មាន? តើអ្នកមានការប្រជុំច្រើនទេ? តើអ្វីដែលជាការងារធម្មតាអ្នកដោះស្រាយប្រចាំថ្ងៃ? តើអ្នកធ្វើការជាមួយនរណា? តើអ្នកបរិភោគអាហារថ្ងៃត្រង់នៅឯណា? តើអ្នកបញ្ចប់ការងារនៅពេលណា?ជាដើម។

**ថ្ងៃធ្វើការងារធម្មតារបស់ខ្ញុំ**



ខ្ញុំធ្វើការនៅ....ដែលមានទីតាំង....ខ្ញុំតែងតែជិះ....ទៅធ្វើការ។ ការងារខ្ញុំចាប់ផ្តើមនៅម៉ោង..............។ ខ្ញុំទទួលខុសត្រូវ..........ការងារដែលខ្ញុំធ្វើ.......។ ខ្ញុំមានមិត្តរួមការងារ..........................................................
..........................................................
..........................................................

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

### ៥.៣.៤ ដំណើរស្វែងរកការសិក្សាអប់រំ

នៅដំណាក់កាលនេះ ផ្អែកលើដំណើរស្វែងរក និងរបកគំហើញពីលើកមុនក្នុងអំឡុងពេលការប្រឹក្សាយោបល់ សិស្សអាចសង្ខេបនូវជម្រើសអាជីព ដែលគួរឲ្យចាប់អារម្មណ៍ ហើយបង្ហាញមុខរបរ ២ ទៅ ៣ ជាជម្រើសអាជីពដែលគេបានគ្រោងទុក។

គោលបំណងនៃលំហាត់នេះ គឺជួយឲ្យសិស្សប្រមូលនូវព័ត៌មានទាក់ទងនឹងការអប់រំ និងការបណ្តុះបណ្តាលដែលត្រូវការនៅក្នុងអាជីព ដែលបានគ្រោងទុកនាពេលអនាគត ហើយជួយគាំទ្រពួកគេ ដើម្បីរៀបចំផ្លូវសិក្សា។ ជារឿងសំខាន់ណាស់ក្នុងការលើកទឹកចិត្តសិស្សឲ្យប្រើប្រាស់ប្រភពព័ត៌មានផ្សេងៗ ដើម្បីប្រមូលព័ត៌មាន ។ ការអានកាតាឡុក ប្រើអ៊ីនធើណេត និងការជជែកជាមួយអ្នកប្រឹក្សាអាជីព ឪពុកម្តាយ និងមនុស្សពេញវ័យផ្សេងទៀត ជាវិធីសាស្ត្រល្អៗ សម្រាប់ការស្វែងរកព័ត៌មាន។ មធ្យោបាយមួយដើម្បីទទួលបានព័ត៌មានដ៏សកម្មនោះគឺ សម្ភាសនរណាម្នាក់ដែលកំពុងរៀន ឬកំពុងធ្វើការខាងវិស័យជាក់លាក់មួយ។ នៅពេលដែលសិស្សប្រមូលបានព័ត៌មានទាំងអស់សម្រាប់តារាងភ្លាម ពួកគេអាចមានគំនិតពាក់ព័ន្ធនឹងការអប់រំ និងជម្រើសអាជីពដែលបានគ្រោងទុក ហើយធ្វើការប្រៀបធៀបបាន។

ការបញ្ចប់លំហាត់នេះ ត្រូវការពេលវេលាច្រើន ដូចនេះវាអាចប្រើក្នុងថ្នាក់រៀនក៏បាន ឬប្រើវាកិច្ចការផ្ទះ។ គ្រូបង្គោលប្រឹក្សាអាជីព មានតួនាទីសំខាន់ក្នុងការណែនាំសិស្សឲ្យប្រើប្រាស់ប្រភពព័ត៌មានទៅតាមគោលដៅ ។

ផ្អែកលើដំណើរស្វែងរក និងរបកគំហើញរបស់អ្នកពីលើកមុន ចូរបង្ហាញពីមុខរបរ ២ ទៅ ៣ ដលអ្នកចាប់អារម្មណ៍បំផុត។ តើការអប់រំឬការបណ្តុះបណ្តាលបែបណា ដែលត្រូវការក្នុងអាជីពាំងនេះ? តើទិដ្ឋភាពសំខាន់ៗអ្វីដែលអ្នកគួរដឹងចំពោះការអប់រំ និងការបណ្តុះបណ្តាល? សំណួរនៅលីតារាង និងជួយអ្នកឲ្យស្វែងរកបាន។ ចូរស្វែងរកព័ត៌មានហើយបំពេញតារាងខាងក្រោម។ ចូរប្រើប្រាស់ប្រភពព័ត៌មានផ្សេងៗ ដូចជាកាតាឡុក អ៊ីនធើណេត និងជជែកជាមួយគ្រូបង្គោលប្រឹក្សារាជីព ឪពុកម្តាយ និងមនុស្សពេញវ័យផ្សេងទៀត។ អ្នកក៏អាចសម្ភាសន៍នរណាម្នាក់ដែលកំពុងបិក្សា ឬធ្វើការខាងវិស័យជាក់លាក់មួយបាន។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# បញ្ជីស្វែងរកការអប់រំរបស់ខ្ញុំ

| | អាជីព ក | អាជីព ខ | អាជីព គ |
|---|---|---|---|
| អាជីពដែលខ្ញុំចាប់អារម្មណ៍ | | | |
| ខ្ញុំចាប់អារម្មណ៍លើអាជីពនេះពីព្រោះ... | | | |
| តើការអប់រំឬការបណ្តុះ បណ្តាលបែបណាដែលគេត្រូវការក្នុងអាជីព/វិស័យនេះ? | | | |
| ក្នុងការអប់រំ ឬកម្មវិធីបណ្តុះបណ្តាលនេះអ្នកអាចជ្រើសរើសយកឯកទេសអ្វីខ្លះ? | | | |
| តើការងារប្រភេទណាដែលអ្នកអាចធ្វើបានពេលរៀនចប់? | | | |
| តើវិទ្យាស្ថានអប់រំណាដែលផ្តល់ការអប់រំ ឬការបណ្តុះបណ្តាលបែបនេះ? តើមួយណានៅជិតផ្ទះរបស់អ្នក? | | | |
| តើមានតម្រូវការអ្វីខ្លះសម្រាប់ការអប់រំ ឬបណ្តុះបណ្តាលបែបនេះ? | | | |
| តើត្រូវការរយៈពេលប៉ុន្មានសម្រាប់ការអប់រំ ឬកម្មវិធីបណ្តុះបណ្តាលនេះ? | | | |
| ចូរសរសេរការងារ និងមុខរបរដែលការអប់រំនេះនឹងផ្តល់ជូននូវជំនាញ និងចំណេះដឹង។ | | | |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ៥.៣.៥ ការស្វែងរកអាជីព

លំហាត់មួយឈុតនេះ នឹងជួយសិស្សស្វែងរកការងារផ្សេងៗ និងស្វែងយល់ការងារមួយចំនួនថា ជាជម្រើសអាជីពដែលបានគ្រោងទុក។ ឈុតនៃលំហាត់នេះមានសកម្មភាព និង/ឬសន្លឹកកិច្ចការដូចតទៅ៖

- ល្បែងផ្គុំការងារ
- បញ្ជីនៃការស្វែងរកអាជីព (និងលំហាត់ដែលពាក់ព័ន្ធ៖ ការងារប្រកបដោយអត្ថន័យ និងភាពរីករាយ ថ្ងៃធ្វើការធម្មតា ឆ្ពោះទៅកាន់អាជីព ២)
- ការសម្ភាសន៍ស្វែងរកព័ត៌មាន

លំហាត់ពីទី១ និងទី២ អាចយកទៅប្រើសម្រាប់ការប្រឹក្សាទល់មុខ និងការប្រឹក្សាក្នុងថ្នាក់ រៀន។ លំហាត់ទាំងពីរនេះអាចយកធ្វើជាកិច្ចការផ្ទះក៏ល្អដែរ ពេលនោះសិស្សមានពេលគ្រប់គ្រាន់ដើម្បីរកបានមកវិញនូវព័ត៌មាន។ ជាសំណូមពរ ការត្រៀមខ្លួនសម្រាប់បទសម្ភាសន៍ស្វែងរកព័ត៌មាន គឺ ធ្វើតាមការណែនាំរបស់អ្នកប្រឹក្សាយោបល់។ ដំបូងលំហាត់នេះហាក់បីដូចជាមានតម្រូវការច្រើនជាងភាពពិតរបស់វា។

លំហាត់ទាំងនេះមានដំណើរការទៅមុខប្រកបដោយភាពរីកចម្រើន និងអាចតម្រូវឲ្យរៀនចប់ មេរៀនប្រឹក្សាយោបល់ ២ ឬ ៣។ ជាជម្រើស យើងអាចធ្វើការជ្រើសយកលំហាត់ណាមួយដោយចៃដន្យទៅតាមតម្រូវការ និងសមត្ថភាពរបស់សិស្ស ដើម្បីបញ្ចប់លំហាត់នោះ។ បញ្ជីស្វែងរកអាជីព និងបទសម្ភាសន៍ស្វែងរកព័ត៌មាន គឺ ស័ក្តិសមសម្រាប់សិស្សកម្រិតមធ្យមសិក្សា ប៉ុន្តែអាចប្រើបានសម្រាប់កម្រិតបឋមសិក្សាផងដែរ ដោយមានការកែប្រែមួយចំនួន ឧទាហរណ៍តាមរយៈការកំណត់ចំនួនសំណួរសំខាន់ៗត្រឹមតែ ៣ ទៅ ៥ ។

បញ្ជីស្វែងរកអាជីព តម្រូវឲ្យសិស្សប្រើប្រភពព័ត៌មានផ្សេងៗ ដែលចំគោលដៅ។ សារៈសំខាន់នៃតួនាទីរបស់អ្នកប្រឹក្សាបល់ក្នុងការណែនាំសិស្សឆ្ពោះទៅរកប្រភពដែលត្រឹមត្រូវ មិនអាចមើលរំលងបានឡើយនៅទីនេះ។

**ចំណុចសំខាន់!** ជារឿងងាយស្រួល និងទាក់ទាញក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីវិស័យអាជីពដោយផ្អែកលើគំនិតរបស់អ្នកដទៃ និងអ្វីដែលយើងបានឃើញតាមការផ្សព្វផ្សាយ។ ចូរផ្តល់ដំបូន្មានដល់សិស្សថា ការសម្រេចចិត្តចម្បងដូចជា ជម្រើសអាជីព មិនគួរធ្វើដោយមនុស្សដែលមានបទពិសោធន៍តែម្នាក់នោះទេ។ លើសពីនេះ ជាការប្រសើរបើសិស្សមានជម្រើសអាជីពផ្សេង ទៀតដែលពាក់ព័ន្ធនឹងវិស័យនោះ ដូចជាផែនការបម្រុងទុកបន្ថែមលើអាជីពក្នុងក្តីសុបិន ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ប្រតិបត្តិ

### ក. ល្បែងផ្គុំការងារ

ចូរសរសេរជម្រើសអាជីពមួយចំនួនសម្រាប់ខ្លួនឯង ហើយបំពេញល្បែងផ្គុំការងារ ។ ចូរធ្វើតាមសេចក្តីណែនាំនៅទំព័របន្ទាប់ ។




១.តើការងារអ្វីខ្លះដែលសមាជិកនៃក្រុមគ្រួសារ ឬមនុស្សផ្សេងៗទៀតមាន? ចូរសរសេរការងារទាំងនេះនៅលើបំណែក A ។

២.ចូរគិតអំពីកន្លែងការងារនៅស្រុកកំណើត ឬភូមិរបស់អ្នក។ តើការងារប្រភេទណាខ្លះមាននៅទីនោះ ? ចូរសរសេរការងារទាំងនេះនៅលើបំណែក B ។

៣.តើអ្នកមានចំណាប់អារម្មណ៍លើការងារដែលអ្នកបានសរសេរនៅក្នុងបំណែក A និង B ដែរទេ ? ចូរគូសរង្វង់ជុំវិញការងារទាំងនោះ ។

៤.តើការងារក្នុងក្តីសុបិនរបស់អ្នកមានអ្វីខ្លះ ? ចូរសរសេរការងារនោះនៅលើបំណែក C។

៥.ជារឿងសំខាន់ក្នុងការមានជម្រើសផ្សេងជាផែនការបម្រុងទុក។ ចូរបង្ហាញការងារមួយចំនួនដែលពាក់ព័ន្ធនឹងការងារក្នុងក្តីសុបិនរបស់អ្នក ហើយសរសេរការងារនោះនៅលើបំណែក D។ បន្ទាប់មក ចូរគិតដោយប្រុងប្រយ័ត្នហើយ ជ្រើសយកការងារពីរដែលអ្នកចាប់អារម្មណ៍បំផុត រួចគូសរង្វង់ជុំវិញវា។

facebook.com/moeyscambodia moeys.gov.kh YouTube youtube.com/moeyscambodia

៦.ផ្ទេរការងារក្នុងក្តីសុបិនរបស់អ្នកពីបំណែក C និងការងារដែលគួរឲ្យចាប់អារម្មណ៍ទាំងអស់ដែលអ្នកបានគូសរង្វង់ជុំវិញលើបំណែក A B និង D ទៅដាក់លើសន្លឹកផ្គុំការងារខាងក្រោម។ ចូរគិតម្តងទៀតដោយប្រុងប្រយ័ត្ន ហើយសង្ខេបនូវជម្រើសនៃការងារដែលគួរឲ្យចាប់អារម្មណ៍បំផុតរបស់អ្នកឲ្យនៅសល់ត្រឹមតែពីរ ឬ បី ហើយគូសរង្វង់វា។ តើអាជីពទាំងនេះស័ក្តិសមនឹងអ្នកដែរទេ?

## ប្រតិបត្តិ



### ខ. បញ្ជីនៃការស្វែងរកអាជីពរបស់ខ្ញុំ

ការស្វែងរកអាជីព គឺប្រៀបដូចជាការដើររកទិញខោអាវថ្មីអញ្ចឹង! អ្នកជ្រើសយកខោអាវពីរ ឬបីដើម្បីសាកល្បងមើលថាតើវាសមនឹងអ្នកប៉ុនណា? អ្នកមានអារម្មណ៍ដូចម្តេច? ហើយវាល្មមនឹងអ្នកដែរឬទេ? លំហាត់នេះនឹងជួយអ្នកឲ្យមើលឃើញថាការងារមានលក្ខណៈយ៉ាងដូចម្តេច ធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ហើយសាកសមនឹងអ្នកយ៉ាងដូចម្តេច។

ចូរបង្ហាញការងារដែលអ្នកនឹងស្វែងរកចំនួន ២ ទៅ ៣។ ឧទាហរណ៍ អ្នកអាចជ្រើសរើសយកការងារដែលគួរឲ្យចាប់អារម្មណ៍បំផុតពីបំណែកនៃល្បែងផ្គុំពាក្យនៅក្នុងលំហាត់មុនៗ (ល្បែងផ្គុំការងារ)។

ចូរបំពេញបញ្ជីស្វែងរកការងារ ចូរប្រើប្រភពឲ្យបានច្រើនដើម្បីរកចម្លើយចំពោះសំណួរដោយការពិនិត្យឡើងវិញនូវការពិពណ៌នាអំពីការងារ កាតាឡុក សៀវភៅ វិបសាយ និងតាមរយៈការជជែកជាមួយមនុស្សដែលធ្វើការក្នុងវិស័យនោះដែរ។

នៅពេលដែលអ្នកមានព័ត៌មានទាំងអស់នៅលើតារាង អ្នកអាចសង្ខេបព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងជម្រើសអាជីព ដែលបានគ្រោងទុករបស់អ្នកបានយ៉ាងប្រសើរ។ បញ្ជីនៃការស្វែងរកការងារគឺជាតារាងសង្ខេបនូវលក្ខណៈការងារផ្សេងៗ ដើម្បីឲ្យអ្នកអាចវាយតម្លៃថាការងារមួយណាស័ក្តិសមបំផុតសម្រាប់អ្នក។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# បញ្ជីនៃការស្វែងរកអាជីពរបស់ខ្ញុំ

| | អាជីព ក | អាជីព ខ | អាជីព គ |
|---|---|---|---|
| អាជីពដែលខ្ញុំចាប់អារម្មណ៍ | | | |
| ហេតុអ្វីបានជាអ្នកយល់ឃើញថាការងារនេះគួរឲ្យចាប់អារម្មណ៍? | | | |
| នៅមាតុភូមិ ឬភូមិរបស់អ្នក តើកន្លែងការងារណាមាននៅក្នុងវិស័យនេះ? | | | |
| តើត្រូវការជំនាញបែបណាខ្លះដែលត្រូវនឹងការងារនេះ? | | | |
| តើមុខវិជ្ជាអ្វីខ្លះដែលអ្នកគួរសិក្សាបើសិនជាអ្នកស្វែងរកការងារក្នុងវិស័យបែបនេះ? | | | |
| តើប្រភេទនៃការអប់រំ ឬបណ្តុះបណ្តាលបែបណាដែលត្រូវនឹងការងារនេះ | | | |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | | |
|---|---|---|---|
| តើប្រភេទនៃកិច្ចការបែបណាដែលត្រូវធ្វើចំពោះការងារនេះ? | | | |
| តើមានតម្រូវការពិសេសអ្វីខ្លះសម្រាប់ការងារនេះ (ឧទា. តម្រូវការផ្នែកសុខភាព) ដែលគួរយកមកពិចារណា | | | |
| តើចំណុចល្អនៃការងារនេះមានអ្វីខ្លះ? | | | |
| តើអ្នកអាចមើលឃើញពីទិដ្ឋភាពអវិជ្ជមាននៃការងារនេះទេ? | | | |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## សំណួរ និងសកម្មភាពបន្ថែម

១.តើការងារណាមួយនៅក្នុងបញ្ជីស្វែងរកការងារ ធ្វើឲ្យអ្នកចាប់អារម្មណ៍បំផុត? ហេតុអ្វី?

________________________________________

________________________________________

២.តើអនាគតយ៉ាងដូចម្តេចនៅក្នុងវិស័យនោះ? តើអាចរកការងារបានដែរឬទេ?

________________________________________

________________________________________

៣.ឥឡូវនេះដោយសារអ្នកបានស្វែងយល់ច្រើនពីការងារជាក់លាក់មួយហើយ ចូរសួរខ្លួនឯងនូវសំណួរបន្ទាប់៖ តើអ្នកអាចមើលឃើញខ្លួនឯងថាជា____________________ទេ?

(មុខតំណែង)

៤.ចូរសាកល្បងប្រមើលមើលខ្លួនឯងចំពោះការងារនេះ ដោយស្រមៃថាខ្លួនឯងក្រោកទៅធ្វើការងារឬមុខរបរនេះ។ ចូរស្រមៃថាអ្នកទៅធ្វើការងារនេះរាល់ថ្ងៃ។ តើមានអារម្មណ៍យ៉ាងដូចម្តេចដែរ? (អ្នកក៏អាចបញ្ចប់លំហាត់នៅដំណាក់កាលនេះបានដែរ៖ ការងារដែលប្រកបដោយអត្ថន័យ និងភាពរីករាយនិងថ្ងៃធ្វើការធម្មតា)។

________________________________________

________________________________________

បើសិនជាអ្នកមើលឃើញខ្លួនឯងថាកំពុងប្រកបមុខរបរនេះ វាអាចមានប្រយោជន៍សម្រាប់ រកក្នុងការស្វែងរកមុខរបរពាក់ព័ន្ធផងដែរ។ អ្នកមិនដែលដឹងថាអ្នកនឹងជួបប្រទះអ្វីឡើយ!

## ប្រតិបត្តិ



### គ. ការសម្ភាសន៍ស្វែងរកព័ត៌មាន

តើអ្នកចង់បានព័ត៌មានបន្ថែមពាក់ព័ន្ធនឹងអាជីពអ្វី?

ជាញឹកញាប់ព័ត៌មានថ្មីៗហើយពាក់ព័ន្ធនឹងអាជីព មិនមាននៅតាមអនឡាញ ឬតាមសៀវភៅ ទ។ ព័ត៌មានដ៏ល្អបំផុត គឺបានមកពីមនុស្ស ដែលធ្វើការក្នុងវិស័យនោះពិតប្រាកដ។

បទសម្ភាសន៍ស្វែងរកព័ត៌មានការងារ គឺជាការពិភាក្សាក្រៅផ្លូវការជាមួយនរណាម្នាក់ដែល ធ្វីការខាងវិស័យដែលអ្នកចាប់អារម្មណ៍។ វាជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការស្វែងរកអាជីព ក្រៅពីការអានសៀវភៅ ការប្រើអ៊ិនធើណិត និងការអានពិពណ៌នាអំពីការងារ។ អ្នកអាចមាន រម្មណ៍ខ្មាសអៀនចំពោះការរៀបចំខ្លួន ដើម្បីជជែកជាមួយមនុស្ស ដែលអ្នកមិនស្គាល់ពាក់ព័ន្ធនឹង ារងាររបស់គេ។ ទោះយ៉ាងណា មនុស្សភាគច្រើនពិតជាមានការពេញចិត្តនឹងចំណាយពេលពីរបី នាទីក្រោយពេលការងាររបស់គេ ដើម្បីផ្តល់ដំបូន្មានទៅឲ្យនរណាម្នាក់ ដែលមានចំណាប់អារម្មណ៍ ឹងវិស័យរបស់គេ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

តើរកមនុស្សដើម្បីសម្ភាសន៍ដោយរបៀបណា? សួរគ្រួសារ មិត្តភ័ក្តិ អ្នកជិតខាង គ្រូបង្រៀន គ្រូប្រឹក្សាយោបល់។ មនុស្សដែលអ្នកស្គាល់ស្រាប់ ទោះជាគេមិនស្ថិតក្នុងវិស័យដែលអ្នកចាប់អារម្មណ៍ក៏ដោយ ក៏គេអាចនាំអ្នកទៅជួបមនុស្សដែលធ្វើការក្នុងវិស័យនោះបានដែរ។

តើសំណួរបែបណាដែលគួរសួរ? អ្នកអាចសួរពីប្រធានបទដូចជា ថ្ងៃធ្វើការធម្មតា ការអប់រំ ឬការបណ្តុះបណ្តាលបែបណាដែលត្រូវការចាំបាច់សម្រាប់វិស័យនោះ។ អ្នកក៏អាចស្នើឲ្យអ្នកដែលត្រូវសម្ភាសន៍ប្រាប់នូវរឿងរ៉ាវផ្ទាល់ខ្លួនអំពីការជ្រើសរើសអាជីពបានដែរ។

ចូរប្រើសំណួរដូចតទៅ ឬបង្កើតសំណួរដោយខ្លួនឯង។ ចំណុចសំខាន់ គឺ អ្នកជ្រើសរើសយកសំណួរណាដែលជួយអ្នកក្នុងជម្រើសអាជីព។

សំណួរសម្រាប់សួរក្នុងបទសម្ភាសន៍ស្វែងរកព័ត៌មានអំពីអាជីព៖

១. តើអ្នកមានចំណាប់អារម្មណ៍លើវិស័យនេះដោយរបៀបណា?

២. តើអ្នកធ្វើការនៅទីនេះអស់រយៈពេលប៉ុន្មានហើយ?

៣. តើថ្ងៃធ្វើការធម្មតារបស់អ្នកដូចម្តេចដែរ?

៤. តើអ្នកធ្វើកិច្ចការអ្វីខ្លះ?

៥. តើអ្នកចូលចិត្តអ្វីបំផុតចំពោះការងាររបស់អ្នក?

៦. តើអ្វីដែលអ្នកមិនចូលចិត្តចំពោះការងារ?

៧. តើការអប់រំ ឬការបណ្តុះបណ្តាលបែបណាដែលត្រូវការចាំបាច់សម្រាប់ការងារអ្នក?

៨. តើជំនាញ និងចំណេះដឹងបែបណាដែលសំខាន់សម្រាប់ការងាររបស់អ្នក?

៩. តើមានតម្រូវការអ្វីទេចំពោះអាជីពហ្នឹង (សុខភាព ។ល។)?

១០. តើប្រាក់ខែដំបូងប៉ុន្មានសម្រាប់វិស័យនេះ?

១១. តើអ្នកយល់ឃើញយ៉ាងណាដែរចំពោះអនាគតនៃវិស័យនេះ?

១២. តើអ្នកមានដំបូន្មានអ្វីខ្លះសម្រាប់ផ្តល់ឲ្យអ្នកដែលកំពុងពិចារណាការងារបែបនេះ?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## បទសម្ភាសន៍ស្វែងរកព័ត៌មាន

ឈ្មោះអ្នកដែលត្រូវសម្ភាសន៍ ______________________________

កន្លែងការងារ/ ក្រុមហ៊ុន ______________________________

ការងារបច្ចុប្បន្ន ______________________________

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................



facebook.com/moeyscambodia YouTube youtube.com/moeyscambodia

moeys.gov.kh

### ៥.៣.៦ តេស្តហូឡែនខូដ ( RIASEC test )

គំនិតចម្បងផ្នែកមុខរបរហូឡែន គឺជាទ្រឹស្តីដែលបង្កើតឡើងដោយលោក ចន ហូឡែន។ ចន ហូឡែន និយាយថា ជម្រើសនៃអាជីព គឺជាការបញ្ជាក់ពីចរិយាសម្បត្តិ។ លើសពីនេះ ការជ្រើសយកអាជីព មុខជំនាញ ឬកម្មវិធីបណ្តុះបណ្តាល ឲ្យត្រូវនឹងចរិយាសម្បត្តិ គឺនាំមកនូវការពេញចិត្ត និងភាពជោគជ័យក្នុងការងារ។

យោងតាមលោកហូឡែន មនុស្សត្រូវបានបែងចែក ដោយផ្អែកលើមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់ជីវិតរបស់គេ ទៅជាប្រាំមួយក្រុមដោយមានទម្រង់នៃបុគ្គលិកលក្ខណៈ ឬចំណាប់អារម្មណ៍ផ្សេងៗគ្នាដូចជា៖ អ្នកប្រាកដនិយម អ្នកពូកែអង្កេត អ្នកសិល្បៈនិយម អ្នកខាងសង្គម អ្នកខាង សណ្តាប់ធ្នាប់ និងអ្នកខាងត្រិះរិះពិចារណា។ ប្រភេទទាំងប្រាំមួយនាំឲ្យមានអក្សរកាត់ថា RIASEC។

ការយកចិត្តទុកដាក់ចំពោះប្រភេទនៃបុគ្គលិកលក្ខណៈដ៏ខ្លាំងរបស់អ្នក គឺជារឿងសំខាន់។ ទោះជាយ៉ាងណាក៏ដោយ លក្ខណៈអាជីព មិនអាចរៀបរាប់ឲ្យស៊ីជម្រៅដោយផ្អែកលើក្រុមតែមួយបានទេ។ យោងតាមលោក ហូ ឡែន យើងទាំងអស់គ្នាមានចំណាប់អារម្មណ៍មួយចំនួន ប្រហាក់ប្រហែលគ្នានឹងប្រភេទពីរឬបីក្នុងចំណោមប្រភេទទាំងប្រាំមួយ (R, I, A, S, E or C) ប៉ុន្តែយើងចាប់អារម្មណ៍ជាចំបងតែលើបីប្រភេទនៃវិស័យទាំងនោះដែលកើតចេញពីបន្សំនៃចម្លាស់អក្សរទាំង៦តួខាងលើ។ អក្សរទាំងបីនោះគឺជាលេខកូដហូឡែន ឬលេខកូដចំណាប់អារម្មណ៍។ លេខកូដចំណាប់អារម្មណ៍អាចមានលើសពី១៥០ (ឧទា. RES, IAS ។ល។)

តេស្តលេខកូដ ហូ ឡែន ជាម៉ូដែលកំពុងពេញនិយមសម្រាប់ប្រើធ្វើតេស្តស្តីពីអាជីពនាពេលបច្ចុប្បន្ន។ ទោះជាតេស្តមិនតម្រូវឲ្យមានចម្លើយពិតប្រាកដក៏ដោយ ក៏វាមិនមានន័យថាតេស្តសមត្ថភាពនេះ មិនគួរឲ្យទុកចិត្តបាននោះទេ។ ទោះជាយ៉ាងណាក៏ដោយ អ្នកគួរចាំទុកក្នុងចិត្តថាលទ្ធផលនៃតេស្តនេះគ្រាន់តែនាំអ្នកឲ្យស្គាល់ពីរបៀបជ្រើសផ្លូវអាជីពប៉ុណ្ណោះទេ។

**ប្រតិបត្តិ** 

### ក. ការធ្វើតេស្តលេខកូដហូឡែន

តេស្តនេះរៀបចំឡើងដើម្បីជួយអ្នកផ្គូរផ្គងចំណាប់អារម្មណ៍របស់អ្នក ជាមួយជំនាញដែលមានអាជីពស្រដៀងគ្នា។ វាអាចជួយអ្នកឲ្យចាប់ផ្តើមគិតអំពីបុគ្គលិកលក្ខណៈរបស់អ្នក ដែលសមស្របទៅនឹងបរិស្ថានការងារ និងអាជីព។

ខាងក្រោមនេះមានប្រយោគចំនួន៤២។ ចូរអានប្រយោគនីមួយៗដោយប្រុងប្រយ័ត្ន។ បើអ្នកយល់ព្រម ចូរគូស (✓) នៅក្នុងប្រអប់នៅក្បែរនោះ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | ខ្ញុំចូលចិត្តធ្វើការលើឡាន | ☐ | | | | | |
| ២ | ខ្ញុំចូលចិត្តល្បែងតម្រៀប ឬផ្គុំ | | ☐ | | | | |
| ៣ | ខ្ញុំពូកែធ្វើការឯករាជ្យ | | | ☐ | | | |
| ៤ | ខ្ញុំចូលចិត្តការងារជាក្រុម | | | | ☐ | | |
| ៥ | ខ្ញុំជាមនុស្សមានមហិច្ឆតា ខ្ញុំរៀបចំគោលដៅសម្រាប់ខ្លួនឯង | | | | | ☐ | |
| ៦ | ខ្ញុំចូលចិត្តរៀបចំទុកដាក់ (សំណុំឯកសារ តុការិយាល័យ) | | | | | | ☐ |
| ៧ | ខ្ញុំចូលចិត្តសាងសង់ | ☐ | | | | | |
| ៨ | ខ្ញុំចូលចិត្តអានអំពីសិល្បៈ និងតន្ត្រី | | | ☐ | | | |
| ៩ | ខ្ញុំចូលចិត្តការណែនាំច្បាស់លាស់ដើម្បីធ្វើតាម | | | | | | ☐ |
| ១០ | ខ្ញុំចូលចិត្តប្រើឥទ្ធិពល ឬបញ្ចុះបញ្ចូលមនុស្ស | | | | | ☐ | |
| ១១ | ខ្ញុំចូលចិត្តពិសោធន៍ | | ☐ | | | | |
| ១២ | ខ្ញុំចូលចិត្តបង្រៀន ឬបណ្ដុះបណ្ដាលមនុស្ស | | | ☐ | | | |
| ១៣ | ខ្ញុំចូលចិត្តជួយដោះស្រាយបញ្ហាឲ្យគេ | | | ☐ | | | |
| ១៤ | ខ្ញុំចូលចិត្តថែរក្សាសុខភាពសត្វ | ☐ | | | | | |
| ១៥ | ខ្ញុំមិនជំទាស់នឹងធ្វើការក្នុងការិយាល័យ៨ម៉ោងក្នុងមួយថ្ងៃទេ | | | | | | ☐ |
| ១៦ | ខ្ញុំចូលចិត្តលក់ | | | | | ☐ | |
| ១៧ | ខ្ញុំចូលចិត្តការនិពន្ធបែបច្នៃប្រឌិត | | | ☐ | | | |
| ១៨ | ខ្ញុំចូលចិត្តវិទ្យាសាស្ត្រ | | ☐ | | | | |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៩ | ខ្ញុំឆាប់ចាប់បាននូវទំនួលខុសត្រូវថ្មី | | | | | ☐ | |
| ២០ | ខ្ញុំចាប់អារម្មណ៍លើការព្យាបាលមនុស្សឲ្យជាសះស្បើយ | | | | ☐ | | |
| ២១ | ខ្ញុំចូលចិត្តស្វែងយល់ពីដំណើរការនៃការងារ | | ☐ | | | | |
| | សរុបទី១ | R | I | A | S | E | C |
| ២២ | ខ្ញុំចូលចិត្តដាក់របស់នៅជុំគ្នា ឬប្រមូលរបស់ទុក | ☐ | | | | | |
| ២៣ | ខ្ញុំជាមនុស្សដែលមានការច្នៃប្រឌិត | | | ☐ | | | |
| ២៤ | ខ្ញុំយកចិត្តទុកដាក់នឹងភាពល្អិតល្អន់ | | | | | | ☐ |
| ២៥ | ខ្ញុំចូលចិត្តរៀបចំឯកសារ ឬវាយឯកសារ | | | | | | ☐ |
| ២៦ | ខ្ញុំចូលចិត្តវិភាគ (បញ្ហា/ស្ថានភាព) | | ☐ | | | | |
| ២៧ | ខ្ញុំចូលចិត្តលេងភ្លេង ឬច្រៀង | | | ☐ | | | |
| ២៨ | ខ្ញុំចូលចិត្តរៀនអំពីវប្បធម៌ផ្សេងៗ | | | | ☐ | | |
| ២៩ | ខ្ញុំចង់ចាប់ផ្តើមជំនួញរបស់ខ្ញុំ | | | | | ☐ | |
| ៣០ | ខ្ញុំចូលចិត្តធ្វើម្ហូប | ☐ | | | | | |
| ៣១ | ខ្ញុំចូលចិត្តសំដែង | | | ☐ | | | |
| ៣២ | ខ្ញុំជាមនុស្សប្រសប់ការងារ | ☐ | | | | | |
| ៣៣ | ខ្ញុំចូលចិត្តធ្វើការជាមួយលេខ ឬតារាង | | ☐ | | | | |
| ៣៤ | ខ្ញុំចូលចិត្តពិភាក្សាអំពីបញ្ហា | | | | ☐ | | |
| ៣៥ | ខ្ញុំពូកែខាងរក្សាកំណត់ហេតុការងារ | | | | | | ☐ |

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣៦ | ខ្ញុំចូលចិត្តដឹកនាំ | | | | | ☐ | |
| ៣៧ | ខ្ញុំចូលចិត្តការងារក្រៅការិយាល័យ | ☐ | | | | | |
| ៣៨ | ខ្ញុំចូលចិត្តធ្វើការក្នុងការិយាល័យ | | | | | | ☐ |
| ៣៩ | ខ្ញុំពូកែគណិតវិទ្យា | | ☐ | | | | |
| ៤០ | ខ្ញុំចូលចិត្តជួយមនុស្ស | | | | ☐ | | |
| ៤១ | ខ្ញុំចូលចិត្តគូររូប | | | ☐ | | | |
| ៤២ | ខ្ញុំចូលចិត្តថ្លែងសុន្ទរកថា | | | | | ☐ | |
| | សរុបទី២ | R | I | A | S | E | C |
| | **ពិន្ទុសរុបរួម** (សរុបទី១ + សរុបទី២) | | | | | | |
| | | R | I | A | S | E | C |

## ខ. លទ្ធផលនៃតេស្ត RIASEC

តេស្តនេះ គឺផ្អែកលើទ្រឹស្តីរបស់បណ្ឌិតហូឡែន ដែលចែងថាមនុស្ស និងបរិស្ថានការងារអាចបងចែកជាប្រាំមួយក្រុមផ្សេងៗគ្នា។ បុគ្គលិកលក្ខណៈរបស់មនុស្សអាចទាក់ទងនឹងបរិស្ថានការងារច្រើនជាងនេះ។

### ខ.១. ចូរផ្ទេរពិន្ទុសរុបទាំងអស់របស់អ្នកចូលក្នុងតូឡេនខាងក្រោមឲ្យបានត្រឹមត្រូវ

| | ប្រភេទបុគ្គលិកលក្ខណៈ (Personality Type) | ពិន្ទុសរុបទាំងអស់ (Grand Total Scores) |
|---|---|---|
| R | អ្នកប្រាកដនិយម (Realistic) | |
| I | អ្នកពូកែស៊ើបអង្កេត (Investigative) | |
| A | អ្នកសិល្បៈនិយម (Artistic) | |
| S | អ្នកខាងសង្គម (Social) | |
| E | អ្នកត្រិះរិះពិចារណា (Enterprising) | |
| C | អ្នកខាងសណ្តាប់ធ្នាប់ (Conventional) | |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

ប្រភេទនៃបុគ្គលិកលក្ខណៈរបស់ខ្ញុំ គឺ_______________________

(ប្រភេទនៃបុគ្គលិកលក្ខណៈដែលមានពិន្ទុសរុបខ្ពស់)

តើប្រភេទនៃបុគ្គលិកលក្ខណៈដែលមានពិន្ទុរៀបរាប់បានល្អពីអ្នកដែរទេ?

______________________________________________________________

______________________________________________________________

✱✱✱ ចូរអានការពិពណ៌នាអំពីប្រភេទបុគ្គលិកលក្ខណៈ (មើលទំព័រចុងក្រោយ)។

**ខ. ២. លេខកូដហូឡែនរបស់ខ្ញុំ** ________ ______ ______

អក្សរបីដែលមានពិន្ទុខ្ពស់បានពីលេខកូដហូឡែន ជាលេខកូដចំណាប់អារម្មណ៍របស់អ្នក។ អ្នកអាចមានចំណាប់អាម្មណ៍មួយចំនួនប្រហាក់ប្រហែលគ្នានឹងប្រភេទពីរឬបី ក្នុងចំណោម ប្រភេទទាំងប្រាំមួយក្រុម ប៉ុន្តែអ្នកអាចមានចំណាប់អារម្មណ៍ខ្លាំងតែលើបីប្រភេទនៃវិស័យនោះប៉ុណ្ណោះ។ អក្សរទាំងបីនោះគឺជាលេខកូដហូឡែន (Holand Code) របស់អ្នក។

➢ តើលេខកូដហូឡែនរបស់អ្នកដូចគ្នានឹងក្តីរំពឹងរបស់អ្នកឬទេ?

______________________________________________________________

______________________________________________________________

➢ យោងតាមលទ្ធផលតេស្ត តើវិស័យអាជីពការងារ និងកិច្ចការអ្វីខ្លះដែលស័ក្តិសមនឹងអ្នក?

______________________________________________________________

______________________________________________________________

➢ តើអ្នកចាប់អារម្មណ៍លើវិស័យទាំងនោះដែរឬទេ? ចូរជ្រើសយកវិស័យបីដែលអ្នកចាប់អារម្មណ៍បំផុត?

**គ. ការពិពណ៌នាប្រភេទនៃបុគ្គលិកលក្ខណៈរបស់ ហូ ឡែន**

| ប្រភេនៃបុគ្គលិកលក្ខណៈ | ការពិពណ៌នាទូទៅ | វិស័យនៃអាជីព |
|---|---|---|
| **អ្នកប្រាកដនិយម**<br>R | មនុស្សប្រាកដនិយម ប្រសប់នឹងការងារ ហ្មឹងធឹង ធម្មតា មានការតស៊ូ ដាក់ខ្លួន ស្ងៀមស្ងាត់ ចិត្តទូលាយ និងអៀនខ្មាស។ ពួកគេមានសមត្ថភាពខាងអត្តពលកម្ម និងខាងយានយន្ត។ គេចូលចិត្តធ្វើការជាមួយ ម៉ាស៊ីន ឧបករណ៍ រោងចក្រ សត្វ ឬក្រៅការិយាល័យ។ ពួកគេមិនចូលចិត្តការងារក្រដាសស្នាម និងអាចមានអារម្មណ៍មិនស្រួលក្នុងមជ្ឈដ្ឋានសង្គម។ | កសិកម្ម<br>សេវាសុខភាព<br>បច្ចេកវិទ្យាព័ត៌មាន<br>ការសាងសង់<br>គ្រឿងយន្ត វិស្វកម្ម<br>អាហារ និង<br>បដិសណ្ឋារកិច្ច |
| | | ជីវវិទ្យា |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| **អ្នកពូកែអង្កេត**<br>I | អ្នកអង្កេត ជាប្រភេទមនុស្សចេះវិភាគ ឆ្លាតខាងវិទ្យាសាស្រ្ត ខាងរុករក ទិតៀន ចង់ចេះចង់ដឹង ឯករាជ្យ ឆ្អើង និងគោរពពេលវេលា។ គេចូលចិត្តសង្កេត វិភាគវាយតម្លៃ ឬដោះស្រាយបញ្ហា។ ពួកគេផ្តោតលើ លទ្ធផលការងារ និងចូលចិត្តកិច្ចការផ្សេងៗគ្នា។ ពួកគេចូលចិត្តធ្វើការឯករាជ្យ ហើយមិនចូលចិត្តសកម្មភាពដដែលៗទេ។ ពួកគេអាចខ្វះជំនាញដឹកនាំ។ | វិស្វកម្ម<br>គីមី<br>ឱសថ/សល្យសាស្រ្ត<br>សេដ្ឋកិច្ច<br>អតិថិជន<br>ចិត្តវិទ្យា |
| **អ្នកសិល្បៈនិយម**<br>A | មនុស្សសិល្បៈ មានគំនិតច្នៃប្រឌិត ចិត្តទូលាយ បង្កើតថ្មី រក្សាភាពដើម឵ ឆាប់ដឹង ឆាប់យល់អារម្មណ៍ ឯករាជ្យ ហើយឆាប់រំជួលចិត្ត។ គេមិនចូលចិត្តរចនាសម្ព័ន្ធ ក្បួនច្បាប់ទេ ពោលគឺ អ្នកសិល្បៈធ្វើការក្នុងបរិស្ថានប្រកបដោយសេរីភាព ដោយប្រើក្តីស្រមៃរបស់គេ។ ពួកគេសុខចិត្តប្រថុយប្រថាន ដើម្បីសាកល្បងអ្វីដែលថ្មី ប៉ុន្តែមិនសូវចូលចិត្តយកចិត្តទុកដាក់លើភាពល្អិតល្អន់ទេ។ | ការទំនាក់ទំនង<br>លោហធាតុវិទ្យា<br>វិចិត្រសិល្បៈ និងការសំដែង ការថតរូប<br>វិទ្យុ និងទូរទស្សន៍<br>ការតុបតែងផ្ទះ<br>ស្ថាបត្យកម្ម<br>សិល្បៈ និង<br>ការទាក់ទង |
| **អ្នកខាងសង្គម**<br>S | មនុស្សខាងសង្គម មានភាពរួសរាយ ចិត្តល្អ ពូកែយល់ ចេះជួយសហការ គាំទ្រ រាក់ទាក់ និងមានទំនួលខុសត្រូវ ។ ពួកគេចូលចិត្តធ្វើការជាមួយមនុស្ស ហើយមានការបារម្ភពីសុខមាលភាពអ្នកដទៃ។ ពួកគេមានជំនាញថ្វីមាត់ និងទំនាក់ទំនងល្អ។ មនុស្សខាងសង្គមមិនចូលចិត្តធ្វើការងារជាមួយម៉ាស៊ីន ឬស្ថានភាពដែលមានរចនាសម្ព័ន្ធទំនើបពេកទេ។ | ការប្រឹក្សាយោបល់<br>ការព្យាបាល<br>ការព្យាបាលផ្លូវចិត្ត<br>ការធ្វើដំណើរ<br>ការផ្សព្វផ្សាយ<br>ទំនាក់ទំនងអន្តរជាតិ<br>ការអប់រំ សេវាសុខភាព សេវាកម្មធនធានមនុស្ស និងសេវាសាធារណៈ |
| **អ្នកខាងសណ្តាប់ធ្នាប់**<br>E | មនុស្សខាងសហគ្រាស គឺមានមហិច្ឆតាខ្ពស់ ប្រកួតជែង មានកម្លាំងចិត្ត ប្រកបដោយសុទិដ្ឋិនិយម រួសរាយ មានទំនុកចិត្តលើខ្លួនឯង និងក្លាហាន។ ពួកគេក៏ឲ្យតម្លៃលើ | សុរិយោដី<br>ទីផ្សារ/ផ្នែកលក់ |

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

| | | |
|---|---|---|
| | កិត្តយស អំណាច លុយ និងឋានៈ។ គេចូលចិត្តធ្វើការជាមួយអ្នកដទៃ ហើយចូលចិត្តធ្វើអ្វីធ្វើឲ្យកើត។ ពួកគេជាអ្នកដឹកនាំដ៏ខ្លាំងប្រកបដោយជំនាញថ្វីមាត់ និងមានឆន្ទៈមោះមុតដើម្បីសម្រេចគោលដៅរបស់អង្គភាព ឬភាពចំណេញផ្នែកសេដ្ឋកិច្ច។ ពួកគេមិនចូលចិត្តវិទ្យាសាស្រ្ត និងការគិតជាប្រព័ន្ធឡើយ។ | ច្បាប់ វិទ្យាសាស្រ្តនយោបាយ<br>ពាណិជ្ជកម្មអន្តរជាតិ<br>ជំនួញផ្នែកហិរញ្ញវត្ថុ/ធនាគារ |
| **អ្នកខាងត្រិះរិះ**<br>**C** | អ្នកខាងត្រិះរិះ ជាមនុស្សផ្តោតលើភាពល្អិតល្អន់ មានសណ្តាប់ធ្នាប់ មានមនសិការ មានប្រសិទ្ធផល ប្រសប់នឹងការងារ ស្ងប់ស្ងាត់ មានទំនួលខុសត្រូវ អភិរក្ស និងផ្ញើង។ ពួកគេចូលចិត្តបរិស្ថានរៀបរយ ហើយធ្វើតាមនីតិវិធី និងទម្លាប់ដែលបានរៀបចំទុក។ គេជាមនុស្សមានប្រសិទ្ធភាព ចំពោះកិច្ចការដែលមានភាពច្បាស់លាស់។ ពួកគេចូលចិត្តការងារខាងទិន្នន័យ និងការងារលំអិតជាជាងការប្រើគំនិត។ ពួកគេជៀសវាងស្ថានភាព ឬបញ្ហាមិនច្បាស់លាស់។ | គណនេយ្យ<br>របាយការណ៍<br>តុលាការ<br>ការធានារ៉ាប់រង<br>រដ្ឋបាល<br>កំណត់ត្រាឱសថ<br>ធនាគារ<br>ការគ្រប់គ្រងទិន្នន័យ |

### ៥.៣.៧ ផែនការបន្ទាប់ពីការសិក្សានាពេលបច្ចុប្បន្នរបស់ខ្ញុំ

ក្នុងអំឡុងពេលសិក្សាឆ្នាំចុងក្រោយ សិស្សគួរតែទទួលបានរូបភាពច្បាស់លាស់អំពីការអប់រំ និងផែនការអាជីពរបស់គេ។ គោលបំណងនៃលំហាត់នេះ គឺជួយបណ្តុះគំនិតសិស្សអំពីផែនការទាំងអស់នោះ ធ្វើឲ្យផែនការស្តែងជាលទ្ធផល ចង្អុលបង្ហាញនូវជំហានបន្ទាប់ដែលត្រូវការដើម្បីឈានទៅរកការអប់រំ និងផ្លូវអាជីពបន្ទាប់ពីរៀនចប់។ គោលបំណងនេះ គឺរៀបរាប់ក្រៅផ្លូវការនូវផែនការបែបណាដែលសិស្សមាន បន្ទាប់ពីរៀនចប់។ ពួកគេមានផែនការច្បាស់លាស់សម្រាប់ការអប់រំនាពេលអនាគតរបស់គេ ***ផែនការសិក្សារបស់ខ្ញុំ*** នឹងជួយឲ្យពួកគេស្វែងរកព័ត៌មានពាក់ព័ន្ធនឹងដំណើរការដាក់ពាក្យ ហេតុដូច្នេះហើយផែនការអាចជួយពួកគេឲ្យត្រៀមខ្លួនបានល្អទុកជាមុន។ ជាអនុសាសន៍ ចូរណែនាំសិស្សឲ្យមានជម្រើសច្រើនជាងមួយសម្រាប់ផែនការសិក្សារបស់ពួកគេ យ៉ាងហោចណាស់ក៏មានជម្រើសទី២ ដែលជាការបន្ថែមលើជម្រើសទី១។ កាលណាពួកគេបើកទ្វារកាន់តែច្រើនសម្រាប់អនាគតរបស់គេ ពួកគេកាន់តែមានភាពប្រសើរ។

ជំនួសឲ្យការដាក់ពាក្យចូលរៀន ឬចូលរួមកម្មវិធីបណ្តុះបណ្តាល សិស្សក៏អាចរៀបចំផែនការដើម្បីរកការងារធ្វើដែរ បន្ទាប់ពីការសិក្សា។ ចំពោះសិស្សទាំងនេះ ***ផែនការការងាររបស់ខ្ញុំ*** នឹងជួយរៀបចំជំហានបន្ទាប់ក្នុងការស្វែងរកការងារ។

facebook.com/moeyscambodia YouTube youtube.com/moeyscambodia www.moeys.gov.kh

ជាចុងក្រោយ គួរជំរុញឲ្យសិស្សគិតពីជម្រើសផ្សេងទៀតដែលគេមាន ប្រសិនបើសិស្សទាំងនេះមិនត្រូវបានទទួលឲ្យចូលរួមកម្មវិធីបណ្តុះបណ្តាល ឬមិនអាចរកការងារបានធ្វើ។ ឧទាហរណ៍ តើមាន វិស័យពាក់ព័ន្ធណាផ្សេងទៀតដែលពួកគេអាចយកធ្វើជាផែនការបម្រុងបាន?

## ប្រតិបត្តិ



### ក. ផែនការបន្ទាប់ពីការសិក្សានាពេលបច្ចុប្បន្នរបស់ខ្ញុំ

លំហាត់នេះនឹងជួយអ្នកពិចារណា និងរៀបចំជំហានបន្តបន្ទាប់។ អ្នកបានស្វែងរកជម្រើសអាជីពដែលបានប៉ងទុកមួយចំនួនហើយ។ ឥឡូវដល់ពេលនិយាយពីជម្រើស និងធ្វើឲ្យគោលដៅរបស់អ្នកក្លាយជាពិតហើយ!

តើអ្នកមានផែនការបែបណាបន្ទាប់ពីរៀនចប់? សិក្សា ការងារ ឬអ្វីផ្សេងទៀត? ចូរសរសេរគំនិត និងការគិតឃើញផ្សេងៗនៅលើសៀវភៅនេះ។

ផែនការបន្ទាប់ពីការសិក្សារបស់ខ្ញុំ

ការសិក្សា...............................

ការងារ.................................



បច្ចុប្បន្នខ្ញុំរៀននៅថ្នាក់ទី១០ នៃវិ...........។

បន្ទាប់ពីចប់មធ្យមសិក្សាខ្ញុំនឹង..............

| | | | |
|---|---|---|---|
| ទី១០ | | | |
| ទី១១ | | | |
| ទី១២ | | | |

មធ្យោបាយដើម្បីសម្រេចបំណងនេះ

.........................................................

facebook.com/moeyscambodia moeys.gov.kh YouTube youtube.com/moeyscambodia

## ខ. ផែនការនៃការសិក្សារបស់ខ្ញុំ

តើអ្នកមានផែនការច្បាស់លាស់សម្រាប់ការអប់រំនាពេលអនាគតរបស់អ្នករួចហើយឬនៅ? ចូរត្រៀមខ្លួនទុកជាមុន ស្វែងរកព័ត៌មានដែលពាក់ព័ន្ធ ព័ត៌មានទាក់ទងនឹងដំណើរការដាក់ពាក្យសុំការងារ ហើយបំពេញទម្រង់ដូចខាងក្រោម។ អ្នកគួរមានជម្រើសច្រើនជាងមួយសម្រាប់ផែនការនៃការសិក្សារបស់អ្នក យ៉ាងហោចណាស់ក៏មានជាម្រើសទី២ ដែលជាការបន្ថែមលើជម្រើសទី១ដែរ។ កាលណា ពួកគេ បើកទ្វារកាន់តែច្រើនសម្រាប់អនាគតរបស់គេ ពួកគេកាន់តែមានភាពប្រសើរ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ជម្រើសទី១

ការអប់រំ ឬកម្មវិធីបណ្តុះបណ្តាល

គ្រឹះស្ថានអប់រំ (មជ្ឈមណ្ឌលបណ្តុះបណ្តាល សាកលវិទ្យាល័យ មហាវិទ្យាល័យ...)

សញ្ញាបត្រ/ បរិញ្ញាបត្រ

តម្រូវការ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការចូលរៀន

ដាក់ពាក្យពេលណា? ពេលកំណត់នៃការដាក់ពាក្យ

ដាក់ពាក្យដោយរបៀបណា? ការដាក់ពាក្យ និងឯកសារបន្ថែម

ការប្រឡងចូលរៀន
នៅពេលណា?____________________
សម្ភារៈដែលត្រូវការ?____________________
កិច្ចការដំបូង____________________
ព័ត៌មានពាក់ព័ន្ធផ្សេងទៀត

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ជម្រើសរើសទី២

ការអប់រំ ឬកម្មវិធីបណ្តុះបណ្តាល

______________________________

គ្រឹះស្ថានអប់រំ (មជ្ឈមណ្ឌលបណ្តុះបណ្តាល សាកលវិទ្យាល័យ មហាវិទ្យាល័យ...)

______________________________

សញ្ញាបត្រ/ បរិញ្ញាបត្រ

______________________________

តម្រូវការ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការចូលរៀន

______________________________

______________________________

ដាក់ពាក្យពេលណា? ពេលកំណត់នៃការដាក់ពាក្យ

______________________________

ដាក់ពាក្យដោយរបៀបណា? ការដាប់ពាក្យ និងឯកសារបន្ថែម

______________________________

______________________________

______________________________

ការប្រឡងចូលរៀន

នៅពេលណា?______________________________

សម្ភារៈដែលត្រូវការ? ______________________________

កិច្ចការដំបូង ______________________________

ព័ត៌មានពាក់ព័ន្ធផ្សេងទៀត

______________________________

______________________________

______________________________

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## គ. ផែនការការងាររបស់ខ្ញុំ

១. តើអ្នកមានផែនការរកការងារធ្វើក្រោយការសិក្សាភ្លាមឬ? លំហាត់នេះនឹងជួយអ្នកឲ្យរៀបចំជំហានបន្ទាប់ក្នុងការស្វែងរកការងារ។

តើអ្នកចង់ធ្វើការងារនៅឯណា?

______________________________

______________________________

តើខ្ញុំអាចទាក់ទងនរណាដើម្បីរកការងារ? តើខ្ញុំទាក់ទងគេដោយរបៀបណា?

______________________________

______________________________

តើខ្ញុំអាចរកព័ត៌មានអំពីការងារនៅឯណា?

______________________________

______________________________

តើដាក់ពាក្យដោយវិធីណា? តើទម្រង់នៃការដាក់ពាក្យបែបណាដែលត្រូវការ?

______________________________

______________________________

______________________________

តើត្រូវត្រៀមខ្លួនសម្រាប់ការសម្ភាសន៍យ៉ាងដូចម្តេច?

______________________________

______________________________

______________________________

ព័ត៌មានពាក់ព័ន្ធផ្សេងៗ

______________________________

______________________________

______________________________

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

២. តើនឹងមានរឿងអ្វីកើតឡើងបើសិនគេមិនទទួលអ្នកឲ្យចូលរួមកម្មវិធីបណ្ដុះបណ្ដាល ឬផ្ដល់ការងារឲ្យធ្វើ? តើមានជម្រើសអ្វីផ្សេងទៀតទេ? ចូរសរសេរផែនការបម្រុងទុកក្នុងសៀវភៅនេះ។

**ផែនការបម្រុងទុករបស់ខ្ញុំ**

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

## ៤.៣.៨ ផែនការអប់រំ និងអាជីព

គោលបំណងនៃលំហាត់នេះ គឺជួយឲ្យសិស្សយល់ដឹងនូវទិដ្ឋភាពទាំងឡាយដែលមានឥទ្ធិពល វល់ជម្រើសនៃអាជីព និងផែនការបន្ទាប់ពីការសិក្សារបស់ពួកគេ។ តាមរយៈការបញ្ជាក់សកម្មភាពនេះ បិស្សក៏អាចរៀបចំផែនការដែលអាចជួយពួកគេឲ្យសម្រេចគោលដៅបានដែរ។

សំណួរនៅលើសន្លឹកកិច្ចការ និងម៉ូដែលសង្ខេប នឹងនាំសិស្សបញ្ចប់លំហាត់ *ការសង្ខេបផែនការ អប់រំ និងអាជីព*។ សិស្សអាចប្រមូលព័ត៌មាន លទ្ធផល និងការគិតរបស់គេពីលំហាត់មុនៗ និងតេស្តដែល គបានធ្វើក្នុងអំឡុងពេលរៀនមេរៀនប្រឹក្សាយោបល់។ ពេលប្រមូលចប់ ការសង្ខេបនឹងជួយសិស្សឲ្យ បល់ថាតើជំនាញ សមត្ថភាព ចំណាប់អារម្មណ៍ ការចូលចិត្ត ក្ដីរំពឹងទុក ស្របគ្នានឹងផែនការបន្ទាប់ពីការ បិក្សារបស់គេដែរឬអត់ ហើយតើមានតម្រូវការអ្វីដែលត្រូវពិចារណាឡើងវិញ ចំពោះអាជីពដែលស័ក្តិស រនឹងពួកគេ យោងតាមចំណាប់អារម្មណ៍ និងចំណង់ចំណូលចិត្តរបស់ពួកគេ។ លំហាត់នេះអាចយកប្រើ បម្រាប់ការប្រឹក្សាយោបល់ទល់មុខ ឬក្នុងថ្នាក់រៀនបានដែរ និង/ឬប្រើសម្រាប់កិច្ចការផ្ទះក៏បាន។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ប្រតិបត្តិ

ចូររៀបចំផែនការសង្ខេបនៃការអប់រំ និងអាជីពរបស់អ្នកនៅលើក្រដាសមួយសន្លឹក។ សំណួរខាងក្រោម និងម៉ូដែលសង្ខេបនឹងជួយអ្នកឲ្យបញ្ជាក់វាបាន។ អ្នកអាចប្រមូលព័ត៌មាន លទ្ធផល ការគិតពី លំហាត់មុនៗ និងតេស្តដែលគេបានធ្វើក្នុងអំឡុងពេលរៀនមេរៀនប្រឹក្សាយោបល់។

**អំពីខ្ញុំ**

១. តើមុខវិជ្ជាអ្វីដែលអ្នកពេញចិត្តនៅសាលារៀន?

២. តើជំនាញ និងចំណុចខ្លាំងរបស់អ្នកមានអ្វីខ្លះ?

៣. តើអ្នកត្រូវការអភិវឌ្ឍជំនាញអ្វី? តើចំណុចខ្សោយរបស់អ្នកមានអ្វីខ្លះ?

៤. តើអ្នកចំណាប់អារម្មណ៍ និងល្បែងកំសាន្តរបស់អ្នកមានអ្វីខ្លះ?

៥. តើអ្នកមានបទពិសោធន៍ការងារបែបណាខ្លះ? ឧទាហរណ៍ ការងារក្រោយការសិក្សា ការជួយក្រុមគ្រួសារធ្វើចំការ ឬជំនួញ ឬការស្ម័គ្រចិត្តចំពោះកម្មវិធីក្នុងស្រុក។

៦. ចូររៀបរាប់អំពីអ្វីដែលអ្នកពេញចិត្តធ្វើ ឬអ្វីដែលអ្នកពូកែ ដែលមិនបានរៀបរាប់ខាងលើ (ឧទាហរណ៍ ការលេងភ្លេង ការនិពន្ធរឿង ការលេងហ្គេមតាមកុំព្យូទ័រ ការសង់ ឬការជួសជុល)។ ចូររាប់បញ្ចូលទាំងសកម្មភាពដែលពាក់ព័ន្ធនឹងសាលារៀន និងសកម្មភាពដែលមិនពាក់ព័ន្ធ។

៧. ចូរបង្ហាញពីគុណតម្លៃដែលសំខាន់ចំពោះការងាររបស់អ្នក (ដូចជាការងារឯករាជ្យ ការងារខាងក្រៅ។ល។)

## ផែនការបន្ទាប់ពីការសិក្សានាពេលបច្ចុប្បន្នរបស់ខ្ញុំ

អ្នកបានស្វែងរកជម្រើសដែលប៉ងទុកពីរបីរួចមកហើយកាលពីមុន។ ឥឡូវនេះ ដល់ពេលនិយាយពីជម្រើសរបស់អ្នកហើយ។ តើការអប់រំនិងកម្មវិធីបណ្តុះបណ្តាលណាដែលអ្នកយល់ថាគួរឲ្យចាប់អារម្មណ៍បំផុត?

១. តើអ្នកបានគិតអំពីផ្លូវអាជីពផ្សេងៗដែលមានទំនាក់ទំនងនឹងកម្រិតនៃការអប់រំ និងការបណ្តុះបណ្តាលឬទេ?

២. ការងារស្រដៀងគ្នាជាច្រើនត្រូវការកម្រិតនៃការអប់រំ (ឧទាហរណ៍ អ្នកបច្ចេកទេស និងស្វូករ)។ តើកម្រិតណាដែលស័ក្តិសមនឹងអ្នកបំផុត ពាក់ព័ន្ធនឹងរបៀបនៃការសិក្សា គោលដៅអាជីព និងស្ថានភាពសេដ្ឋកិច្ច?

៣. តើអ្នកនឹងចាប់ផ្តើមធ្វើការបន្ទាប់ពីអ្នកបញ្ចប់ការសិក្សាភ្លាមមែនទេ? តើអ្នកចង់ធ្វើការនៅទីណា?

៤. មានមនុស្សប៉ុន្មាននាក់ដែលយល់ថា ផែនការបម្រុងទុកមានសារៈប្រយោជន៍?

៥. តើនឹងមានរឿងអ្វីកើតឡើងបើសិនជាគេមិនទទួលអ្នកឲ្យចូលរៀន ឬធ្វើការ? តើអ្នកមានជម្រើសអ្វីផ្សេងទៀត?

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

## ការទៅដល់ទីនោះពីទីនេះ

១. តើអ្នកអាចធ្វើអ្វីបានទៅពេលដែលអ្នកកំពុងសិក្សាដើម្បីត្រៀមខ្លួនសម្រាប់ការអប់រំ និងការងារនាពេលអនាគតរបស់អ្នក?

២. តើមុខវិជ្ជាអ្វីដែលអ្នកគួរសិក្សាបន្ថែម?

៣. តើអ្នកអាចធ្វើអ្វីបានទៀតដើម្បីពង្រឹងជំនាញ និងចំណេះដឹងរបស់អ្នក? តើមានមុខវិជ្ជាបន្ថែមដែលអ្នកអាចរៀនបានទេ?




facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# សេចក្តីសង្ខេបពីផែនការការអប់រំ និងអាជីពរបស់ខ្ញុំ

## អំពីខ្ញុំ

**មុខវិជ្ជាដែលខ្ញុំពេញចិត្ត**
- ✓ អង់គ្លេស
- ✓ ភូមិវិទ្យា
- ✓ ប្រវត្តិវិទ្យា

**បទពិសោធន៍ការងារដែលពាក់ព័ន្ធ**

ការងារក្រោយការសិក្សា
- ☐ វប្បធម៌បរទេស និងភាសា
- ☐ សកម្មភាពនៅក្លឹប
- ☐ ការងារស្ម័គ្រចិត្តផ្សេងទៀត
- ☐ លេខាធិការនៃសមាគមន៍

**ល្បែងកំសាន្ត និងចំណាប់អារម្មណ៍**
- ☐ បាល់ទះ
- ☐ វប្បធម៌បរទេ ភាសា
- ☐ សកម្មភាពនេ
- ☐ ការងារស្ម័គ្រ

**គុណតម្លៃសំខាន់ចំពោះការងារ**
- ▪ ធ្វើការជាមួយមនុស្ស
- ▪ ម៉ោងការងារបត់បែន
- ▪ ការងារឯករាជ្យ
- ▪ ការធ្វើដំណើរទៅបរទេស

**ជំនាញ និ ខ្លាំង**
- ➢ ពូកែភាសា
- ➢ ការងារជាប្រ
- ➢ ខាងសង្គម
- ➢ ទំនួលខុស

**ខ្ញុំចូលចិត្ត**
- ● អាន
- ● ផ្គុំពាក្យ
- ● ធ្វើដំណើរ
- ● ស្រាវជ្រាវ និងអង្កេត

**ចំណុ យ**
- ☐ គណិតវិទ្យា
- ☐ សុទិដ្ឋិនិយម

youtube.com/moeyscambodia
facebook.com/moeys.gov.kh

## ផែនការបន្ទាប់ពីការសិក្សា

**ជម្រើសនៃអាជីព និងការអប់រំ**
1. ធុរៈកិច្ច (សាកលវិទ្យាល័យ)
2. ការធ្វើដំណើរ និងវិស័យទេសចរណ៍ (មហាវិទ្យាល័យ)
3. បូរាណវិទ្យា (សាកលវិទ្យាល័យ)

**ផែនការបម្រុងទុក**
- ✓ សម្រាកមួយឆ្នាំដើម្បីទទួលបទពិសោធន៍ការងារ
- ✓ ការសិក្សាតាមបណ្តាញអ៊ីនធើណេត នៅសាកលវិទ្យាល័យបើកទូលាយ

**ការទៅដល់ទីនោះពីទីនេះ:**
- ✓ សង្កត់ធ្ងន់លើការសិក្សាភាសា
- ✓ រៀនគណិតវិទ្យាបន្ថែម
- ✓ ស្គាល់សៀវភៅសិក្សាសម្រាប់ប្រឡងចូលរៀន

# សំណួរដែលត្រូវពិចារណាបន្ទាប់ពីអ្នកបានបញ្ចប់សេចក្តីសង្ខេប ផែនការក្រោយការសិក្សារបស់អ្នក

១. តើចំណាប់អារម្មណ៍ ចំណង់ចំណូលចិត្ត និងក្តីរំពឹង ស្របនឹងផែនការបន្ទាប់ពីការសិក្សារបស់អ្នកដែរឬទេ? បើមិនមែន តើមានវិស័យអាជីពណា ដែលស័ក្តិសមនឹងអ្នក យោងតាមចំណង់ចំណូលចិត្តរបស់អ្នក?

២. តើជំនាញ និងសមត្ថភាពបច្ចុប្បន្នធ្វើឲ្យអ្នកអាចទទួលការអប់រំ និងចូលរួមកម្មវិធីបណ្តុះបណ្តាលបានទេ ឬតើជំនាញ និងសមត្ថភាពរបស់អ្នក ជួយបំពេញតម្រូវការការងារនានាដែលអ្នកកំពុងស្វែងរកដែរទេ?

៣. ចូរចាប់ផ្តើមដោយពិនិត្យឡើងវិញនូវការអប់រំទូទៅ ឬតម្រូវការចាំបាច់ចំពោះការងារ និងសួរខ្លួនឯងថា «តើខ្ញុំអាចធ្វើវាបានឬទេ?»

សូមសំណាងល្អនៅពេលដែលអ្នកបន្តធ្វើផែនការអនាគតរបស់អ្នក!

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

### ៤.៣.៩. ផែនទីកំណាប់ទ្រព្យ

តើអ្នកមើលឃើញខ្លួនឯងនៅឯណារយៈពេល១០ឆ្នាំទៀត?

- តើអ្នកធ្វើអ្វី?
- តើអ្នកធ្វើការនៅឯណា?
- តើអ្នកមានគ្រួសារទេ?
- តើអ្នករស់នៅឯណា?
- តើចំណាប់អារម្មណ៍ និងល្បែងកំសាន្តរបស់អ្នកមានអ្វីខ្លះ?
- តើអ្នកមានមិត្តភក្តិបែបណា?

«បើអ្នកអាចស្រមៃឃើញវា អ្នកអាចសម្រេចវាបាន បើអ្នកអាចយល់សប្តិឃើញវា អ្នកអាចក្លាយជាវាបាន» ។ **វីលាម អាសឺវែដ** (William Arthur Ward)

ផែនទីកំណាប់ទ្រព្យ (អាចហៅបានថា ក្ដារទស្សនៈវិស័យ ឬក្ដារនៃក្ដីសុបិន) ជាទម្រង់នៃរូបភាពនៃក្ដីសុបិន្តគោលដៅរបស់អ្នក ហើយវាជាអ្វីដែលធ្វើឲ្យអ្នកសប្បាយចិត្ត។ ក្រៅពីរូបភាពនេះ ផែនទីកំណាប់ទ្រព្យអាចរាប់បញ្ចូលពាក្យ ឃ្លា ប្រយោគ ឬនរណាម្នាក់ ដែលអាចអះអាងនូវបំណងរបស់អ្នក។ ផែនទីកំណាប់ទ្រព្យ គឺជាឧបករណ៍ដែលមានប្រយោជន៍ ជួយឲ្យអ្នកគិតឃើញនូវគោលដៅ ហើយអាចប្រើជាប្រភពនៃការលើកទឹកចិត្ត ខណៈដែលអ្នកធ្វើការឆ្ពោះទៅកាន់ការសម្រេចបាននូវក្ដីសុបិន្តរបស់អ្នក។ គំនិតនៅពីក្រោយនេះ គឺ អ្នកហ៊ុមព័ទ្ធទៅដោយរូបភាពដែលបញ្ជាក់ថា អ្នកចង់ក្លាយជាអ្វី អ្នកចង់បានអ្វី អ្នកចង់រស់នៅទីណា ឬអ្នកចង់ឈប់សម្រាកលំហែនៅទីណា ព្រមទាំងការផ្លាស់ប្ដូរនៃជីវិតដែលសមស្របនឹងរូបភាព និងក្ដីប្រាថ្នាទាំងនោះ។

**តើអ្នកបង្កើតផែនទីកំណាប់ទ្រព្យដោយរបៀបណា?**

អ្នកគ្រាន់តែត្រូវការៈ

- ក្ដារដែលមានផ្ទាំងរូបភាពធំៗ ផ្ទាំងក្រដាសធំសម្រាប់សរសេរ ឬក្រដាសធំផ្សេងទៀត
- ទស្សនាវដ្ដី កាសែត សៀវភៅស្ដើង ខិតប័ណ្ណ កាតប៉ុស្ដាល់ចាស់ៗ រូបថត ។ល។
- កាវ ហ្វឺត និងប៊ិចពណ៌ (កន្ត្រៃ)។

ជំហានទី១ ៖ មើលត្រួសៗនូវទស្សនាវដ្ដី សម្ភារផ្សេងៗដែលមាន ហែករូបភាព ពាក្យ និងចំណងជើងទៅតាមន័យដែលអ្នកចង់បាន។

ជំហានទី២ ៖ ចាប់ផ្ដើមដោយដាក់រូបភាពនៅលើក្ដារ អ្នកអាចសរសេរន័យរបស់វានៅជ្រុងក្ដារ (ឧទា. សុខភាព ការងារ ទំនាក់ទំនង...) ឬដាក់រូបពាសពេញផែនទីកំណាប់ទ្រព្យ

ជំហានទី៣៖ យកការបិទរូបទាំងអស់នៅលើក្ដារ សរសេរពាក្យ ឃ្លា និងពាក្យស្លោក ឬគូររូបដោយប្រើហ្វឺត និងប៊ិចពណ៌ បើសិនជាអ្នកចង់សរសេរ។

ជំហានទី៤៖ ព្យួរផែនទីកំណាប់ទ្រព្យរបស់អ្នកនៅទីកន្លែងដែលអ្នកមើលឃើញញឹកញាប់។

facebook.com/moeyscambodia YouTube youtube.com/moeyscambodia




facebook.com/moeyscambodia YouTube youtube.com/moeyscambodia

# ជំពូកទី ៦
# កម្មវិធីផ្នែកប្រឹក្សាអាជីព
# នៅមធ្យមសិក្សា

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ៦. កម្មវិធីសិក្សាផ្នែកប្រឹក្សាអាជីពនៅមធ្យមសិក្សា

## ៦.១. កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ

ការផ្លាស់ប្តូរប្រកបដោយសុវត្ថិភាពសម្រាប់សិស្សពីបឋមសិក្សាទៅអនុវិទ្យាល័យ គឺមានការគាំទ្រពីគ្រូបង្គោលប្រឹក្សាអាជីព ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយនាយកសាលា និងលោកគ្រូ អ្នកគ្រូ ដែលជាដៃគូនៅសាលាបឋមសិក្សា។

សម្រាប់ការអប់រំនៅអនុវិទ្យាល័យ មគ្គុទេសក៍នៃការសិក្សា និងវិជ្ជាជីវៈរួមបញ្ចូលនូវចំណុចសំខាន់ៗមួយចំនួនដូចជា ការសិក្សាជំនាញ ការធ្វើការនៅសហគមន៍របស់សាលា ចំណេះដឹងផ្ទាល់ខ្លួន ជម្រើសសម្រាប់ការសិក្សាបន្ត មុខរបរ និងវិស័យនៃមុខរបរ ព្រមទាំងជីវិតការងារ។ លើសពីការប្រឹក្សាយោបល់ក្នុងថ្នាក់រៀនប្រកបដោយភាពរីកចម្រើនជាប្រចាំ សិស្សទាំងអស់ក៏នឹងត្រូវទទួលការប្រឹក្សា យោបល់ទល់មុខ ឬជាក្រុមតូចៗទៅតាមការស្នើសុំ។

នៅឆ្នាំចុងក្រោយនៃអនុវិទ្យាល័យ សិស្សត្រូវទទួលការណែនាំឲ្យស្គាល់ពីផែនការបន្ទាប់ពីសាលា។ សិស្សក៏ត្រូវទទួលការណែនាំឲ្យប្រើប្រាស់ព័ត៌មាន ដែលជាជំនួយដល់ជម្រើសនៃការសិក្សា និងអាជីពរបស់ពួកគេ ព្រមទាំងប្រើប្រាស់សេវាប្រឹក្សាយោបល់ ដែលផ្តល់ដោយគ្រឹះស្ថានអប់រំ រដ្ឋបាលការងារ និងភ្នាក់ងារសាធារណៈផ្សេងៗ។

ក្នុងអំឡុងពេលសិក្សាថ្នាក់ទី៩ សិស្ស មានឱកាសបញ្ចប់មុខវិជ្ជា ដែលផ្តល់ការណែនាំឲ្យស្គាល់ពីជីវិតការងារ។ មុខវិជ្ជានេះជួយដល់ការជ្រើសរើសផ្នែកអប់រំ និងអាជីព ហើយអាចរៀបចំជាបកម្មភាពបន្ទាប់ពីសាលា។ ការផ្លាស់ប្តូរប្រកបដោយសុវត្ថិភាពសម្រាប់សិស្សពីបឋមសិក្សា ទៅអនុវិទ្យាល័យ ឬការបណ្តុះបណ្តាលផ្នែកអាជីព គឺទទួលការគាំទ្រតាមរយៈកិច្ចសហការរវាងគ្រូបង្គោលប្រឹក្សាអាជីព លោកគ្រូ អ្នកគ្រូ នាយក នាយិកា ដែលជាដៃគូនៅតាមសាលា និងវិទ្យាស្ថាននានា។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| គោលដៅ | មាតិកាសំខាន់ៗ | ថ្នាក់ | ម៉ោង | វិធីសាស្ត្រ |
|---|---|---|---|---|
| **ដំណាក់កាលផ្លាស់ប្តូរ** | | 6 → 7 | មិនកំណត់ | |
| សិស្សទទួលការគាំទ្រ និងការណែនាំទៅតាមដំណាក់កាលផ្លាស់ប្តូរផ្សេងៗ នៃផ្លូវសិក្សារបស់ពួកគេ | – ការធ្វើឲ្យប្រាកដថាការផ្លាស់ប្តូរពិតជាមានសុវត្ថិភាព<br>– ការណែនាំសិស្សថ្នាក់ទី៦រៀននៅបឋមសាលាក្នុងស្រុកឲ្យស្គាល់ពីការអប់រំនៅអនុវិទ្យាល័យ | | | – គ្រូប្រឹក្សាអាជីពធ្វើទស្សនកិច្ចសាលាបឋមសិក្សាក្នុងស្រុក<br>– សិស្សបឋមសិក្សាធ្វើទស្សនកិច្ចនៅអនុវិទ្យាល័យ(ថ្ងៃទំនេរ)<br>– សហប្រតិបត្តិការ និងការចែករំលែកព័ត៌មានដល់គ្រូបឋម |
| **ការពិគ្រោះយោបល់អំពីការសិក្សា** | | 7 | | |
| សិស្សរៀន<br>– ពីរបៀបធ្វើការក្នុងសហគម៍<br>– នូវភាពឯ[illegible]រ និងទំនួលខុសត្រូវ<br>– សហប្រតិ[illegible]ការ និងជំនាញទំនាក់ទំនង<br>– អភិវឌ្ឍជំ[illegible] សិក្សា និងជំនាញវង្វាយតម្លៃខ្លួនឯង<br>– ប្រើប្រាស់[illegible]ស្ត្រ និងប្រភពព័ត៌មានផ្សេងៗ<br>– អភិវឌ្ឍយុ[illegible]ស្ត្រសិក្សាជាលក្ខណៈបុគ្គល | – ការសិក្សានៅអនុវិទ្យាល័យ (ការផ្លាស់ប្តូរ បញ្ហាប្រឈម សារៈសំខាន់នៃការសិក្សា ការគាំទ្រពីមនុស្សដទៃ ការសិក្សានៅសាលា)<br>– ក្បួនច្បាប់សម្រាប់ការងារសាលា (បរិយាកាសរៀនសូត្រប្រកបដោយភាពស្ងៀមស្ងាត់ សម្ភារសិក្សាចាំបាច់ ។ល។)<br>– ដើរតួជាសមាជិកដែលមានការទទួលខុសត្រូវដល់ក្រុមជំនាញសិក្សា (ទទួលព័ត៌មានកិច្ចការផ្ទះ ការកត់ត្រាទុក វិធីសាស្ត្រចងចាំ ការរំលឹកមេរៀនប្រឡង ការគ្រប់គ្រងពេលវេលា)<br>– ការវាយតម្លៃ | | | – ការពិភាក្សាជាក្រុមនិងសកម្មភាពផ្សេងៗក្នុងថ្នាក់<br>– សិក្ខាសាលាការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ |

youtube.com/moeyscambodia facebook.com/moeys.gov.kh

| គោលដៅ | មាតិកាសំខាន់ៗ | ថ្នាក់ | ម៉ោង | វិធីសាស្ត្រ |
|---|---|---|---|---|
| **ការអភិវឌ្ឍខ្លួនឯង និងផ្នែកសង្គម** | | 7 | | |
| សិស្សនឹង<br>– យល់ពីខ្លួនឯងថាជាបុគ្គលមួយរូប<br>– និងជាសមាជិកនៃសហគមន៍នានា<br>– បង្កើនចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេ<br>– អភិវឌ្ឍជំនាញទំនាក់ទំនងប្រកបដោយការគោរពបុគ្គល និងក្រុមផ្សេងៗ<br>– ប្រើជំនាញសុវត្ថិភាពផ្ទាល់ខ្លួន<br>– និងយុទ្ធសាស្ត្រដោះស្រាយបញ្ហា | – គំនិតផ្ទាល់ខ្លួន និងការពង្រឹងការគោរពខ្លួនឯង<br>– ការធ្វើឲ្យមានតុល្យភាពតួនាទីជីវិត<br>– របៀបទទួលស្គាល់ខ្លួនឯង (អ្នក និងគុណតម្លៃរបស់អ្នក)<br>– ការធ្វើជាសមាជិកចូលរួមដល់សហគមន៍នានានៃពិភពលោក<br>– ទំនាក់ទំនងប្រកបដោយគុណភាព<br>– ការគោរពខ្លួនឯង និងអ្នកដទៃ<br>– ការទទួលខុសត្រូវផ្ទាល់ខ្លួនលើទំនាក់ទំនង<br>– ជម្រើសប្រកបដោយសុវត្ថិភាព<br>– និងសុខភាពក្នុងជីវិត<br>– ការប្រឈមនឹងបញ្ហា និងការខកចិត្ត<br>– ការគ្រប់គ្រងអារម្មណ៍<br>– ការដោះស្រាយភាពតានតឹង | | | – ការពិភាក្សាជាក្រុម និងសកម្មភាពផ្សេងៗក្នុងថ្នាក់<br>– សិក្ខាសាលាការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ (ទៅតាមសំណូពរ) |
| **ចំណេះដឹងផ្ទាល់ខ្លួន** | | 7 | | |
| សិស្សនឹង<br>– បង្កើនចំណេះដឹងខ្លួនឯង | | | | – ការពិភាក្សាជាក្រុមនិងសកម្មភាពផ្សេងៗក្នុងថ្នាក់ |

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

| | | | | |
|---|---|---|---|---|
| – ទទួលស្គាល់បណ្ដាញមនុស្សដែលអាចផ្ដល់ការគាំទ្រដល់ជីវិតប្រចាំថ្ងៃនៅសាលា និងនៅផ្ទះ ឬផ្ដល់ការគាំទ្រដល់ការកសាងអនាគតរបស់ពួកគេ<br>– សង្កេតមើលតើឱកាសអ្វីដែលបរិស្ថាននៃការរស់នៅរបស់ពួកគេអាចផ្ដល់ឲ្យបាន | – ចំណាប់អារម្មណ៍<br>– ការងារបណ្ដាញរបស់ខ្ញុំ<br>– បរិស្ថាននៃការរស់នៅរបស់ខ្ញុំ | | | – ការសិក្សា<br>– សិក្ខាសាលា<br>– ការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ (ទៅតាមសំណូពរ) |
| **ជីវិត និងក្ដីសុបិន្តនៃអាជីព** | | 8 | | |
| សិស្សនឹង<br>– បង្កើនចំណេះដឹងផ្ទាល់ខ្លួនបន្ថែមដោយបង្ហាញពីក្ដីប្រាថ្នា និងក្ដីសុបិននាពេលអនាគតរបស់ពួកគេ<br>– ស្វែងយល់នូវ[illegible]ពអ្វីដែលមានសារៈសំខាន់ក្នុងជីវិតការងា[illegible]អាជីពរបស់ពួកគេ<br>– ស្គាល់ពីអ្វីដែល[illegible]គេត្រូវការរៀនសូត្រដើម្បីសម្រេចបានក្ដី[illegible]ន និងគោលបំណងរបស់ពួកគេ | – ជីវិត និងក្ដីសុបិននៃអាជីព<br>– រូបភាពនៃការងារ (ភ្ជាប់ជាមួយកិច្ចការ រូបភាព អារម្មណ៍ គំនិត សញ្ញាណ ការគិតទុកជាមុន ។ល។)<br>– ទិដ្ឋភាពសំខាន់ក្នុងជីវិតការងារ<br>– ជំនាញនិងចំណេះដឹងដែលត្រូវការសម្រាប់ការងារក្នុងក្ដីសុបិន | | | – ការពិភាក្សាជាក្រុម<br>– និងសកម្មភាពផ្សេងៗក្នុងថ្នាក់<br>– សិក្ខាសាលា<br>– ការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ (ទៅតាមសំណូមពរ) |

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

| គោលដៅ | មាតិកាសំខាន់ៗ | ថ្នាក់ | ម៉ោង | វិធីសាស្ត្រ |
|---|---|---|---|---|
| **ការសិក្សា** | | 8 | | |
| សិស្សនឹង<br>– យល់ថាការសិក្សាជាដំណើរការពេញមួយជីវិត<br>– យកចិត្តទុកដាក់ចំពោះបំណិនជីវិត និងអាចមានសមត្ថភាពរៀនសូត្រ<br>– កំណត់ខ្លួនឯងថាជាអ្នកសិក្សា៖ ស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយ បង្ហាញនូវបទពិសោធន៍សិក្សាដែលសំខាន់ និងដឹងនូវរបៀបសិក្សាផ្សេងៗ<br>– បង្កើនសមត្ថភ[illegible]ការសិក្សា ទទួលស្គាល់ភ[illegible]បាកនៃការសិក្សា និងស្វែងរកជំ[illegible]ស្ថានភាពលំបាក<br>– រៀនបង្កើតយុ[illegible]ស្ត្ររៀងខ្លួន | – តើការសិក្សាជាអ្វី?<br>– តើប្រភេទនៃការសិក្សាមានអ្វីខ្លះ?<br>– តើយើងអាចរៀននៅទីណា ពេលណា និងរបៀបណា?<br>– ដំណើរការនៃការសិក្សា<br>– បទពិសោធន៍នៃការសិក្សាថ្មីៗ<br>– តើខ្ញុំជានរណាក្នុងនាមជាអ្នកសិក្សា?<br>– បំណិនជីវិតទម្លាប់ដែលជួយដល់ការសិក្សា (ឧ. របៀបរស់នៅ ការដេក ចំណីអាហារ កីឡា គោលបំណង ការលើកទឹកចិត្ត ឥរិយាបថ ។ល។)<br>– ការកំណត់ខ្លួនឯងថាជាអ្នកសិក្សារបៀបនៃការសិក្សា<br>– ដំណើរការនៃកាសិក្សារបស់ខ្ញុំ | | | – ការពិភាក្សាជាក្រុមនិងសកម្មភាពផ្សេងៗក្នុងថ្នាក់<br>– សិក្ខាសាលាការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ (ទៅតាមសំណូមពរ)<br>– តេស្តពីរបៀបនៃការសិក្សា |
| **ជំន[illegible] និងភាពខ្លាំង** | | 8 | | |
| សិស្សរៀន | – ការស្វែងយល់ពីចំណុចខ្លាំង និងចំណុចពូកែ | | | – ការពិភាក្សាជាក្រុម |

youtube.com/moeyscambodia
facebook.com/moeys.gov.kh

| | | | | |
|---|---|---|---|---|
| – បង្ហាញពីភាពខ្លាំង ជំនាញ និងបុគ្គលិកលក្ខណៈល្អៗ ហើយពិពណ៌នាទាំងអស់<br>– ពង្រីកការគិតពីរបៀបធ្វើចំណុចខ្សោយឲ្យទៅចំណុចខ្លាំងតាមការសិក្សា និងអនុវត្តន៍<br>– មើលឃើញពីទំនាក់ទំនងរវាងរូបភាពខ្លួនឯង និងជម្រើសនៃអាជីព | – ការកំណត់ភាពខ្លាំង និងអ្វីដែលសិស្សពូកែ<br>– ស្វែងយល់ពីជំនាញ<br>– ស្វែងយល់ពីចំណុចខ្លាំងតាមក្រសែភ្នែកអ្នកដទៃ<br>– ជំនាញ និងបុគ្គលិកលក្ខណៈជាសញ្ញាដំបូងឆ្ពោះទៅកាន់ផ្លូវអាជីព | | | – ការពិភាក្សាក្រុមនិងសកម្មភាពផ្សេងៗក្នុងថ្នាក់រៀន<br>– សិក្ខាសាលា<br>– ការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ (ទៅតាមសំណូមពរ)<br>– តេស្តពហុបញ្ញា (ហ្គាដនើ ហាវីដ) |
| **ការអភិវឌ្ឍវិជ្ជាជីវៈ ការអប់រំ និងជម្រើសអាជីព** | | 9 | | |
| សិស្សនឹង<br>– យល់ដឹងពីទិដ្ឋ[illegible]ពាក់ព័ន្ធដែលមានឥទ្ធិពលលើជ[illegible]នៃអាជីព និងផែនការបន្ទាប់ពីសាល[illegible]ប់ពួកគេ<br>– ស្វែងយល់ពីចំ[illegible]ប់អារម្មណ៍ថ្មីៗ ក្តីរំពឹងទុក ក្តីប្រ[illegible] សម្រាប់អាជីពនាពេលអនាគតរបស់[illegible]<br>– រៀនទទួលព័ត៌[illegible] សម្រាប់ផែនការជីវិតដោយប្រើ អា[illegible]ធី និងប្រភពព័ត៌មាន | – កត្តាដែលមានឥទ្ធិពលលើជម្រើសនៃការងារ (មនុស្សដទៃ បុគ្គលិកលក្ខណៈ លក្ខណៈពិសេសនៃការងារ ។ល។)<br>– ការតម្រង់ទិសឲ្យស្គាល់ពីមុខរបរ និងវិស័យនៃមុខរបរ<br>– ចំណេះដឹងនៃជីវិតការងារ<br>– ភាពស្មើគ្នាក្នុងសង្គម និងជីវិតការងារ<br>– ការស្វែងរកការងារ<br>– ផែនការបន្ទាប់ពីរៀនចប់ថ្មីៗ | | | – ការពិភាក្សាជាក្រុមនិងសកម្មភាពក្នុងថ្នាក់រៀនផ្សេងទៀត<br>– សិក្ខាសាលា<br>– ការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ (ទៅតាមសំណូមពរ)<br>– លេខកូដហូឡែន (RIASEC) |

YouTube youtube.com/moeyscambodia facebook.com/moeys.gov.kh facebook.com/moeyscambodia

| | | | | |
|---|---|---|---|---|
| – ទទួលព័ត៌មានមូលដ្ឋានអំពីជីវិតការងារ និងវិស័យអាជីពផ្សេងៗ<br>– យល់ថាជម្រើសអាជីពសំខាន់ជាងរបាំងយេនឌ័រ<br>– រៀបចំផែនការដែលជួយឲ្យពួកគេសម្រេចគោលដៅអប់រំ និងអាជីព | | | | |
| **ជម្រើសនៃការសិក្សា** | | 9 | | |
| សិស្សនឹង<br>– ដឹងពីរចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំនៅកម្ពុជា<br>– រៀនរកព័ត៌មានស្តីពីលទ្ធភាពសំរាប់ការសិក្សាបន្តបន្ទាប់ពីអនុវិទ្យាល័យ<br>– ដឹងពីរបៀបដាក់ពាក្យដើម្បីសិក្សាបន្ត | – ប្រព័ន្ធអប់រំនៅកម្ពុជា<br>– ការទទួលព័ត៌មានអំពី:<br>– ការអប់រំ និងបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈ និងបច្ចេកទេស<br>– ការអប់រំនៅវិទ្យាល័យ<br>– ជម្រើសផ្សេងៗសម្រាប់ការសិក្សាបន្តបន្ទាប់ពីអនុវិទ្យាល័យ | | | – ការពិភាក្សាជាក្រុមនិងសកម្មភាពក្នុងថ្នាក់រៀនផ្សេងទៀត<br>– សិក្ខាសាលា<br>– ការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ (ទៅតាមសំណូមពរ)<br>– ការស្វែងរកព័ត៌មាន |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | | | |
|---|---|---|---|---|
| **បណ្ដាញការងារ** | | 7, 8, 9 | | |
| កិច្ចសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាលក្នុងស្រុក និងសហគមធុរៈកិច្ច និងការងារជួយឲ្យសិស្សទទួលបានព័ត៌មានអំពីជម្រើសនៃការសិក្សា វិស័យមុខរបរ មុខរបរ និងជីវិតការងារ និងបានស្គាល់ពីសកម្មភាពសហគ្រិន | (សូមមើលវិធីសាស្ត្រ) | | | – ដំណើរទស្សនៈកិច្ចទៅកាន់ក្រុមហ៊ុនក្នុងស្រុក និងវិទ្យាស្ថានបណ្តុះបណ្តាល<br>– ការអញ្ជើញវាគ្មិន |
| **ការណែនាំឲ្យស្គាល់ពីជីវិតការងារ (ជាជម្រើស)** | | 9 | | |
| សិស្សគាំទ្រជម្រើសនៃការអប់រំ និងអាជីពរបស់ពួកគេ ហើយពង្រឹងការគោរពការងារដោយទទួលនូវបទពិសោធន៍ផ្ទាល់ពីជីវិតការងារ និងមុខរបរនៅក្នុងបរិយាកាសការងារពិតប្រាកដ។ | – បង្កើតផែនការសម្រាប់មុខវិជ្ជា (គោលបំណង គោលដៅ មាតិកា តារាងកាលវិភាគ ។ល។)<br>– ការស្គាល់មុខរបរនៅក្នុងបរិស្ថានការងារពិតប្រាកដ<br>– ការវាយតម្លៃនៃព័ត៌មាន និងបទពិសោធន៍ដែលទទួលបាន | | | សកម្មភាពបន្ទាប់ពីសាលា |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ៦.២. កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ

ការផ្លាស់ប្តូរប្រកបដោយសុវត្ថិភាពសម្រាប់សិស្សពីអនុវិទ្យាល័យទៅវិទ្យាល័យ គឺមានការគាំទ្រតាមរយៈកិច្ចសហការជាមួយគ្រូប្រឹក្សាអាជីព លោកគ្រូ អ្នកគ្រូ នាយកសាលា ដែលជាដៃគូដ៏ល្អនៅអនុវិទ្យាល័យ។

មគ្គុទ្ទេសក៍នៃការអប់រំ និងវិជ្ជាជីវៈ ជាដំណើរការដែលបន្តពេញមួយរយៈពេលនៃការសិក្សានៅវិទ្យាល័យ។ តួនាទីរបស់មគ្គុទ្ទេសក៍នៃការអប់រំ និងវិជ្ជាជីវៈ គឺជួយគាំទ្រដល់ការសិក្សារបស់សិស្ស និងនាំឲ្យសិស្សទទួលបានជំនាញ និងចំណេះដឹងគ្រប់គ្រាន់ ដើម្បីបន្តការសិក្សា និងចូលបម្រើការងារ។ ការប្រឹក្សាយោបល់នៅក្នុងថ្នាក់រៀនប្រកបដោយភាពរីកចម្រើនជាប្រចាំ ការផ្តល់ឱកាសដល់សិស្សឲ្យទទួលបាននូវជំនាញ និងចំណេះដឹងពិតប្រាកដ ដែលអាចជួយពួកគេរៀបចំផែនការបន្តការសិក្សា និងធ្វើការជ្រើសរើសអាជីព។ សិស្សត្រូវមានការលើកទឹកចិត្តឲ្យស្វែងរកការប្រឹក្សាយោបល់ទល់មុខជាលក្ខណៈបុគ្គល ដើម្បីពិភាក្សាបញ្ហាដែលពាក់ព័ន្ធនឹងការសិក្សា ជម្រើសនៃការអប់រំ ផែនការអាជីព កាលៈទេសៈបច្ចុប្បន្នក្នុងជីវិតរបស់ពួកគេ និងផែនការនាពេលអនាគតរបស់ពួកគេ។ នៅក្នុងក្រុមតូច សិស្សអាចពិភាក្សាពីបញ្ហាទាំងឡាយណាដែលមានអត្ថន័យសម្រាប់ក្រុម ហើយជាលទ្ធផលទទួលបានការគាំទ្រពីសមាជិកក្រុម។ សិស្សក៏ត្រូវមានការណែនាំផងដែរអំពីការទទួលព័ត៌មានដោយប្រើបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង។ សិស្សរៀនពីសេចក្តីណែនាំសំខាន់ៗនៃរបៀបប្រើប្រាស់ ពាក់ព័ន្ធនឹងការអប់រំបន្តនៅកម្រិតខ្ពស់ និងជម្រើសនៃអាជីព ព្រមទាំងប្រភពព័ត៌មាន និងដឹងពីរបៀបទទួលផលពីព័ត៌មាន ទាក់ទងនឹងបណ្តាញការងារដោយឯករាជ្យ ដែលជាការគាំទ្រដល់ការដាក់ពាក្យបន្តការសិក្សា។

គោលបំណង គឺដើម្បីឲ្យសិស្សមានសមត្ថភាពដាក់ពាក្យបន្តការសិក្សា នៅពេលដែលពួកគេបញ្ចប់ការសិក្សានៅវិទ្យាល័យភ្លាម។ លើសពីនេះ តួនាទីមគ្គុទ្ទេសក៍នេះ គឺជួយផ្តល់ព័ត៌មានអំពីជីវិតសង្គមកិច្ច និងការងារ ព្រមទាំងសហគ្រិនភាព។ សិស្សមានឱកាសបានស្គាល់ពីមុខរបរ ជីវិតការងារ ព្រមទាំងគ្រឹះស្ថានសម្រាប់សិក្សាបន្ទាប់ពីវិទ្យាល័យ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| គោលដៅ | មាតិកាសំខាន់ៗ | ថ្នាក់ | ម៉ោង | វិធីសាស្រ្ត |
|---|---|---|---|---|
| **ដំណាក់កាលផ្លាស់ប្តូរ** | | 9 → 10 | មិនកំណត់ | |
| សិស្សទទួលការគាំទ្រ និងការណែនាំទៅតាមដំណាក់កាលផ្លាស់ប្តូរផ្សេងៗនៃផ្លូវសិក្សារបស់ពួកគេ | – ការធ្វើឲ្យប្រាកដថាការផ្លាស់ប្តូរពិតជាមានសុវត្ថិភាព<br>– ការណែនាំសិស្សថ្នាក់ទី៩នៅអនុវិទ្យាល័យក្នុងស្រុកឲ្យស្គាល់ពីការអប់រំនៅវិទ្យាល័យ | | | – គ្រូប្រឹក្សាអាជីពទស្សនកិច្ចទៅកាន់អនុវិទ្យាល័យក្នុងស្រុក<br>– សិស្សអនុវិទ្យាល័យធ្វើទស្សនកិច្ចនៅវិទ្យាល័យ (ថ្ងៃទំនេរ)<br>– សហប្រតិបត្តិការ និងការចែករំលែកព័ត៌មានដល់គ្រូអនុវិទ្យាល័យ |
| **ការប្រឹក្សាយោបល់ផ្នែកសិក្សា** | | 10 | | |
| – មានភាពងាយស្រួលក្នុងការទទួលយកជំនាញ និងចំណេះដឹងដែលពាក់ព័ន្ធនឹងការចាប់ផ្តើម និង[illegible]ការសិក្សានៅវិទ្យាល័យ។<br>– សិស្សត្រូវទទួ[illegible]រណែនាំឲ្យដឹងពីឯករាជ្យភាព និងទំនួ[illegible]សត្រូវ បង្កើតផែនការសិក្សារៀងខ្លួន ស្វែង[illegible]ពីបញ្ហាពាក់ព័ន្ធនឹងការសិក្សា និងរក[illegible]ដើម្បីដោះស្រាយបញ្ហា។<br>– សិស្សត្រូវទទួ[illegible]រណែនាំឲ្យស្គាល់ពីជំនាញផ្នែកការសិក្ស[illegible]រង្វាយតម្លៃ និងស្វែងយល់ពី របៀបនៃក[illegible]ក្សា ព្រមទាំងភាពខ្លាំងរបស់ពួកគេ។<br>– សិស្សទទួល[illegible]ណនាំ និងគាំទ្រខាងជំនាញគ្រប់គ្រងជីវិត | -តែងសេចក្តីអំពីការសិក្សា និងការអនុវត្តនៅវិទ្យាល័យ<br>-ផែនការសិក្សា (ធ្វើបច្ចុប្បន្នភាពម្តងម្កាល)<br>　– គោលដៅជាបុគ្គល<br>　– ខ្លឹមសារនៃការសិក្សា<br>　– មុខវិជ្ជាបន្ថែម ឬការសិក្សា<br>　– សកម្មភាពបន្ថែមលើការសិក្សា<br>-ការបង្កើតជំនាញសិក្សាផ្ទាល់ខ្លួន<br>-ការបង្កើតចំណេះដឹងផ្ទាល់ខ្លួននិងការបង្កើតជំនាញវង្វាយតម្លៃខ្លួនឯង<br>-ការអភិវឌ្ឍជំនាញស្វែងរកព័ត៌មាន<br>-ការទទួលស្គាល់ម៉ូដែលសម្រាប់ប្រតិបត្តិ និងភាពខ្លាំង ព្រមទាំងចំណាប់អារម្មណ៍របស់ខ្លួនផ្ទាល់ និងជំនាញគ្រប់គ្រងជីវិត | | | – ការពិភាក្សាជាក្រុម និងសកម្មភាពផ្សេងៗក្នុងថ្នាក់<br>– សិក្ខាសាលា<br>– ការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ (ទៅតាមសំណូមពរ) |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| គោលដៅ | មាតិកាសំខាន់ៗ | ថ្នាក់ | ម៉ោង | វិធីសាស្ត្រ |
|---|---|---|---|---|
| **ការរៀបចំផែនការមុខរបរ និងជីវិតការងារ** | | 11 | | |
| – សិស្សទទួលការណែនាំឲ្យស្គាល់ពីបញ្ហាដែលមានសារៈសំខាន់ក្នុងការអភិវឌ្ឍអាជីពនិងជំនាញរៀបចំផែនការ និងទទួលបាននូវជំនាញក្នុងការបន្តការសិក្សាកម្រិតខ្ពស់ និងឈានទៅរកជីវិតការងារ។<br>– សិស្សបង្កើនជំនាញជីវិតការងារ និងស្វែងរកការងារ។<br>– សិស្សរៀនរកព័ត៌មានសម្រាប់ការសិក្សានិងផែនការជីវិត[illegible]ប្រើលទ្ធភាពផ្តល់ដោយបច្ចេកវិទ្យាទំនា[illegible]ង និងព័ត៌មានព្រមទាំងប្រភពព័ត៌មា[illegible]ងៗ។<br>– សិស្សពង្រឹង[illegible]ះដឹងនៃជីវិតការងារដោយទទួលព័ត៌មា[illegible]លំទូលាយអំពីវិស័យមុខរបរ ផ្សេងៗ [illegible]ាមដានបញ្ហាដែលទាក់ទងនឹងការងារក្នុ[illegible]ន់ និងជីវិតសេដ្ឋកិច្ច។ | – ការអនុវត្តជំនាញស្វែងរកការងារ<br>– ការតម្រង់ទិសមុខរបរ<br>– ចំណេះដឹងនៃជីវិតការងារ<br>– ភាពជាសហគ្រិន<br>– ការផ្លាស់ប្តូរការងារ<br>– ការសរសេរពាក្យសុំការងារធ្វើ | | | – ការពិភាក្សាជាក្រុម និងសកម្មភាពផ្សេងៗក្នុងថ្នាក់រៀន<br>– សិក្ខាសាលា<br>– ការងារជាបុគ្គល<br>– ការប្រឹក្សាយោបល់ទល់មុខ (ទៅតាមសំណូមពរ)<br>– ការស្វែងរកព័ត៌មាន<br>– ការងារបណ្តាញ<br>– ដំណើរទស្សនកិច្ចសិក្សាទៅកាន់មជ្ឈមណ្ឌលការងារ សមាគម និងអង្គការក្រៅរដ្ឋាភិបាល<br>– ការអញ្ជើញវាគ្មិន |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| គោលដៅ | មាតិកាសំខាន់ៗ | ថ្នាក់ | ម៉ោង | វិធីសាស្ត្រ |
|---|---|---|---|---|
| **ការអប់រំ និងជម្រើសនៃអាជីព** | | 12 | | |
| – សិស្សទទួលការណែនាំឲ្យស្គាល់ពីបញ្ហាដែលមានសារៈសំខាន់ក្នុងការអភិវឌ្ឍអាជីព និងជំនាញរៀបចំផែនការ និងទទួលបាននូវជំនាញក្នុងការបន្តការសិក្សាកម្រិតខ្ពស់ និងឈានទៅរកជីវិតការងារ។ | – ការស្វែងរកព័ត៌មានបែបទំនើប ជម្រើសសម្រាប់បន្តការសិក្សានៅកម្ពុជា និងបរទេស<br>– ការអប់រំ និងបណ្តុះបណ្តាលផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ<br>– ការអប់រំនៅសាកលវិទ្យាល័យ<br>– ជម្រើសផ្សេងៗសម្រាប់បន្តការសិក្សាបន្ទាប់ពីវិទ្យាល័យ។ | | | ការពិភាក្សាជាក្រុម<br>និងសកម្មភាពផ្សេងៗក្នុងថ្នាក់រៀន<br>សិក្ខាសាលា<br>ការងារជាបុគ្គល<br>ការប្រឹក្សាយោបល់ទល់មុខ<br>(ទៅតាមសំណូមពរ) |
| – សិស្សប្រមូលព័ត៌មានអំពីការអប់រំ និងការបណ្តុះបណ្ត ... ដែលត្រូវការចាំបាច់សម្រាប់អា ... វលគ្រោងទុកនាពេលអនាគត និ ... ពួកគេឲ្យរៀបចំផែនការសម្រាប់ផ្លូវ ... ។<br>– សិស្សស្វែង ... ពីជម្រើសនៃអាជីពផ្សេងៗដែលពាក់ព័ ... វិស័យ។<br>– សិស្សអាច ... ពីជំហានបន្ទាប់ដែលត្រូវការដើម្បីចូ ... ក្សា និងផ្លូវអាជីពបន្ទាប់ពីសាលា។<br>– សិស្សអា ... ប្រភពព័ត៌មានផ្សេងៗ | – ការស្វែងរកជម្រើសនៃការអប់រំ<br>– ផែនការបន្ទាប់ពីសាលាថ្មីៗ<br>– ផែនការបន្ទាប់បន្សំ<br>– ការសង្ខេបនៃផែនការអាជីព និងការអប់រំ<br>– ដំណើរការដាក់ពាក្យបន្តការសិក្សា | | | ការស្វែងរកព័ត៌មាន<br>ការងារបណ្តាញ:<br>– ដំណើរទស្សនកិច្ចសិក្សាទៅកាន់មជ្ឈមណ្ឌលការងារ សមាគម និង អង្គការក្រៅរដ្ឋាភិបាល<br>– ការអញ្ជើញវាគ្មិន |

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

| | | | | |
|---|---|---|---|---|
| រួមមាន ឱកាសប្រើ ICT ដើម្បីគាំទ្រការសិក្សា និងការរៀបចំផែនការអាជីព។<br>– សិស្សស្គាល់វិទ្យាស្ថានដែលផ្តល់ឱកាសក្នុងបន្តការសិក្សា។<br>– សិស្សទទួលការណែនាំពីដំណើរការនៃការដាក់ពាក្យសុំការងារធ្វើ។ | | | | |
| **ការណែនាំឲ្យស្គាល់ពីជីវិតការងារ (ជាជម្រើស)** | | 12 | 20 – 40 | |
| សិស្សគាំទ្រជម្រើសនៃការអប់រំ និងអាជីពរបស់ពួកគេ ហើយពង្រឹងការគោរពការងារ ដោយទទួលនូវបទពិសោធន៍ផ្ទាល់នៃជីវិតការងារ និងមុខរបរនៅក្នុងបរិយាកាសការងារពិតប្រាកដ។ | – បង្កើតផែនការសម្រាប់មុខវិជ្ជា (គោលបំណង គោលដៅ មាតិកា តារាងកាលវិភាគ ។ល។)<br>– ការស្គាល់មុខរបរនៅក្នុងបរិស្ថានការងារពិតប្រាកដ<br>– ការវាយតម្លៃនៃព័ត៌មាន និងបទពិសោធន៍ដែលទទួលបាន។ | | | សកម្មភាពបន្ទាប់ពីសាលារៀន |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៧
# ការប្រឹក្សាយោបល់ការសិក្សា
# និងបញ្ហាផ្ទាល់ខ្លួន

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ៧. ការប្រឹក្សាយោបល់ការសិក្សា និងបញ្ហាផ្ទាល់ខ្លួន

### គោលបំណង

1. ជួយសិស្សឲ្យបន្តការសិក្សាបានត្រឹមត្រូវ។ ចំណុចនេះមានន័យថា សិស្សម្នាក់ត្រូវបានលើកទឹកចិត្តឲ្យបង្កើនការចូលរួមរបស់ខ្លួនក្នុងសង្គមបានច្រើន។
2. ជំរុញសិស្សម្នាក់ៗឲ្យចេះសម្រេចចិត្តអំពីផ្លូវសិក្សារបស់ខ្លួន។ ពួកគេត្រូវតែស្គាល់ជម្រើសទាំងឡាយ ដែលពួកគេនឹងជ្រើស ហើយចេះកំណត់ថាតើជម្រើសទាំងនោះជាជម្រើសរវាងមុខវិជ្ជាសិក្សា កម្មវិធីសិក្សា ឬសាលារៀន។ ពួកគេត្រូវដឹងអំពីជម្រើស និងការរួមបញ្ចូលមុខវិជ្ជា តើមុខវិជ្ជានោះពាក់ព័ន្ធនឹងអ្វីខ្លះនៅក្នុងថ្នាក់រៀន មុខវិជ្ជាដែលអាចរៀនបាន តើមុខវិជ្ជានីមួយៗនាំឲ្យគេយល់ដឹងពីអ្វី សាលារៀនដែលអាចរៀនបាន លក្ខខ័ណ្ឌតម្រូវដើម្បីចុះឈ្មោះចូលរៀន និងឱកាសពាក់ព័ន្ធនឹងការអប់រំផ្សេងៗទៀត។
3. សម្របសម្រួលការផ្ទេរសិស្សបានរលូនពីបឋមភូមិ ទៅទុតិយភូមិ និងពីទុតិយភូមិទៅស្ថាប័នក្រោយមធ្យមសិក្សា និងពិភពការងារ។ ការផ្ទេរចុងក្រោយពីប្រព័ន្ធអប់រំទៅជាកម្លាំងពលកម្ម ហាក់ដូចជាសំខាន់ជាងគេបង្អស់ ហើយក៏ជាបញ្ហាប្រឈមជាងគេបំផុតដែរចំពោះសិស្ស។
4. ជួយសិស្សឲ្យចេះដោះស្រាយចំពោះក្តីបារម្ភក្នុងពេលប្រឡង។ ការភ័យខ្លាចប្រឡងធ្លាក់ និងការចង់បានពិន្ទុខ្ពស់បំផុត គឺជាប្រភពដ៏សំខាន់ ដែលនាំឲ្យមានសម្ពាធក្នុងចំណោមសិស្សានុសិស្សទាំងអស់។
5. ជួយឲ្យសិស្សចេះបង្កើតទម្លាប់សិក្សាល្អ និងមានប្រសិទ្ធភាព។ សិស្ស ត្រូវបានជួយអភិវឌ្ឍសមត្ថភាពអំណាន ការកត់សម្គាល់អំពីលទ្ធផលសិក្សាជាដើម។
6. ជំរុញទឹកចិត្តសិស្សឲ្យក្លាហានក្នុងការចែករំលែកនូវបញ្ហាផ្ទាល់ខ្លួន ដូចជា *បញ្ហាខឹងក្រោធ បញ្ហាទំនាស់ បញ្ហាទុក្ខព្រួយ បញ្ហាទំនាក់ទំនងផ្សេងៗ ការឲ្យតម្លៃខ្លួនឯងទាប ការបាក់ទឹកចិត្ត ការរងធ្វើបាប ឬអំពើហិង្សា* ជាដើម ដើម្បីផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់ពួកគេ។

## ៧. ការប្រឹក្សាយោបល់ការសិក្សា និងបញ្ហាផ្ទាល់ខ្លួន

### ៧.១. ការប្រឹក្សាយោបល់ការសិក្សា

#### សិស្សរៀន

- របៀបធ្វើការងារក្នុងសហគមនៃសាលារៀន
- ឯករាជ្យ និងទំនួលខុសត្រូវ
- ជំនាញសហប្រតិបត្តិការ និងទំនាក់ទំនង

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

– អភិវឌ្ឍជំនាញសិក្សា និងជំនាញវង្វាយតម្លៃខ្លួនឯង
– ប្រើវិធីសាស្ត្រសិក្សាផ្សេងៗ
– អភិវឌ្ឍយុទ្ធសាស្ត្រសិក្សារបស់ពួកគេរៀងខ្លួន

**គំនិតចម្បងក្នុងការប្រឹក្សាយោបល់ផ្នែកសិក្សាគឺ៖**

១. ជីវិតនៅអនុវិទ្យាល័យ/ ជីវិតនៅវិទ្យាល័យ

២. បំណិន និងបច្ចេកទេសសិក្សា

គំនិតចម្បងទាំងនេះត្រូវបានបែងចែកជាគំនិតបន្ទាប់បន្សំដែលអាចប្រើជាកញ្ចប់មេរៀន ឬអាចបែងចែកទៅជាស៊េរីនៃ មេរៀនយោងតាមខ្លឹមសារនៃមេរៀន។

គោលការណ៍ណែនាំសម្រាប់លោកគ្រូអ្នកគ្រូចាប់ផ្តើមដោយណែនាំសិស្សឲ្យស្គាល់ពីគំនិតចម្បង។ គោលបំណងគឺជួយគ្រូ ដើម្បីណែនាំសិស្សឲ្យស្គាល់ពីប្រធានបទ។ គោលការណ៍ណែនាំក៏អាចរួមមានសំណួរ កិច្ចពិភាក្សាដើម្បីធ្វើការតំរង់ទិស ដល់សិស្សអំពី ចំណុច សំខាន់ៗ និងការពន្យល់សកម្មភាពរបស់សិស្ស។ វិធីសាស្ត្រដែលប្រើក្នុងការប្រឹក្សាយោបល់ ផ្នែកសិក្សាគឺ ទូលំទូលាយណាស់: ការឆ្លុះបញ្ចាំងរបស់បុគ្គលម្នាក់ៗ ការពិភាក្សាជាក្រុមតូចៗ ការចែករំលែកលទ្ធផលរុងកិច្ចពិភាក្សា ជាក្រុមធំ សំណួរ និងចំលើយ ការបំផុសគំនិត និងសកម្មភាពរួសរវើកផ្សេងទៀតរួចជាការរៀបចំប័ណ្ណប្រកាស។ យើងអាចផ្តល់សន្លឹកកិច្ចការ ដល់សិស្សដែលមានចែងក្នុងគោលការណ៍ណែនាំតែប៉ុណ្ណោះ។

**សំគាល់!** មានសកម្មភាពជាច្រើនប្រភេទនៅក្នុងកញ្ចប់មេរៀននីមួយៗ។ មិនចាំបាច់យកវាទាំងអស់មកប្រើជាមួយសិស្សឡើយ។ អ្នកអាចជ្រើសយកសកម្មភាពទៅតាមតម្រូវការបច្ចុប្បន្នរបស់សិស្ស កំរិតថ្នាក់ ជំនាញរបស់សិស្ស ការមានសម្ភារៈផ្គត់ផ្គង់គ្រប់គ្រាន់ ។ល។ អ្នកក៏អាចកែប្រែ និងប្រើប្រាស់លំហាត់ ព្រមទាំងសន្លឹកកិច្ចការដើម្បីតម្រូវចិត្តរបស់អ្នកបានដែរ។

**៧.១.១ ជីវិតនៅអនុវិទ្យាល័យ**

**ការណែនាំសម្រាប់គ្រូ**

ជាការសំខាន់ណាស់ដែលសិស្សទទួលបានការគាំទ្រ និងការណែនាំទៅតាមដំណាក់កាលផ្លាស់ប្តូរផ្សេងៗនៃផ្លូវសិក្សារបស់គេ។ ការផ្លាស់ប្តូរពីបឋមសិក្សាទៅអនុវិទ្យាល័យ អាចបណ្តាលឲ្យមានអារម្មណ៍ច្រើនយ៉ាងគឺ ពីការរំភើប និងសប្បាយ ទៅជាភាពឯកោ។អនុវិទ្យាល័យ គឺធំជាងបឋមសិក្សា ហើយអាចស្ថិតនៅឆ្ងាយពីផ្ទះ។ មានមុខវិជ្ជាថ្មីដែលត្រូវសិក្សាផងដែរ។ សប្តាហ៍ដំបូងអាចមានភាពងាយរងគ្រោះសំរាប់សិស្សមួយចំនួន និងជាបទពិសោធន៍អវិជ្ជមាន ឬអារម្មណ៍នៃការខ្វះខន្លោះ អាចនាំទៅរកការបោះបង់ការសិក្សា។

ការផ្លាស់ប្តូរប្រកបដោយសុវត្ថិភាពសំរាប់សិស្សពីបឋមសិក្សាទៅអនុវិទ្យាល័យគឺត្រូវមានការគាំទ្រពីគ្រូបង្គោល ប្រឹក្សាអាជីព ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនាយកសាលា និង

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

លោកគ្រូអ្នកគ្រូផ្សេងទៀត។ ដើម្បីធានាការផ្លាស់ប្តូរប្រកបដោយសុវត្ថិភាព គ្រូប្រឹក្សាអាជីពអាចធ្វើទស្សនៈកិច្ចទៅកាន់សាលាបឋមសិក្សាក្នុងស្រុក ហើយប្រាប់អំពីការអប់រំនៅអនុវិទ្យាល័យដល់សិស្សថ្នាក់ទី៦។ គេអាចរៀបចំឲ្យមានថ្ងៃទំនេរណាមួយ ហើយនាំសិស្សទៅលេងអនុវិទ្យាល័យទាំងនោះ។ លើសពីនេះ វាមានសារៈសំខាន់ណាស់ក្នុងការធ្វើសហប្រតិបត្តិការ និងចែករំលែកព័ត៌មានដល់លោកគ្រូអ្នកគ្រូប្រចាំសាលាបឋមសិក្សា ហើយសារៈសំខាន់របស់មាតាបិតា ឬអាណាព្យាបាល និងលោកគ្រូអ្នកគ្រូដែលធ្វើការរួមគ្នាដើម្បីការអប់រំរបស់កូន មិនអាចមិនយកចិត្តទុកដាក់បានឡើយ។ គ្រូបង្គោលប្រឹក្សាអាជីពមានតួនាទីសំខាន់ក្នុងការស្វែងរកមធ្យោបាយដែលសិស្សធំអាចជួយដល់ការសិក្សារបស់ក្មេងបាន។

ក្នុងអំឡុងពេលនៃសប្តាហ៍ដំបូងបង្អស់ សិស្សថ្នាក់ទី៧ ត្រូវការការតំរង់ទិសសំរាប់ជីវិតនៅអនុវិទ្យាល័យ។ មានការអនុវត្តន៍ជាក់ស្តែងជាច្រើន ដែលខុសពីការអនុវត្តន៍នៅសាលាបឋមសិក្សា។ នៅពេលដែលដឹងថាត្រូវធ្វើយ៉ាងណា នៅ ក្នុងសហគមនៃសាលារៀន វាមានភាពងាយស្រួលសំរាប់សិស្សក្នុងការធ្វើការផ្លាស់ប្តូរ។

កញ្ចប់មេរៀន *ជីវិតនៅអនុវិទ្យាល័យ* អាចបែងចែកជាស៊េរីនៃមេរៀន ហើយវាមានខ្លឹមសារបន្ទាប់បន្សំដូចខាងក្រោម៖

១) ការស្វាគមន៍មកកាន់អនុវិទ្យាល័យ
២) បទបញ្ជាផ្ទៃក្នុងសាលា
៣) ទំនួលខុសត្រូវរបស់សមាជិកក្នុងក្រុម
៤) ការសិក្សានៅអនុវិទ្យាល័យ
៥) ការវាយតម្លៃ និងការដាក់ពិន្ទុ

### ៧.១.២ ការស្វាគមន៍មកកាន់អនុវិទ្យាល័យ

### គោលការណ៍ណែនាំសំរាប់គ្រូ

ដើម្បីធានាការផ្លាស់ប្តូរប្រកបដោយសុវត្ថិភាពទៅកាន់អនុវិទ្យាល័យ និងសម្រប សម្រួលដល់វិហានរបស់សិស្សក្នុងការជ្រើសរើសផ្លូវសិក្សា វាមានសារៈសំខាន់ ក្នុងការជ្រើសយក ប្រធានបទដូចខាងក្រោមមកបង្រៀនសិស្ស នៅដើមឆ្នាំសិក្សា៖

– អារម្មណ៍ និងចំណាប់អារម្មណ៍ដំបូង
– ការផ្លាស់ប្តូរ និងបញ្ហាប្រឈម
– ការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ និងការដោះស្រាយបញ្ហាប្រឈម
– មនុស្សគាំទ្រការសិក្សា ការសិក្សា និងជីវិតនៅសាលារៀន

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

– សារៈសំខាន់នៃការអប់រំ

ការពិភាក្សា និងការចែករំលែកគ្នានូវលទ្ធផលនៃសកម្មភាពសិស្សគឺជាការកសាងទំនុកចិត្ត និងពង្រឹងការប្តេជ្ញាចិត្តក្នុងការសិក្សាជាមួយគ្នា។

**សកម្មភាពសិស្ស ទី១**

ចូរផ្តល់ច្បាប់ចម្លងនៃសន្លឹកកិច្ចការទី១ ទៅឲ្យសិស្សម្នាក់ៗ ឬសរសេរសំណួរនៅលើក្តារ។ (សន្លឹកកិច្ចការទី១/ ការស្វាគមន៍មកកាន់អនុវិទ្យាល័យ)

ជំហានទី១ «*ការឆ្លុះបញ្ចាំងរបស់បុគ្គល*»

ចូរប្រាប់សិស្សឲ្យគិតអំពីសំណួរដោយហ្មត់ចត់ និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកសរសេរចម្លើយនៅលើសន្លឹកកិច្ចការ ឬសៀវភៅកំណត់ត្រា។ ចូរផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សិស្សដើម្បីបញ្ចប់លំហាត់។ សំរាប់សិស្សមួយចំនួន គេអាចមានភាពលំបាកក្នុងការបញ្ចេញអារម្មណ៍ និងចំណាប់អារម្មណ៍ដំបូងរបស់ពួកគេភ្លាមៗ។

ជំហានទី២ «*ការងារជាដៃគូ*»

ប្រាប់សិស្សឲ្យចាប់ដៃគូដើម្បីចែករំលែក ពិភាក្សាពីអារម្មណ៍ និងបទពិសោធន៍របស់ពួកគេ។ ចូរផ្តល់ពេលយ៉ាងហោច១០នាទីសម្រាប់ការពិភាក្សាជាដៃគូនេះ។

ជំហានទី៣ «*ការចែករំលែកលទ្ធផលក្នុងកិច្ចពិភាក្សាជាក្រុមធំ*»

បន្ទាប់មក ចូរឲ្យសិស្សចែករំលែកពីអារម្មណ៍ បទពិសោធន៍ និងគំនិតជាមួយគ្នានៅក្នុងក្រុមធំ។ ជាការល្អក្នុងការជ្រើសយកគ្រូ ឬសិស្សម្នាក់ឲ្យធ្វើជាអ្នកដឹកនាំកិច្ចពិភាក្សា។ ចូរសង្ខេបលទ្ធផលនៃសកម្មភាពដោយសរសេរគំនិតសំខាន់ៗនៅលើក្តារ។ ចូរប្រើកូឡោន ឬប្រអប់អត្ថបទដើម្បីបែងចែកចំលើយទៅតាមសំណួរខុសៗគ្នា។

សូមផ្តល់ជាអនុសាសន៍ថា បន្ទាប់ពីសកម្មភាពនេះ គ្រូត្រូវប្រាកដថាគ្រប់គ្នាមានអារម្មណ៍ធម្មតា ហើយសិស្សមិនមានព័ត៌មានយល់ច្រឡំអំពីការសិក្សានៅអនុវិទ្យាល័យ។

ឧទាហរណ៍:

- ចូរផ្តល់ភាពងាយស្រួលដល់សិស្សដោយនិយាយថា ការមានអារម្មណ៍ផ្សេងៗអំពីការសិក្សានៅអនុវិទ្យាល័យជារឿងធម្មតា
- និយាយសង្ខេបអំពីភាពខុសគ្នាចម្បងរវាងការសិក្សានៅបឋមសិក្សា និងអនុវិទ្យាល័យ
- ចូរផ្តល់ដំបូន្មានក្នុងការដោះស្រាយបញ្ហាប្រឈម
- និយាយត្រួសៗអំពីទំនួលខុសត្រូវមួយចំនួនរបស់សិស្សនៅកម្រិតអនុវិទ្យាល័យ
- សង្កត់ធ្ងន់លើសារៈសំខាន់នៃការអប់រំ និងលទ្ធផលនៃការរៀនសូត្រ និងការទទួលបាននូវជំនាញ និងចំណេះដឹង

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**សកម្មភាពសិស្ស ទី២**

ចូរផ្តល់ច្បាប់ចម្លងនៃសន្លឹកកិច្ចការទី២ ទៅឲ្យសិស្សម្នាក់ៗ (សន្លឹកកិច្ចការទី២/ ការស្វាគមន៍មកកាន់អនុវិទ្យាល័យ)។ ជាជម្រើស ចូរសរសេរកិច្ចការនៅលើក្តារ ឬអានវាឲ្យខ្លាំង ហើយប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹក រួច គូររូបមនុស្សមួយក្រុមតូច (បិទរូបភាពក៏បានដែរ) នៅចំកណ្តាលក្រដាស់នោះ។

**ជំហានទី១ «*ការឆ្លុះបញ្ចាំងរបស់បុគ្គល*»**

ចូរប្រាប់សិស្សឲ្យគិតអំពីសំណួរដោយហ្មត់ចត់ និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកសរសេរចំណាងជើង និង/ឬឈ្មោះរបស់មនុស្សដែលអាចជួយដល់ការសិក្សារបស់ពួកគេ ការសិក្សា និងជីវិតនៅអនុវិទ្យាល័យ ជុំវិញរូបភាពនោះ។ ចូរផ្តល់ពេលគ្រប់គ្រាន់ដល់សិស្សដើម្បីបំពេញកិច្ចការនេះ។

**ជំហានទី២ «*ការងារជាដៃគូ*»**

ចូរប្រាប់សិស្សឲ្យចាប់ដៃគូ ហើយប្រៀបធៀបបញ្ជីរបស់ពួកគេ។ តើមានមនុស្សប៉ុន្មាននាក់ដែលចុះក្នុងបញ្ជីដូចគ្នា?

**ជំហានទី៣ «*ការចែករំលែកលទ្ធផលនៅក្នុងការពិភាក្សាជាក្រុមធំ*»**

រន្ទាប់មក ចែករំលែកលទ្ធផលនៃសកម្មភាពនៅក្នុងការពិភាក្សាក្នុងថ្នាក់។ ចូរឲ្យសិស្សប្រាប់ពីរម្លើយ ហើយសរសេរចំលើយនោះនៅលើក្តារខៀន។

**ជំហានទី៤ «*បច្ចុប្បន្នភាពរបស់គ្រូ*»**

រន្ទាប់ពីការពិភាក្សាជាក្រុមធំ ចូរបន្ត និងបន្ថែមមនុស្សទៅក្នុងបញ្ជីដែលអ្នកគិតថាមិនទាន់មានឈ្មោះ។ មានមនុស្សជាច្រើន ដែលអាចជួយសិស្ស ឧទាហរណ៍ គ្រូប្រឹក្សាអាជីព គ្រូផ្សេងៗ នាយកហលា ពេទ្យប្រចាំ សាលា មិត្តភ័ក្តិ សមាជិកគ្រួសារ ឬសាច់ញាតិ មនុស្សនៅក្បែរផ្ទះអ្នក ។ល។ រុងក្រោយ ប្រាប់សិស្សថាគេអាចសុំជំនួយពីអ្នកបាន! តួនាទីរបស់អ្នកប្រឹក្សាអាជីពគឺជួយគាំទ្រពួកគ និងផ្តល់ដំបូន្មានដល់ពួកគេចំពោះអ្នកដែលគេអាចទាក់ទងដើម្បីសុំជំនួយបន្ថែម។

**សន្លឹកកិច្ចការទី១ « ការស្វាគមន៍មកកាន់អនុវិទ្យាល័យ»**




សូមស្វាគមន៍មកកាន់អនុវិទ្យាល័យ! អ្នកបានរៀនជំនាញ និងទទួលបាន ចំណេះដឹង យ៉ាងច្រើននៅសាលាបឋមសិក្សា។ ឥឡូវនេះរកមានឱកាសរៀនសូត្របន្ថែមទៀត។ អ្នកនឹងបង្កើតមិត្តថ្មីជាច្រើនទៀត និងចែករំលែក ដំណើរ នៃការសិក្សាជាមួយពួកគាត់។

ដំបូង អ្នកអាចមានការរំភើបជាខ្លាំងចំពោះការសិក្សានៅអនុវិទ្យាល័យ ហើយមានក្តីរំពឹងទុក ជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ ការចាប់ផ្តើមសិក្សានៅ សាលាថ្មីរាចបណ្តាល ឲ្យមានអារម្មណ៍ភ័យព្រួយ ឬឯការ។ មានការផ្លាស់ប្តូរជាច្រើន ចំពោះការអនុវត្តន៍នៅរាមសាលារៀន និងមានមុខវិជ្ជាថ្មីៗដែលត្រូវរៀន។ ប្រហែល អនុវិទ្យាល័យអាចធំជាងសាលាបឋម

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

សិក្សារបស់អ្នក ហើយវានៅឆ្ងាយពីផ្ទះរបស់អ្នក។ ជាការប្រសើរដែលអ្នកបញ្ចេញយោបល់ និង អារម្មណ៍ជាមួយមិត្តរួមថ្នាក់របស់អ្នក!

ចូរគិតអំពីសំណួរដោយប្រុងប្រយ័ត្ន បន្ទាប់មកសរសេរចម្លើយរបស់អ្នក។

អ្នកទើបតែបញ្ចប់ការសិក្សានៅសាលាបឋម ហើយផ្លាស់មករៀននៅអនុវិទ្យាល័យ តើអ្នកមាន អារម្មណ៍ដូចម្តេចដែរ?

តើអនុវិទ្យាល័យខុសពីបឋមសិក្សាដូចម្តេចដែរ? តើចំណាប់អារម្មណ៍របស់អ្នកជាលើកដំបូងដូចម្តេចខ្លះ?

តើមានការផ្លាស់ប្តូរបែបវិជ្ជមានដែរទេ? ចូរនិយាយអំពីការប្រែប្រួលមួយចំនួន។

តើការផ្លាស់ប្តូរបែបណាដែលអ្នកយល់ថាពិបាកដោះស្រាយ?

តើអ្នកអាចដោះស្រាយបញ្ហាប្រឈមទាំងនេះបានទេ? ចូរឲ្យដំបូន្មានដល់ខ្លួនឯង។

ហេតុអ្វីបានជាការទៅសាលារៀន និងរៀនមានសារៈសំខាន់?

តើអ្នកមានទំនួលខុសត្រូវបន្ថែមលើការសិក្សាដែរទេ? បើមាន តើទំនួលខុសត្រូវបែបណាខ្លះ?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**សន្លឹកកិច្ចការទី២ «ការស្វាគមន៍មកកាន់អនុវិទ្យាល័យ»**

យើងទាំងអស់គ្នាអាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូរដោយមធ្យោបាយផ្សេងៗគ្នា។ អ្នកខ្លះអាចសម្របខ្លួនយ៉ាងងាយស្រួលដោយខ្លួនឯង ប៉ុន្តែអ្នកផ្សេងទៀតត្រូវការជំនួយ និងការជ្រោមជ្រែង។ ទោះជាយ៉ាងណាក្តី មានមនុស្សនៅសាលារៀន នៅផ្ទះ ឬនៅក្បែរអ្នកដែលអាចជួយគាំទ្រដល់ការសិក្សារបស់អ្នក និងជីវិតនៅសាលារៀនបាន។

តើនរណាអាចជួយដល់ការសិក្សារបស់អ្នក និងជីវិតនៅសាលារៀនបាន? ចូរសរសេរជុំវិញរូបភាព:



(សន្លឹកកិច្ចការនេះជាទម្រង់លំហាត់ដែលណែនាំដោយ ហោកគីណិន គូរ៉ូណិន វ៉ាលូទី ២០១៥)

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

### ៧.១.៣ បទបញ្ជាផ្ទៃក្នុង

### ក. សិស្សដែលមានទំនួលខុសត្រូវ

### គោលការណ៍ណែនាំសម្រាប់គ្រូ

នៅដើមឆ្នាំសិក្សាថ្មី វាមានសារៈសំខាន់ណាស់ក្នុងការពិភាក្សាអំពីការទទួលខុសត្រូវរបស់សិស្សនៅសាលារៀន។ សកម្មភាព ខាងក្រោមនេះ រៀបរាប់ពីការអនុវត្តន៍មួយចំនួន និងបទបញ្ជាសាលាដែលធានានូវ វិន័យវិជ្ជមាននៅក្នុងថ្នាក់ និងជួយសម្រួលដល់ការសិក្សា។

សកម្មភាពសិស្សទី១ «សម្ភារចាំបាច់របស់សាលារៀន»

ចូរផ្តល់សន្លឹកកិច្ចការទី៣ មួយច្បាប់ ទៅឲ្យសិស្សម្នាក់ៗ។ ជាជម្រើស ចូរសរសេរកិច្ចការនៅ លើក្តារខៀន ឬអានវាឲ្យខ្លាំង ហើយប្រាប់សិស្សឲ្យសរសេរក្នុងសៀវភៅកំណត់ត្រារបស់គេ។ (សន្លឹកកិច្ចការទី៣/ បទបញ្ជាផ្ទៃក្នុង)។

១)ប្រាប់សិស្សឲ្យសរសេរឬគូរសម្ភារៈសាលាទាំងអស់ដែលពួកគេគិតថាសំខាន់ និងជួយបម្រួលដល់ការសិក្សា)

២) បន្ទាប់មក អនុញ្ញាតឲ្យសិស្សចែករំលែកគំនិត នៅក្នុងការពិភាក្សាជាក្រុមធំនៅក្នុងថ្នាក់។ ប្រមូលគំនិត ហើយសរសេរវានៅលើក្តារខៀន។

ជាជម្រើស អនុញ្ញាតឲ្យសិស្សធ្វើការជាដៃគូ ឬជាក្រុមតូច ដើម្បីបំផុសគំនិតអំពីសម្ភារៈសាលាដែលចាំបាច់ ហើយរៀបចំបណ្ណប្រកាសដោយមានរូបភាពសម្ភារៈទាំងនេះ។ ដើរយឺតជុំវិញថ្នាក់ម្តងម្កាល ពិនិត្យមើលនូវរបៀបពិភាក្សារបស់សិស្ស និងផ្តល់យោបល់អំពីសម្ភារសំខាន់ៗ បើចាំបាច់។

សកម្មភាពសិស្សទី២ «បន្តប្រយោគ»

ចូរប្រគល់ សន្លឹកកិច្ចការទី៤មួយច្បាប់ ទៅឲ្យសិស្សនីមួយៗ។ ជាជម្រើស សរសេរកិច្ចការនៅលើក្តារខៀន ឬអានវាឲ្យខ្លាំង ហើយប្រាប់សិស្សឲ្យសរសេរចម្លើយ នៅក្នុងសៀវភៅកំណត់ត្រារបស់គេ (សន្លឹកកិច្ចការទី៤ / បទបញ្ជាផ្ទៃក្នុង)។

១) ប្រាប់សិស្សឲ្យធ្វើម្នាក់ឯង អានប្រយោគ និងសរសេរតដោយប្រើគំនិតរបស់ពួកគេផ្ទាល់។

២) ដើម្បីចែករំលែកនូវលទ្ធផលនៃសកម្មភាពនេះ អនុញ្ញាតឲ្យសិស្សពិភាក្សាជាក្រុមធំនៅក្នុងថ្នាក់ និងប្រាប់អំពីគំនិត និងយោបល់របស់ពួកគេ។ បើចាំបាច់ ផ្តោតលើបញ្ហាខាងក្រោម៖

- ប្រភេទត្រឹមត្រូវនៃសម្ភារៈសាលាគឺ ជួយសម្រួលដល់ការសិក្សា
- សារៈសំខាន់នៃកាលវិភាគ និងការមករៀនទាន់ពេលវេលា
- អត្ថប្រយោជន៍នៃការធ្វើឲ្យបន្ទប់រៀនស្អាត

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

– មូលហេតុនៃការថែរក្សាសៀវភៅ និងសម្ភារៈសិក្សាផ្សេងៗ។

## ខ. បរិស្ថានសាលារៀនដែលស្ងប់ស្ងាត់

### គោលការណ៍ណែនាំសំរាប់គ្រូ

ចូរចែករំលែកសេចក្តីផ្តើមនៃប្រធានបទខាងក្រោមជាមួយសិស្សរបស់អ្នក។

សាលារៀនជាកន្លែងធ្វើការសម្រាប់គ្រូ និងសិស្ស។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបាននូវបរិស្ថានសិក្សា ការងារប្រកបដោយសុវត្ថិភាព ការគាំទ្រ និងភាពស្ងប់ស្ងាត់។ យើងត្រូវគិតគូរដល់មនុស្សដទៃ និងគោរពសិទ្ធិរបស់គេ។ ការធ្វើចិត្តទូលាយ ការចេះគិតដល់ដទៃ និងការជួយយកអាសារគេ មិនចំណាយលុយកាក់ច្រើនឡើយ ប៉ុន្តែគេទទួលបានជោគជ័យច្រើន។ បរិយាកាសល្អអាចជួយសម្រួលដល់ការសិក្សា។ ផ្ទុយទៅវិញ បរិយាកាសមិនអំណោយផលពិតជារារាំង និងធ្វើឲ្យឱកាសនៃការសិក្សាចុះខ្សោយ។ ដើម្បីធានាការអប់រំប្រកបដោយសុវត្ថិភាព និងការសិក្សាប្រកបដោយការគាំទ្រ សាលារៀនត្រូវមានបទបញ្ជាផ្ទៃក្នុង និងការអនុវត្តន៍ច្បាស់លាស់។ មនុស្សគ្រប់រូបគួរតែអនុវត្ត និងរក្សាបទបញ្ជាទាំងនេះ។

សិស្សរាល់គ្នានៅក្នុងថ្នាក់មានទំនួលខុសត្រូវចំពោះការបង្កើតបរិយាកាសសាលារៀន ប្រកបដោយភាពស្ងប់ស្ងាត់។ មានពេលវេលាដែលសិស្សត្រូវយកចិត្តទុកដាក់ ស្តាប់ដោយស្ងៀមស្ងាត់ និងអង្គុយនៅនឹងកន្លែង។ ការសិក្សាអាចពាក់ព័ន្ធនឹងការពិភាក្សា និងសកម្មភាពដ៏រួសរវើក។ ហើយបន្ទាប់មក ការចងចាំក្នុងចិត្ត ថានៅជុំវិញយើងមានមនុស្សផ្សេងទៀត ពិតជាមានសារៈសំខាន់។

### សកម្មភាពសិស្សទី ១

បំបែកសិស្សជាបួនក្រុមដែលមានមនុស្ស៤ – ៥ នាក់ ហើយចែករំលែកគំនិត និងអារម្មណ៍ចំពោះបរិស្ថានសាលារៀនប្រកបដោយភាពស្ងប់ស្ងាត់ជាមួយសមាជិកក្រុម។

### សំណួរពិភាក្សា

– តើអ្នកមានបរិយាកាសសិក្សាប្រកបដោយភាពស្ងៀមស្ងាត់ដែរទេ? ចូរផ្តល់ឧទាហរណ៍ដែលរៀបរាប់ពីអ្វីដែលធ្វើឲ្យវាស្ងប់ស្ងាត់ / មិនស្រួល និងមិនស្ងប់។
– តើអ្នកបង្កើត និង ថែរក្សាបរិស្ថានដ៏ស្ងប់ស្ងាត់ដោយរបៀបណា?
– តើពេលណាសមរម្យសំរាប់ការនិយាយឡូឡា និងធ្វើការខ្លាំងៗនៅបន្ទប់រៀនបាន?
– តើអ្នកធ្វើដូចម្តេចនៅពេលដែលមិត្តរបស់អ្នកចង់និយាយជាមួយអ្នក ប៉ុន្តែអ្នកចង់ផ្តោតអារម្មណ៍លើការបង្រៀន?

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

**សកម្មភាពសិស្សទី២**

ចូរធ្វើការក្នុងក្រុមតូច ហើយបំផុសគំនិតរកមធ្យោបាយដើម្បីធ្វើឲ្យបរិស្ថានសាលារៀនរបស់អ្នកកាន់តែមានភាពស្ងប់ស្ងាត់។ ចូរបង្កើតបញ្ជីអនុសាសន៍។

## គ. ការសម្លុត និងការលលេង

## គោលការណ៍ណែនាំសម្រាប់គ្រូ

**សកម្មភាពសិស្សទី១**

ចូរពិភាក្សានៅក្នុងថ្នាក់ជាមួយសិស្សរបស់អ្នក។

សំណួរពិភាក្សា

- អ្វីជាការសម្លុត?
- តើការសម្លុត និងការនិយាយលេងខុសគ្នាដូចម្ដេច? ចូរឲ្យឧទាហរណ៍។

ចូរចែករំលែកសេចក្ដីផ្ដើមនៃប្រធានបទខាងក្រោមជាមួយសិស្សរបស់អ្នក។

ជួនកាលវាពិបាកដឹងថាអ្វីជាការសម្លុត និងអ្វីពុំមែនជាការសម្លុត។ ជាញឹកញាប់សកម្មភាពផ្ដើមចេញពីការសប្បាយ ប៉ុន្តែចំណុចណាមួយពិតជាអាចប្រែក្លាយទៅជាការសម្លុតតែម្ដង។ អ្នករាល់គ្នាមានសិទ្ធិទទួលបាននូវអារម្មណ៍សុវត្ថិភាពនៅសាលារៀន។ គ្មាននរណាម្នាក់ត្រូវគេអនុញ្ញាតឲ្យធ្វើបាបអ្នកដទៃទាំងផ្លូវកាយ ឬផ្លូវចិត្តឡើយ។ ការហៅឈ្មោះ ការរុញ ការវាយ និងការទាត់ធាក់ ជាសកម្មភាពដែលមិនត្រឹមត្រូវ។ ការមិនរាប់បញ្ចូលនរណាម្នាក់ក្នុងសកម្មភាព ការសន្ទនា ឬការងារជាក្រុម និងការនិយាយដើមគេបែបចំអក ក៏ជាការសម្លុតដែរ។

មនុស្សយើងទាំងអស់គឺខុសៗគ្នា។ ពួកគេមើលទៅផ្សេងពីគ្នា និងមានទម្លាប់ ជំនឿ និងមតិមិនដូចគ្នាទេ។ មនុស្សយើងក៏មានជំនាញ និងសមត្ថភាពផ្សេងគ្នាដែរ។ ការខុសគ្នាគឺជាឱកាស វាជាភាពខ្លាំងរបស់យើង មិនមែនជាភាពខ្សោយឡើយ។

**សកម្មភាពសិស្សទី២**

ចូរធ្វើការជាក្រុមតូចៗ និងចែករំលែកគំនិត និងអារម្មណ៍របស់អ្នក។

**សំណួរពិភាក្សា**

- តើសិស្សនៅក្នុងសាលារៀនរបស់អ្នកធ្លាប់ទទួលការរិះគន់ដែរទេ? តើគេរិះគន់ពីអ្វី (រូបសម្បត្តិ សម្លៀកបំពាក់ ពិការភាព ។ល។)? តើអ្នកគិតថាសិស្សទាំងអស់ មានអារម្មណ៍យ៉ាងដូចម្ដេចចំពោះរឿងនេះ? ចុះអ្នកមានអារម្មណ៍ដូចម្ដេចដែរ?
- ហេតុអ្វីបានជាការធ្វើអន្តរាគមន៍ដល់ការសម្លុតមានសារៈសំខាន់?
- តើនរណាអាចនិយាយអំពីការសម្លុត និងលលេងបាន?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

– ចូរពិភាក្សាអំពីរបៀបការពារមិនឲ្យមានការសម្លុត និងការលលេងនៅសាលារៀនរបស់អ្នក។

**សកម្មភាពសិស្សទី៣**

ចូររៀបចំកិច្ចសន្យាក្នុងថ្នាក់ ដែលសិស្សអាចសរសេរក្បួនច្បាប់ ដើម្បីទទួលបាននូវ បន្ទប់រៀនប្រកបដោយការ យកចិត្តទុកដាក់ និងការកោតសរសើរ។ ព្យួរវានៅលើជញ្ជាំង។

**សកម្មភាពសិស្សទី៤**

ចូរអង្គុយជារង្វង់មូលនៅក្នុងថ្នាក់ (ឬរង្វង់មូលដែលមានសិស្សយ៉ាងច្រើនបំផុត ១៥ នាក់)។ ប្រគល់ក្រដាស់ (ពណ៌លឿង) ទៅឲ្យសិស្សម្នាក់ៗ។ ចូរប្រាប់សិស្សឲ្យគូររូបព្រះអាទិត្យចំកណ្ដាលក្រដាស់ដែលមានឈ្មោះ។ បន្ទាប់មកប្រាប់សិស្សឲ្យហុចគំនូរនោះទៅសិស្សនៅឆ្វេងដៃ។ សិស្សនិមួយៗសរសេររឿងវិជ្ជមាន (បុគ្គលិកលក្ខណៈ រូបសម្បត្តិ ជំនាញ ការប៉ិនប្រសប់ ។ល។) នៅលើគំនូរ រួចហុចទៅឲ្យអ្នកបន្ទាប់។ បន្តសកម្មភាពនេះរហូតដល់សិស្សម្នាក់ៗនៅក្នុងក្រុម បានបញ្ចេញយោបល់របស់គេ។

**ឃ. ទណ្ឌកម្ម**

**គោលការណ៍ណែនាំសម្រាប់គ្រូ**

ទង្វើមិនល្អ និងការបំពានច្បាប់របស់សាលាអាចនាំទៅរកការដាក់ទណ្ឌកម្ម។ ចូរពិភាក្សាជាក្រុមជាមួយសិស្សអំពីអ្វីដែលនឹងកើតឡើង បើសិននរណាម្នាក់រំលោភច្បាប់។

**សេចក្ដីសន្និដ្ឋានលើសកម្មភាពសិស្ស / បទបញ្ជាផ្ទៃក្នុង**

– ចូររៀបចំឲ្យមានវគ្គបំផុសគំនិត ដើម្បីបញ្ចេញយោបល់សំរាប់បទបញ្ជាផ្ទៃក្នុង។ ចូររៀបចំសរសេរនៅលើក្រដាស ហើយព្យួរវាលើជញ្ជាំង។
– ការដាក់វណ្ណយុត្តិលើកិច្ចការសំណេរខ្លីរបស់សិស្ស ជាមធ្យោបាយដែលមានឥទ្ធិពលមួយ ដើម្បីវាយតម្លៃលើគំរិតយល់ដឹងរបស់សិស្ស ។ ប្រាប់សិស្សរបស់អ្នកឲ្យសរសេរអំពី អ្វីដែលជារឿងសំខាន់បំផុតដែលអ្នកបានរៀនសូត្រពីកញ្ចប់មេរៀននៃបទបញ្ជាផ្ទៃក្នុងសាលា ចូរប្រាប់សិស្សថាពួកគេ មានពេលមួយនាទី ដើម្បីសរសេរ ចម្លើយ (ឈ្មោះថា ក្រដាសមួយនាទី)។ បន្ទាប់មក ចូរឲ្យសិស្សចែករំលែកនូវលទ្ធផលនៃការសិក្សា នៅក្នុងថ្នាក់។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

### សន្លឹកកិច្ចការទី៣ «បទបញ្ជាផ្ទៃក្នុង»

ចូរសរសេរ ហើយ/ឬគូរសម្ភារៈសិក្សា ដែលអ្នកត្រូវការនៅសាលា និងសម្រាប់ កិច្ចការផ្ទះរបស់អ្នក។ តើនាពេលនេះ មានសម្ភារណាដែលអ្នកត្រូវការបំផុត នៅអនុវិទ្យាល័យ?



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**សន្លឹកកិច្ចការទី៤ / បទបញ្ជាផ្ទៃក្នុង**




បន្តប្រយោគដូចតទៅដោយប្រើគំនិតរបស់អ្នក:

ខ្ញុំយកសម្ភារៈសំខាន់ៗទាំងអស់មកជាមួយពីព្រោះ...

___

ខ្ញុំជឿជាក់ថាខ្ញុំមកសាលាទាន់ពេលពីព្រោះ...

___

ខ្ញុំមិនយករបស់គ្រោះថ្នាក់ ឬរបស់គ្មានសុវត្ថិភាពមកសាលាទេពីព្រោះ...

___

ខ្ញុំនៅក្នុងបរិវេណសាលានៅពេលថ្ងៃពីព្រោះ...

___

ខ្ញុំរក្សាបន្ទប់រៀនបានស្អាត និងមានសណ្តាប់ធ្នាប់ពីព្រោះ...

___

ខ្ញុំថែរក្សាសៀវភៅ និងសម្ភារៈសិក្សាផ្សេងៗទៀតបានល្អពីព្រោះ...

___

សន្លឹកកិច្ចការនេះជាទម្រង់លំហាត់ដែលណែនាំដោយ ហោកគីណិន គូរ៉ូណិន វ៉ាលូទី ២០១៥)

### ៤.១.៤ សមាជិកទទួលខុសត្រូវក្នុងក្រុម

មេរៀននេះផ្តោតលើការងារជាក្រុម និងការអភិវឌ្ឍន៍ជំនាញ និងការអនុវត្តន៍ផ្សេងៗដែលត្រូវការចាំបាច់ ដើម្បី ធានាបាននូវការគ្រប់គ្រងថ្នាក់រៀនដែលមានភាពកក់ក្តៅ ប៉ុន្តែតឹងរឹង។ គោលបំណងគឺធ្វើឲ្យសិស្សមានការ តាំងចិត្តទាំងអស់គ្នា ដើម្បីធ្វើសហប្រតិបត្តិការ និងទទួលខុសត្រូវលើការសិក្សា ព្រមទាំងជួយគ្នាក្នុងការសិក្សា។

**គោលការណ៍ណែនាំសម្រាប់គ្រូ**

ចូរចែករំលែកសេចក្តីផ្តើមនៃប្រធានបទខាងក្រោមជាមួយសិស្សរបស់អ្នក។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

នៅពេលចាប់ផ្តើមចូលរៀននៅឆ្នាំសិក្សាថ្មី នៅសាលាថ្មី សិស្សក៏ជួបមិត្តថ្មី និងក្លាយជាសមាជិកនៃក្រុមថ្មីដែរ។ មានមនុស្សជាច្រើនប្រភេទដែលមាន បុគ្គលិកលក្ខណៈ ជំនាញ និងសារតាខុសគ្នា នៅក្នុងក្រុមនិមួយៗ។ ប៉ុន្តែភាពខុសគ្នានាំនូវគុណសម្បត្តិជាច្រើនដល់ក្រុម។

ការធ្វើការងារជាក្រុមត្រូវការជំនាញទំនាក់ទំនងផ្នែកសង្គមដ៏ល្អ និងការគិតគូរដល់អ្នកដទៃ។ លើសពីនេះ អ្នកត្រូវតែចេះស្វែងរកជំនួយពីគេ។ បន្ទាប់មក បន្តសកម្មភាពសិស្ស។

**សកម្មភាពសិស្ស**

ចូរធ្វើការងារជាក្រុម ហើយចែករំលែកគំនិត និងអារម្មណ៍អំពីស្មារតីក្រុម។

សំណួរពិភាក្សា

- តើអ្វីធ្វើ ឲ្យការងារក្រុមសប្បាយ? អ្វីដែលធ្វើឲ្យមិនសប្បាយ?
- តើអ្វីធ្វើ ឲ្យអ្នកមានអារម្មណ៍ថាជាផ្នែកសំខាន់របស់ក្រុម?

## គ. សហប្រតិបត្តិការ

### គោលការណ៍ណែនាំសម្រាប់គ្រូ

**សកម្មភាពសិស្សទី១**

ដើម្បីនាំណែនាំសិស្សឲ្យស្គាល់ពីប្រធានបទបន្ទាប់ (សហប្រតិបត្តិការ) ចូរធ្វើសកម្មភាពក្រុមដោយមានការ ប្រាស្រ័យទាក់ទងគ្នា។ ឧទាហរណ៍:

១. បែងចែកសិស្សទៅជាបួនក្រុម ហើយប្រាប់ពួកគេថា គេនឹងប្រគុំតន្ត្រី។ ក្រុមមួយទះដៃ ក្រុមមួយគោះតុអង្គុយ ជាដើម ។ល។ ក្រុមនិមួយៗបន្លឺសម្លេងនៅពេលដែលអ្នកចង្អុលចំពួកគេ។ គោលបំណងសំរាប់ក្រុមនីមួយៗគឺ ធ្វើការជុំគ្នា ដើម្បីបង្កើតអ្វីម្យ៉ាងដែលមានសម្លេងពិរោះ។ ក្នុងការបំពេញកិច្ចការនេះ ពួកគេត្រូវតែស្តាប់នូវ អ្វីដែលអ្នកដទៃកំពុងធ្វើ និងកំពុងកែតម្រូវ។ ចង្អុលម្តងមួយក្រុមៗ ធ្វើយ៉ាងណាឲ្យក្រុមនីមួយៗមានសកម្មភាព ទាំងអស់គ្នា។ បន្ទាប់មក ចាប់ផ្តើមបន្ថែមក្រុមទាំងអស់ ដោយទុកពេលវេលាឲ្យពួកគេកែតម្រូវនូវអ្វីដែលគេកំពុងធ្វើ រហូតដល់សម្លេងបន្លឺឡើងបានល្អ។ ទីបំផុត អ្នកនឹងធ្វើឲ្យក្រុមទាំងអស់លេងជាមួយគ្នាតែម្តង ពោលគឺលេងនៅក្នុងក្រុមភ្លេងមួយដែលប្រគុំយ៉ាងពិរោះរណ្តំ។

នៅពេលដែលការប្រគុំតន្ត្រីចប់ សួរសិស្សថាអ្វីដែលធ្វើឲ្យសកម្មភាពនេះសប្បាយ ហើយហេតុអ្វីបានសកម្មភាព នេះ ត្រូវការសហប្រតិបត្តិការដើម្បីដំណើរការល្អ។ តើអ្នកគួរធ្វើយ៉ាងណាដើម្បីឲ្យប្រសើរជាងនេះ? បើមិនដំណើរការ ហេតុអ្វី? និង/ឬ

២. បែងចែកសិស្សទៅជាក្រុមតូចៗ (មួយក្រុម៥នាក់ជាការល្អ)។ កិច្ចការរបស់គេគឺ បង្កើតម៉ាស៊ីនថ្មីមួយ។ ពួកគេត្រូវដាក់ឈ្មោះវា គូរវា និងសម្រេចថាវាដំណើរការដូចម្តេច។ បន្ទាប់មក ចូរឲ្យ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

ក្រុមនិមួយៗចែករំលែក លទ្ធផល និងបង្ហាញម៉ាស៊ីន ឲ្យសិស្សរួមថ្នាក់បានឃើញ ហើយប្រាប់ពីរបៀបធ្វើការទាំងអស់ គ្នាដើម្បីបង្កើតបានម៉ាស៊ីននោះ។

នៅពេលធ្វើការបង្ហាញចប់ សួរសិស្សថាអ្វីធ្វើឲ្យសកម្មភាពនេះសប្បាយ ហើយហេតុអ្វីបានសកម្មភាពនេះ ត្រូវការសហប្រតិបត្តិការដើម្បីដំណើរការល្អ។ តើអ្នកគួរធ្វើយ៉ាងណា ដើម្បីឲ្យប្រសើរជាងនេះ? បើមិនដំណើរការ ហេតុអ្វី?

### សកម្មភាពសិស្សទី២

ពិសេសជាងនេះទៀត ការសិក្សា និងការធ្វើការងារជាក្រុមតម្រូវឲ្យមានជំនាញសហប្រតិបត្តិការ។ ចូរបន្តសកម្មភាពជាមួយសិស្សក្នុងថ្នាក់ ឬក្នុងការពិភាក្សាជាក្រុមតូចៗ។

### សំណួរសម្រាប់ពិភាក្សា

- តើពាក្យ «សហប្រតិបត្តិការ»មានន័យដូចម្តេច?
- តើការធ្វើសហប្រតិបត្តិការ និងការគ្រាន់តែធ្វើការជាមួយក្រុមខុសគ្នាដូចម្តេច?
- តើធ្វើដូចម្តេចដើម្បីក្លាយជាមនុស្សដែលពូកែខាងសហប្រតិបត្តិការ?
- តើអ្នកអាចដាក់ឈ្មោះអ្វីមួយនៅសាលារៀន ដែលត្រូវការសហប្រតិបត្តិការទេ? និងនៅផ្ទះ?
- ហេតុអ្វីបានជាមានការពិបាកក្នុងការធ្វើសហប្រតិបត្តិការជាមួយមិត្តភ័ក្តិ?
- ចូររៀបរាប់អំពីពេលមួយដែលអ្នកមានភាពលំបាកក្នុងការធ្វើសហប្រតិបត្តិការជាមួយនរណាម្នាក់។ អ្វីធ្វើឲ្យមានការលំបាក? តើអ្នកដោះស្រាយដោយវិធីណា?
- តើអ្វីខ្លះជាចំណុចល្អចំពោះសហប្រតិបត្តិការ ចូរសរសេរអត្ថប្រយោជន៍ទាំងអស់របស់វា។

## ខ. ការស្តាប់អ្នកដទៃ

## គោលការណ៍ណែនាំសម្រាប់គ្រូ

### សកម្មភាពសិស្សទី១

ដើម្បីនាំណែនាំសិស្សឲ្យស្គាល់ពីប្រធានបទបន្ទាប់ (ការស្តាប់អ្នកដទៃ) ចូរធ្វើសកម្មភាពក្រុមដោយមានការ ប្រាស្រ័យទាក់ទងគ្នា។ ឧទាហរណ៍:

១. ធ្វើការជាដៃគូ និងធ្វើជាគំរូជំនាញស្តាប់ដោយឲ្យដៃគូម្នាក់ (សិស្ស«ក») រៀបរាប់អំពីបកម្មភាពរយៈពេលពីរ ឬបីនាទី ខណៈដែលអ្នកដទៃស្តាប់សិស្ស«ខ»។ បន្ទាប់មក ប្រាប់សិស្ស«ក» រៀនិយាយប្រាប់អ្នកនូវរបៀបនៃដៃគូរបស់គេ បង្ហាញថាពួកគេកំពុងស្តាប់។

ចូរពិភាក្សា៖ តើអ្នកអាចបង្ហាញដូចម្តេចថាអ្នក ជាអ្នកពូកែស្តាប់? តើអ្នកអាចបង្ហាញអ្នកដទៃរុចម្តេច ថាអ្នកមិនស្តាប់? និង/ឬ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

២. ចូរផ្តល់មេរៀនផ្នែកសិល្បៈ ប្រើរូបថត កាតប៉ុស្តាល់ រូបភាពយកពីទស្សនាវដ្តី ។ល។ ចូរកុំបង្ហាញរូបភាពឲ្យសិស្សអ្នកជាមុន។ ប្រាប់សិស្សឲ្យយកក្រដាសមួយសន្លឹក និងខ្មៅដៃមួយដើម ឬខ្មៅដៃពណ៌។ ប្រាប់សិស្សឲ្យគូរ ពេលអ្នកពន្យល់។ ចូររៀបរាប់បន្តិចម្តងៗ នូវរបៀបគូររូបភាព។ បន្ទាប់មក អនុញ្ញាតឲ្យសិស្សនិយាយប្រាប់គ្នាអំពីគំនូរ។ តើរូបគំនូរស្រដៀងគ្នាទេ? តើមានភាពខុសគ្នាគួរឲ្យចង់សើចទេ? បន្ទាប់មក បង្ហាញរូបភាពដើមឲ្យពួកគេឃើញ។

សិស្សចាស់ អាចសាកល្បងសកម្មភាពនេះជាមួយដៃគូបាន។ ដៃគូម្នាក់រៀបរាប់អំពីរូបភាព ខណៈអ្នកដទៃស្តាប់ និងគូរវា។ ពេលនោះ គេអាចប្តូរគ្នា ហើយដៃគូដំបូងគូរ ខណៈពេលម្នាក់ទៀតរៀបរាប់អំពីរូបភាព។ នៅពេលគូររូបរួចហើយ ពួកគេអាចបង្ហាញរូបគំនូរនោះនៅក្នុងថ្នាក់បាន។

**សកម្មភាពសិស្សទី២**

បន្តការពិភាក្សាជាមួយក្រុមតូច។

សំណួរពិភាក្សា

- តើអ្នកមានអារម្មណ៍ដូចម្តេច ពេលនរណាម្នាក់មិនស្តាប់គំនិត ឬយោបល់របស់អ្នក?
- តើមានហេតុផលអ្វីខ្លះដែលមនុស្សមិនស្តាប់?
- តើទាស់ខុសដែរទេចំពោះការមិនស្តាប់នរណាម្នាក់កំពុងនិយាយមកកាន់អ្នក?
- តើមានភាពខុសគ្នារវាងការឮ និងការស្តាប់ដែរទេ? តើខុសគ្នាដូចម្តេច?
- តើអ្នកធ្លាប់មានការយល់ខុសពីព្រោះអ្នកមិនស្តាប់ដោយប្រុងប្រយ័ត្នដែរទេ ឬពីព្រោះនរណាម្នាក់មិនស្តាប់អ្នកដោយប្រុងប្រយ័ត្ន?
- តើការស្តាប់ដោយប្រុងប្រយ័ត្នជួយដល់ការសិក្សារបស់អ្នកដោយរបៀបណា?

## គ. ការទទួលខុសត្រូវ

## គោលការណ៍ណែនាំសម្រាប់គ្រូ

**សកម្មភាពសិស្សទី១**

ចូរណែនាំសិស្សឲ្យស្គាល់ពីប្រធានបទបន្ទាប់ (ការទទួលខុសត្រូវ)។ ពិភាក្សានៅក្នុងថ្នាក់អំពីទទួលខុសត្រូវ។

សំណួរពិភាក្សា៖

- តើ "ការទទួលខុសត្រូវ" មានន័យដូចម្តេច?
- តើអ្នកមានការទទួលខុសត្រូវដែរទេ? ដោយរបៀបណា?
- តើក្នុងមធ្យោបាយណាដែលអ្នកមិនទទួលខុសត្រូវ? តើអ្នកគួរធ្វើដូចម្តេចដើម្បីធ្វើឲ្យប្រសើរឡើង?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- តើអ្នកមានបញ្ហាពាក់ព័ន្ធការមិនទទួលខុសត្រូវនៅក្នុងសាលារៀនដែរទេ? តើមានអ្វីកើតឡើង? តើអ្នកនឹងធ្វើអ្វីផ្សេងពីនោះទេ បើអ្នកមានឪកាសសារជាថ្មី?
- តើទំនួលខុសត្រូវអ្វីខ្លះដែលអ្នកមានអារម្មណ៍ផ្ទាល់ចំពោះ ១) ខ្លួនឯង ២) ក្រុមគ្រួសារអ្នក និង ៣) សាលារៀនរបស់អ្នក

**សកម្មភាពសិស្សទី២**

ចូរពិភាក្សាក្នុងថ្នាក់អំពីអ្វីដែលអ្នកអាចធ្វើទាំងអស់គ្នាបាន ដើម្បីទទួលការខុសត្រូវបន្ថែមសម្រាប់បរិស្ថានសាលារៀនរបស់អ្នក (រក្សាឲ្យបានស្អាត ។ល។) ចូររៀបចំផែនការ ហើយរួមគ្នាធ្វើ។

.........................

## ឃ. សេចក្តីសន្និដ្ឋានលើសកម្មភាពសិស្ស «សមាជិកទទួលខុសត្រូវក្រុម»

## គោលការណ៍ណែនាំសម្រាប់

លើសពីសហប្រតិបត្តិការ ការស្តាប់អ្នកដទៃ និងការទទួលខុសត្រូវ មានជំនាញសំខាន់ៗផ្សេងទៀត ដែលត្រូវការចាំបាច់នៅពេលធ្វើការជាក្រុម។

ចូរប្រគល់សន្លឹកកិច្ចការទី៥មួយច្បាប់ទៅឲ្យសិស្សនិមួយៗ ឬស្នើរសុំពួកគេឲ្យប្រើសៀវភៅបរសេរ។ អនុញ្ញាតឲ្យសិស្សបំផុសគំនិតនៅក្នុងក្រុមដែលមានមនុស្ស៥ ទៅ ៦នាក់។ ក្រុមនីមួយៗរៀបចំបញ្ជីនៃជំនាញ ដែលត្រូវការសម្រាប់ការងារក្រុម។ ដើរយឺតៗជុំវិញថ្នាក់យូរៗម្តង ហើយពិនិត្យមើលនូវរបៀបធ្វើការងារក្នុងក្រុម និងជួយពួកគេបើចាំបាច់។ (សន្លឹកកិច្ចការទី៥ «សមាជិកទទួលខុសត្រូវក្នុងក្រុម»)។

ប្រាប់ឲ្យសិស្សពីរក្រុមចូលគ្នា និងចែករំលែកជំនាញនៅក្នុងបញ្ជីរបស់ពួកគេ។ ពួកគេអាចបន្ថែមជំនាញចេញពី បញ្ជីនៃក្រុមជាដៃគូ ទៅលើបញ្ជីរបស់គេផ្ទាល់បាន។

ចូរប្រាប់ដោយសង្ខេបថា ជំនាញ និងសមត្ថភាពដូចតទៅក៏មានសារៈសំខាន់ ក្នុងការកសាងស្មារតីក្រុមដែរ។

- ការយល់ពីអារម្មណ៍ផ្ទាល់ខ្លួន និងវេទនារម្មណ៍
- ការយល់ពីអារម្មណ៍អ្នកដទៃ
- ការសុំទោស
- ការបង្កើតមិត្តយ៉ាងងាយស្រួល
- ជំនាញទំនាក់ទំនង
- ជំនាញបញ្ជាក់ពីទឹកមុខ (ការបើកចិត្តឲ្យទូលាយ ភាពច្បាស់លាស់ ភាពស្មោះត្រង់ ភាពប្រុងប្រយ័ត្ន)
- ជំនាញដោះស្រាយបញ្ហា

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

បន្ទាប់មក ប្រាប់សិស្សឲ្យជ្រើសយកជំនាញបីដែលសំខាន់បំផុតពីបញ្ជី ហើយសរសេរវានៅលើសន្លឹកកិច្ចការ ឬសៀវភៅសរសេរ។ ចូរឲ្យសិស្សពន្យល់ពីមូលហេតុដែលគេយល់ថា ជំនាញពិសេសទាំងនេះមានសារៈសំខាន់។

(កញ្ចប់មេរៀននេះត្រូវបានចងក្រងជាផ្នែកដោយមានទម្រង់លំហាត់ណែនាំដោយ GoodCharacter.com)

**សន្លឹកកិច្ចការទី៥ «សមាជិកទទួលខុសត្រូវក្នុងក្រុម»**

លើសពីសហប្រតិបត្តិការ ការស្តាប់អ្នកដទៃ និងការទទួលខុសត្រូវ មានជំនាញជាច្រើនទៀតដែលត្រូវការ ចាំបាច់នៅពេល ធ្វើការជាក្រុម។

ចូរសរសេរនូវជំនាញដែលត្រូវការចាំបាច់សំរាប់ធ្វើការជាក្រុម។



### ៧.១.៥. ការសិក្សានៅអនុវិទ្យាល័យ

**គោលការណ៍ណែនាំសម្រាប់គ្រូ**

ថ្នាក់ទី៧–៩ ខុសគ្នាច្រើនពីជីវិតនៅបឋមសិក្សា។ មានមុខវិជ្ជាថ្មីមួយចំនួនដែលត្រូវសិក្សា វាចជាមុខវិជ្ជាដែលខានមិនបាន ឬអាចជាមុខវិជ្ជាដែលជ្រើសរើសបាន ដូចនេះកាលវិភាគប្រចាំថ្ងៃរៀងសប្តាហ៍ គឺថ្មីសម្រាប់សិស្ស។ ដើម្បីឲ្យប្រាកដថា ការផ្លាស់មករៀននៅអនុវិទ្យាល័យនេះមានភាពលូន ចូរនិយាយអំពីការផ្លាស់ប្តូរជាមួយសិស្សរបស់អ្នក។

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

ការកំណត់ និងការសំរេចគោលដៅជួយសម្រួលដល់ការសិក្សា។ សូមផ្ដល់ជាយោបល់ថា សិស្សគួរកំណត់គោលដៅសម្រាប់ឆ្នាំសិក្សានិមួយៗ។ តាមមធ្យោបាយនេះ ពួកគេរៀបចំផែនការសិក្សាដោយប្រុងប្រយ័ត្ន និងធ្វើឲ្យស្នាដៃរបស់គេកាន់តែប្រសើរ។ មិនចាំបាច់កំណត់គោលដៅធំពេកទេ។ គោលដៅអាចមានរយៈពេលខ្លី ហើយផ្ដោតលើមុខវិជ្ជាពិសេស ឬជំនាញមួយ។ គោលដៅមានគឺមានលក្ខណៈផ្ទាល់ខ្លួន។ ម្នាក់ៗអាចមានគោលដៅផ្ទាល់ខ្លួនបាន។

**សកម្មភាពសិស្សទី១**

ចូរប្រគល់សន្លឹកកិច្ចការទី៦មួយច្បាប់ឲ្យសិស្សម្នាក់ៗ។ ជាជម្រើស ចូរសរសេរកិច្ចការនៅលើក្ដារខៀន ឬអានវាឲ្យខ្លាំង។ ប្រាប់សិស្សឲ្យធ្វើម្នាក់ឯងក៏បាន ជាមួយដៃគូក៏បាន ដើម្បីឆ្លើយ សំណួរ និងបំពេញតារាងកាលវិភាគ សាលា (សន្លឹកកិច្ចការទី ៦ / ការសិក្សានៅអនុវិទ្យាល័យ)។

ចូរពិភាក្សាក្នុងថ្នាក់ ដើម្បីចែករំលែកលទ្ធផលនៃលំហាត់នេះ។ សំណួរទី៤ និងទី៥ អាចយកមកពិភាក្សា ជាមួយដៃគូ ឬក្នុងក្រុមតូចបាន។

## ក. ការកំណត់ និងការសម្រេចគោលដៅ

បន្តការណែនាំសិស្សឲ្យស្គាល់ពីប្រធានបទបន្ទាប់ (ការកំណត់ និងការសម្រេចគោលដៅ)។

**សកម្មភាពសិស្សទី២**

ចូរឲ្យសិស្សបំបែកគ្នាទៅជាបួនក្រុមដែលមានសមាជិក៤– ៥ នាក់ ហើយចែករំលែកគំនិតនិងអារម្មណ៍អំពី ការកំណត់ និងការសម្រេចគោលដៅទៅឲ្យគ្នា។

**សំណួរពិភាក្សា**

- តើក្ដីប្រាថ្នា និងគោលដៅខុសគ្នាដូចម្ដេច? *
- តើអ្នកធ្លាប់កំណត់គោលដៅសំរាប់ខ្លួនឯងដែរទេ?
- តើបច្ចុប្បន្ននេះអ្នកមានគោលដៅអ្វីខ្លះ? (រយៈពេលខ្លី ឬវែង)?
- តើអ្នកសម្រេចចិត្តថា វាជាគោលដៅដោយវិធីណា?

*សេចក្ដីប្រាថ្នាមិនប្រាកដថាជាគោលដៅរហូតនោះទេ។ គោលដៅមានភាពប្រាកដនិយម។

បន្ទាប់មក ណែនាំសិស្សរបស់អ្នកឲ្យស្គាល់ពីជំហានសម្រាប់កំណត់គោលដៅ។

## ខ. របៀបកំណត់គោលដៅ

១. កំណត់គោលដៅ

២. រៀបចំជំហានដែលត្រូវការដើម្បីសម្រេចវា

៣. ពិចារណានូវឧបសគ្គដែលអាចកើតឡើង និងមធ្យោបាយដោះស្រាយការរាំងស្ទះនោះ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

៤. កំណត់ពេលវេលា

**សកម្មភាពសិស្សទី៣**

ដំបូង អនុញ្ញាតឲ្យសិស្សអនុវត្តលំហាត់នៃការដាក់គោលដៅមួយចំនួន។ នៅក្នុងសម្មតិកម្មនីមួយៗ ចូរឲ្យសិស្សពិនិត្យមើល ដំណើរការនៃការកំណត់គោលដៅ ទាំង៤ជំហាន ដែលផ្តល់ឲ្យខាងលើ។

ឧទាហរណ៍:

លំហាត់កំណត់គោលដៅទី១ ចូរសុំវិភាគទានដើម្បីទិញកំព្យូទ័រថ្មីមួយ ឬសៀវភៅសម្រាប់សាលា។

លំហាត់កំណត់គោលដៅ ទី២ បង្កើតសួនច្បារនៅក្នុងសាលាដើម្បីដាំបន្លែ / ផ្លែឈើ / ផលិតផលផ្សេងៗ។

**សកម្មភាពសិស្សទី៤**

ចូរប្រគល់សន្លឹកកិច្ចការទី៧ ទៅឲ្យសិស្សនីមួយៗ ឬសរសេរកិច្ចការនោះនៅលើក្តារខៀន។ ូរអនុញ្ញាតឲ្យពួកគេកំណត់គោលដៅរយៈពេលខ្លីដែលអាចសំរេចបានក្នុងឆ្នាំសិក្សា។ ឧទាហរណ៍ ួកគេអាចសម្រេចយកពិន្ទុមធ្យមពិតប្រាកដមួយ នៅពេលប្រឡង។ ឬពួកគេអាចកំណត់គោលដៅ ំរាប់ការអភិវឌ្ឍន៍ផ្ទាល់ខ្លួន ឬការអភិវឌ្ឍន៍ជំនាញ ដូចជាការចំណាយពេលបន្ថែមលើកិច្ចការផ្ទះឬ ួយសិស្សផ្សេងទៀតជាមួយការសិក្សា (សន្លឹកកិច្ចការទី៧ / ការសិក្សានៅអនុវិទ្យាល័យ)។

ចូរឲ្យសិស្សបង្ហាញពីគោលបំណង ទៅកាន់សិស្សរួមថ្នាក់ រួមមានផែនការ ការកំណត់ពេល ិងមូលហេតុដែល គោលដៅទាំងនេះសំខាន់សំរាប់ពួកគេ។ ចូរធ្វើការសម្រេចចិត្តលើរង្វាន់សម្រាប់ ារទទួលជោគជ័យ ដូចជាពិចនិចជុំគ្នា ដំណើរទស្សនកិច្ច ការសងមកវិញដោយមានការសប្បាយ។ ្នុងអំឡុងពេលមួយឆ្នាំសិក្សា អនុញ្ញាតឲ្យសិស្សតាមដានវឌ្ឍភាពរបស់គេ ដោយមានផ្តល់ជារបាយ ារណ៍យូរៗម្តងដល់សិស្សទាំងអស់នៅក្នុងថ្នាក់រៀន។

កញ្ចប់មេរៀននេះត្រូវបានចងក្រងជាផ្នែកដោយមានទម្រង់លំហាត់ណែនាំដោយ GoodCharacter.com)

**បន្លឹកកិច្ចការទី៦ «ការសិក្សានៅអនុវិទ្យាល័យ»**

). មុខវិជ្ជាដែលខានមិនបាន នៅក្នុងអនុវិទ្យាល័យគឺ

________________ ________________

________________ ________________

________________ ________________ __________




facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

២. តើមានមុខវិជ្ជាដែលអាចជ្រើសរើសបានដែរទេ?

៣. តើមុខវិជ្ជាអ្វីខ្លះដែលថ្មី (មុខវិជ្ជាដែលអ្នកមិនបានរៀននៅបឋមសិក្សា)?

៤. តើមុខវិជ្ជាទាំងបីដែលអ្នកពេញចិត្តបំផុតមានអ្វីខ្លះ?

៥. ក) តើមានមុខវិជ្ជាពិបាកសំរាប់អ្នក ឬមុខវិជ្ជាណាដែលអ្នកមិនចូលចិត្តទេ?
ខ) តើអ្វីដែលធ្វើឲ្យលំបាក?
គ) តើអ្នកគួរធ្វើដូចម្តេច ដើម្បីចាប់អារម្មណ៍លើមុខវិជ្ជាដែលអ្នកមិនសូវចូលចិត្ត?

៦. តើកាលវិភាគប្រចាំថ្ងៃ និងសប្តាហ៍នៅសាលារបស់អ្នកមានអ្វីខ្លះ? ចូរបំពេញផែនការប្រចាំសប្តាហ៍។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## weekly planner

| TIME | MONDAY | TUESDAY | WEDNESDAY | THURSDAY | FRIDAY | SATURDAY | SUNDAY |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**បន្លឹកកិច្ចការទី៧ «ការសិក្សានៅអនុវិទ្យាល័យ»**

ូរប្រកាសគោលដៅ២ ដែលអ្នកចង់សម្រេច ក្នុងអំឡុងពេលសិក្សានៅឆ្នាំនេះ។ ឧទាហរណ៍ អ្នក ាចសម្រេចយកពិន្ទុមធ្យមពិតប្រាកដមួយ នៅពេលប្រឡង។ ឬអ្នកអាចកំណត់គោលដៅសម្រាប់ ារអភិវឌ្ឍផ្ទាល់ខ្លួន ឬការអភិវឌ្ឍជំនាញ ដូចជាការចំណាយ ពេលបន្ថែម លើកិច្ចការផ្ទះ ឬជួយ បិស្សផ្សេងទៀតជាមួយការសិក្សារបស់គេ។ ចូររៀបចំផែនការ ដើម្បីសំរេចបាននូវគោលដៅទាំង នះ និងកំណត់ពេលវេលា។

| | គោលដៅ ១ | គោលដៅ ២ |
|---|---|---|
| កំណត់គោលដៅ | | |
| រៀបចំជំហានដែលត្រូវការ ដើម្បីសម្រេចវា | | |
| ពិចារណាឧបសគ្គដែលអាចកើតឡើង និងមធ្យោបាយនៃការដោះស្រាយការរាំងស្ទះ | | |
| កំណត់ពេលវេលា | | |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

ហេតុអ្វីបានជាគោលដៅទាំងនេះមានសារៈសំខាន់ចំពោះអ្នក?

________________________________________________

________________________________________________

________________________________________________

________________________________________________

## ៧.១.៦ ការវាយតម្លៃ និងការដាក់ពិន្ទុ

### គោលការណ៍ណែនាំសម្រាប់គ្រូ

ចូរពិភាក្សាជាក្រុមធំនៅក្នុងថ្នាក់ ដើម្បីផ្តល់ឲ្យសិស្សនូវព័ត៌មានវង្វាយតម្លៃដែលយកមកប្រើនៅអនុវិទ្យាល័យ។

- តើការងារសាលាត្រូវវាយតម្លៃដោយវិធីណាៈ ពិន្ទុ ការវាយតម្លៃលើការនិយាយ (ការសរសេរ ឬផ្ទាល់មាត់) ។ល។?
- តើមានប្រភេទនៃការវាយតម្លៃក្រៅពីការប្រឡង និងធ្វើតេស្តទេ ឧទាហរណ៍ កិច្ចការផ្ទះ ការធ្វើបទបង្ហាញក្នុងថ្នាក់ និងការងារអនុវត្តន៍?
- តើប្រឡងពេលណា? តើការប្រឡងជាផ្លូវការរៀបចំនៅពេលណា?
- ភាពខុសគ្នានៃពិន្ទុ ពិន្ទុជាប់ និងពិន្ទុធ្លាក់
- តើមានរឿងអ្វីកើតឡើង បើអ្នកប្រឡងធ្លាក់ /ធ្លាក់មុខវិជ្ជាណាមួយ?
- សញ្ញាបត្របញ្ចប់ការសិក្សា និងតម្រូវការសំរាប់ការបញ្ចប់ការសិក្សានៅអនុវិទ្យាល័យ និងការទទួលសញ្ញាបត្រ។

វង្វាយតម្លៃខ្លួនឯងគឺជា មធ្យោបាយដែលមានសារៈសំខាន់ចំពោះការសិក្សា។ សិស្សគួរមានការលើកទឹកចិត្តឲ្យឆ្លុះបញ្ចាំងពីការអភិវឌ្ឍន៍ និងវឌ្ឍនភាពរបស់គេផ្ទាល់ ដោយប្រៀបធៀបការងារបច្ចុប្បន្នជាមួយ អតីតការងារ និងជាមួយគោលដៅផ្ទាល់ខ្លួនរបស់គេ។ ការវាយតម្លៃការងារផ្ទាល់ខ្លួនរាចជួយសិស្សអភិវឌ្ឍនការយល់ដឹងនៃ គោលដៅរបស់មេរៀន និងរកឲ្យឃើញភាពខ្លាំង និងភាពខ្សោយ និងពិនិត្យមើល ថាតើ ពួកគេអាចធ្វើឲ្យប្រសើរ ដោយរបៀបណា។

បន្ទាប់ពីការពិភាក្សា និងការណែនាំឲ្យស្គាល់ពីការវាយតម្លៃ និងការដាក់ពិន្ទុ ចូរបន្តបកម្មភាពសិស្សផ្សេងទៀត។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**សកម្មភាពសិស្សទី១**

ចូរប្រគល់សន្លឹកកិច្ចការទី៨មួយច្បាប់ទៅឲ្យសិស្សនិមួយៗ ឬសរសេរវានៅលើក្តារខៀន។ នេះជាកិច្ចការឆ្លុះ បញ្ចាំងរបស់បុគ្គលម្នាក់ៗ។ ដូចនេះ ប្រាប់សិស្សឲ្យធ្វើម្នាក់ឯង អានសំណួរ និងគិតដោយប្រុងប្រយ័ត្ន មុនពេល សរសេរចម្លើយ។ ចូរផ្តល់ពេលវេលាឲ្យបានគ្រប់គ្រាន់ដើម្បីបំពេញលំហាត់នេះ (សន្លឹកកិច្ចការទី៨ «ការវាយតម្លៃ និងការដាក់ពិន្ទុ»)។

ចូរពិភាក្សាក្នុងថ្នាក់ ដើម្បីចែករំលែកលទ្ធផលនៃសកម្មភាពនេះ។ ជួយបន្ថែមព័ត៌មានដល់សិស្ស បើចាំបាច់។ ឧទាហរណ៍ ការចូលរួមក្នុងថ្នាក់មានសារៈសំខាន់ពីព្រោះ៖

- ការសួរសំណួរអាចជួយសិស្សរៀនសូត្របន្ថែម និងទទួលការយល់ដឹងនូវមុខវិជ្ជា កាន់តែប្រសើរ (ឬកាន់តែត្រឹមត្រូវ) ឡើង។ ការសួរនៅក្នុងថ្នាក់ក៏អាចសន្សំពេលវេលា និងកិច្ចប្រឹងប្រែងស្វែងយល់រឿងរ៉ាវ បានច្រើនដែរ។
- ការផ្លាស់ប្តូរយោបល់ជាមួយសិស្សផ្សេង ជាមធ្យោបាយល្អក្នុងការសិក្សា។
- ការគិតគឺល្អ ព្រោះដំណើរការនៃការគិតគឺដើម្បីឆ្លើយតបនឹងអ្វីដែលគ្រូនិយាយ និងជួយអ្នកឲ្យគិតអំពីសម្ភារនៅនឹងដៃកាន់តែស៊ីជម្រៅ និងពេញលេញ ។

**សកម្មភាពសិស្សទី២**

ប្រគល់សន្លឹកកិច្ចការទី៩ ទៅឲ្យសិស្សនីមួយៗ ឬសរសេរកិច្ចការនោះនៅលើក្តារខៀន។ ប្រាប់សិស្សឲ្យធ្វើ ម្នាក់ឯង និងបំផុសគំនិតអំពីបញ្ជី/តារាងទាំងបី: ១) បញ្ជីនៃរឿងទាំងឡាយដែលអ្នកគិតថាពូកែ (មុខវិជ្ជាសាលា ជំនាញសិក្សា ដូចជាការអាន ការសរសេរ និងការប្រគុំតន្ត្រី ។ល។) ២) បញ្ជីនៃរឿងទាំងឡាយដែលអ្នកគិតថាលំបាក ៣) បញ្ជីនៃសកម្មភាពទាំងឡាយដែលពួកគេអាចធ្វើបាន ដើម្បីធ្វើឲ្យការសិក្សា និងការអភិវឌ្ឍជំនាញរបស់គេ កាន់តែប្រសើរឡើង (សន្លឹកកិច្ចការទី៩ «ការវាយតម្លៃ និងការដាក់ពិន្ទុ»)។

នៅចុងឆ្នាំសិក្សា ពិនិត្យឡើងវិញនូវបញ្ជីទាំងនោះ ហើយគិតនូវភាពប្រសើរដែលអ្នកបានធ្វើ។

**សន្លឹកកិច្ចការទី៨ «ការវាយតម្លៃ និងការដាក់ពិន្ទុ»**

ចូរអានសំណួរ គិតអំពីប្រធានបទដោយប្រុងប្រយ័ត្ន បន្ទាប់មកសរសេរចម្លើយរបស់អ្នក។

ហេតុអ្វីបានជាគ្រូវាយតម្លៃសិស្សនៅសាលា?

______________________________________________________________

______________________________________________________________

ហេតុអ្វីបានជាការធ្វើកិច្ចការផ្ទះមានសារៈសំខាន់? ចូរផ្តល់មូលហេតុយ៉ាងតិចបី។

______________________________________________________________

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

_______________________________________________

_______________________________________________

ហេតុអ្វីបានជាការចូលរៀន មានសារៈសំខាន់? ចូរផ្ដល់មូលហេតុយ៉ាងតិចបី។

_______________________________________________

_______________________________________________

តើគ្រូផ្ដល់ព័ត៌មានត្រឡប់ នៅពេលណា និងដោយវិធីណា?

_______________________________________________

_______________________________________________

តើអ្នកមានអារម្មណ៍ដូចម្ដេចពេលអ្នកទទួលព័ត៌មានត្រឡប់ល្អសំរាប់ការងារសាលារបស់អ្នក?

_______________________________________________

_______________________________________________

ហតុអ្វីបានជាការឆ្លុះបញ្ចាំង និងការវាយតម្លៃលើការអភិវឌ្ឍន៍ និងវឌ្ឍនភាពរបស់អ្នកជាប្រចាំមានហារៈសំខាន់?

_______________________________________________

_______________________________________________

តីគោលដៅបែបណាខ្លះដែលអ្នកមានចំពោះការងារសាលា និងពិន្ទុ?

_______________________________________________

_______________________________________________

តីសញ្ញបត្របញ្ចប់ការសិក្សាមានសារៈសំខាន់ប៉ុនណា? ហេតុអ្វី?

_______________________________________________

សន្លឹកកិច្ចការនេះជាទម្រង់លំហាត់ដែលណែនាំដោយ ហោកគីណិន គូរ៉ូណិន & វ៉ាលូទី ២០១៥)

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## សន្លឹកកិច្ចការទី ៩ «ការវាយតម្លៃ និងការដាក់ពិន្ទុ»

ចូរបំផុសគំនិតអំពីបញ្ជី/តារាងទាំងបី: ១) បញ្ជីនៃរឿងទាំងឡាយដែលអ្នកគិតថាពូកែ (មុខវិជ្ជាសាលា ជំនាញសិក្សាដូចជាការអាន ការសរសេរ និងការប្រគុំតន្ត្រី ។ល។) ២) បញ្ជីនៃរឿងទាំងឡាយដែលអ្នកគិតថាលំបាក ៣) បញ្ជីនៃសកម្មភាពទាំងឡាយដែលពួកគេអាចធ្វើបាន ដើម្បីធ្វើឲ្យការសិក្សា និងការអភិវឌ្ឍជំនាញរបស់គេ កាន់តែប្រសើរឡើង



facebook.com/moeyscambodia YouTube youtube.com/moeyscambodia

## ២. បំណិនក្នុងការសិក្សា និងបច្ចេកទេសសិក្សា
## ការណែនាំសម្រាប់គ្រូ

កញ្ចប់មេរៀនអំពី បំណិន និងបច្ចេកទេសសិក្សា ក្តោបគ្រួសៗលើសមាសភាគដែលធ្វើឲ្យការសិក្សាទទួលបានជោគជ័យ។ វាមានប្រធានបទបន្ទាប់បន្សំដូចខាងក្រោម៖

- សារៈសំខាន់នៃតួនាទី និងការទទួលខុសត្រូវរបស់សិស្សលើការសិក្សាប្រកបដោយជោគជ័យ
- របៀបសិក្សា
- បច្ចេកទេសសិក្សា

បំណិន និងបច្ចេកទេសសិក្សា គួរលើកយកមកនិយាយនៅដំណាក់កាលដំបូង នៃការសិក្សារបស់សិស្ស ដើម្បីធ្វើឲ្យការសិក្សាមានប្រសិទ្ធិភាព។ សូមផ្តល់ជាយោបល់ផងដែរថា កញ្ចប់មេរៀននេះ គួរបែងចែកជាសេរីនៃមេរៀន ដើម្បីផ្តល់ការយល់ដឹងស៊ីជម្រៅនូវរបៀបសិក្សា និងបច្ចេកទេសសិក្សាដល់សិស្សម្នាក់ៗ។

### សមាសភាគនៃការសិក្សាប្រកបដោយភាពជោគជ័យ

សមាសភាគនៃការសិក្សាប្រកបដោយភាពជោគជ័យ គឺ៖

1. អ្នកសិក្សា: បែបបទនៃការរស់នៅ ការលើកទឹកចិត្ត* ឥរិយាបថ បទពិសោធន៍ គំនិតស្តីពីសមត្ថភាព
2. ដំណើរការសិក្សា: ជំនាញ និងបច្ចេកទេសសិក្សា
3. សមាសភាគផ្សេងៗ: គ្រូ វិធីបង្រៀន បរិយាកាស និងសម្ភារ

* កត្តាជះឥទ្ធិពលដល់ការលើកទឹកចិត្តមាន គោលបំណង បទពិសោធន៍ ឥរិយាបថរបស់អ្នកជុំវិញខ្លួន (ឪពុកម្តាយ មិត្តភ័ក្តិ គ្រូ។ល។) និងការយល់ឃើញអំពីលទ្ធភាពដែលនាំឲ្យទទួលបានជោគជ័យ។

### អ្នកសិក្សា

អ្នកសិក្សា គឺជាអ្នកដែលមានការទទួលការខុសត្រូវលើភាពរីកចម្រើនក្នុងការសិក្សារបស់ពួកគេ។ ការសិក្សា គឺជាការតាំងចិត្តខ្ពស់។ ភាគច្រើន ដើម្បីឲ្យការសិក្សាទទួលជោគជ័យទៅបាន គឺតម្រូវឲ្យមានការខិតខំប្រឹងប្រែង។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ដំណើរការនៃការសិក្សា

ក្នុងដំណើរការនៃការសិក្សា របៀបសិក្សាដើរតួនាទីសំខាន់ដើម្បីធ្វើឲ្យការសិក្សាមានភាពរលូន រីករាយ និងមានប្រយោជន៍។ អ្នកសិក្សាត្រូវយល់ថាគេខ្លួនឯងជាអ្នកសិក្សាបែបណា។ តើគេជាអ្នករៀនដោយផ្អែកលើការមើល ស្តាប់ ឬធ្វើ? គ្រូគួរតែលើកទឹកចិត្តសិស្សអំពីរបៀបសិក្សា និងការប្រើប្រាស់បច្ចេកទេសសិក្សា។

## សមាសភាគផ្សេងៗ

គ្រូមានទំនួលខុសច្រើនលើដំណើរការនៃការសិក្សា។ គ្រូគឺជាអ្នករៀបចំឲ្យមានបរិយាកាសសិក្សា។ ប្រសិនបើគ្រូអាចប្រែក្លាយថ្នាក់រៀនទៅជា កន្លែងមួយដែលគួរឲ្យចាប់អារម្មណ៍ មានការលើកទឹកចិត្ត និងមានរបៀបរៀបរយ ពេលនោះអ្នកសិក្សាក៏នឹងពេញចិត្តនៅទីនោះដែរ។

## គោលការណ៍ណែនាំសម្រាប់គ្រូ

### សកម្មភាពសិស្ស «តួនាទីរបស់សិស្សក្នុងការសិក្សាប្រកបដោយភាពជោគជ័យ»

ដំបូង ចូរពិភាក្សាក្នុងថ្នាក់ អំពីសារៈសំខាន់នៃតួនាទី និងទំនួលខុសត្រូវលើការសិក្សាប្រកបដោយភាពជោគជ័យ។ អ្នកអាចប្រើសន្លឹកកិច្ចការទី១ ដើម្បីជួយសម្រួលដល់ការពិភាក្សា។ សន្លឹកកិច្ចការទី១/ជំនាញ និងបច្ចេកទេសសិក្សា)។

របៀបរស់នៅប្រកបដោយផាសុខភាព ជួយពង្រឹងការសិក្សា។ ទំនាក់ទំនងរវាងចំណីអាហារងការសិក្សា គឺជារឿងសំខាន់។ របបអាហារ និងចំណីអាហារល្អ មានផលវិជ្ជមានលើសុខុមាលភាពព្រមទាំងការបំពេញកិច្ចការរបស់សិស្ស។ ការទទួលទានដំណេកបានគ្រប់គ្រាន់ គឺជាលក្ខខ័ណ្ឌដំបូងបម្រាប់ការសិក្សា។ យើងត្រូវការ«សាកអាគុយ»ឲ្យបានទៀងទាត់។ លើសពីនេះ ក្នុងអំឡុងពេលគង ខួរក្បាលរបស់យើងចាប់ផ្តើមសកម្ម និងធ្វើឲ្យមានដំណើរការដល់ការសិក្សាពេលយើងភ្ញាក់ពីគង។ ការទទួលទានដំណេកមិនគ្រប់គ្រាន់ នាំឲ្យមានការលំបាកក្នុងការសិក្សា ព្រមទាំងមានបញ្ហាផ្នែកឥរិយាបថ។ សកម្មភាពពេលទំនេរ ដូចជាការលេងកីឡា មានឥទ្ធិពលវិជ្ជមានដល់ការផ្ចង់ារម្មណ៍ បំណិនចងចាំ និងបំណិនក្នុងការដោះស្រាយបញ្ហា។

ក្នុងចំណោមកត្តាសំខាន់ជាច្រើន កត្តាសំខាន់មួយដែលមានឥទ្ធិពលដល់ការសិក្សា គឺការលីកទឹកចិត្ត។ គ្មានការលើកទឹកចិត្ត គឺពិតជាគ្មានឆន្ទៈក្នុងការសិក្សាអ្វីដែលថ្មីឡើយ។ មានកត្តាច្រើនទៀតអាស្រ័យលើរបៀបដោះស្រាយពេលសិស្សជួបប្រទះក្នុងមេរៀន និងក្នុងដំណើរការបិក្សាទាំងមូល។ ការកំណត់គោលបំណង និងឥរិយាបថវិជ្ជមានចំពោះការសិក្សា និងមុខវិជ្ជាផ្សេងៗនៅក្នុងសាលារៀន នឹងជួយលើកកម្ពស់លទ្ធផលសិក្សាកាន់តែល្អប្រសើរ។ ហើយការជឿជាក់លើ

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

សមត្ថភាពខ្លួនឯង ក៏គឺជារឿងសំខាន់មួយក្នុងការសិក្សា។ ជួនកាលយើងមិនទាំងបានសាកល្បងធ្វើអ្វីមួយឡើយ ដោយសារតែមានការភ័យខ្លាចនឹងភាពបរាជ័យ។

**សកម្មភាពសិស្ស «ឥរិយាបថ»**

ចូរប្រាប់សិស្សឲ្យគូររូបដែលធ្វើឲ្យពួកគេនឹកឃើញដល់ឥរិយាបថល្អៗ។ ប្រាប់ពួកគេឲ្យព្យួរនៅទីកន្លែងណាដែលគេអាចមើលឃើញរូបនោះ។

### ៣. ដំណើរការនៃការសិក្សា

### ក. របៀបនៃការសិក្សា

### គោលការណ៍ណែនាំសម្រាប់គ្រូ

គម្រូនៃរបៀបសិក្សាដែលមានអក្សរកាត់ថា VAK (Visual«មើល», Auditory«ស្តាប់», Kinesthetic«អនុវត្ត») បង្ហាញពីចំណាត់ថ្នាក់នៃមធ្យោបាយយ៉ាងសាមញ្ញស្តីពីរបៀបសិក្សារបស់មនុស្ស។ យោងតាមគំរូនេះ មនុស្សយើងភាគច្រើន ជាអ្នកសិក្សាដោយផ្អែកលើការមើល ការស្តាប់ និងការអនុវត្តផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តជាក់ស្តែង មនុស្សយើងតែងមានលក្ខណៈលាយចូលគ្នា និងស៊ីគ្នា រវាងរបៀបសិក្សាទាំងបីនេះ។

- ការមើល៖ អ្នកសិក្សាដែលផ្អែកលើការមើល ទទួល និងរក្សាព័ត៌មានបានល្អ នៅពេលវាបង្ហាញជារូបភាពដ្យាក្រាម និងតារាង។
- ការស្តាប់៖ អ្នកសិក្សាដែលផ្អែកលើការស្តាប់ ចូលចិត្តស្តាប់អ្វីដែលកំពុងបង្ហាញជាង។ ពួកគេឆ្លើយតបបានល្អតាមរយៈការបង្រៀន ឬការពិភាក្សាជាក្រុម។ ការស្តាប់ឮសំឡេងនិយាយដដែលៗអំពីអ្វីមួយទៅកាន់គ្រូក៏មានប្រយោជន៍ដែរ។
- ការអនុវត្តផ្ទាល់៖ អ្នកសិក្សាដែលផ្អែកលើការអនុវត្តផ្ទាល់ ចូលចិត្តបទពិសោធន៍ខាងសម្បទារាងកាយជាង។ ពួកគេចូលចិត្តការប្រើដៃ និងចង់ប៉ះ ឬស្ទាបវត្ថុ។

អក្សរកាត់មួយផ្សេងទៀត គឺ VARK (Visual, Auditory, Reading/Writing «អាន ឬសរសេរ», Kinesthetic)។

- ការអាន/ការសរសេរ៖ អ្នកសិក្សាដែលផ្អែកលើការអាន ឬសរសេរ ច្រើនប្រើប្រាស់ពាក្យ និងការសរសេរដដែលៗ។ មានការត្រួតស៊ីគ្នារវាងរបៀបសិក្សាតាមការមើល និងការស្តាប់ ពីព្រោះពាក្យ និងការសរសេរ អាចទាក់ទងនឹងរបៀបសិក្សាទាំងពីរនេះ ប៉ុន្តែអ្នកដែលចូលចិត្តរៀនតាមបែបនេះ មានការចងចាំ ឬរៀបចំអ្វីៗបានប្រសើរ នៅក្នុងចិត្តរបស់គេតាមរយៈការកត់ត្រា។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ប្រតិបត្តិ

### សកម្មភាពសិស្ស «របៀបសិក្សា»

ចូរពិភាក្សានៅក្នុងថ្នាក់អំពីរបៀបសិក្សាផ្សេងៗរបស់មនុស្ស។ ដំបូងអនុញ្ញាតឲ្យសិស្សរៀបរាប់អំពីគំនិត និងបទពិសោធន៍ដោយប្រើប្រាស់ពាក្យពេចន៍របស់គេផ្ទាល់។ បន្ទាប់មក ចូរឲ្យសិស្សធ្វើលំហាត់អំពីគម្រូនៃរបៀបសិក្សា។ ចូរចែកលទ្ធផលតេស្តទៅសមាជិកនៅក្នុងក្រុមតូច និងនៅក្នុងថ្នាក់។

### ខ. បច្ចេកទេសសិក្សា

### គោលការណ៍ណែនាំសម្រាប់គ្រូ

ចូរណែនាំសិស្សឲ្យស្គាល់អំពីប្រធានបទ ហើយឲ្យសិស្សពិភាក្សាជាក្រុមតូច ដោយមានការកត់ត្រា។

### សំណួរពិភាក្សា៖

តើវិធីសាស្ត្រណាខ្លះដែលអ្នកប្រើនៅពេលដែលអ្នក៖

- កំពុងស្ដាប់ការបង្រៀននៅក្នុងថ្នាក់?
- កំពុងធ្វើកិច្ចការផ្ទះ?
- កំពុងស្វែងរកព័ត៌មាន/ឬធ្វើការស្រាវជ្រាវ?
- កំពុងកត់ត្រា?

បន្ទាប់មក ប្រាប់សិស្សឲ្យជ្រើសយកវិធីសាស្ត្រនៃការសិក្សាសំខាន់ៗចំនួន៥ពីបញ្ជីរបស់គេ។ ប្រមូលយកវិធីសាសត្រទាំងនោះមកសរសេរលើក្ដារខៀន ឬនៅលើផ្ទាំងក្រដាសធំ ហើយព្យួរនៅលើជញ្ជាំង។ ម្នាក់ៗអាចរៀនបច្ចេកទេសផ្សេងៗ និងអភិវឌ្ឍបំណិនឬជំនាញសិក្សា ដើម្បីពង្រឹងការសិក្សារបស់គេ។ បន្ទាប់មក យើងនឹងនិយាយអំពីមធ្យោបាយមួយចំនួនក្នុងការអនុវត្តបច្ចេកទេសនៃការសិក្សា និងផ្ដល់ជាគន្លឹះដើម្បីធ្វើឲ្យការសិក្សាកាន់តែមានប្រសិទ្ធិភាព។

### ខ.១ បំណិនស្វែងរកព័ត៌មាន

បំណិនស្វែងរកព័ត៌មាន គឺត្រូវការចាំបាច់ ឧទាហរណ៍ នៅពេលរៀបចំកិច្ចការ និងការធ្វើបទបង្ហាញនៅក្នុងថ្នាក់។ សារៈសំខាន់នៃបំណិនស្វែងរកព័ត៌មានដ៏ល្អ នឹងត្រូវបានប្រើប្រាស់កាន់តែច្រើនថែមទៀត នៅពេលសិស្សបន្តការសិក្សាកាន់តែខ្ពស់ ឬក្នុងជីវិតការងារជាដើម។ បំណិនស្រាវជ្រាវ និងសមត្ថភាពញែក «អង្ករចេញពីអង្កាម» នៅក្នុងលទ្ធផលស្រាវជ្រាវ គឺមានសារៈសំខាន់សម្រាប់គ្រូ ក្នុងការផ្ទេរចំណេះដឹងទៅឲ្យសិស្ស។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ប្រតិបត្តិ

**សកម្មភាពសិស្ស «បំណិនស្វែងរកព័ត៌មាន ១»**

ចូរឲ្យសិស្សបំផុសគំនិតអំពីរបៀបទទួលយកព័ត៌មានគួរជាទីទុកចិត្តបានដែលពាក់ព័ន្ធនឹង៖

- តារាងពេលវេលារបស់ឡានក្រុង
- របៀបជួសជុលម៉ូតូ
- ការសិក្សាបន្ថែម (ការអប់រំផ្នែកវិជ្ជាជីវៈ និងការអប់រំកម្រិតខ្ពស់)

**សកម្មភាពសិស្ស «បំណិនស្វែងរកព័ត៌មាន ២»**

ចូរបំបែកសិស្សជាក្រុមតូចៗ ហើយផ្តល់ប្រធានបទឲ្យក្រុមនីមួយៗ (សត្វ ប្រទេស សកម្មភាពពេលទំនេរ។ល។) ដើម្បីធ្វើបទបង្ហាញខ្លីមួយក្នុងថ្នាក់។ ដើម្បីអនុវត្តជំហានដំបូងនៃការស្រាវជ្រាវខ្នាតតូច ចូរប្រាប់សិស្សឲ្យបំផុសគំនិតនៅក្នុងក្រុមតូច ហើយកត់ត្រាអំពី៖

- ❖ តើអ្នកដឹងអ្វីខ្លះអំពីប្រធានបទ?
- ❖ តើព័ត៌មានអ្វីខ្លះដែលអ្នកត្រូវការបន្ថែម?
- ❖ តើយើងអាចស្វែងរកព័ត៌មានពាក់ព័ន្ធនៅឯណា? តើមានប្រភពព័ត៌មានអ្វីខ្លះដែលមាននៅទីនោះ?
- ❖ តើយើងអាចស្វែងរកព័ត៌មានដោយរបៀបណា?
- ❖ តើព័ត៌មានទាំងអស់ អាចទុកចិត្តបាន ថ្មី និងត្រឹមត្រូវដែរឬទេ? តើយើងធានាថាទុកចិត្តបានដោយរបៀបណា?

### ខ.២ ការធ្វើឲ្យបំណិនចងចាំប្រសើរឡើង

សមត្ថភាពមនុស្សក្នុងការចងចាំព័ត៌មានមានលក្ខណៈផ្សេងពីគ្នា។ មនុស្សខ្លះរក្សាព័ត៌មានបន្ថែមដោយការស្តាប់ ការបង្រៀន ចំណែកអ្នកខ្លះទៀត ចូលចិត្តបទបង្ហាញដោយការមើលផងស្តាប់ផង ឬការអាន និងការសរសេរ។

**សកម្មភាពសិស្ស «ការធ្វើឲ្យបំណិនចងចាំប្រសើរឡើង ១»**

ចូរណែនាំសិស្សឲ្យស្គាល់ប្រធានបទ ដោយការពិភាក្សាជាក្រុមធំ ឬជាក្រុមតូច។

**សំណួរពិភាក្សា៖**

- តើអ្នករៀនបទចម្រៀងដោយវិធីណា?
- តើអ្នកងាយភ្លេចអ្វីជាងគេ?
- ហេតុអ្វីបានជាការធ្វើកិច្ចការផ្ទះបន្ទាប់ពីរៀនចប់ពីសាលាភ្លាម មានសារៈសំខាន់?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

### សកម្មភាពសិស្ស «ការធ្វើឲ្យបំណិនចងចាំប្រសើរឡើង ២»

បង្កើតកាតល្បែងចងចាំ ដោយប្រើពាក្យ ឬរូបភាព (ពោលគឺ ការងារ កិច្ចការ កន្លែងការងារ) ហើយលេងជាមួយសិស្សរបស់អ្នក។

### សកម្មភាពសិស្ស «ការធ្វើឲ្យបំណិនចងចាំប្រសើរឡើង ៣»

ចូរដាក់របស់ឬវត្ថុចំនួន ១៥ ទៅ ២០ នៅលើតុ។ ប្រាប់សិស្សរបស់អ្នកឲ្យឈរជុំវិញតុ ហើយហាមនិយាយគ្នា។ អនុញ្ញាតឲ្យសិស្សមើលវត្ថុទាំងនោះចំនួនមួយនាទី រួចសឹមគ្របតុឬវត្ថុ ដោយក្រដាសធំមួយផ្ទាំង។ បន្ទាប់មក ប្រាប់ពួកគេឲ្យសរសេរវត្ថុទាំងនោះ នៅក្នុងសៀវភៅទៅតាមការចងចាំរបស់ពួកគេ។

### សកម្មភាពសិស្ស «ការធ្វើឲ្យបំណិនចងចាំប្រសើរឡើង ៤»

ប្រាប់សិស្សឲ្យធ្វើការជាមួយដៃគូ (សិស្ស ក និងសិស្ស ខ)។ សិស្ស ក ប្រាប់សិស្ស ខ អំពី __________ (ពោលគឺ សកម្មភាពជាទីពេញចិត្តណាមួយ ឬ ក្រុមគ្រួសារ) ដោយប្រើពេល ២ ឬ ៣នាទី។ បន្ទាប់មក សិស្ស ខ និយាយប្រាប់សិស្ស ក វិញនូវអ្វីដែលគេបានប្រាប់ដោយនិយាយថា «ខ្ញុំឮអ្នកនិយាយថា...» ។ ចូរបញ្ចប់សកម្មភាពដោយសួរសិស្សថា តើពួកគេចាំរឿងដើមបានច្រើនប៉ុណ្ណា?

### ខ.៣ ការអានដែលមានប្រសិទ្ធិភាព

ការអានសៀវភៅមិនមានភាពលំបាក ឬស៊ីពេលដូចអ្នកគិតនោះទេ។ ចំណុចសំខាន់ គឺការរៀនរបៀបអានឲ្យមានប្រសិទ្ធិភាព។ ជំហានខាងក្រោមនឹងជួយអ្នកឲ្យស្រូបយក និងរក្សាព័ត៌មានខណៈដែលអ្នកកំពុងអាន៖

- ពិនិត្យមើលជំពូកមុនពេលអាន។ អានចំណងជើងជំពូកនោះឲ្យលឿន ចំណងជើង រូបភាព ក្រាហ្វិក ដ្យាក្រាម និងតារាង។ ចូរអានកថាខ័ណ្ឌដំបូង និងសេចក្តីសង្ខេបនៅខាងក្រោយជំពូក។ ចូរស្វែងរកពាក្យសំខាន់ៗ និងគំនិតថ្មីៗ។ គោលបំណងនៃការពិនិត្យជំពូក គឺដើម្បីដឹងឲ្យបានឆាប់ថាជំពូកនោះនិយាយអំពីអ្វី មុនពេលអ្នកអានជំពូកទាំងស្រុង។
- ផ្ចង់អារម្មណ៍ អានជំពូកឲ្យបានស៊ីជម្រៅ។ គូសបន្ទាត់ពីក្រោមពាក្យគន្លឹះ និងព័ត៌មានសំខាន់ៗ និងកត់ត្រាទុក។
- សូត្រ ឬអានផ្នែកខ្លីៗ ហើយឈប់។ ចូរគិតអំពីអ្វីដែលអ្នកបានអាន និងព័ត៌មានដែលអ្នកបានសិក្សា។ ជំនួសការខំប្រឹងទន្ទេញទាំងអស់ ចូរស្វែងយល់អត្ថបទឲ្យបានស៊ីជម្រៅ។ ចូរអានផ្នែកបន្ទាប់ នៅពេលដែលអ្នកមានអារម្មណ៍ថា អ្នកយល់ច្បាស់នូវខ្លឹមសារហើយ ចូរអ្នកព្យាយាមរកនឹកប្រធានបទសំខាន់ៗ និងពាក្យគន្លឹះសំខាន់ៗដោយខ្លួនឯង។ ការ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

រៀបចំគំនិតទាំងនោះឡើងវិញ ដោយប្រើប្រាស់ពាក្យរបស់អ្នកខ្លួនឯង នឹងជួយឲ្យមានការចងចាំបានល្អ។ ប្រសិនបើអ្នកនៅមិនទាន់ច្បាស់ទេ ចូរអានអត្ថបទម្តងទៀត។

- ❖ រំឭកសារឡើងវិញ នូវអ្វីដែលអ្នកបានរៀន។ មើលកំណត់ត្រាត្រួសៗ ដើម្បីរំឭកនូវប្រធានបទសំខាន់ៗ ដែលបានរៀននៅក្នុងជំពូកនោះ។ ចូរព្យាយាមទាយសំណួរដែលគ្រូរបស់អ្នកអាចចេញនៅពេលប្រឡង ហើយរៀនឆ្លើយសំណួរ។

## ជំហានផ្សេងៗសម្រាប់ការអានដែលមានប្រសិទ្ធិភាព

- ❖ អានដោយប្រើល្បឿនផ្សេងគ្នា។ ចូរមើលត្រួសៗ និងអានចុះអានឡើងឲ្យបានឆាប់អំពីព័ត៌មានមិនសូវសំខាន់ និងអានផ្នែកដែលសំខាន់ដោយប្រុងប្រយ័ត្ន។
- ❖ ចូរនិយាយអំពីអត្ថបទ ជំពូក ឬសៀវភៅជាមួយនរណាម្នាក់។
- ❖ ការពិនិត្យឡើងវិញ នូវកំណត់ត្រារបស់អ្នកឲ្យបានទៀងទាត់ និងការអានក្នុងអំឡុងឆ្នាំសិក្សា នឹងជួយសម្រួលដល់បន្ទុកការងាររបស់អ្នក និងជួយអ្នកឲ្យមានភាពជោគជ័យក្នុងការប្រឡង។

## ខ.៤ ការកត់ត្រា

ការរៀនអំពីរបៀបកត់ត្រាបានល្អ ពិតជាមានសារៈសំខាន់ណាស់។ ការកត់ត្រាជួយដល់ការយល់ដឹង និងចងចាំ នូវខ្លឹមសារនៃការបង្រៀន និងឯកសារអំនានផ្សេងៗផងដែរ។ អ្នកនឹងត្រូវមើលកំណត់ត្រារបស់អ្នកផងដែរ នៅពេលអ្នកសិក្សាដើម្បីធ្វើតេស្ត និងការប្រឡង។ អ្នកអាចពង្រឹងគុណភាពនៃកំណត់ត្រារបស់អ្នកដោយប្រើទម្រង់ផ្សេងៗគ្នា និងបច្ចេកទេសផ្សេងៗគ្នាក្នុងការកត់ត្រាព័ត៌មាន។

ចូរប្រើកាតកត់ត្រាដើម្បីសិក្សាឡើងវិញនូវគំនិត និងព័ត៌មានសំខាន់ៗ។ កាន់កាតមកជាមួយអ្នក (ពោលគឺ ដាក់ក្នុងកាបូប) ពីព្រោះកាតកត់ត្រាមានភាពងាយស្រួលក្នុងការអានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ អ្នកអាចដាក់ក្រដាសស្អិត នៅលើជញ្ជាំង ឬតុនៅផ្ទះ។ កាតកត់ត្រាក៏មានប្រយោជន៍នៅពេលមានការរៀបចំ និងសរសេរកិច្ចការ។ អ្នកអាចដាក់វាតាមលំដាប់លំដោយឡើងវិញ ឬដាក់លើកម្រាល ដើម្បីភ្ជាប់គំនិត និងការគិតរបស់អ្នក។

## ខ.៥ ការប្រើចន្លោះទំនេរពណ៌ស «ការកត់ត្រាលើគែមក្រដាស»

ចូរសង្ខេបគំនិតចម្បងរបស់កថាខ័ណ្ឌនៅលើគែមក្រដាស។ វាជួយឲ្យអ្នករកព័ត៌មានបានឆាប់រហ័ស ខណៈដែលអ្នកពិនិត្យអត្ថបទឡើងវិញ។ អ្នកក៏អាចដាក់សញ្ញា « ? » នៅគែមក្រដាសត្រង់ផ្នែកដែលច្របូកច្របល់ ឬផ្នែកដែលអ្នកមិនទាន់យល់ទាំងស្រុង។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ខ.៦ ការបញ្ចូលគ្នា ហើយស្វែងយល់

ចូរប្រើក្រដាស A4 ដើម្បីឲ្យមានកន្លែងគ្រប់គ្រាន់សម្រាប់សរសេរ គូរតារាង ឬរូបភាព។ ចូរបញ្ចូលព័ត៌មានចាស់ជាមួយព័ត៌មានថ្មី។ ចូរប្រើពាក្យរបស់អ្នកផ្ទាល់ ដើម្បីពន្យល់ពាក្យ និងគំនិត។

## ខ.៧ ផែនទីគំនិត

ការគូរផែនទីដែលអាចមើលឃើញ អាចយកទៅប្រើនៅពេលត្រៀមខ្លួនប្រឡង ការរៀបចំរចនាសម្ព័ន្ធសម្រាប់តែងសេចក្តី និងការធ្វើបទបង្ហាញ ការបំផុសគំនិត និងការទន្ទេញកំណត់ត្រាអំពីមុខវិជ្ជា សៀវភៅ និងឯកសារផ្សេងៗ។ ផែនទីគំនិត អាចធ្វើឲ្យអ្នកទទួលបាននូវហេតុនិងផល និងការយល់ដឹងកាន់តែច្បាស់ជាងមុន។




## ខ.៨ ការគ្រប់គ្រងពេលវេលា

ការធ្វើផែនការអំពីរបៀបប្រើពេលវេលាដែលអ្នកមាន ជារឿងសំខាន់។ ការអប់រំ និងការគ្រប់គ្រងពេលវេលា មានសារៈសំខាន់ ប៉ុន្តែសិស្សត្រូវមានពេលវេលាសម្រាប់កិច្ចការផ្សេងៗក្នុងជីវិតរបស់គេដែរ ដូចជាពេលវេលាសម្រាប់គ្រួសារ និងមិត្តភ័ក្តិ ពេលវេលាសម្រាប់កំសាន្ត សម្រាប់

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

ទទួលទានដំណេក និងសម្រាក បើមិនដូច្នោះទេ ពួកគេមិនអាចរៀនទាន់គេឡើយ។ តើសិស្សអាចស្វែងរកតុល្យភាពរវាងជីវិត និងពេលទំនេរបានយ៉ាងដូចម្តេច?

**ប្រតិបត្តិ**

**សកម្មភាពសិស្ស/ការគ្រប់គ្រងពេលវេលា**

ចូរឲ្យសិស្សសរសេរអំពីការងារប្រចាំថ្ងៃ:

*តើគេធ្វើអ្វីរាល់ថ្ងៃ (សាលា កិច្ចការផ្ទះ ការជួបមិត្តភ័ក្តិ ការងារផ្ទះ ការទទួលទានដំណេក។ល។)? តើពួកគេប្រើពេលវេលាប៉ុន្មានសម្រាប់សកម្មភាពផ្សេងៗ?*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| *រៀន* | | | | | | | | |
| Facebook | | | | | | | | |
| *កិច្ចការផ្ទះ* | | | | | | | | |
| *កីឡា* | | | | | | | | |
| *ការដេក* | | | | | | | | |
| *ផ្សេងៗ* | | | | | | | | |

បន្ទាប់មក ប្រាប់ពួកគេឲ្យគូរតារាង (មើលរូបតារាងខាងលើ) ហើយនឹកគិតក្នុងចិត្ត ចំពោះការប្រើប្រាស់ពេលវេលា ដោយផាត់ពណ៌លើប្រអប់ជួរដេកនៃសកម្មភាពនីមួយៗ ពីព្រោះពួកគេចំណាយពេលរាប់ម៉ោងធ្វើសកម្មភាពរាល់ថ្ងៃ។

ចូរបញ្ចប់សកម្មភាពដោយពិភាក្សាជាមួយដៃគូ ឬជាក្រុមតូច។

**សំណួរពិភាក្សា៖**

- តើអ្នកប្រើប្រាស់ពេលវេលាមានប្រយោជន៍ដែរឬទេ?
- តើអ្នកអាចប្រើប្រាស់ពេលវេលាឲ្យបានប្រសើរជាងនេះដោយរបៀបណា?

ចូរផ្តល់ដំបូន្មានដល់សិស្សរបស់អ្នកឲ្យរៀបចំការងារប្រចាំថ្ងៃ ហើយរៀបចំពេលវេលាសិក្សា រួមមានការអាន ការសិក្សាកំណត់ត្រាឡើងវិញ ក្រុមសិក្សា ការរៀបចំកិច្ចការ។ល។)

**ការធ្វើកាលវិភាគប្រចាំថ្ងៃ និងកាលវិភាគសិក្សា**

កាលវិភាគ គឺជាត្រីវិស័យមួយសម្រាប់ចង្អុលបង្ហាញសកម្មភាពប្រចាំថ្ងៃរបស់សិស្ស។ សិស្សត្រូវមានកាលវិភាគផ្លូវការមួយ និងកាលវិភាគសិក្សាផ្ទាល់ខ្លួនមួយ ទើបសកម្មភាពរបស់ពួកគេមានវិន័យ។ ជាងនេះទៅទៀត ពួកគេអាចជៀសវាងទំនោរយឺតយ៉ាវចំពោះការងារ រហូតជិតដល់ពេលកំណត់ ដែលជាហេតុធ្វើឲ្យគេត្រូវធ្វើការរងសម្ពាធ។ កាលវិភាគ ក៏នឹងជួយសិស្សឲ្យចាត់ទុកពេលវេលាសិក្សារបស់គេជាការតាំងចិត្តមោះមុត និងគោរពពេលវេលា សម្រាប់ការងារផ្ទះ និងការកំសាន្តផងដែរ។ ចំណុចនេះសំខាន់ដោយឡែកសម្រាប់សិស្សស្រី ដែលត្រូវធ្វើកិច្ចការផ្ទះប្រចាំថ្ងៃផងដែរ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

ចូរណែនាំឲ្យសិស្សរៀបចំធ្វើកាលវិភាគផ្លូវការប្រចាំថ្ងៃ និងកាលវិភាគសិក្សា ដោយអោយសិស្សធ្វើការជាបុគ្គល ពិភាក្សាជាក្រុមតូច ឬជាក្រុមធំ។ បន្ទាប់ពីសិស្សរៀបចំកាលវិភាគរបស់ពួកគេ ឬក្រុមពួកគេរួចរាល់ គ្រូប្រឹក្សាអាជីពត្រូវឲ្យសិស្សឡើងបង្ហាញកាលវិភាគរបស់ពួកគេនៅក្នុងថ្នាក់ ហើយឲ្យសិស្ស ឬក្រុមដទៃទៀត ពន្យល់អំពីមូលហេតុដែលក្រុមខ្លួនបង្កើតកាលវិភាគនេះឡើង។

## ឥរិយាបថក្នុងការប្រឡង

### គោលការណ៍ណែនាំអនុវត្ត

ចូរបែងចែកសិស្សជា ៣ក្រុម ដោយក្រុមទី១ ពិភាក្សាអំពីឥរិយាបថមុនពេលប្រឡង ក្រុមទី២ ពិភាក្សាអំពីឥរិយបថក្នុងពេលប្រឡង រីឯក្រុមទី៣ ពិភាក្សាអំពីឥរិយាបថក្រោយពេលប្រឡង។ ក្រោយពីសិស្សពិភាក្សាទៅតាមចំនួនម៉ោងដែលគ្រូបានកំណត់រួច គ្រូត្រូវឲ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍អំពីការយល់ឃើញរបស់ពួកគេ។ បន្ទាប់ពីក្រុមទាំង៣ឡើងរាយការណ៍រួចមក គ្រូត្រូវទុករយៈពេលសមស្របណាមួយ ដើម្បីឲ្យក្រុមទាំង៣ មានមតិកែលម្អ ឬបន្ថែមនូវព័ត៌មាន ឬសកម្មភាពដែលពួកគេយល់ឃើញទៅតាមដំណាក់កាលនីមួយៗ។

### ប្រតិបត្តិ



គ្រូបែងចែកក្រដាសផ្ទាំងធំ និងប៊ិចហ្វឺត ដល់ក្រុមទាំង៣ ដើម្បីកត់ត្រាការពិភាក្សាក្រុម។ គ្រូត្រូវដើរតួជាអ្នកសម្របសម្រួលក្នុងអំឡុងពេលពិភាក្សា អំឡុងពេលឡើងរាយការណ៍ និងក្រោយពេលផ្លាស់ប្តូរយោបល់រវាងក្រុមទាំង៣ និងបំពេញបន្ថែមនូវព័ត៌មានមួយចំនួនដល់សិស្សដូចខាងក្រោម៖

**ឥរិយាបថមុនពេលប្រឡង**

- បន្តរៀនរហូតដល់ថ្ងៃប្រឡង
- អាន និងព្យាយាមឆ្លើយវិញ្ញាសាមុនៗ ឬធ្វើវិញ្ញាសាមុនៗ ទើបអ្នកអាចយល់ដឹងពីកម្រិតនៃភាពលំបាករបស់វិញ្ញាសាប្រឡងបាន
- ត្រូវស្វែងយល់អំពីបទប្បញ្ញត្តិប្រឡង និងត្រូវចេះពីរបៀបគ្រប់គ្រងពេលវេលាក្នុងការប្រឡង
- ត្រូវពិនិត្យមើលកាលវិភាគប្រឡង ម៉ោងប្រឡងឲ្យច្បាស់ ដើម្បីដឹងថាតើអ្នកត្រូវប្រឡងមុខវិជ្ជាអ្វី នៅថ្ងៃណា ម៉ោងណា។ ត្រូវអាន ឬរំឭកឡើងវិញនូវបទប្បញ្ញត្តិក្នុងការប្រឡង ថាតើគេអនុញ្ញាតឲ្យអ្នកយកអ្វីខ្លះចូលបន្ទប់ប្រឡង។ នៅយប់មុនថ្ងៃប្រឡងមួយយប់ ត្រូវត្រៀមឲ្យស្រេចនូវ សម្ភារដែលចាំបាច់ដូចជា ប៊ិច ខ្មៅដៃ បន្ទាត់ត្រង់ បន្ទាត់កែង ប៉ារ៉ាបូល រ៉ាប់ប៉ទ័រ នាឡិការដៃ និងសម្ភារណាដែលចាំបាច់ផ្សេងទៀត។
- ត្រូវស្រូតចូលគេង ទើបអ្នកគេងបានគ្រប់គ្រាន់ ដើម្បីការប្រឡងថ្ងៃស្អែក។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

### ឥរិយាបថក្នុងពេលប្រឡង

- កុំភ្លេចយកប៊ិច ខ្មៅដៃ នាឡិកាដៃ និងសម្ភារមួយចំនួនទៀត ទៅតាមខ្លួនពេលទៅប្រឡង
- ក្នុងអំឡុងពេលប្រឡង ត្រូវធ្វើចិត្តឲ្យស្ងប់ តាមដែលអ្នកអាចធ្វើបាន
- ចូរអានការណែនាំនៅលើវិញ្ញាសាដោយប្រុងប្រយ័ត្ន ហើយកត់សម្គាល់ដូចខាងក្រោម៖
    - តើវាជាផ្នែក ឬសំណួរដែលយើងត្រូវតែធ្វើ ឬអាចរំលងចោលបាន?
    - តើសំណួរហ្នឹងបានពិន្ទុប៉ុន្មាន?
    - តើសំណួរដែលត្រូវតែឆ្លើយយកពិន្ទុមានប៉ុន្មានសំណួរ?
    - តើត្រូវសរសេរលេខចម្លើយ ទៅក្នុងក្រដាសចម្លើយយ៉ាងដូចម្តេច?
- ត្រូវខិតខំប្រឹងប្រែងយកឲ្យបានពិន្ទុខ្ពស់លើវិញ្ញាសាពិសេសណាមួយ។ អ្នកត្រូវគិតថា រាល់ពិន្ទុ នៅក្នុងផ្នែក ឬរ៉ូម៉ាំងនីមួយក្នុងសន្លឹកវិញ្ញាសា គឺសុទ្ធតែជាពិន្ទុដែលធ្វើឲ្យអ្នកជាប់ក្នុងការប្រឡង។ អ្នកត្រូវចាំថា រាល់ពិន្ទុបន្ថែម អាចនឹងផ្លាស់ប្តូរជីវិត និងអាជីពរបស់អ្នកពេញមួយជីវិត។
- ត្រូវឆ្លើយសំណួរងាយៗមុនគេ បន្ទាប់មកសឹមឆ្លើយសំណួរពិបាកៗ។
- ត្រូវសរសេរចម្លើយរបស់អ្នកឲ្យផ្ចិតផ្ចង់ និងមានរបៀប ដើម្បីបង្កើនចំណាប់អារម្មណ៍ល្អដល់អ្នកកែ។
- ត្រូវបង់លេខចម្លើយ ចំពោះសំណួរនីមួយៗឲ្យបានច្បាស់លាស់
- ត្រូវយកចិត្តទុកដាក់ ក្នុងការសរសេរអក្ខរាវិរុទ្ធ និងល្បះឲ្យបានត្រឹមត្រូវ នៅក្នុងចម្លើយរបស់អ្នក ពីព្រោះថាកំហុសឆ្គងទាំងអស់នេះ នឹងបន្ថយចំណាប់អារម្មណ៍ល្អចំពោះអ្នកកែ ហើយអាចនឹងធ្វើឲ្យអ្នកកែផ្តល់ពិន្ទុដោយមិនបានពិនិត្យចម្លើយរបស់អ្នកត្រឹមត្រូវ។
- បើអ្នកប្រឡងតែងសេចក្តី អ្នកត្រូវមានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់។ អ្នកត្រូវសិក្សាប្រធានបទឲ្យបានច្បាស់ថា តើជាប្រធានបែបពិពណ៌នា បែបពន្យល់ ពិភាក្សា ឬប្រៀបធៀប ទើបអ្នកអាចកំណត់គម្រោងតែងបានត្រឹមត្រូវល្អ។
- រវាងចម្លើយមួយ និងចម្លើយមួយទៀត អ្នកត្រូវចុះបន្ទាត់ដោយរំលងមួយបន្ទាត់ ដើម្បីឲ្យអ្នកកែ ដឹងថាអ្នកកំពុងឆ្លើយសំណួរបន្ទាប់។
- អ្នកត្រូវយល់អត្ថន័យកិរិយាស័ព្ទ ឬពាក្យគន្លឹះ ដែលគេតែងប្រើនៅក្នុងវិញ្ញាសាប្រឡង ដូចជា ប្រៀបធៀប ពន្យល់ កំណត់ ចង្អុលបង្ហាញ ពណ៌នា ពិភាក្សា បរិយាយ វាយតម្លៃ បកស្រាយ បង្ហាញភាពសមហេតុផល គូសបញ្ជាក់ អះអាង ភ្ជាប់ សង្ខេប រៀបរាប់ត្រួសៗ...
- ប្រសិនបើអ្នកធ្វើវិញ្ញាសាប្រឡងចប់មុនម៉ោងកំណត់ អ្នកត្រូវអានវិញ្ញាសាម្តងទៀត ហើយពិនិត្យមើលសំណួរ ដោយផ្តោតលើកិរិយាស័ព្ទ ឬពាក្យគន្លឹះ ដើម្បីឲ្យដឹងថា តើអ្នកបានឆ្លើយត្រូវតាមការចង់បានរបស់សំណួរឬអត់។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**ឥរិយាបថក្រោយពេលប្រឡង**

- ប្រសិនបើពួមិត្តភក្តិរបស់អ្នកនិយាយគ្នាអំពីអ្វីដែលពួកគេបានឆ្លើយនៅពេលប្រឡង អ្នកមិនត្រូវបាក់ទឹកចិត្ត នឹងការសន្និដ្ឋានភ្លាមៗរបស់ពួកគេនោះទេ។ អ្នកត្រូវតែត្រៀមខ្លួនសម្រាប់ប្រឡងវិញ្ញាសាបន្ទាប់ ឬមួយសម្រាក។
- ប្រសិនបើលទ្ធផលចេញមកថា អ្នកប្រឡងជាប់ នោះអ្នកនឹងទទួលបានសារអបអរសាទរមួយចំនួន។ ចុះបើសិនលទ្ធផលចេញមក បង្ហាញថា អ្នកមិនស្ថិតក្នុងចំណោមអ្នកដែលមានសំណាងទាំងនោះទេ តើអ្នកត្រូវឆ្លើយតបនឹងស្ថានភាពបែបនេះយ៉ាងដូចម្តេច?

## ២.៩ ការសន្និដ្ឋានលើសកម្មភាពសិស្ស

ចូរសរសេររូបមន្តនៃការសិក្សាដោយប្រាប់ខ្លួនឯងអំពីរបៀបសិក្សាប្រកបដោយប្រសិទ្ធិភាព។ ចូរដាក់បញ្ចូលគ្រឿងផ្សំ និង «រូបមន្ត» (ជំហាន) ដើម្បីក្លាយជាអ្នកសិក្សាដ៏មានប្រសិទ្ធិភាព។

## ៤. កត្តាដែលមានឥទ្ធិពលលើការសិក្សា

ចូរចំណាយពេលអានសំណួរខាងក្រោមឲ្យបានហ្មត់ចត់ ហើយបន្ទាប់មកចូរសរសេរចម្លើយរបស់អ្នក។

- តើអ្នកមានអារម្មណ៍ដូចម្តេចនៅពេលអ្នកទទួលទានដំណេកមិនបានល្អ ឬមិនគ្រប់គ្រាន់?
- តើអ្នកមានអារម្មណ៍ដូចម្តេចបន្ទាប់ពីបានសកម្មភាពជាទីពេញចិត្ត ដូចជាលេងកីឡា ឬការកំសាន្តផ្សេងៗ?
- ហេតុអ្វីបានជាការជឿជាក់ថា អ្នកនឹងជោគជ័យ និងគ្រប់គ្រងការសិក្សារបស់អ្នកបានល្អពិតជាមានសារៈសំខាន់?
- ហេតុអ្វីបានជាការកំណត់គោលដៅសម្រាប់ខ្លួនឯងមានសារៈសំខាន់?

ចូររៀបរាប់អំពីបទពិសោធន៍ដ៏រីករាយដែលអ្នកមាន ទាក់ទងនឹងការរៀនសូត្រ និងការសិក្សាពីអ្វីមួយ។

- តើអ្វីជាកត្តាជំរុញ និងលើកទឹកចិត្តអ្នក?
- តើអ្នកមានប្រតិកម្មដូចម្តេចបើសិនជាអ្នកបានពិន្ទុមិនល្អក្នុងការប្រឡង?
- បើសិនជាអ្នកមានបញ្ហាក្នុងការរៀនសូត្រនៅសាលារៀន តើអ្នកអាចដោះស្រាយបញ្ហានោះយ៉ាងដូចម្តេច? តើអាចនឹងមានអ្វីកើតឡើងប្រសិនបើអ្នកមិនធ្វើអ្វីសោះ?
- ប្រសិនបើអ្នកត្រូវការជំនួយ ហើយមិនសុំគេឲ្យជួយ តើវាអាចនាំឲ្យមានបញ្ហាថែមទៀតដោយរបៀបណា?
- តើអ្នកនិយាយ ឬធ្វើយ៉ាងដូចម្តេច នៅពេលដែលមានមនុស្សដែលអ្នកស្គាល់ ត្រូវការជំនួយពីអ្នក?

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

## ៧.២. ការប្រឹក្សាយោបល់លើបញ្ហាផ្ទាល់ខ្លួន

កញ្ចប់មេរៀននេះ មានបង្ហាញនូវចំណុចសំខាន់ៗដូចខាងក្រោម៖

- បញ្ហាពាក់ព័ន្ធនឹងអារម្មណ៍
- បញ្ហាពាក់ព័ន្ធនឹងការខកចិត្ត
- បញ្ហាពាក់ព័ន្ធនឹងការរងសម្ពាធ
- បញ្ហាពាក់ព័ន្ធនឹងក្តីបារម្ភអំពីអនាគត
- បញ្ហាពាក់ព័ន្ធនឹងជម្លោះ

ផ្នែកនីមួយៗ មានគោលការណ៍ណែនាំសម្រាប់គ្រូ ដោយមានសេចក្តីផ្តើមខ្លីពាក់ព័ន្ធនឹងចំណុចសំខាន់ៗ ឬការរួមបញ្ចូលនូវអានុសាសន៍ និងការណែនាំសម្រាប់សកម្មភាពសិស្ស។ វិធីសាស្ត្រសិក្សាសំខាន់ៗដែលប្រើ គឺការឆ្លុះបញ្ចាំងពីបុគ្គលម្នាក់ៗ និងការងារជាក្រុម។

មេរៀនទាំងនេះអាចយកទៅបង្រៀនពេញមួយឆ្នាំសិក្សាបាន។ ទោះជាយ៉ាងណា ដើម្បីចៀសវាងកុំឲ្យមានបញ្ហាកើតឡើង ការគិតទុកមុននូវស្ថានភាពដែលអាចនឹងកើតមាននាពេលអនាគត និងការបង្កើនសេចក្តីក្លាហានរបស់សិស្ស ឲ្យលើកឡើងនូវបញ្ហាលំបាក ព្រមទាំងការដោះស្រាយបញ្ហានោះ ពិតជាមានសារៈសំខាន់។ *សកម្មភាព និងសំណួរពិភាក្សាជាច្រើន អាចយកមកប្រើបានផងដែរសម្រាប់ការប្រឹក្សាទល់មុខ។*

**ប្រតិបត្តិ** 

### ក. បញ្ហាពាក់ព័ន្ធនឹងអារម្មណ៍

ចូរណែនាំសិស្សរបស់អ្នកឲ្យស្គាល់ពីប្រធានបទដោយសកម្មភាព ១ ២ ឬ ៣ ខាងក្រោម។

### សកម្មភាពសិស្ស «បញ្ហាពាក់ព័ន្ធនឹងអារម្មណ៍ ១»

ចូរពិភាក្សាជាក្រុមតូច៖

*តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចថ្ងៃនេះ? ឥឡូវនេះអ្នកកំពុងមានអារម្មណ៍ដូចម្តេចដែរ?*

*តើអ្នកមានអារម្មណ៍បែបណាខ្លះចំពោះការងារប្រចាំថ្ងៃ?*

*តើអារម្មណ៍បែបណាដែលពិបាកបង្ហាញបំផុត? ហេតុអ្វី?*

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## សកម្មភាពសិស្ស «បញ្ហាពាក់ព័ន្ធនឹងអារម្មណ៍ ២»

ចូរធ្វើការជាក្រុមតូចៗ ហើយប្រាប់សិស្សឲ្យរៀបរាប់អំពីពេលមួយដែលពួកគេមានអារម្មណ៍ ហើយនិយាយត្រួសៗអំពីស្ថានភាពនោះ។ (កំណត់សម្គាល់ចំពោះគ្រូ: ចូរជ្រើសយកអារម្មណ៍ម្តងមួយ ដើម្បីពិភាក្សា ដូចជា សប្បាយ ក្រៀមក្រំ ច្របូកច្របល់ ឯកា ។ល។)

## សកម្មភាពសិស្ស «បញ្ហាពាក់ព័ន្ធនឹងអារម្មណ៍ ៣»

ចូរធ្វើការជាក្រុមដែលមានសមាជិក ពី៥ ទៅ៦នាក់។ ចែកក្រដាស ឲ្យសិស្សម្នាក់២សន្លឹក។ ប្រាប់ពួកគេឲ្យសរសេរនូវអារម្មណ៍មួយ (សប្បាយ កើតទុក្ខ ច្របូកច្របល់។ល។) នៅលើក្រដាស។ បត់ក្រដាស ហើយដាក់គរលើគ្នាលើតុ។ ចូរពន្យល់ប្រាប់ពួកគេឲ្យដូរ វេណគ្នា និងជ្រើសរើសយកក្រដាសដែលបត់ម្តងមួយៗ ហើយអានឲ្យខ្លាំងៗ បន្ទាប់មក៖

ក. ចូរនិយាយប្រាប់សមាជិកក្រុមផ្សេងទៀតអំពីសត្វដែលធ្វើឲ្យគេមានអារម្មណ៍បែបហ្នឹង (ឧទា. ឃ្មុំ=រវល់ បក្សី=សប្បាយរីករាយ ខ្លាឃ្មុំ=ឯកា) ហើយ

ខ. រៀបរាប់អំពីសត្វប្រភេទណាដែលធ្វើឲ្យគេមានអារម្មណ៍បែបនោះ។ បន្ទាប់មក ចែករំលែកសេចក្តីផ្តើមពាក់ព័ន្ធនឹងអារម្មណ៍ទៅកាន់សិស្ស។ ជួនកាលយើងមានអារម្មណ៍ល្អ ហើយជួនកាលយើងមានអារម្មណ៍មិនល្អ។ ជាការពិតណាស់ យើងទាំងអស់គ្នា ពេញចិត្តនឹងអារម្មណ៍ល្អ ប៉ុន្តែជារឿងធម្មតាទេដែលថាមនុស្សយើងមានអារម្មណ៍ទាំងពីរបែបនេះ។ យើងត្រូវបើកចិត្តទទួលយកអារម្មណ៍ទាំងអស់ មិនចាំបាច់តែអាម្មណ៍វិជ្ជាមានៗនោះទេ។ អារម្មណ៍ជាច្រើនបែប តែងមានវត្តមានពេញមួយថ្ងៃនៅក្នុងខ្លួនយើង និងក្នុងខ្លួនអ្នកដទៃ។

នៅពេលយើងមិនពេញចិត្តនឹងអារម្មណ៍ដែលយើងកំពុងមាន យើងតែងតែមិនដឹងថាត្រូវធ្វើយ៉ាងដូចម្តេច ហើយត្រូវដោះស្រាយយ៉ាងណា។ ដំបូងយើងត្រូវទទួលយកអារម្មណ៍បែបនោះសិន បន្ទាប់មកយើងបណ្តោយអារម្មណ៍ហ្នឹងសិនទៅ។ មានតែធ្វើដូច្នេះទេទើបយើងអាចដោះស្រាយជាមួយវាបាន។

### ចូរបន្តពិភាក្សានៅក្នុងក្រុមតូច:

*ចូរពិពណ៌នា អំពីស្ថានភាពមួយ ដែលអ្នកមានអារម្មណ៍ ថាខឹងចំពោះអ្វីមួយដែលពាក់ព័ន្ធនឹងសាលារៀន។ តើអ្នកនិយាយ ឬធ្វើដូចម្តេចក្នុងស្ថានភាពនេះ? តើមនុស្សផ្សេងទៀត មានប្រតិកម្មបែបណា? ហេតុអ្វីបានជាការបញ្ចេញអារម្មណ៍ដោយការនិយាយមកកាន់នរណាម្នាក់ ឬការសរសេរអំពីអារម្មណ៍នោះ មានសារៈសំខាន់?*

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**សកម្មភាពសិស្សបន្ថែម «បញ្ហាពាក់ព័ន្ធនឹងអារម្មណ៍»**

ក. ចូរប្រាប់សិស្សឲ្យសរសេរក្នុងបញ្ជី នូវរឿងទាំងឡាយណាដែលធ្វើឲ្យពួកគេសប្បាយ ឬមានអារម្មណ៍ល្អលើខ្លួនឯង។

ខ. ចូរប្រាប់សិស្សក្នុងថ្នាក់ឲ្យសរសេរក្នុងបញ្ជីនូវឈ្មោះអ្នកអាចជួយ និងមានពេលមកជួបពួកគេបាន នៅពេលណាដែលពួកគេមិនសប្បាយចិត្ត ព្រួយបារម្ភ ឬភ័យខ្លាចអំពីអ្វីមួយ។

## ខ. បញ្ហាពាក់ព័ន្ធនឹងការខកចិត្ត

ចូរណែនាំសិស្សឲ្យស្គាល់ពីប្រធានបទដោយសកម្មភាពដូចខាងក្រោម។

**សកម្មភាពសិស្ស «បញ្ហាពាក់ព័ន្ធនឹងការខកចិត្ត ១»**

ចូរប្រាប់សិស្សឲ្យធ្វើការជាបុគ្គល ហើយគូរតារាង (ចូរមើលតារាងគំរូ ខាងក្រោម) នៅក្នុងសៀវភៅរបស់គេ។ បន្ទាប់មកប្រាប់ពួកគេឲ្យពិពណ៌នាត្រួសៗអំពីស្ថានភាព ៣ ក្នុងជីវិត នៅពេលរឿងទាំងនោះមិនបានកើតឡើងដូចក្តីសង្ឃឹមទាល់តែសោះ។

| ស្ថានភាព | តើអ្នកមានអារម្មណ៍ដូចម្តេច? តើអ្វីខ្លះដែលធ្វើឲ្យមានការលំបាកសម្រាប់អ្នក? | តើអ្នកដោះស្រាយដោយរបៀបណា? |
|---|---|---|
| 1. | | |
| 2. | | |
| 3. | | |

ដោយសារតែកូឡោនពីរដំបូងអាចមានព័ត៌មានផ្ទាល់ខ្លួន និងបទពិសោធន៍ សូមផ្តល់អនុហាសន៍ថា ព័ត៌មានក្នុងនោះត្រូវចែករំលែកទៅឲ្យមិត្តរួមថ្នាក់ល្អម្នាក់ ហើយមានតែលទ្ធផលនៃកូឡានទី៣ទេ ដែលអាចចែករំលែកទៅឲ្យសិស្សក្នុងថ្នាក់បាន។ ចូរហៅសិស្សឲ្យនិយាយប្រាប់ពី

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

របៀបដោះស្រាយស្ថានភាព ឬអារម្មណ៍អាក់អន់ចិត្ត ហើយសរសេរនៅក្តារខៀន។ បន្ទាប់មក ចូរឲ្យសិស្សផ្តល់ជាយោបល់ផ្សេងៗ ដើម្បីដោះស្រាយការអាក់អន់ចិត្ត និងដើម្បីឲ្យអារម្មណ៍របស់គេកាន់តែប្រសើរឡើង។ ចូរសរសេរយោបល់នៅលើក្តារខៀន។ ពិភាក្សាគំនិតនីមួយៗ ហើយប្រាប់សិស្សឲ្យផ្តល់ជាឧទាហរណ៍ផង។

ចុងក្រោយ ចូរចែករំលែកគំនិតខាងក្រោមនេះជាមួយសិស្សរបស់អ្នក។

នៅពេលដែលការងារណាមួយមិនសមដូចបំណង អ្វីៗមើលទៅហាក់ដូចជាងងឹត។ មនុស្សម្នាក់ៗតែងមានអារម្មណ៍អាក់អន់ចិត្តប្រហាក់ប្រហែលគ្នា យើងមិនអាចចៀសផុតពីភាពលំបាក និងបរាជ័យបានទេ ព្រោះវាជាចំណែកក្នុងជីវិតរបស់យើងដែលមានជាប់ពីធម្មជាតិមក។ ទោះជាយ៉ាងក៏ដោយ យើងត្រូវរៀនពីកំហុស ពីព្រោះកំហុសមួយៗបង្ហាញពីឱកាសក្នុងការសិក្សាអ្វីដែលថ្មី។

ខាងក្រោមនេះ គឺជាជំបូន្មានមួយចំនួនដែលយើងអាចប្រើបាន ដើម្បីប្រែក្លាយការខកចិត្តទៅជារឿងល្អបំផុតចំពោះយើង៖

- ✓ កុំវិនិច្ឆ័យខ្លួនឯង ការបរាជ័យលើអ្វីមួយមិនមានន័យថា អ្នកបរាជ័យនោះទេ។
- ✓ ចូរធ្វើអ្វីមួយផ្សេងទៀតមួយរយៈសិន ពោលគឺអ្វីដែលធ្វើឲ្យអ្នកមានរម្មណ៍ប្រសើរឡើងវិញ ដូចជា លេងហ្គេម អាន មើលភាពយន្ត ឬស្តាប់តន្ត្រីដែលអ្នកពេញចិត្ត។
- ✓ និយាយអំពីបញ្ហានោះជាមួយឪពុកម្តាយ មិត្តភ័ក្តិ គ្រូប្រឹក្សាយោបល់ ឬសរសេរវានៅក្នុងសៀវភៅកំណត់ហេតុ។
- ✓ ចូរគិតដល់ស្នាដៃពីមុនរបស់អ្នក។
- ✓ ចូរគិតអំពីគុណសម្បត្តិរបស់អ្នក។
- ✓ ចូរក្រឡេកមើលដោយភាពស្រស់ស្រាយ វាតែងតែមានឱកាសថ្មីដែលយើងអាចរកបាន មានការប្រឡងថ្មីៗនៅសាលា មានមនុស្សថ្មីៗដែលយើងអាចសេពគប់ជាមិត្តបាន។
- ✓ ចូរផ្តោតលើអ្វីដែលយើងអាចស្វែងរកបាន ជាជាងអ្វីដែលមិនសូវមាន។
- ✓ ចូរគិតអ្វីដែលអ្នកអាចរៀនសូត្របានពីបទពិសោធន៍ និងរបៀបដែលអ្នកអាចធ្វើឲ្យប្រសើរទៅបាននៅពេលក្រោយ។

### គ. បញ្ហាពាក់ព័ន្ធនឹងសម្ពាធ

ចូរប្រាប់សិស្សឲ្យសរសេរសំបុត្រទៅកាន់អ្នក អំពីប្រភេទនៃសម្ពាធដែលពួកគេមាន

- ថ្មីៗនៅសាលារៀន
- អ្នកដទៃកំពុងដាក់លើពួកគេ
- អំពីអនាគត

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

ចូរប្រមូលសំបុត្រទាំងនោះ ហើយអាន។ ចូរផ្តល់ប្រឹក្សាទល់មុខ ដល់សិស្សណាដែលត្រូវការចាំបាច់។

**ចូរពិភាក្សាជាមួយគ្នា៖**

- តើសម្ពាធខាងក្នុង និងខាងក្រៅខុសគ្នាដូចម្តេច?
- តើសិស្សដាក់សម្ពាធលើខ្លួនឯងខ្លាំងពេក រហូតដល់ពួកគេមិនពេញចិត្តនឹងអ្វី ដែលខ្លួនកំពុងធ្វើមែនទេ?
- តើសិស្សដាក់សម្ពាធលើខ្លួនឯងដោយការប្រៀបធៀបខ្លួនគេជាមួយអ្នកដទៃមែនទេ?
- តើការធ្វើបែបនេះល្អដែរឬទេ?
- តើសិស្សមានគិតថាការដាក់សម្ពាធជូនកាលអាចប៉ះពាល់ដល់ការជ្រើសរើសរបស់ពួកគេដែរឬទេ? ដោយរបៀបណាខ្លះ?
- នៅពេលដែលសិស្សជួបបញ្ហាធំ តើពួកគេមានសុំជំនួយដែរឬទេ?

**សម្ពាធ** គឺជាផ្នែកដ៏សាមញ្ញមួយក្នុងជីវិត។ ការចូលរៀននៅមធ្យមសិក្សានាំមកនូវសម្ពាធថ្មីៗមួយចំនួន។ អ្វីដែលជាបញ្ហាពិតប្រាកដនោះ មិនមែនរឿងអ្នកមានសម្ពាធច្រើនប៉ុណ្ណានោះទេ ប៉ុន្តែគឺរឿងថាអ្នកគិតពីស្ថានភាពនោះបានសមហេតុផលប៉ុណ្ណា ហើយដោះស្រាយវាបានល្អប៉ុណ្ណា។

ទាំងនេះ គឺជាមធ្យោបាយវិជ្ជមានមួយចំនួនសម្រាប់ដោះស្រាយសម្ពាធ៖

- សម្រាក ហើយធ្វើអ្វីផ្សេងមួយរយៈ ធ្វើអ្វីសប្បាយៗដែលអាចធ្វើឲ្យអ្នកភ្លេចសម្ពាធនោះបាន។
- ជជែកជាមួយនរណាម្នាក់ ដូចជា មិត្តភ័ក្តិ ឪពុកម្តាយ ឬគ្រូផ្តល់ប្រឹក្សា ឬសរសេរចូលក្នុងសៀវភៅកំណត់ហេតុ។
- សុំជំនួយ
- កុំបន្ទោសខ្លួនឯងច្រើនពេក
- ត្រូវដឹងពីដែនកំណត់ខ្លួនឯង ហើយកុំធ្វើអ្វីដែលហួសពីអ្វីដែលខ្លួនឯងអាចធ្វើបាន

**ឃ. បញ្ហាពាក់ព័ន្ធនឹងជម្លោះ**

ចូរពិភាក្សាជាមួយសិស្សរបស់អ្នក:

តើអ្នកធ្លាប់មិនចុះសម្រុងជាមួយមិត្តរួមថ្នាក់ដែរឬទេ?

តើអ្វីដែលបណ្តាលឲ្យមានការមិនចុះសម្រុងនឹងគ្នា?

តើអ្នកមានអារម្មណ៍ដូចម្តេច? តើអ្វីនិយាយ ឬធ្វើអ្វីខ្លះ?

ចូរសរសេរជំហានសម្រាប់ការដោះស្រាយជម្លោះនៅលើក្តារខៀន។ ចូរពិភាក្សាជំហានមួយៗ ជាមួយសិស្ស។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

### របៀបដោះស្រាយបញ្ហាពាក់ព័ន្ធនឹងជម្លោះ

១. បញ្ឈប់ កុំឲ្យជម្លោះកាន់តែធ្ងន់ធ្ងរទៅ។
២. និយាយអំពីអ្វីដែលអ្នកគិតថាបណ្ដាលឲ្យមានភាពមិនចុះសម្រុងគ្នា។
៣. ស្ដាប់គំនិតអ្នកដទៃ និងស្វែងយល់ពីអារម្មណ៍អ្នកដទៃ។
៤. គិតស្វែងរកដំណោះស្រាយដែលធ្វើឲ្យអ្នកទាំងពីរពេញចិត្ត

### សកម្មភាពសិស្ស «បញ្ហាពាក់ព័ន្ធនឹងជម្លោះ»

ចូរប្រាប់សិស្សរបស់អ្នកឲ្យពិពណ៌នាអំពីជម្លោះ ឬភាពមិនចុះសម្រុងគ្នាដែលតែងតែកើតឡើងនៅក្នុងសាលារបស់អ្នក។ ចូរសរសេរដាក់លើក្ដារខៀន បន្ទាប់មកជ្រើសយកស្ថានភាពពីរ ឬបី ហើយពិភាក្សាថាតើជំហានសម្រាប់ដោះស្រាយបញ្ហាទាំងនេះ អាចយកមកប្រើក្នុងស្ថានភាពនីមួយៗដោយរបៀបណា។

### គំរូរបៀបដោះស្រាយជម្លោះ៥ខាងវៃ

ជម្លោះចាំបាច់ត្រូវតែដោះស្រាយដើម្បីកុំឲ្យមានភាពជាប់គាំង និងការស្ដីបន្ទោស និងដើម្បីនាំរកសុវត្ថិភាព និងការសន្ទនាមកវិញ។ ប៉ុន្តែបញ្ហានៅត្រង់ថា «តើត្រូវដោះស្រាយដោយវិធីណា?»។ វាគោលការណ៍ មានវិធីសាស្ត្រ៦យ៉ាងខុសៗគ្នា ក្នុងការដោះស្រាយស្ថានភាពជម្លោះ។ គោលការណ៍ទាំងនោះ មាន *រំដោះខ្លួន វាយតប់ បោះបង់ គេចវេសទំនួលខុសត្រូវ ចចារ ឬឈានដល់ការសុះស្រួលមតិ។*

1. **រំដោះខ្លួន** គឺជាការចៀសវាងជម្លោះ។ បើគេមិនដោះស្រាយជម្លោះទេ នោះបញ្ហានឹងនៅដដែល។ គេអាចសន្មតបានថា គ្មានភាគីណាមួយទទួលបានលទ្ធផលទេ។ នេះ គឺជាស្ថានភាពចាញ់-ចាញ់។
2. **វាយតប់** អ្នកដែលដោះស្រាយជម្លោះដោយប្រទូស្តរ៉ាយ មានគោលបំណងតែមួយគត់ គឺដើម្បីឈ្នះ។ ប៉ុន្តែការឈ្នះតែឯង មិនទាន់គ្រប់គ្រាន់ទេ នៅពេលដែលអ្នកម្ខាងទៀតចាញ់នោះ។ វិធីមួយនេះ គឺដើម្បីយកឈ្នះដៃគូរបស់ខ្លួន និងដើម្បីសំញ៉ែងអំពីជំហរផ្ទាល់ខ្លួន ដើម្បីប្រឈមនឹងការប្រឆាំងពីអ្នកដទៃ។ លទ្ធផល គឺជាស្ថានភាពឈ្នះ-ចាញ់។
3. **បោះបង់** អ្នកណាដែលបោះបង់ជំហរផ្ទាល់ខ្លួនក្នុងជម្លោះ គឺដើរចេញពីជម្លោះដោយការដកថយ ពោលគឺសុខចិត្តចាញ់។ លទ្ធផល គឺស្ថានភាពចាញ់-ឈ្នះ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

4. **គេចវេសទំនួលខុសត្រូវ** គេតែងតែ ផ្តល់អំណាចឲ្យមជ្ឈិតករ ដែលមានអារម្មណ៍នឹងន ធ្វើសេចក្តីសម្រេចចិត្ត ក៏ដូចជាប្រឈមនឹងជម្លោះ។ អំណាចនេះអាចដោះស្រាយជម្លោះឲ្យពួកគេបាន ប៉ុន្តែមិនប្រកបដោយគតិបណ្ឌិត ហើយក៏មិនប្រាកដថាត្រូវតាមចំណាប់អារម្មណ៍របស់មជ្ឈិតករដែរ។ វាអាចមានហានិភ័យត្រង់ថាភាគីជម្លោះទាំងសងខាង នឹងចាញ់ដូចគ្នា។ លទ្ធផល គឺស្ថានភាពចាញ់-ចាញ់។
5. **ចចារ** អាស្រ័យលើការបកស្រាយ ការចចារ គឺជាដំណោះស្រាយដែលអាចទទួលយកបានពីសំណាក់ភាគីទាំងពីរ។ ទោះបីជាដំណោះស្រាយនោះ មិនត្រឹមត្រូវឥតខ្ចោះក៏ដោយ ក៏វាសមហេតុផលចំពោះកាលៈទេសៈមួយចំនួនដែរ។ លទ្ធផល គឺឈ្នះ-ចាញ់/ឈ្នះ-ចាញ់។
6. **ឈានដល់ការស្រុះស្រួលមតិ** ការស្រុះស្រួលមតិគ្នា គឺជាដំណោះស្រាយថ្មីមួយដែលបង្កើតឡើងដោយភាគីទាំងពីរ។ វាផ្ទុយពីការចចារ។ វាគឺជាស្ថានភាពឈ្នះ-ឈ្នះសម្រាប់ភាគីទាំងសងខាង ពីព្រោះគ្មានភាគីណាមួយត្រូវដកថយ ឬចុះចាញ់។ ជាជំនួសវិញ ភាគីទាំងពីរ «បង្កើតផ្លូវទីបី» ជាមួយគ្នា។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ២
# ការវាយតម្លៃបុគ្គលិកលក្ខណៈ ដើម្បីតម្រង់ទិសជំនាញ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី1

## វិធីស្វែងយល់ពីខ្លួនឯង




ជំហានដំបូងក្នុងការជ្រើសរើស និងតម្រង់ទិសការងារ សិស្ស ឬនិស្សិត គឺត្រូវស្វែងយល់ពីខ្លួនឯងជាមុនសិន។ ការស្គាល់ខ្លួនឯង តម្រូវឲ្យអ្នកធ្វើការវិភាគស៊ីជម្រៅអំពីភាពខ្លាំង ភាពខ្សោយ ចរិតលក្ខណៈ ជំនាញ និងចំណាប់អារម្មណ៍ផ្សេងៗរបស់ខ្លួន។ ជំពូកនេះ នឹងផ្តោតលម្អិតពីប្រភពទាំងពីរយ៉ាង ដែលអាចជួយឲ្យអ្នកស្វែងយល់ពីខ្លួនឯង គឺ**តាមរយៈប្រភពក្រៅខ្លួន** ដូចជាការធ្វើកម្រងសំណួរ ការសាកសួរពីអត្តចរិត របៀបធ្វើការរបស់អ្នក ពីមិត្តភក្តិ ឬអ្នកដែលអ្នកធ្លាប់ធ្វើការជាមួយ និង**តាមរយៈប្រភពក្នុងខ្លួន** ពោលគឺការគិតវិភាគដោយខ្លួនឯង ដោយផ្អែកលើការប្រៀបធៀបយោបល់អ្នកដទៃ ជាមួយនឹងអ្វីដែលអ្នកសង្កេតពីខ្លួនឯង។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia




# តើអ្វីជាការស្វែងយល់ពីខ្លួនឯង?

ការស្វែងយល់ពីខ្លួនឯង ពុំមែនគ្រាន់តែតម្រូវឲ្យអ្នកអង្គុយសញ្ជឹងគិតនៅមួយកន្លែងតែប៉ុណ្ណោះទេ។ អ្នកក៏គួរធ្វើការងារជាមួយមនុស្សច្រើនប្រភេទ និងជំរុញខ្លួនប្រកបកិច្ចការដែលតម្រូវឲ្យអ្នករៀននិងប្រើប្រាស់ជំនាញផ្សេងៗឲ្យបានច្រើន ដូចជាការងារស្ម័គ្រចិត្តរៀបចំកម្មវិធីក្នុងសាលា ឬការបង្កើតក្លឹបសិក្សាជាដើម។ ប្រការដែលសំខាន់ គឺអ្នកបានសាកល្បងការងារផ្សេងៗឲ្យបានច្រើនប្រភេទ បើទោះជាអ្នកគិតថាខ្លួនប្រហែលជាមិនអាចធ្វើបានក៏ដោយពីព្រោះថាវាអាចគ្រាន់តែជាការប៉ាន់ស្មានរបស់អ្នកតែប៉ុណ្ណោះ។ ជួនកាល លុះត្រាតែអ្នកសាកល្បងទើបអាចឲ្យអ្នកដឹងថាខ្លួនឯងពូកែ ឬមិនពូកែ ចូលចិត្ត ឬមិនចូលចិត្តអ្វីមួយ។ តាមរយៈការប្រមូលបទពិសោធន៍នេះ អ្នកអាចស្វែងយល់ពីចំណាប់អារម្មណ៍ គុណតម្លៃ ចំនុចខ្លាំង និងចំនុចដែលអ្នកត្រូវពង្រឹងបន្ថែម។

## **ការស្វែងយល់តាមរយៈប្រភពក្រៅខ្លួន** - កម្រងសំណួរ Myers-Briggs Type Indicator (MBIT)

កម្រងសំណួរ MBIT ជាប្រភេទកម្រងសំណួរដែលវិភាគអំពីបុគ្គលិកលក្ខណៈរបស់មនុស្សតាមរយៈការសាកសួរពីប្រតិកម្មផ្សេងៗរបស់បុគ្គលម្នាក់ៗក្នុងស្ថានការណ៍ផ្សេងៗ។ លទ្ធផលពីកម្រងសំណួរនេះ រៀបរាប់ពីបុគ្គលិកលក្ខណៈទៅតាមចិត្តសាស្ត្ររបស់មនុស្សម្នាក់ៗ ដូចជា របៀបប្រមូលកម្លាំងស្មារតី របៀបស្រូបយកព័ត៌មាន របៀបសម្រេចចិត្ត របៀបរស់នៅ និងប្រកបការងារជាដើម។ ទោ[illegible]ះជាវាពុំចង្អុលបង្ហាញថា តើការងារប្រាក[illegible]ាមួយដែលអ្នកត្រូវរៀន ការស្ដាប់ពីបុគ្គល[illegible]ក្ខណៈទាំងនេះ អាចជួយឲ្យអ្នកប៉ានស្មាន[illegible]ខ្លះពីគុណតម្លៃ បន្ទាប់ពីធ្វើ និងគណនា[illegible]បរបស់អ្នកហើយ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

### **ផ្នែកទី១៖**

ចូរជ្រើសរើស[illegible]យ A B ឬ C ដែលអ្នកធ្លាប់ធ្វើ ឬគិតថានឹង[illegible]លស្ថិតក្នុងស្ថានការណ៍ផ្សេងៗ។ វាគ្[illegible]ម្លើយត្រូវ ឬខុសឡើយ។

1. ពេលអ្នក[illegible]ទៅណា អ្នកតែងតែ

*A. រៀបគម្រោងទុកជាមុន ថានឹងត្រូវធ្វើអ្វីខ្លះ ហើយនៅពេលណា។*

*B. ទៅតែម្ដង (ដោយពុំចាំបាច់រៀបចំគម្រោងអ្វីច្រើន)។*

2. ប្រសិនបើអ្នកជាគ្រូបង្រៀន អ្នកចង់បង្រៀន

*A. មុខវិជ្ជាដែលនិយាយពីតថភាព (ឧ. វិទ្យាសាស្ត្រ គណិតវិទ្យា)។*

*B. មុខវិជ្ជាដែលទាក់ទងនឹងទ្រឹស្ដី (ឧ. សីលធម៌ អក្សរសិល្ប៍ ទស្សនវិជ្ជា)។*

3. អ្នកជាមនុស្សដែល

*A. ងាយចុះសម្រុងជាមួយអ្នកដទៃ។*

*B. ស្ងប់ស្ងាត់ អៀនពុំសូវនិយាយស្ដីច្រើន។*

4. ជាញឹកញាប់ ក្នុងការសម្រេចចិត្ត អ្នក

*A. ប្រើប្រាស់អារម្មណ៍ជាជាងការគិតរកខុសត្រូវ។*

*B. ប្រើប្រាស់ការគិតរកខុសត្រូវជាជាងអារម្មណ៍។*

5. ក្នុងការបំពេញកិច្ចការផ្សេងៗ អ្នកចូលចិត្ត

*A. រកវិធីធ្វើដោយខ្លួនឯង។*

*B. ធ្វើដូចអ្វីដែលគេធ្លាប់ធ្វើជោគជ័យពីមុន។*

6. ក្នុងចំណោមក្រុមមិត្តភក្តិ អ្នកជាមនុស្សដែល

*A. ដឹងឮព័ត៌មានថ្មីៗច្រើន។*

*B. ជាអ្នកដឹងរឿងក្រោយគេ។*

7. ចំពោះការសរសេរព្រាងពីកិច្ចការ ដែលត្រូវធ្វើចុងសប្ដាហ៍

*A. មើលទៅមានប្រយោជន៍។*

*B. មិនគួរឲ្យចង់ធ្វើសោះ។*

*C. ធ្វើឲ្យអ្នកតានតឹង តែក្នុងផ្លូវល្អ (ឧ.ជំរុញឲ្យអ្នកសម្រេចកិច្ចការ)*

8. ឧបមាថា អ្នកទទួលបានការងារពិសេសមួយ អ្នកនឹង

*A. រៀបចំគម្រោងយ៉ាងល្អិតល្អន់មុននឹងធ្វើ។*

*B. ស្វែងរកថាតើត្រូវធ្វើអ្វីខ្លះបណ្ដើរៗ ដោយពុំចាំបាច់ធ្វើគម្រោងល្អិតល្អន់ពេក។*

9. អ្នកមាន

*A. មិត្តភក្តិច្រើន និងមកពីប្រភេទក្រុមផ្សេង*

ៗគ្នា។

B. មិត្តភក្តិមួយចំនួនតូច តែសុទ្ធជិតស្និទ្ធិ។

10. ប្រភេទមនុស្សដែលអ្នកសសើរជាងគេគឺ

A. ជាមនុស្សដែលដើរតាមក្រិត្យក្រមវិន័យ ដូច្នេះពុំសូវទទួលការរិះគន់។

B. ជាមនុស្សដែលធ្វើអ្វីៗ ដែលគេពុំធ្លាប់ធ្វើពីមុន ហើយពុំខ្វល់ពីពាក្យរិះគន់ឡើយ។

11. ពេលរៀបចំពិធីជប់លៀង អ្នកចូលចិត្ត

A. ព្រៀងទុកជាមុន ថាគួរមានកម្មវិធីកំសាន្តអ្វីខ្លះ។

B. មិនចាំបាច់គិតច្រើន ចាំរកកម្មវិធីកំសាន្តក្នុងពេល ...ទុំតែម្តង។

12. អ្នកចូល... ះសម្រុងជាមួយ

A. អ្នកមាន... ប្រាកដប្រជា។

B. អ្នកដែល... មីស្រមៃច្រើន។

13. ពេលអ្នក... រុងក្រុម អ្នក

A. ចូលចិត្ត... ន្ទនាជាមួយក្រុម។

B. ស្ងាត់ស្ងៀ... ាំស្តាប់គេនិយាយ។

14. តើការស... បែបណាដែលអ្នកគិតថាល្អ?

A. មនុស្សដែ... ចេះបញ្ចេញអារម្មណ៍ពិត។

B. មនុស្សដែ... បញ្ចេញហេតុផល។

youtube.com/moeyscambodia
facebook.com/moeys.gov.kh

15. ពេលអ្នកអានអត្ថបទ ឬសៀវភៅសម្រាប់កំសាន្ត អ្នកចូលចិត្ត

A. ការសរសេរដែលចេះទាក់ទាញចំណាប់អារម្មណ៍អ្នកអានតាម រយៈការប្រើប្រាស់ពាក្យពេចន៍ពិពណ៌នាប្លែកៗ។

B. ការសរសេរខ្លីៗត្រង់ចំណុច ពុំចាំបាច់រៀបរាប់ក្បាច់ក្បូរច្រើន។

16. អ្នកជាប្រភេទមនុស្សដែល

A. អាចនិយាយចុះសម្រុងជាមួយអ្នកដទៃបានភ្លាមឲ្យតែអ្នកចង់។

B. អាចនិយាយបានច្រើនតែជាមួយមនុស្សមួយចំនួន ឬក្នុងកាលៈ ទេសៈណាមួយ។

17. ចំពោះការធ្វើការតាមការវិភាគ ឬគម្រោងច្បាស់លាស់

A. អ្នកចូលចិត្តចាប់អារម្មណ៍។

B. ធ្វើឲ្យអ្នកហត់ មានអារម្មណ៍ស្ពឹកស្រពន់។

18. នៅពេលមានការកំណត់ជាមុនថាអ្នកត្រូវធ្វើសកម្មភាពមួយនៅពេលជាក់លាក់ណាមួយ ដែលពុំអាចប្តូរបាន

A. អ្នកមានអារម្មណ៍ល្អ ដែលអាចរៀបគម្រោងបានមុន។

B. វាមិនសូវជាល្អ ព្រោះត្រូវជាប់មិនអាចធ្វើអ្វីផ្សេងបាន។

19. អ្នកនឹងទទួលបានជោគជ័យច្រើនពេល

A. ធ្វើតាមគម្រោងមួយច្បាស់លាស់។

B. ដោះស្រាយបញ្ហា ដែលកើតឡើងដោយពុំមានការរំពឹងទុក និងមើលឃើញពីកិច្ចការដែលគួរធ្វើភ្លាមៗ។

20. អ្នកចង់ឲ្យគេហៅខ្លួនឯងថា

A. ជាមនុស្សចេះយល់ការជាក់ស្តែង។

B. ជាមនុស្សមានទេពកោសល្យ។

21. នៅក្នុងក្រុមមនុស្សច្រើន អ្នក

A. តែងតែដើរណែនាំខ្លួនឯងឲ្យគេ ស្គាល់។

B. ត្រូវបានអ្នកដទៃណែនាំឲ្យគេស្គាល់។

22. អ្នកជាមនុស្សដែលឲ្យតម្លៃលើ

A. មនោសញ្ចេតនាជាងហេតុផល។

B. ហេតុផលជាងមនោសញ្ចេតនា។

23. អ្នកចង់មានមិត្តភក្តិ ដែល

A. ជាមនុស្សដែលតែងតែមានគំនិតថ្មីៗ។

B. ជាមនុស្សនឹងធឹងមិនឆេវឆាវ។

24. តើមនុស្សថ្មីដែលទើបជួបអ្នក អាចដឹងពី

ចំណាប់អារម្មណ៍ ឬចំណង់ចំណូលចិត្តផ្សេងៗរបស់អ្នកបានលឿនប៉ុណ្ណា?

A. *ភ្លាមៗ។*

B. *ទាល់តែស្គាល់គ្នាយូរ។*

25. នៅក្នុងកិច្ចការប្រចាំថ្ងៃរបស់អ្នក (សម្រាប់សំណួរនេះ បើត្រូវ២ចម្លើយ អាចគូសបានទាំងពីរ)

A. *ដើម្បីកាត់បន្ថយសម្ពាធការងារ អ្នកតែងតែគ្រោងទុកមុន ថាតើត្រូវធ្វើអ្វីខ្លះ។*

B. *អ្នកចូលចិត្តធ្វើការងារបន្ទាន់ៗ ឬភ្លាមៗ ដែលតម្រូវឲ្យអ្នកធ្វើការប្រជែងជាមួយពេលវេលា។*

C. *អ្នកស្អប់[illegible]ធ្វើការក្រោមសម្ពាធខ្ពស់។*

26. អ្នកតែង[illegible]

A. *បង្ហាញ[illegible]ម្មណ៍របស់អ្នកដោយសេរី។*

B. *មិនងាយ[illegible]បញ្ចេញអារម្មណ៍របស់ខ្លួន។*

**ផ្នែកទី២៖**

ដោយផ្អែកលើ[illegible]ន័យនៃពាក្យ ឬកន្សោមពាក្យ ចូរជ្រើស[illegible]សមួយពាក្យ ឬកន្សោមពាក្យក្នុងចំណោម[illegible]សទាំង២ដែលអ្នកចាប់អារម្មណ៍ជាងគេ។

27.

A. *គម្រោងការ*

B. *គ្មានការគ្រោងទុក*

28.

A. *ការពិត*

B. *គំនិត*

29.

A. *ស្ងប់ស្ងៀម*

B. *រួសរាយរាក់ទាក់*

30.

A. *សមហេតុផលគួរឲ្យជឿ*

B. *ធ្វើឲ្យអារម្មណ៍រំភើប*

31.

A. *ស្រមើស្រមៃ*

B. *ទៅតាមស្ថានភាពជាក់ស្តែង*

32.

A. *ការទទួលគុណប្រយោជន៍*

B. *ការធ្វើឲ្យមានគុណប្រយោជន៍*

33.

A. *អ្នកនាំឲ្យមានសន្តិភាព*

B. *អ្នកវិនិច្ឆ័យរកខុសត្រូវ*

34.

A. *ដែលកើតឡើងតាមប្រព័ន្ធមានលំដាប់លំដោយ*

B. *ដែលកើតឡើងដោយឯកឯង*

35.

A. *សេចក្តីថ្លែងការណ៍*

B. *គំនិតធ្វើអ្វីមួយ*

36.

A. *អ៊ឹមអៀន*

B. *ពូកែនិយាយ*

37.

A. *វិភាគរកខុសត្រូវ*

B. *អាណិតអាសូរ*

38.

A. *បង្កើតរបស់ថ្មី*

B. *ធ្វើ*

39.

A. *តាំងចិត្តពុះពារ*

B. *លះបង់ដើម្បីធ្វើអ្វីមួយ*

40.

A. *សុភាពទន់ភ្លន់*

youtube.com/moeyscambodia YouTube facebook.com/moeys.gov.kh

B. រឹងមាំ ម៉ត់ចត់

41.

A. ជាលក្ខណៈតាមប្រព័ន្ធ

B. ជាលក្ខណៈធម្មតា

42.

A. ភាពប្រាកដប្រជា

B. ទ្រឹស្តី

43.

A. ស្ងប់ស្ងាត់

B. រស់រវើក

44.

A. យុត្តិធម៌

B. ការអ[illegible]ទឲ្យគ្នា

45.

A. មនុ[illegible]កគួរឲ្យចាប់អារម្មណ៍

B. មនុ[illegible]លទំនងមានហេតុផល

46.

A. ទឹកប[illegible]មាំ

B. កក់[illegible]

47.

A. ប្រើ[illegible]អារម្មណ៍

B. ប្រើ[illegible]ការគិត

48.

A. ន័យត្រង់

B. ន័យធៀប

49.

A. ការគិតគូរគ្រោងទុក

B. ការអាណិតអាសូរ

50.

A. ចិត្តរឹង

B. ចិត្តទន់

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# របៀបគណនា

| NO. | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| A | 2 (J) | 2 (J) | 2 (J) | 1 (F) | 1 (N) | 2 (E) | 1 (J) | 1 (J) | 2 (E) | 1 (S) | 2 (J) | 1 (S) | 1 (E) | 1 (F) | 0 (N) | 2 (E) | 2 (J) | 1 (J) | 1 (J) | 2 (S) | 2 (E) | 2 (F) | 1 (N) | 1 (E) | 1 (J) |
| B | 2 (P) | 2 (N) | 2 (I) | 2 (T) | 1 (S) | 1 (I) | 1 (P) | 2 (P) | 1 (I) | 2 (N) | 1 (P) | 2 (N) | 2 (I) | 2 (T) | 1 (S) | 2 (I) | 2 (P) | 1 (P) | 1 (P) | 2 (N) | 2 (I) | 2 (T) | 2 (S) | 1 (I) | 1 (P) |
| C | | | | | | | 1 (P) | | | | | | | | | | | | | | | | | | |

| NO. | 26 | 27 | 28 | 29 | 30 | 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 | 40 | 41 | 42 | 43 | 44 | 45 | 46 | 47 | 48 | 49 | 50 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| A | 1 (E) | 2 (J) | 2 (S) | 2 (I) | 2 (T) | 0 (N) | 1 (T) | 0 (F) | 2 (J) | 2 (S) | 1 (I) | 1 (T) | 0 (N) | 1 (T) | 1 (F) | 2 (J) | 1 (S) | 1 (I) | 1 (T) | 0 (N) | 2 (T) | 1 (F) | 1 (S) | 2 (T) | 2 (T) |
| B | 0 (I) | 2 (P) | 1 (N) | 2 (E) | 1 (P) | 2 (S) | 1 (F) | 2 (T) | 2 (P) | 1 (N) | 2 (E) | 2 (F) | 2 (S) | 1 (F) | 2 (T) | 2 (P) | 2 (N) | 1 (E) | 2 (F) | 2 (S) | 2 (F) | 2 (T) | 1 (N) | 1 (F) | 0 (F) |
| C | | | | | | | | | | | | | | | | | | | | | | | | | |

ឧទាហរណ៍៖

សំណួរទី១ អ្នកជ្រើសចម្លើយ A = 2 (J) នោះអ្នកទទួលបាន ២ ពិន្ទុ សម្រាប់អក្សរ J

សំណួរទី២ អ្នកជ្រើសចម្លើយ A = 2 (J) នោះអ្នកទទួលបាន ២ ពិន្ទុ បន្ថែមទៀតសម្រាប់អក្សរ J

សំណួរទី៣ អ្នកជ្រើសចម្លើយ A = 1 (T) នោះអ្នកទទួលបាន ១ ពិន្ទុ សម្រាប់អក្សរ T

ចុងក្រោយបូកសរុបសម្រាប់តួអក្សរនីមួយៗ រួចសរសេរនៅលើបន្ទាត់ខាងក្រោម៖

1. E: __ I: ___ តួអក្សរដែលបានខ្ពស់ជាងគេ (E ឬ I?): ___
2. S: __ N:___ តួអក្សរដែលបានខ្ពស់ជាងគេ (S ឬ N?):
3. T: __ F:___ តួអក្សរដែលបានខ្ពស់ជាងគេ (T ឬ F?):
4. U: __ P:___ តួអក្សរដែលបានខ្ពស់ជាងគេ (J ឬ P?):

| | |
|---|---|
| E = Extraverted; | I = Introverted |
| S = Sensing; | N = Intuition |
| T = Thinker; | F = Feeler |
| J = Judger; | P = Perceiver |

ក្នុងករណីពិន្ទុស្មើគ្នា

1. បើ E & I យក I
2. បើ S & N យក N
3. បើ T & F យក អ្នកភេទប្រុសយក T បើភេទស្រី យក F
4. បើ J & P យក P

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# របៀបប្រមូលកម្លាំងស្មារតី

**E** Extraverted

√ មានកម្លាំងស្មារតីពេលបានប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ
√ ចូលចិត្តនិងចង់បានការចាប់អារម្មណ៍ពីអ្នកដទៃ
√ ធ្វើសកម្មភាព ប្រព្រឹត្តហើយទើបគិត
√ ចូលចិត្តនិយាយពីអ្វីដែលខ្លួនកំពុងគិត
√ ឆាប់ដឹងចិត្តអ្នកដទៃ
√ ចែករំ ព័ត៌មានផ្ទាល់ខ្លួនបានលឿន
√ ចូលចិ ភាក្សាប្រធានបទផ្សេងៗច្រើន
√ ចូលចិ យាយច្រើនជាងស្តាប់គេនិយាយ
√ អាចប្រ ស្រ័យទាក់ទងជាមួយមនុស្សដោយរីករាយ
√ ឆ្លើយ បានឆាប់រហ័ស និងចូលចិត្តការរស់នៅរបៀបលឿនៗ
√ ផ្តោត ម្មណ៍ទៅលើបរិស្ថានជុំវិញខ្លួន
√ ឆាប់ប ះសម្រុងជាមួយអ្នកដទៃក្នុងក្រុម
√ មានមិ ក្តិ និងស្គាល់មនុស្សម្នាច្រើន

**I** Introverted

√ មានកម្លាំងពេលនៅម្នាក់ឯង
√ មិនចូលចិត្តឲ្យអ្នកដទៃចាប់អារម្មណ៍លើខ្លួនឯង
√ ចំណាយពេលគិតច្រើនមុននឹងធ្វើសកម្មភាពអ្វីមួយ
√ គិតក្នុងចិត្តច្រើន
√ មិនសូវនិយាយ ឬចែករំលែកព័ត៌មានផ្ទាល់ខ្លួនទៅអ្នកដទៃ
√ ចូលចិត្តនិយាយប្រធានបទតិច តែស៊ីជម្រៅ
√ ចូលចិត្តស្តាប់គេនិយាយច្រើនជាងនិយាយដោយខ្លួនឯង
√ រក្សាទុកអារម្មណ៍របស់ខ្លួនក្នុងចិត្តមិនឲ្យគេដឹង
√ ចំណាយពេលគិតគូរយូរមុននឹងឆ្លើយតប
√ ផ្តោតលើគំនិត និងអារម្មណ៍ក្នុងខ្លួនជាជាងមជ្ឈដ្ឋានខាងក្រៅ
√ ចូលចិត្តធ្វើការងារម្នាក់ឯង
√ មានមិត្តភក្តិតិច តែជិតស្និទ្ធខ្លាំង
√ ជាមនុស្សស្ងប់ស្ងៀម

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## របៀបស្រូបយកព័ត៌មាន

### S Sensors

- √ ទុកចិត្តលើអ្វីដែលពិត មើលឃើញជាក់ស្តែង
- √ ទាញយកគំនិតថ្មីៗមកប្រើប្រាស់ លុះត្រាតែអាច លុះត្រាតែអាចមើលឃើញពីអត្ថប្រយោជន៍ជាក់ស្តែង
- √ ឲ្យតម្លៃលើភាពពិត និងអ្វីដែលសមហេតុផល
- √ ព្យាយាមប្រើប្រាស់ និងពង្រឹងជំនាញដែលខ្លួនមានស្រាប់
- √ និយាយ[illegible] ជាក់លាក់ និងចេះរៀបរាប់លម្អិត
- √ ពន្យល់ជ[illegible]ានៗ
- √ អារម្មណ៍[illegible]ពីពេលបច្ចុប្បន្ន
- √ ទំនោរទេ[illegible]អ្វីដែលកើតឡើងភ្លាមៗ អាចស[illegible]ឃើញជាក់ស្តែង
- √ មានភាព[illegible]ាត់អត់ធ្មត់ បើទោះបីជាធ្វើការងារដដែលៗ
- √ ពេលរំឭ[illegible]ត្តិការណ៍ផ្សេងៗ ចងចាំលម្អិតនូវអ្វី ដែលកើ[illegible]ង

### N Intuitive

- √ ទុកចិត្តលើអារម្មណ៍ និងការទាញសេចក្តីសន្និដ្ឋាន
- √ ចូលចិត្តគំនិតថ្មីៗ ដោយសារវាជាអ្វីដែលថ្មី
- √ ឲ្យតម្លៃលើការស្រមើស្រមៃ គំនិតច្នៃប្រឌិត និងការបង្កើតថ្មី
- √ ចូលចិត្តរៀនជំនាញ ឬវិធីថ្មីៗក្នុងការធ្វើអ្វីមួយ និងឆាប់ធុញពេលរៀនចេះ
- √ និយាយពីលក្ខណៈទូទៅ ពុំសូវលំអិត និងប្រើការប្រៀបធៀបច្រើន
- √ ពេលពន្យល់ពីអ្វីមួយ ពុំមានជំហាន ឬលំដាប់លំដោយ ច្បាស់លាស់
- √ អារម្មណ៍គិតទៅរកអនាគត
- √ ទំនោរទៅរកលទ្ធភាព ឬឱកាសដែលអាចអាចកើតមានឡើង បើទោះជាពុំមានរូបភាពច្បាស់លាស់
- √ មានការស្រមើស្រមៃ ឆាប់យល់ និងចេះក្តោបរូបភាពរួមនៃ ស្ថានការណ៍ដែលកើតមានឡើង
- √ មានភាពអត់ធ្មត់ធ្វើគម្រោងដែលគ្មានរូបរាង ឬទិសដៅច្បាស់លាស់
- √ ពេលរំឭកពីព្រឹត្តិការណ៍ផ្សេងៗ តែងចងចាំ នូវអារម្មណ៍ និងអ្វីដែល ខ្លួនសង្កេតឃើញនាពេលនោះ ជាជាងព័ត៌មានលម្អិតដែលកើតឡើង

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# របៀបសម្រេចចិត្ត

## T Thinkers

√ ដឹងពេលដែលត្រូវថយក្រោយ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានជាថ្មី
√ ឲ្យតម្លៃលើភាពសមហេតុផល យុត្តិធម៌ ការស្មើភាព និងគោរពតាមបទដ្ឋានច្បាស់លាស់
√ តែងមើលឃើញ និងចង្អុលបង្ហាញចំណុចចន្លោះប្រហោង
√ គិតថាមនុស្សដែលស្មោះត្រង់ សំខាន់ជាងមនុស្សដែលពូកែខាងទំនាក់ទំនងជាមួយអ្នកដទៃ
√ ជឿថាអារម្មណ៍មានសុពលភាពទាល់តែជាអារម្មណ៍ដែល[illegible]បីភាពសមហេតុផល
√ លើក[illegible]ត្តដោយចង់សម្រេចសមិទ្ធផល និងបង្កើតស្នាដៃ
√ ធ្វើការ[illegible]ម្រេចចិត្តដោយការវិភាគថ្លឹងថ្លែងរកហេតុផល
√ តម្រង់[illegible]ទៅរកបច្ចេកទេស ផ្នែកស្រាវជ្រាវ និងវិទ្យាសាស្ត្រ
√ ព្យាយ[illegible]ស្វែងរកការពិតដោយពុំលម្អៀងទៅរកបុគ្គល
√ បើទោ[illegible]មានផលប៉ះពាល់អ្វីក៏ដោយ ត្រូវបានគេមើលឃើញថាជាមនុ[illegible]លនិយាយត្រង់ និងម៉ឺងម៉ាត់
√ គិតរិះ[illegible]បីភាពប្រែប្រួល មិនច្បាស់លាស់របស់អ្នកដទៃ

## F Feelers

√ ដើរមួយជំហានគិតមួយជំហានដោយពិចារណាមើលផលប៉ះពាល់ដែលអាចកើតមានឡើងចំពោះអ្នកដទៃ
√ ឲ្យតម្លៃលើការចេះយល់ចិត្តអ្នកដទៃ ចេះស្រុះស្រួលគ្នា ហើយគិតថាច្បាប់វិន័យអាចបត់បែនបាន
√ គិតថាការរក្សាទំនាក់ទំនងជាមួយអ្នកដទៃក៏សំខាន់ដូចការនិយាយស្មោះត្រង់ដែរ
√ ជឿថាគ្រប់អារម្មណ៍ទាំងអស់មានសុពលភាព មិនថាវាសមហេតុផល ឬក៏អត់នោះទេ
√ ចង់បានការសរសើរពីអ្នកដទៃ
√ ធ្វើការសម្រេចចិត្ត ដោយពឹងផ្អែកទៅលើអារម្មណ៍ និងគុណតម្លៃផ្ទាល់ខ្លួន
√ តម្រង់ទិសទៅរកការងារដែលទាក់ទងជាមួយមនុស្ស
√ ស្វែងរកអ្វីដែលសំខាន់សម្រាប់អ្នកដទៃ
√ ព្យាយាមស្វែងរកភាពស្រុះស្រួលគ្នា និងចេះសហការគ្នា ជួនកាលមើលរំលងពីផលប៉ះពាល់
√ ត្រូវគេមើលឃើញថា ជាមនុស្សមានភាពកក់ក្ដៅ និងចេះយោគយល់
√ ស្វែងរកពីចំណុចល្អរបស់អ្នកដទៃ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# របៀបរស់នៅ និងប្រកបកិច្ចការ

## J Judger

- √ សប្បាយចិត្តពេលបានធ្វើការសម្រេចចិត្តដាច់ស្រេចលើបញ្ហាអ្វីមួយ
- √ មានក្រមសីលធម៌ការងារខ្ពស់ ពោលគឺធ្វើការឲ្យចប់សិនទើបលេងសប្បាយតាមក្រោយ
- √ ឲ្យតម្លៃទៅលើភាពមានរបៀបរៀបរយ
- √ មានលំដាប់លំដោយ និងស្ថានការណ៍ដែលអាចប៉ាន់ស្មានបាន
- √ ត្រូវការដឹងច្បាស់ថាខ្លួនកំពុងធ្វើអ្វី និងដល់ពេលណានាពេល [illegible]អនាគត
- √ ជាមនុ[illegible]ដលធ្វើការតម្រង់ទៅរក និងផ្តោតសំខាន់លើលទ្ធផ[illegible]ារងារ
- √ ទាញ[illegible]ការពេញចិត្តនឹងសមត្ថភាពរបស់ខ្លួនតាមរយៈការស[illegible]កិច្ចការផ្សេងៗ
- √ គិតថា[illegible]រឿងសំខាន់ដែលការងារត្រូវបញ្ចប់តាមកាលកំណត់
- √ មានទំ[illegible]គ្រប់គ្រងជីវិតក្នុងផ្លូវមួយដែលមានរបៀបរៀបរយមាន[illegible]ការច្បាស់លាស់ និងអាចធ្វើការសម្រេចចិត្តបានរហ័ស[illegible]ចិត្ត
- √ មានភា[illegible]ត់ធ្មត់ និងចូលចិត្តដំណើរការងារដដែលៗ
- √ មុននឹង[illegible]ផ្តើមធ្វើការ តែងតែរាយតារាងកិច្ចការដែលត្រូវធ្វើ

## P Perceiver

- √ ចូលចិត្តទុកចន្លោះដើម្បីអាចផ្លាស់ប្តូរយកជម្រើសថ្មី
- √ ចូលចិត្តលេងសប្បាយសិន មុននឹងធ្វើការងារបញ្ចប់
- √ ទុកឲ្យរឿងរ៉ាវកើតឡើងតាមដំណើរ និងមានលទ្ធភាពអាចដោះស្រាយបញ្ហាដែលកើតឡើងភ្លាមៗ
- √ អាចប្តូរគោលដៅភ្លាមៗ នៅពេលទទួលបានព័ត៌មានបន្ថែមថ្មីៗ
- √ ជាមនុស្សដែលឲ្យតម្លៃលើដំណើរការការងារ ជាជាងលទ្ធផលព្រមទាំងផ្តោតសំខាន់លើរបៀបក្នុងការសម្រេចកិច្ចការ
- √ ទាញយកមោទនភាពលើខ្លួនឯងតាមរយៈការចាប់ផ្តើមធ្វើកិច្ចការឬគម្រោងផ្សេងៗ
- √ គិតថា ការធ្វើរឿងដដែលៗរាល់ថ្ងៃ ជារឿងដែលគួរឲ្យធុញទ្រាន់និងពិបាកទ្រាំ
- √ ចាត់ទុកពេលវេលាជាធនធាន ដែលមានរហូត ដូច្នេះគិតថាពេលវេលាកំណត់បញ្ចប់កិច្ចការពុំសូវសំខាន់ និងអាចពន្យាបាន
- √ សម្របជីវិតទៅតាមអ្វីដែលកើតឡើងដោយតែងតែត្រងត្រាប់យកព័ត៌មាន និងចំណេះដឹងថ្មីៗ និងតែងទុកផ្លូវជីវិតឲ្យបើកទូលាយអាចបត់បែនបាន
- √ មានភាពធូរលុងក្នុងការធ្វើការងារ មិនចូលចិត្តត្រៀមរៀបចំផែនការអ្វីច្រើន

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## កម្រងសំណួរការងារ តាមទ្រឹស្ដី Holland

ទ្រឹស្ដី Holland បែងចែកការងារជា ០៦ប្រភេទ ទៅតាមភាពខ្លាំង ចំណង់ចំណូលចិត្ត និងរបៀបធ្វើការរបស់មនុស្សម្នាក់ៗ។ ក្នុងកម្រងសំណួរខាងក្រោមនេះ ចូរដាក់ពិន្ទុដូចខាងក្រោម៖

- ២ ពិន្ទុ បើត្រូវចំពោះអ្នក១០០%
- ១ ពិន្ទុ បើត្រូវចំពោះអ្នក៥០%
- ០ ពិន្ទុ បើមិនត្រូវចំពោះអ្នកសោះ

1. ចូលចិត្តផ្សងព្រេង _____ F
2. មានមហិច្ឆិតាខ្ពស់ _____ F
3. ចូលចិត្តវិភាគ _____ C
4. ចូលចិត្តវែកញែក _____ F
5. ពូកែលេងកីឡា _____ A
6. ចូលចិត្តឲ្យគេចាប់អារម្មណ៍លើខ្លួន _____ E
7. ស្ងប់ស្ងាត់ មិនឆេវឆាវ _____ B
8. ចូលចិត្តធ្វើការដោយ ភាពច្បាស់លាស់ _____ C
9. តែងមានអារ ... កវាយ _____ E
10. ចូលចិត្តការ ... ប្រជែង _____ F
11. គិតស្មុគស្មា ... ន _____ D
12. ជឿជាក់លើ ... ភាពរបស់ខ្លួន _____ C
13. ឆាប់ស្របតា _____ A
14. ធ្វើការដោយ ... ត្តទុកដាក់ _____ B
15. ចូលចិត្តធ្វើការដោ ... ភាការ ជាមួយអ្នកដទៃ _____ E
16. មានការច្នៃប្រឌិត _____ C
17.ឆ្ងល់ច្រើន _____ C
18. អាចពឹងពាក់បាន _____ B
19. ជាមនុស្សដែលមា ... វ _____ B
20. ចូលចិត្តជជែកពិភ _____ D
21. មិនចូលចិត្តធ្វើស ... ច្រើន _____ B
22. គ្មានសណ្ដាប់ធ្នាប់ _____ D
23. ចូលចិត្តតួនាទីដែ ... គ្រប់គ្រងគម្រោង ... រដទៃ _____ E
24. ធ្វើអ្វីជាក់លាក់ និងហ្មត់ចត់ _____ B
25. ឆាប់មានអារម្មណ៍រំភើប _____ D
26. ចូលចិត្តភាពស្វាហាប់ _____ E
27. ចូលចិត្តស្វែងរកដំណោះស្រាយ _____ C
28. មានឆន្ទៈពុះពារក្នុងការធ្វើអ្វីមួយ _____ F
29. ចូលចិត្តធ្វើចរិតឲ្យគេចូលចិត្ត _____ F
30. ចូលចិត្តនិយាយត្រង់ៗ មិនបត់បែនច្រើន _____ A
31. រួសរាយរាក់ទាក់ _____ E
32. ធ្វើបាននៅពេលដែលកិច្ចការនោះ បានគិតព្រាងទុកជាមុន _____ B
33. ចេះជួយយកអាសារអ្នកដទៃ _____ E
34. មានឧត្ដមគតិខ្ពស់ _____ D
35. មិនប្រាកដនិយម _____ D
36. ធ្វើការតាមឆន្ទៈ និងអារម្មណ៍ _____ D
37. មានភាពឯករាជ្យ និងម្ចាស់ការ _____ C
38. ចូលចិត្តហាមឃាត់គេ _____ B
39. ប្រើពេលត្រិះរិះពិចារណា _____ D
40. អាចគិតឃើញបានលឿន _____ D
41. ពិបាកនិយាយបញ្ចុះបញ្ចូលអ្នកដទៃ _____ C
42. ចង់បានសម្ភារៈច្រើន _____ A
43. ចេះប្រើម៉ាស៊ីន ឬឧបករណ៍ស្ទាត់ _____ A
44. មិនងាយឲ្យគេបញ្ចុះបញ្ចូលបាន _____ D
45. ចេះស្ដាប់បង្គាប់អ្នកដទៃ _____ B
46. សុទិដ្ឋិនិយម _____ F
47. មានសណ្ដាប់ធ្នាប់ _____ B
48. ពូកែខាងសិល្បៈ និងការរចនា _____ D
49. ចូលចិត្តការគិត _____ C
50. ចេះតស៊ូ _____ A
51. ពូកែបញ្ចុះបញ្ចូលគេ _____ F
52. ជាមនុស្សមានប្រជាប្រិយ _____ E
53. មិនសាំញ៉ាំច្រើន _____ A
54. ចូលចិត្តធ្វើកិច្ចការណាដែល មានអ្នកចាំបង្គាប់ចង្អុលបង្ហាញ _____ B
55. ចូលចិត្តធ្វើការជាមួយមនុស្ស ជាជាងម៉ាស៊ីន _____ E
56. ចូលចិត្តជជីករកវិធីដោះស្រាយបញ្ហា _____ C
57. មិនសូវមាត់ក _____ C
58. ចូលចិត្តប្រថុយគ្រោះថ្នាក់ _____ D
59. មានកម្លាំងខ្លាំង មាំមួន _____ A
60. ចូលចិត្តខាងស្រាវជ្រាវវិទ្យាសាស្ត្រ _____ C
61. ជឿទុកចិត្តលើខ្លួនឯង _____ F
62. ឆាប់ទទួលអារម្មណ៍ពីមជ្ឈដ្ឋានក្រៅ _____ D
63. អឹមអៀន _____ A
64. ចូលចិត្តកិច្ចការដែលបម្រើសង្គម _____ E
65. ចូលចិត្តកីឡា _____ A
66. រឹងប៉ឹង _____ A
67. ប៉ិនប្រសប់ប្រាស្រ័យទាក់ទង ជាមួយអ្នកដទៃ _____ E
68. ចូលចិត្តបង្រៀន អភិវឌ្ឍអ្នកដទៃ _____ E
69. ចេះត្បិតត្បៀត មិនខ្ជះខ្ជាយ _____ A
70. ចេះយល់ចិត្ត និងអារម្មណ៍អ្នកដទៃ _____ E
71. ពូកែនិយាយ _____ F
72. មិនចូលចិត្តឲ្យគេសសើរ _____ B

**បូកសរុបពិន្ទុទៅតាមតួអក្សរនីមួយៗ ពី A ដល់ F**

| *A* | *B* | *C* | *D* | *E* | *F* |
|---|---|---|---|---|---|
| ◯ | ◯ | ◯ | ◯ | ◯ | ◯ |

A = ការងារបែបប្រាកដនិយម (Realistic jobs)
B = ការងារផ្នែករៀបចំ (Conventional jobs)
C = ការងារបែបស៊ើបអង្កេត (Investigative jobs)
D = ការងារផ្នែកសិល្បៈ (Artistic jobs)
E = ការងារផ្នែកសង្គម (Social jobs)
F = ការងារជាអ្នកដឹកនាំ (Jobs of leader and Entrepreneurs)

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ការពន្យល់អំពី បុគ្គលិកលក្ខណៈ គុណតម្លៃ និងជំនាញ នៃការងារទាំង៦ប្រភេទ របស់ទ្រឹស្តី Holland




**បុគ្គលិកលក្ខណៈ:** មនុស្សប្រាកដនិយម ជាមនុស្សដែលសកម្ម ចេះថ្លឹងថ្លែង និងចូលចិត្តសកម្មភាពអនុវត្តជាក់ស្តែង ដូចជា ការសាងសង់ ការប្រើប្រាស់គ្រឿងចក្រ ការហាត់កីឡាសម្បទាជាដើម។ មនុស្សប្រាកដនិយម ចូលចិត្តនិយាយត្រង់ៗ និងឲ្យតម្លៃទៅលើវត្ថុសម្ភារផ្សេងៗ។

**គុណតម្លៃ និងចំ[illegible]រអារម្មណ៍ផ្ទាល់ខ្លួន** ពួកគេ ចូលចិត្តធ្វើ[illegible] មួយឧបករណ៍ ឬទាក់ទងជាមួយសត្វ និងរុក្ខជាតិ ជា[illegible] ការងារដែលប្រើប្រាស់គំនិតយោបល់ ឬការងារដែលត[illegible] កគេទាក់ទងជាមួយនឹងមនុស្សនានាច្រើន។ មនុស្ស[illegible] និយម ចូលចិត្តរៀនដោយធ្វើការក្នុងរបៀប ឬស្ថានកា[illegible] ដែលត្រូវការការអនុវត្តន៍ជាក់ស្តែងជាជាង ការអង្គុយរៀ[illegible]ភ្នាក់។

**ជំនាញ និងស[illegible]** ពួកគេ មើលឃើញថា ខ្លួនឯងពូកែខាងប្រើប្រាស់គ្រ[illegible]ស៊ីន ឬគ្រឿងចក្រ ប៉ុន្តែពុំមានអារម្មណ៍សុខស្រួ[illegible]រធ្វើការជាមួយមនុស្ស។ ពួកគេ អាចធ្វើការក្នុងបរិយាក[illegible]រងារណា ដែលតម្រូវឲ្យខ្លួនប្រើប្រាស់ ឬបង្កើនសមត្ថភា[illegible]រច្ចេកទេស និងអាចទទួលលទ្ធផលមើលឃើញជាក់[illegible]

**វិស័យការងារ[illegible]ក់ព័ន្ធ** ការអនុវត្តជាក់ស្តែង កសិកម្ម សេវាសុខភាព ប[illegible]ព្យាព័ត៌មាន ការសាងសង់ គ្រឿងយន្ត វិស្វកម្ម អាហារ និ[illegible] បណ្ណារកិច្ច។




**បុគ្គលិកលក្ខណៈ:** ជាមនុស្សដែលចូលចិត្តវិភាគដោយប្រើប្រាស់គំនិតឆ្លាតវៃ និងពូកែសង្កេត។ ពួកគេក៏ជាប្រភេទមនុស្សដែលចូលចិត្តនៅតែម្នាក់ឯង និងអាចផ្តោតអារម្មណ៍ក្នុងការរកដំណោះស្រាយបញ្ហាផ្សេងៗ។

**គុណតម្លៃ និងចំណាប់អារម្មណ៍ផ្ទាល់ខ្លួន** ពួកគេទាក់ទាញទៅប្រភេទការងារ ដែលពុំចាំបាច់ត្រូវមានសេចក្តីណែនាំច្បាស់លាស់ ហើយក៏ប្រហែលចូលចិត្តគិតវិភាគរកហេតុផលដើម្បីអាចដោះស្រាយបញ្ហាដែលស្មុគស្មាញ ឬគ្មានរូបភាពច្បាស់លាស់។ ពួកគេចូលចិត្តអង្កេត ដូច្នេះពួកគេចូលចិត្តធ្វើការឯករាជ្យតែឯង និងមិនចង់បានតួនាទីដឹកនាំអ្វីទេ។ ពួកគេឲ្យតម្លៃខ្ពស់លើការងារ ដែលប្រើប្រាស់វិទ្យាសាស្ត្រ និងលើការរៀន។

**ជំនាញ និងសមត្ថភាព** ពួកគេចូលចិត្តសកម្មភាពដែលទាក់ទងនឹងការស្រាវជ្រាវ ការប្រើប្រាស់គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ពួកគេមើលឃើញថា ខ្លួនឯងជាមនុស្សដែលមានចេះដឹងជ្រៅជ្រះ និងមានសមត្ថភាពខាងវិទ្យាសាស្ត្រ និងគណិតវិទ្យា ប៉ុន្តែអាចខ្វះជំនាញដឹកនាំ និងបញ្ចុះបញ្ចូលអ្នកដទៃឲ្យយល់ស្របជាមួយខ្លួន។ ពួកគេ ចូលចិត្តបរិយាកាសធ្វើការ ដែលតម្រូវឲ្យមានការវិភាគអង្កេតច្រើន ដែលជំរុញបង្កើនសមត្ថភាពខាងវិទ្យាសាស្ត្រ ធ្វើការដោយឯករាជ្យ និងអាចឲ្យគេផ្តោតទៅលើការស្វែងរកដំណោះស្រាយថ្មីៗ លើបញ្ហាស្មុគស្មាញនានា។

**វិស័យការងារដែលពាក់ព័ន្ធ** វិទ្យាសាស្ត្រ ជីវវិទ្យា វិស្វកម្ម គីមី ឱសថសាស្ត្រ សល្យសាស្ត្រ ធម្មជាតិ សេដ្ឋកិច្ច អតិថិជនចិត្តវិទ្យា។




**បុគ្គលិកលក្ខណៈ:** មានភាពច្នៃប្រឌិត បង្កើតគំនិត ឬរបស់ថ្មីដែលពុំចាំបាច់ត្រូវយកលំនាំតាមអ្នកដទៃ។ ក្រុមនេះ ជាប្រភេទមនុស្សដែលមានការស្រមើស្រមៃ និងមានអព្ភន្តរញ្ញាណខ្ពស់។ ពួកគេអាចធ្វើការតាមឆន្ទៈ ដោយមិនចាំបាច់គិតពិចារណាច្រើន ឆាប់រំភើបចិត្ត បើកទូលាយក្នុងការប្រាស្រ័យទាក់ទង និងសម្តែងមនោសញ្ចេតនា។

**គុណតម្លៃ និងចំណាប់អារម្មណ៍ផ្ទាល់ខ្លួន** ចូលចិត្តកែប្រែវត្ថុមានរូប ឬគ្មានរូបឲ្យទៅជាវត្ថុប្រកបដោយសិល្បៈ និងភាពច្នៃប្រឌិត (ឧទា. ចម្លាក់ គំនូរ ជាដើម) ព្រមទាំងឲ្យតម្លៃខ្ពស់ទៅលើសោភ័ណភាព។ ពួកគេចូលចិត្តធ្វើសកម្មភាពដែលតម្រូវឲ្យមានភាពច្នៃប្រឌិត ដូចជាការតែងបទភ្លេង និពន្ធ ឬគូររូបជាដើម ចូលចិត្តធ្វើការនៅកន្លែងដែលជំរុញឲ្យបង្កើនភាពច្នៃប្រឌិត ដោយពុំយកលំនាំតាមអ្នកដទៃ ព្រមទាំងអាចប្រើប្រាស់ក្តីស្រមៃក្នុងទម្រង់មួយដែលពុំមានបែបបទច្បាស់លាស់។

**ជំនាញ និងសមត្ថភាព** ជាក្រុមមនុស្ស ដែលមានសមត្ថភាពខាងសិល្បៈ វិចិត្រសាល ឬសរសេរ ប៉ុន្តែខ្វះជំនាញក្នុងការរៀបចំការងារឲ្យមានរបៀបរៀបរយផ្នែកសង្គម។ មនុស្សដែលនៅក្នុងក្រុមនេះ អាចធ្វើកិច្ចការដែលមានភាពបត់បែនតាមកាលៈទេសៈជាជាងត្រូវគោរពតាមច្បាប់ទម្លាប់ដែលពិបាកនឹងផ្លាស់ប្តូរ។

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

**វិស័យការងារដែលពាក់ព័ន្ធ** ការទំនាក់ទំនង លោហធាតុវិទ្យា វិចិត្រសិល្បៈ ការសម្តែង ការថតរូប វិទ្យុ ទូរទស្សន៍ ការតុបតែងផ្ទះ ស្ថាបត្យកម្ម សិល្បៈ និងទំនាក់ទំនង។



**បុគ្គលិកលក្ខណៈ** មានមនុស្សធម៌ មានឧត្តមគតិ និងទំនួលខុសត្រូវខ្ពស់ ព្រមទាំងជាប្រភេទមនុស្សដែលយកចិត្តទុកដាក់នឹងសុខទុក្ខរបស់អ្នកដទៃ។

**គុណតម្លៃ និងចំ... ...រអារម្មណ៍ផ្ទាល់ខ្លួន** ពួកគេ ចូលចិត្ត
ធ្វើការជាមួយមនុ... ...ដើម្បីផ្តល់ព័ត៌មាន ជួយ ឬអភិវឌ្ឍអ្នកដ
ទៃ។ ជាទូទៅ ... ...ក្នុងក្រុមសង្គម តែងផ្តោតសំខាន់លើ
ទំនាក់ទំនង ប្រ... ...ដោះស្រាយបញ្ហានានាដែលទាក់ទង
នឹងមនុស្ស។ ពួ... ...យល់ថាខ្លួនជាមនុស្សដែលចេះយោគ
យល់ ចេះជួយយ... ...ារ និងពោរពេញដោយភាពរីករាយ។

**ជំនាញ និងស... ...ភាព** ក្រុមនេះ មានជំនាញក្នុងការ
បង្រៀន និងអភិវ... ...ដទៃ ប៉ុន្តែពុំសូវប៉ិនប្រសប់ខាងជំនាញ
បច្ចេកទេស។ ប្រ... ...ក្រុមចូលចិត្តសកម្មភាពណាដែលតម្រូវ
ឲ្យធ្វើការជាក្រុម ... ...បង្រៀន ផ្តល់ប្រឹក្សា ឬអភិវឌ្ឍអ្នកដទៃ។
ពួកគេ ស្វែងរកឱ... ...ការងារ ដែលមានការពិភាក្សាជាក្រុម
ដើម្បីដោះស្រាយ... ...ផ្សេងៗ ប៉ុន្តែពុំចូលចិត្តការងារណា
មានបែបបទ វិន័យ... ...រពេកនោះទេ។

**វិស័យការងារដែ... ...ក់ព័ន្ធ** ការប្រឹក្សាយោបល់ ការ
ព្យាបាល ការព្យា... ...ផ្លូវចិត្ត ការធ្វើដំណើរ ការផ្សព្វផ្សាយ
ទំនាក់ទំនងអន្តរជ... ...ការអប់រំ សេវាសុខភាព សេវាកម្ម
ធនធានមនុស្ស និ... ...ាកម្មសាធារណៈ។

facebook.com/moeyscambodia YouTube youtube.com/moeys.gov.kh youtube.com/moeyscambodia



**បុគ្គលិកលក្ខណៈ** ប្រកបដោយកម្លាំងថាមពល មានមហិច្ឆិតា ចរិតផ្សងព្រេង មានទំនុកចិត្តលើខ្លួនឯងខ្ពស់ និងអាចធ្វើទំនាក់ទំនងជាមួយមនុស្សបានល្អ។ ជាទូទៅ ត្រូវបានគេមើលឃើញថា ជាអ្នកពូកែខាងនិយាយក្នុងទីសាធារណៈ និងអាចចូលចុះក្នុងសង្គម ប៉ុន្តែប្រហែលជាអាចត្រូវបានមើលឃើញថា ចូលចិត្តចេញមុខចេញមាត់បន្តិច។

**គុណតម្លៃ និងចំណាប់អារម្មណ៍ផ្ទាល់ខ្លួន** ក្រុមនេះចូលចិត្តប្រើប្រាស់សមត្ថភាពដឹកនាំ និងបញ្ចុះបញ្ចូលរបស់ខ្លួនក្នុងការងារដែលមានឥទ្ធិពល ដើម្បីឈានសម្រេចគោលដៅរបស់អង្គភាព ឬបង្កើនសេដ្ឋកិច្ច។ ប៉ុន្តែពុំចូលចិត្តសកម្មភាព ដែលមានទម្លាប់ដដែលៗ ឬត្រូវគោរពតាមគោលការណ៍ និងប្រព័ន្ធជាក់លាក់ណាមួយ។

**ជំនាញ និងសមត្ថភាព** ពួកគេចូលចិត្តធ្វើសកម្មភាពដែលតម្រូវឲ្យពួកគេបញ្ចុះបញ្ចូលអ្នកដទៃ ឬមានតួនាទីជាអ្នកដឹកនាំក្រុម។ មនុស្សក្រុមនេះ ចូលចិត្តបរិស្ថានការងារ ដែលជំរុញឲ្យពួកគេអាចផ្សារភ្ជាប់ ជាមួយសកម្មភាពផ្សេងៗ ដូចជាកិច្ចការដឹកនាំ គ្រប់គ្រង លក់ដូរ ដើម្បីទទួលបានការតបស្នងណាមួយ។

**វិស័យការងារដែលពាក់ព័ន្ធ** សុរិយោដី ទីផ្សារ ផ្នែកលក់ច្បាប់ វិទ្យាសាស្ត្រនយោបាយ ពាណិជ្ជកម្មអន្តរជាតិ ជំនួញ ធនាគារ។



**បុគ្គលិកលក្ខណៈ** ធ្វើការមានប្រសិទ្ធភាពខ្ពស់ ប្រយ័ត្នប្រយែង និងតឹងរឹងស្របតាមវិន័យ និងគោលការណ៍ច្បាស់លាស់។ ពួកគេ ជាមនុស្សហ្មត់ចត់ តស៊ូអត់ធ្មត់ អាចទុកចិត្តបាន និងមានទំនួលខុសត្រូវខ្ពស់ក្នុងការងារ។

**គុណតម្លៃ និងចំណាប់អារម្មណ៍ផ្ទាល់ខ្លួន** ចូលចិត្តរៀបចំទិន្នន័យឲ្យលេចចេញជារូបរាងជាក់ស្តែង។ ពួកគេ អាចធ្វើការបានល្អ ក្នុងកន្លែងដែលមានឋានានុក្រម និងមានការណែនាំច្បាស់លាស់ ព្រមទាំងផ្តល់តម្លៃខ្ពស់លើការធ្វើការងារតាមច្បាប់វិន័យ។

**ជំនាញ និងសមត្ថភាព** ចូលចិត្តសកម្មភាព ដែលមានការរៀបចំ និងប្រព័ន្ធគ្រប់គ្រងត្រឹមត្រូវ និងពុំចូលចិត្តធ្វើការ ដែលពុំមានគ្រោងការ ទិសដៅច្បាស់លាស់នោះទេ។ ពួកគេ ស្វែងរកការងារណា ដែលជំរុញសមត្ថភាព រៀបចំរចនាសម្ព័ន្ធ ចូលចិត្តរៀបចំការងារផ្នែកទិន្នន័យ រៀបចំកាលវិភាគ ពេលវេលា ផែនការ គម្រោង និងការប្រើប្រាស់ជំនាញខាងគិតលេខជាដើម។

**វិស័យការងារដែលពាក់ព័ន្ធ** គណនេយ្យ របាយការណ៍តុលាការ ការធានារ៉ាប់រង រដ្ឋបាល កំណត់ត្រាឱសថ ធនាគារ ការគ្រប់គ្រងទិន្នន័យ ស្ថិតិ។

## ការឆ្លុះបញ្ចាំងពីក្នុងខ្លួន - សំណួរសម្រាប់ត្រិះរិះពិចារណា

ទោះបីមានកម្រងសំណួរអំពីបុគ្គលិកលក្ខណៈជាជំនួយសម្រាប់អ្នកក៏ដោយ អ្នកក៏ត្រូវតែរៀនសញ្ជឹងគិត និងវិភាគដោយខ្លួនឯង។ អ្នកអាចឆ្លុះបញ្ចាំងពីខ្លួនឯង តាមរយៈវិធីសាស្ត្រផ្សេងៗគ្នា ដូចជាប្រឹក្សាយោបល់ជាមួយមិត្តភក្តិ ឬអ្នកធ្វើការជាមួយ អាចសាកល្បងធ្វើកិច្ចការថ្មីៗ សរសេរ និងរំឭកអានកំណត់ហេតុប្រចាំថ្ងៃ។ ការឆ្លើយសំណួរពីអត្តចរិត ចំណាប់ចំណូលចិត្ត ខាងក្រោមនេះ តម្រូវឲ្យអ្នកឆ្លើយដោយស្មោះត្រង់ និងហ៊ានរិះគន់ខ្លួនឯង ដើម្បីការស្ថាបនា។

ខាងក្រោមនេះជាប្រភេទសំណួរដែលតម្រូវឲ្យអ្នកគិតទៅដល់អត្តចរិត ចំណាប់ចំណូលចិត្ត និងអកប្បកិរិយាផ្សេងៗ ដែលអ្នកមាន៖

1. តើសកម្មភាពអ្វីខ្លះដែលចូលចិត្តធ្វើជាងគេ? (អាចជាការកំសាន្ត ឬការរៀនមុខវិជ្ជាអ្វីមួយ)
2. តើសកម្មភាពក្រៅម៉ោងរៀនអ្វីខ្លះ ដែលអ្នកចូលចិត្តធ្វើជាងគេ?
3. តើអ្នកចូលចិត្តធ្វើការជាមួយមនុស្សប្រភេទណា?
4. តើអ្នកមានមនុស្សដែលខ្លួនគោរពដែរឬទេ? គាត់ជាមនុស្សប្រភេទណា? ហេតុអ្វីបានជាអ្នកគោរពគាត់?
5. តើអ្នកចូលចិត្តនិយាយពីរឿងអ្វី ឬប្រធានបទអ្វី?
6. តើអ្នកពូកែ ឬក៏មានទេពកោសល្យពីកំណើតទៅលើអ្វីមួយ?
7. តើកិច្ចការ សកម្មភាព ជំនាញ ការងារ អ្វីដែលស្រួលសម្រាប់អ្នក តែពិបាកសម្រាប់អ្នកដទៃ?
8. ពេលដែលអ្នកទៅបណ្ណាល័យ ឬបណ្ណាគារ តើអ្នកអាន ឬទិញសៀវភៅប្រភេទណា?
9. ប្រសិនបើអ្នកមានពេលមួយថ្ងៃសម្រាប់រៀនវិជ្ជាជីវៈ ឬធ្វើសកម្មភាពមួយ តើអ្នកនឹងធ្វើអ្វី? តើអ្នកអាចធ្វើសកម្មភាពអ្វីក្នុងរយៈពេលយូរដោយមិនមានអារម្មណ៍ធុញទ្រាន់?

## ការសរសេរកំណត់ហេតុប្រចាំថ្ងៃចន្ទ

បុគ្គលម្នាក់ៗ តែងមានការប្រែប្រួលទៅតាមកាលៈទេសៈ និងពេលដែលទទួលបានបទពិសោធន៍ថ្មីៗ។ ហេតុនេះហើយ ការសរសេរកំណត់ហេតុប្រចាំថ្ងៃ អាចជួយអ្នកមើលឃើញ ពីបំរែបំរួល និងភាពរីកចម្រើនទាំងនោះមិនថាលើផ្នែកចំណេះដឹង ជំនាញ ភាពខ្លាំង ភាពខ្សោយ ចំណាប់អារម្មណ៍ ឬក៏ផ្នត់គំនិតរបស់អ្នក។

កំណត់ហេតុប្រចាំថ្ងៃ មានទម្រង់ផ្សេងៗទៅតាមបុគ្គលម្នាក់ៗ។ ប្រសិនបើអ្នកពុំដឹងច្បាស់ ថាតើគួរសរសេរពីអ្វី អ្នកអាចចាប់ផ្តើមឆ្លើយសំណួរដូចគម្រូនៅខាងក្រោម៖

1. តើអ្វីដែលធ្វើឲ្យអ្នកសប្បាយចិត្ត ឬមិនសប្បាយចិត្តនៅថ្ងៃនេះ? ហេតុអ្វី?
2. តើទង្វើណាមួយរបស់អ្នកនៅថ្ងៃនេះ ដែលធ្វើឲ្យអ្នកពេញចិត្តជាងគេ? ព្រោះអ្វី?
3. តើអ្នកមានប្រព្រឹត្តកំហុសអ្វីទេនៅថ្ងៃនេះ? តើមកពីមូលហេតុអ្វី? តើអ្នកដោះស្រាយវាដោយរបៀបណា? តើអ្នកពេញចិត្តនឹងដំណោះស្រាយនេះដែរឬទេ? ប្រសិនបើមានឱកាស តើអ្នកនឹងកែប្រែទង្វើរបស់អ្នកដោយរបៀបណា?
4. តើថ្ងៃនេះអ្នកមានធ្វើអ្វី ដែលថ្មីដែរឬទេ? តើអ្នកចូលចិត្តវាដែរឬទេ? ព្រោះអ្វី?



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី2



## ការស្វែងរកព័ត៌មានបន្ថែម

នៅក្នុងជំពូកនេះ អ្នកនឹងស្វែងយល់ពីប្រភព ដែលអាចផ្តល់ព័ត៌មានបន្ថែម ទាក់ទិននឹងមុខជំនាញក៏ដូចជាអាជីពដែលអ្នកចាប់អារម្មណ៍។

### ហេតុអ្វីត្រូវចាំបាច់ត្រូវស្វែងរកព័ត៌មានបន្ថែម?

ការសម្រេចដែលល្អ ពឹងផ្អែកលើព័ត៌មានដោយច្បាស់លាស់ ពុំមែនដោយការធ្វើតាមអ្នកដទៃ ព្រោះថាគ្រប់ការងារទាំងអស់មានតម្រូវការ បុគ្គលិកលក្ខណៈ ជំនាញ និងគុណតម្លៃផ្សេងៗគ្នា។ ដើម្បីអាចដឹងថាតើការងារប្រភេទណា ដែលសមស្របទៅនឹងអ្វីដែល ស្ថានភាពរបស់អ្នកត្រូវចាំបាច់ស្វះស្វែងស្រាវជ្រាវតាមប្រភពព័ត៌មាន និងប្រឹក្សាជាមួយអ្នកដែលធ្លាប់មានបទពិសោធន៍អោយបានច្រើន។

អ្នកអាចប្រមូលព័ត៌មានបន្ថែមពីអាជីពការងារពីប្រភពធំៗបីគឺ៖

- គេហទំព័រមុខរបរ និងការងារផ្សេងៗ
- បណ្ណាល័យ និងស្ថាប័ននានា
- ជួបសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកមានបទពិសោធន៍ អាជីព

ត្រូវចងចាំថា បុគ្គលដែលទទួលបានជោគជ័យ ពុំអង្គុយរង់ចាំអោយគេជួយខ្លួននោះទេ។ ពួកគេជាប្រភេទមនុស្សដែលសកម្ម និងចេះស្វែងរកមធ្យោបាយដោះស្រាយបញ្ហា និងបង្កើនឱកាសសម្រាប់ខ្លួនឯង។

### ប្រភពព័ត៌មានស្ថាប័នអប់រំនានា

អ្នកអាចស្វែងរកព័ត៌មានតាមបណ្តាញស្ថាប័ននានា ដូចជាបណ្ណាល័យ មជ្ឈមណ្ឌលសិក្សាជាដើម។ នៅទីនោះ អ្នកអាចសាកសួរព័ត៌មាន និងរកសៀវភៅល្អៗ ច្រើនទាក់ទងនឹងការរៀបចំផែនការអាជីព ក៏ដូចជាទាក់ទងប្រធានបទផ្សេងៗ សំរាប់ជាជំនួយដល់ការសម្រេចចិត្ត និងការត្រៀមខ្លួនរបស់អ្នក។ ខាងក្រោមនេះជាទីតាំងមួយចំនួនដែលអ្នកអាចចុះទៅជួបដោយផ្ទាល់៖

**ទីក្រុងភ្នំពេញ**

អាសយដ្ឋាន No 3 មហាវិថីសហពន្ធ័រុស្ស៊ី

facebook.com/moeyscambodia moeys.gov.kh YouTube youtube.com/moeyscambodia

ទូរស័ព្ទ 023 633 6002, 077 232 378
អ៊ីម៉ែល jc_pp@nea.giv.kh

**បាត់ដំបង**
អាសយដ្ឋាន វិទ្យាស្ថានពហុបច្ចេកវិទ្យាបាត់ដំបង
ទូរស័ព្ទ 053 733 111
អ៊ីម៉ែល jc_battambang@nea.gov.kh

**សៀមរាប**
អាសយដ្ឋាន មជ្ឈមណ្ឌលគុរកោសល្យខេត្តភូមិបន្ទាយចាស់សង្កាត់ស្លក្រោម
ទូរស័ព្ទ 063 210 277
អ៊ីម៉ែល jc_siemreap@nea.gov.kh

**កំពត**
អាសយដ្ឋាន វិទ្យាស្ថានពហុបច្ចេកវិទ្យាកំពតភូមិ១ឧសភា ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ
ទូរស័ព្ទ 033 210 277
អ៊ីម៉ែល jc_kampot@nea.gov.kh

**ស្វាយរៀង**
អាសយដ្ឋាន វិទ្យាស្ថានហ្វឹកហ្វឺនបច្ចេកទេស ភូមិមេ ភ្លើង ឃុំស្វាយរៀង ស្រុកស្វាយរៀង
ទូរស័ព្ទ 044 715 277
អ៊ីម៉ែល jc_svayrieng@nea.gov.kh

The American Corner
ជាបណ្ណាល័យរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា។ នៅ American Corner មានសៀវភៅល្អៗជាច្រើន ជាពិសេសទាក់ទង នឹងការរៀនភាសារអង់គ្លេស និងចំណេះដឹងទូទៅផ្សេងៗ។ អ្នកក៏អាចរកមើល សៀវភៅទាក់ទងនឹងការសិក្សានៅសហរដ្ឋអាមេរិក ដែលក្នុងនោះមានរាយព័ត៌មានលម្អិតនៃមុខវិជ្ជាសិក្សា និងការងារ។

**ភ្នំពេញ**
សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
អាសយដ្ឋាន មហាវិថីព្រះនរោត្តម



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

ទូរស័ព្ទ 023 993 957

អ៊ីម៉ែល acc@puc.edu.kh

**កំពង់ចាម**

សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME)
អាសយដ្ឋាន ផ្លូវជាតិលេខ7 ក្រុងកំពង់ចាម
ទូរស័ព្ទ 066 777 317 / 086 24 81 86
អ៊ីម៉ែល tek.kimleang@ume-kpc.edu.kh, kimleangtek@gmail.com

**បាត់ដំបង**

សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME)
អាសយដ្ឋាន No.76 ភូមិព្រែកព្រះស្តេច
ទូរស័ព្ទ 096 612 240 5
អ៊ីម៉ែល corner.btb@gmail.om

**សៀមរាប**

សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ (USEA)
អាសយដ្ឋាន ទល់មុខវិទ្យាល័យអង្គរក្រុងសៀមរាប
ទូរស័ព្ទ 097 98 98 536
អ៊ីម៉ែល dara_hun@hotmail.com

**ក្រុមសេវាប្រឹក្សាការងារ** ( Career Advising Services)

សាកលវិទ្យាល័យភ្នំពេញល័យ
ជាក្រុមនិស្សិតស្ម័គ្រចិត្តដែលផ្តល់មគ្គុទ្ទេសក៍ និងព័ត៌មានពីការសិក្សាដល់សិស្ស និស្សិត
ទូរស័ព្ទ 077 716 289/ 010 757 936
អ៊ីម៉ែល sbounchan11@gmail.com

**ប្រភពព័ត៌មានតាមប្រព័ន្ធអ៊ីនធើណែត**

តាមគេហទំព័រទីភ្នាក់ងារជាតិមុខរបរ និងការងារ (National Employment Agency)
http:// www.nea.org.kh



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

នេះជាវែបសាយរបស់ភ្នាក់ងារជាតិ មុខរបរ និងការងារ។ វែប សាយនេះមានព័ត៌មានថ្មីៗទាក់ទងនឹងទីផ្សារការងារ វគ្គបណ្តុះបណ្តាលថ្មីៗ ព្រមទាំងការណែនាំផ្សេងៗ ទាក់ទងនឹងមុខរបរ និងការងារ។

World Economic Forum:

http://www.weforum.org/

នេះជាវែបសាយរបស់អង្គការ World Economic Forum។ វែបសាយនេះមានអត្ថបទពីអ្នកជំនាញល្បីទាក់ទិននឹងការអភិវឌ្ឍ បច្ចេកវិទ្យា និង ទំនោរសេដ្ឋកិច្ចពិភពលោក និង វិធីសាស្ត្រ ត្រៀមខ្លួនក្តាប់យកឱកាសផ្សេងៗ។

Singapore Workforce Development Agency:

http://www.wda.gov.sg

វែបសាយរបស់រដ្ឋាភិបាលសឹង្ហបូរីនេះ មានព័ត៌មាន និងគន្លឹះល្អៗ ក្នុងការរៀបចំគោលដៅជីវិត។ អ្នកក៏អាចស្វែងរក ព័ត៌មានពីតម្រូវការនិងការត្រៀមខ្លួនសម្រាប់ការងារផ្សេងៗ។

Wayne State College:

http://www.wsc.edu/advising_services/career_planning/exploration/what_can_i_do_with/

វែបសាយរបស់មហាវិទ្យាល័យនៅសហរដ្ឋអាមេរិកមួយនេះ បកស្រាយលម្អិតថា តើការងារអ្វីដែលអ្នកអាចធ្វើបានចេញពីមុខវិជ្ជានីមួយៗ។

វីដេអូខ្លី

របៀបស្វែងរកអត្ថន័យជីវិត How to find meaning of life by 3rd Grader:

https://www.youtube.com/watch?v=3Y6YVLXprII

មូលហេតុដែលអ្នកនឹងបរាជ័យក្នុងការស្វែងរកការងារដ៏អស្ចារ្យ។

Why you will fail to have a great career:

https://www.youtube.com/watch?v=iKHTawgyKWQ

តាមដានដំណឹងជ្រើសរើសបុគ្គលិកដែលអាចរកបាននៅក្នុងកាសែត ទស្សនាវដ្តី ឬគេហទំព័រ (bongthom.com, pelprek.com) ទោះបីជាអ្នកពុំទាន់ត្រូវស្វែងរកការងារធ្វើក៏ដោយ។ ធ្វើការកត់សម្គាល់ពីដំណឹងជ្រើសរើសបុគ្គលិកទាំងនោះ តើគេរើសតំណែងអ្វី ហើយតើអ្នកដាក់ពាក្យដែលមានជំនាញ បុគ្គលិកលក្ខណៈ បែបណា ដែលគេចង់បាន? ជាទូទៅនៅក្នុងដំណឹងជ្រើសរើសបុគ្គលិកនីមួយៗ គេតែងដាក់ព័ត៌មានលម្អិតដូចជា មុខតំណែង ការរៀបរាប់ពីតួនាទី និងការងារបានដូចជាការអប់រំ បទពិសោធន៍ បុគ្គលិកលក្ខណៈ ឬជំនាញផ្សេងៗ។

ការធ្វើបែបនេះអាចជួយអោយអ្នកប៉ាន់ស្មានពីទីផ្សារការងារ និងអាចត្រៀមខ្លួនអភិវឌ្ឍន៍ជំនាញផ្សេងៗពេលអ្នកកំពុងសិក្សា ដើម្បីបង្កើនគុណភាព លទ្ធភាព និងឱកាសរបស់ខ្លួន។



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ការចុះសម្ភាសន៍អ្នកជំនាញដោយផ្ទាល់

អ្នកអាចចូលរួមពិព័ណ៌ការងារ ឬកម្មវិធីផ្សេងៗ ដើម្បីជួបនិយាយ ដោយផ្ទាល់ ជាមួយមន្ត្រីជ្រើសរើសបុគ្គលិករបស់ក្រុមហ៊ុន ឬស្ថានប័នផ្សេងៗ។

ពេលអ្នកមានឱកាសជួបសាកសួរព័ត៌មានពីអ្នកជំនាញ អ្នកដែលមានបទពិសោធន៍ការងារណាមួយ អ្នកគួរត្រៀមសំណួរមួយចំនួន។ អ្នកអាចប្រើប្រាស់តារាងសំណួរ នៅខាងស្តាំសម្រាប់ជាជំនួយ។

បន្ទាប់ពីបានសិក្សាស្វែងយល់ពីព័ត៌មានបន្ថែមទាក់ទង នឹងអាជីពការងារដែលអ្នកចាប់អារម្មណ៍រួច ចូររំលឹកទៅតារាងការងារ ដែលពឹងផ្អែកលើគុណតម្លៃ ចំណាប់អារម្មណ៍ និងជំនាញ តើមានការងារអ្វីដែលអ្នកចង់លុបចេញ ឬចង់បន្ថែមដែរឬទេ? ចូរបន្តសម្រួចការងារនេះរហូតដល់ អ្នកអាចមើលឃើញថាតើ (ក្រុម) អាជីពណាមួយ ដែលអ្នកអាចធ្វើបាន។

## ត្រូវចងចាំ

នៅពេលដែលអ្នកស្តាប់យោបល់អ្នកដទៃ ចូរចងចាំថា ការងារដែលអ្នកស្តាប់មើលទៅល្អសម្រាប់មនុស្សម្នាក់ មិនប្រាកដថាល្អចំពោះអ្នកនោះទេ។ អ្នកត្រូវចេះបែងចែកពីអ្វី ដែលហៅថាការពិត និងអ្វីដែលជាគំនិតផ្ទាល់ខ្លួនរបស់បុគ្គល។ អ្នកត្រូវចេះចម្រាញ់នូវអ្វីដែលជាព័ត៌មានពិតជាក់ស្តែង អ្វីដែលជាអារម្មណ៍របស់បុគ្គល។ ដើម្បីកុំអោយអារម្មណ៍នោះ ជះឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នក។ ជាក់ស្តែងកាលពីបីឆ្នាំមុន មានសិស្សម្នាក់គាត់បានចូលរួមពិព័ណ៌ជំនាញសិក្សា និងការងារ របស់សមាគម FUSAAC។ គាត់បានស្តាប់វាគ្មិនម្នាក់ ចែករំលែកបទពិសោធន៍ពីការងារជាអ្នកគីមីជីវៈ។ ដោយសារវាគ្មិនជាមនុស្សដែលពូកែនិយាយ មានសម្មិទ្ធិផលគួរអោយស្ញប់ស្ញែងជាច្រើន សិស្សនោះក៏សម្រេចចិត្តរៀនមុខវិជ្ជាគីមីជីវៈ តាមវាគ្មិនដោយសង្ឃឹមថា នឹងអាចទទួលជោគជ័យដូចវាគ្មិននោះ។ បន្ទាប់ពីបានរៀនមុខវិជ្ជានេះទើបដឹងថា ជំនាញខាងគីមីជីវៈពុំមែនជាអ្វីដែលខ្លួនចូលចិត្ត។ដូច្នេះត្រូវចងចាំថាអ្វីដែលមើលទៅឡូយ ពុំប្រាកដថាធ្វើអោយអ្នកសប្បាយចិត្តនោះទេ។

## សំណួរសម្រាប់សម្ភាសន៍

មុននឹងជួបសម្ភាសន៍ជាមួយអ្នកជំនាញក្នុងអាជីពណាមួយ អ្នកគួរចំណាយពេលស្រាវជ្រាវ និងត្រៀមសំណួរផ្សេងៗទាក់ទងជំនាញ ឬអាជីពនេះ។

## ន្ថែមអាជីព

អ្នកអាចប្រើប្រាស់តារាងសំណួរពីអាជីពខាងក្រោម និងបន្ថែមសំណួរផ្សេងៗ ដែលអ្នកចង់ដឹង។

ឈ្មោះអាជីព________________________ ឈ្មោះអ្នកដែលត្រូវសម្ភាសន៍________________________

១. ចូរអ្នករៀបរាប់ពីកិច្ចការដែលអ្នកធ្វើជាប្រចាំ? មួយថ្ងៃតើធ្វើអ្វីខ្លះ?

________________________________________________



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

២. តើអ្នកចូលចិត្តការងារនោះត្រង់កន្លែងណា? មិនចូលចិត្តត្រង់កន្លែងណា?

៣. តើអ្នកធ្លាប់បានឆ្លងកាត់វគ្គបណ្ដុះបណ្ដាល ឬបទពិសោធន៍ការងារអ្វីខ្លះ មុននឹងមកដល់ការងារសព្វថ្ងៃនេះ?

៤. តើមនុស្សដែលមានបុគ្គលិកលក្ខណៈទេពកោសល្យ និងចំណាប់អារម្មណ៍របៀបណា ដែលអ្នកគិតថាសាកសមសម្រាប់ការងារនេះ?

៥. តើអ្នកបានរៀបចំខ្លួនយ៉ាងដូចម្ដេចខ្លះដើម្បីឈោងចាប់អាជីពនោះ? (ទាំងការ សិក្សា បទពិសោធន៍ការងារ ជំនាញបន្ថែម ការបង្កើតបណ្ដាញ ។ល។)

៦. តើបងគិតថាតម្រូវការសម្រាប់ជំនាញ ឬអាជីពនោះយ៉ាងម៉េចដែរនាពេល បច្ចុប្បន្ន? ចុះក្នុងរយៈពេល ៥ ទៅ ១០ឆ្នាំទៀតតើមុខងារប្រភេទនេះនឹងរីកចម្រើនទៅដល់ណា?

៧. តើមានការងារប្រភេទណា ដែលស្រដៀងគ្នា ដែលខ្ញុំគួរពិចារណាដែរឬទេ?

៨. (សំណួរដែលអ្នកចង់សួរ)



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី3

## ការបង្កើតគម្រោងឆ្ពោះទៅរកអាជីព



មកទល់ពេលនេះ អ្នកបានស្វែងយល់ពីខ្លួនឯងច្បាស់ជាងមុនបន្ទាប់ពីអ្នកបានសិក្សាពីខ្លួនឯងនៅក្នុងជំពូករងទី១ និងប្រមូលព័ត៌មានបន្ថែមពីប្រភពផ្សេងៗ។ ក្នុងជំពូករងនេះអ្នកនឹងធ្វើការសម្រេចចិត្ត និងរៀបជាគម្រោង ដើម្បីឈានចាប់អាជីពដែលអ្នកចង់បាន ដែលមានបីជំហានសំខាន់ៗគឺៈ

1. រៀបចំព័ត៌មាន (Making sense of information)
2. ការសម្រេចចិត្ត
3. ការរៀបចំផែនការឈានទៅរកគោលដៅអាជីព

## ការរៀបចំវិភាគព័ត៌មានដែលប្រមូលបាន

គ្រប់អាជីពទាំងអស់ មានគុណតម្លៃ និងជំនាញផ្សេងៗគ្នា។ តើការងារទាំងនោះមានលក្ខណៈសមស្របទៅនឹងអ្វីដែលអ្នកចង់បានដែរឬទេ? អ្នកអាចរំលឹកឡើងវិញនៅជំពូករងទី១ ការស្វែងយល់ពីខ្លួនឯង។ តើបរិស្ថានការងារ ជំនាញ និងគុណតម្លៃអាជីព ដែលអ្នកប្រាថ្នាចង់បាន តើមានអ្វីខ្លះ? តើអ្នកជាមនុស្សដែលអោយតម្លៃខ្លាំងទៅលើអ្វី? ដោយផ្អែកលើការឆ្លុះបញ្ចាំង ដែលអ្នកបានធ្វើនៅក្នុងជំពូករងទី១ សូមធ្វើចំណាត់ថ្នាក់ពីកត្តាដែលសំខាន់សម្រាប់អ្នកដែលអ្នកអោយតម្លៃបំផុត ក្នុងការធ្វើការងារនាពេលអនាគត។

**គុណតម្លៃ**[1]

____ភាពច្នៃប្រឌិត
____អាចរកប្រាក់កម្រៃបានច្រើន
____ឱកាសរៀនពីការងារបានច្រើន
____ឯករាជ្យភាព
____ទីតាំងការងារ
____ស្ថេរភាពការងារ
____ភាពជាអ្នកដឹកនាំ
____ភាពថ្លៃថ្នូរ
____វប្បធម៌ការងារ
____តុល្យភាពការងារ និងកិច្ចការផ្ទាល់ខ្លួន
____ការជួយអ្នកដទៃ
____ឱកាសធ្វើដំណើរ
____អត្ថប្រយោជន៍ផ្សេងៗ (វិស្សមកាល ធានារ៉ាប់រងសុខភាព)
____ធ្វើការងារចម្រុះ
____បរិស្ថានការងារ
____ពេលវេលាធ្វើការ
____ផ្សេងៗ

**ចំណាប់អារម្មណ៍**[2]

____អាចធ្វើការងារជួយសហគមន៍
____សិល្បៈច្នៃប្រឌិត
____ការរចនាម៉ូដ
____ការពង្រឹងទំនាក់ទំនងជាមួយអ្នកដទៃ
____អក្សរសិល្ប៍
____គ្រប់គ្រងថវិកាឬហិរញ្ញវត្ថុ
____តូរ្យតន្ត្រី



facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

____ធម្មជាតិ/ បរិស្ថាន
____ការរៀបចំ
____ការធ្វើគម្រោងផែនការ
____នយោបាយ
____ការលក់ដូរ
____វិទ្យាសាស្ត្រ
____កីឡា
____ការបង្រៀន
____បច្ចេកវិទ្យា
____ផ្សេងៗ

**ជំនាញ**[3]

____វិភាគដោះស្រាយបញ្ហា
____កីឡា
____ទំនាក់ទំនង
____ប្រឹក្សាយោបល់
____រកគំនិតច្នៃប្រឌិត
____ច្នៃម៉ូដ រចនា
____យល់ពីគន្លឹះ/របៀបធ្វើអ្វី១
____ទំនាក់ទំនងរវាងបុគ្គល និងបុគ្គល
____ភាពជាអ្នកដឹកនាំ

____សិល្បៈនៃការគ្រប់គ្រង
____ទាក់ទងនឹងគ្រឿងចក្រ
____ទាក់ទងនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងស្ថាប័ន
____ការស្រាវជ្រាវ
____ទាក់ទងការស្រាវជ្រាវខាងវិទ្យាសាស្ត្រ
____ជំនាញបច្ចេកទេស
____បង្កើតទស្សនៈវិស័យសម្រាប់អនាគត
____ផ្សេងៗ

1. សំដៅលើគោលការណ៍នៃការងារដែលអ្នកគិតថាសំខាន់ ដែលមានគុណប្រយោជន៍សាកសម នឹងអោយអ្នកខិតខំធ្វើការងារនោះ
2. សំដៅលើប្រភេទការងារដែលអ្នកចាប់អារម្មណ៍ ឬចូលចិត្ត
3. ជំនាញទាំងឡាយដែលអ្នកមានស្រាប់ ឬនឹងអភិវឌ្ឍបន្ថែម

ចូរស្រង់នូវកត្តាដែលមានចំណាត់ថ្នាក់ខ្ពស់ជាងគេ (1-5) នៃតារាងនីមួយៗដាក់ក្នុងតារាងខាងក្រោមនេះ៖

| **គុណតម្លៃ** | **ចំណាប់អារម្មណ៍** | **ជំនាញ** |
|---|---|---|
| 1. ____________ | 1. ____________ | 1. ____________ |
| 2. ____________ | 2. ____________ | 2. ____________ |
| 3. ____________ | 3. ____________ | 3. ____________ |
| 4. ____________ | 4. ____________ | 4. ____________ |
| 5. ____________ | 5. ____________ | 5. ____________ |

ផ្អែកលើព័ត៌មានដែលប្រមូលបាន ទាំងតារាងការងារដែលស្របតាមMBIT និងទ្រឹស្តី Holland ព្រមទាំងការស្រាវជ្រាវព័ត៌មានបន្ថែមផ្សេងៗ តើអ្នកគិតថាការងារណាដែលសមស្របជាមួយនឹងគោលការណ៍ នៃគុណតម្លៃរបស់អ្នក ព្រមទាំងត្រូវនឹងចំណាប់អារម្មណ៍ និងជំនាញដែលអ្នកចង់បាន?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

ចូរបំពេញតារាងខាងក្រោម

ការងារសមស្របជាមួយគុណតម្លៃ

______________________

______________________

______________________

ការងារសមស្របជាមួយចំណាប់អារម្មណ៍

______________________

______________________

______________________

ការងារសមស្របជាមួយជំនាញ

______________________

______________________

______________________

តើការងារណាដែលមានទាំងគុណតម្លៃ ត្រូវនឹងចំណាប់អារម្មណ៍ និងជំនាញរបស់អ្នក?

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**ចុះបើ...**

ចុះបើអ្នករៀនមុខវិជ្ជាខុស ដែលអ្នកគិតថាពុំមែនជាអ្វីដែលអ្នកចូលចិត្ត?

ប្រសិនបើអ្នករៀនមុខវិជ្ជាដែលក្រោយមកអ្នកគិតថាពុំមែនជាអ្វីដែលខ្លួនស្រលាញ់ពិតប្រាកដនោះ អ្នកពុំចាំបាច់បារម្ភអ្វីឡើយ ព្រោះថាមានមនុស្សជាច្រើន ដែលស្ថិតក្នុងស្ថានភាពដូចអ្នកដែរ។ ប្រសិនបើជួបបញ្ហានេះ តើត្រូវធ្វើដូចម្តេច?

អ្នកអាចសួរខ្លួនឯងនូវសំណួរមួយចំនួនដូចខាងក្រោមនេះ៖

- ❖ តើអ្នកពុំចូលចិត្តមុខវិជ្ជាសព្វថ្ងៃត្រង់កន្លែងណា? តើមានវិធីយ៉ាងណាដើម្បីបំពេញភាពខ្វះខាតនេះដែរឬទេ? ឧទាហរណ៍ ដូចជាការរៀនជំនាញបន្ថែមក្រៅម៉ោងសិក្សា ឬការធ្វើការងារហាត់ការផ្សេងៗ។
- ❖ តើមានចំណុចត្រង់ណានៃមុខវិជ្ជានេះដែលអ្នកចូលចិត្តដែរឬទេ? ការព្យាយាមស្វែងរកចំណុចវិជ្ជមាននៃអ្វីមួយដែលអ្នកពុំចូលចិត្តអាចជួយអោយអ្នកត្រឡប់ទៅជាមានអារម្មណ៍ល្អឡើងវិញ។

ទោះជាយ៉ាងណាការត្រៀមខ្លួនដែលល្អ ពឹងផ្អែកលើការអាចរួមបញ្ចូល មុខវិជ្ជាសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា ក៏ដូចជាបទពិសោធន៍ការងារផងដែរ។ វាពុំចាំបាច់ដែលអ្នកត្រូវតែធ្វើការងារ ដែលត្រូវមុខជំនាញសិក្សានោះទេ ព្រោះថាជាទូទៅ មុខជំនាញសិក្សាមួយ ពុំប្រាកដថានឹងនាំទៅរកអាជីពការងារតែមួយនោះទេ។ តួយ៉ាងដូចការងារខាងផ្នែកទីផ្សារ អាចរើសបុគ្គលិកដែលមានជំនាញខាងប្រព័ន្ធផ្សព្វផ្សាយ គ្រប់គ្រងពាណិជ្ជកម្ម ចិត្តសាស្ត្រ។ល។ សូម្បីជំនាញបច្ចេកទេសដូចជាកសិកម្ម វិស្វកម្ម ក៏អាចបែកខ្នែងទៅការងារច្រើនប្រភេទដែរ។

- ❖ តើធ្វើយ៉ាងម៉េចទើបអ្នកអាចប្រើប្រាស់នូវស្ថានភាពសព្វថ្ងៃរបស់អ្នក អោយអស់ពីលទ្ធភាព?
- ❖ តើសារៈប្រយោជន៍ដែលអ្នកនឹងបានទទួល ច្រើនជាងការខាតបង់ដែលកើតឡើងដោយសារអ្នកប្តូរមុខវិជ្ជាសិក្សាដែរឬទេ?

ចូរចងចាំថា មានពេលខ្លះអារម្មណ៍ចូលចិត្ត ឬពុំចូលចិត្តអ្វីមួយ អាចកើតឡើងតែក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។ ហេតុនេះអ្នកពុំគួរប្រញាប់សម្រេចចិត្តលឿនពេកនោះទេ។ ប្រសិនបើបន្ទាប់ពីអ្នកបានគិតច្បាស់លាស់ និងបានប្រឹក្សាយោបល់ជាមួយអ្នកដទៃ និងបានស្រាវ ជ្រាវរកព័ត៌មានបន្ថែមរួចហើយ អ្នកជឿជាក់ថាមុខវិជ្ជាដែលអ្នករៀនសព្វថ្ងៃពុំមែនជាអ្វីដែលអ្នកចង់បាន អ្នកអាចនឹងពិចារណាបោះបង់ និងប្តូររៀនមុខវិជ្ជាផ្សេងៗ។ ប៉ុន្តែអ្នកក៏ត្រូវដឹងច្បាស់ពីផលប៉ះពាល់ដែលនឹងកើតមានឡើង បន្ទាប់ពីអ្នកបានប្តូរមុខវិជ្ជារួចហើយ។

**ចុះបើ**អ្នកពុំទាន់សម្រេចចិត្តបានថាតើត្រូវរើសយកការងារ ឬអាជីពណាមួយនោះ?

មានសិស្សខ្លះដឹងច្បាស់ថា ចង់ធ្វើកិច្ចការឬរៀនមុខវិជ្ជាអ្វី នៅពេលដែលគេត្រូវចូលមហាវិទ្យាល័យ អ្នកខ្លះទៀតពុំដឹងនោះឡើយ។ប្រសិនបើអ្នកពុំទាន់អាចសម្រេចចិត្តថាគួររៀនមុខវិជ្ជាអ្វីដើម្បីអាចឈានចាប់អាជីពណាមួយដោយច្បាស់ អ្នកអាចជ្រើសរើសមុខវិជ្ជាណាដែល អ្នកមានអារម្មណ៍ស្រលាញ់ខ្លាំងជាងគេសិន។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ការរៀបចំគម្រោងអាជីព

បន្ទាប់ពីសម្រេចចិត្តរើសអាជីពការងារណាមួយរួចមក ជំហានបន្ទាប់ គឺការរៀបចំគម្រោងអាជីព។ ហេតុអ្វីចាំបាច់ត្រូវរៀបចំគម្រោងអាជីព?

ដូចគោលដៅផ្សេងៗដែរ ការចង់សម្រេចបានអាជីពណាមួយពឹងផ្អែកលើការរៀបចំផែនការមួយដែលល្អ មានជំហានច្បាស់ លាស់ ដែលអាចវាស់វែងបាន។ ការមានគម្រោងច្បាស់ លាស់ជួយបង្កើនឱកាសជោគជ័យរបស់អ្នក និងជួយអ្នកឈានមួយ ជំហានមុនអ្នកដទៃ ដោយសារអ្នកអាចចាប់ផ្តើមសន្សំ បទពិសោធន៍ ដែលមានសារៈប្រយោជន៍ទៅគោលដៅការងារអនាគត របស់អ្នកនៅពេលកំពុងសិក្សា។

មុននឹងរៀបចំគម្រោងអាជីព ចូរក្រឡេកមើលព័ត៌មាន ដែលអ្នកប្រមូលបានពីជំពូក១ និង២។ អ្នកអាចសិក្សាបន្ថែមទាក់ទងអាជីពការងារដែលអ្នកចង់ធ្វើ ថាតើមានតម្រូវការអ្វីខ្លះ? តើតម្រូវអោយអ្នកសិក្សា មុខវិជ្ជាអ្វីខ្លះ? ចុះបទពិសោធន៍ការងារវិញ? អ្នកក៏អាចស្វែងយល់ថា គួរពង្រឹងបន្ថែមជំនាញអ្វីខ្លះ ដែលស្ថាប័ននានាដែលអ្នកចង់ធ្វើគេចង់បាន។ ការត្រៀមខ្លួនដែលល្អពឹងផ្អែកលើការអាចរួមបញ្ចូលមុខវិជ្ជាសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា ក៏ដូចជាបទពិសោធន៍ការងារ។

ឈ្មោះ ______________________________ កាលបរិច្ឆេទ ____________________

**ព័ត៌មានត្រួសៗ**

ជំនាញសព្វថ្ងៃដែលខ្ញុំមាន (ឧ. ទំនាក់ទំនង ស្រាវជ្រាវ គ្រឿងចក្រ)

________________________________________________

គុណតម្លៃរបស់ខ្ញុំ (ឧ. អាចរកប្រាក់កំរៃ ជួយអ្នកដទៃ)

________________________________________________

ចំណាប់អារម្មណ៍របស់ខ្ញុំ (ឧ. ការច្នៃប្រឌិត បរិស្ថានវិទ្យាសាស្ត្រ បច្ចេកវិទ្យា)

________________________________________________

បុគ្គលិកលក្ខណៈរបស់ខ្ញុំ (ឧ. ស្ងប់ស្ងៀម ធ្វើច្រើនជាងគិត)

________________________________________________

**ការសិក្សារបស់ខ្ញុំ**

កម្រិតសិក្សាសព្វថ្ងៃ ______________________________

មុខវិជ្ជាដែលចូលចិត្តបំផុត ឬពូកែជាងគេ ______________________________

មុខវិជ្ជាដែលពុំសូវពូកែ ឬពុំសូវចូលចិត្ត ______________________________

សមិទ្ធផល និងពានរង្វាន់ក្នុងការសិក្សា ______________________________

**អាជីពដែលខ្ញុំចង់បាន**

តួនាទីការងារ: ______________________________

កម្រិតសិក្សាដែលត្រូវបំពេញ: ______________________________

តម្រូវការជំនាញ និងបទពិសោធន៍ផ្សេងៗ: ______________________________

ក្រុមហ៊ុនស្ថាប័នដែលអាចនឹងទៅធ្វើការជាមួយ: ______________________________

ព័ត៌មានផ្សេងៗ: ______________________________

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ការកំណត់គោលដៅ

មុននឹងរៀបចំគម្រោងផែនការមួយដែលល្អ អ្នកអាចស្វែងយល់បន្ថែមរបៀបរៀបចំគោលដៅជាមុនសិន។ ការកំណត់គោលដៅ គឺជាការដាក់នូវផែនការ ដើម្បីសម្រេចបានក្នុងពេលកំណត់មួយ។ ការកំណត់គោលដៅ ជួយឲ្យបុគ្គលម្នាក់ៗ អាចមើលឃើញនូវទស្សនៈវិស័យយូរអង្វែង មានទំនុកចិត្ត និងមានកម្លាំងចិត្តក្នុងការឈានទៅរកគោលដៅ។ ពេលមានគោលដៅផែនការច្បាស់លាស់ អ្នកអាចផ្តោតរកមើលចំណេះដឹងថ្មីៗ និងឱកាសផ្សេងៗ ដើម្បីបំពេញបន្ថែម ឬដើម្បីមើលថាតើគួរចាត់ចែងពេលវេលា ឬធនធានយ៉ាងណា អោយមានប្រសិទ្ធភាព។ អ្នកក៏អាចតាមដានពីការរីកចម្រើននៃផែនការរបស់ខ្លួនផងដែរ។




facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## លក្ខណៈ៥យ៉ាងនៃគោលដៅល្អ

នៅពេលកំណត់គោលដៅ ត្រូវតែមានលក្ខណៈ៥ (SMART) ដូចរៀបរាប់ក្នុងរូបភាពខាងលើ។ ប្រសិនបើគោលដៅរបស់អ្នកមានទំហំធំ យូរអង្វែង អ្នកអាចបំបែកវាជាគោលដៅតូចៗ។ ធ្វើបែបនេះនឹងជួយអ្នក អាចមើលឃើញពីដំណើរការរបស់អ្នក និងមានកម្លាំងចិត្តក្នុងការសម្រេចវា។ ម្យ៉ាងទៀតអ្នកក៏គួរឧស្សាហ៍ពិនិត្យឡើងវិញ នូវគោលដៅរបស់អ្នក និងកុំស្ទាក់ស្ទើរនឹងដូរទិសដៅ ឬសកម្មភាព ប្រសិនបើអ្នកមើលឃើញថាមានបញ្ហាណាមួយ។

នៅទំព័របន្ទាប់ អ្នកនឹងសាកគិតគូររៀបចំផែនការគោលដៅអាជីពរបស់អ្នកដោយពឹងផ្អែកលើគោលការណ៍ SMART របស់គោលដៅដែលល្អ។ នៅក្នុងការរៀបចំគម្រោងអាជីព អ្នកគួរគិតពីកម្រិតអប់រំដែលអ្នកត្រូវសម្រេចបាន ជំនាញបន្ថែមក្រៅការសិក្សា ដែលអ្នកត្រូវអភិវឌ្ឍ ក៏ដូចជាបទពិសោធន៍ផ្សេងៗ ដែលអ្នកគួរមាន មុននឹងអាចឈោងចាប់អាជីពដែលអ្នកចង់បាន។

ដើម្បីរៀបចំផែនការមួយដែលល្អ និងអាចទទួលជោគជ័យ អ្នកគួររំលឹកឡើងវិញ នូវព័ត៌មានដែល អ្នកប្រមូលបានក្នុងជំពូកមុនៗ និងប្រឹក្សាបន្ថែម ជាមួយអ្នកដែលមានបទពិសោធន៍ផ្សេងៗ ជាដើម។

### ការរៀបចំគោលដៅដើម្បីឈានទៅរកអាជីព

| | គោលដៅ | សកម្មភាពត្រូវធ្វើ | កាលបរិច្ឆេទដែលត្រូវសម្រេច | កាលបរិច្ឆេទដែលសម្រេចបាន | រង្វាន់សម្រាប់ខ្លួនឯងប្រសិនបើជោគជ័យ |
|---|---|---|---|---|---|
| ទាក់ទ ការអប់រំ | | | | | |
| ទាក់ទ ការអភិវឌ្ឍជំនាញ | | | | | |
| ទាក់ទ បទពិសោធន៍ដែលត្រ ន៍ | | | | | |
| ទាក់ទ បណ្ដាញមនុស្ស ត្រូវស្គាល់ | | | | | |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី4



## ការបន្តអភិវឌ្ឍជំនាញ និងចំណេះដឹង

### ហេតុអ្វីក៏ត្រូវអភិវឌ្ឍជំនាញក្រៅសាលា?

ទីផ្សារការងារសព្វថ្ងៃនេះ មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ ជំនាញដែលមើលទៅជាតម្រូវការកាលពី១០ឆ្នាំមុន មិនប្រាកដថាសំខាន់ក្នុងទីផ្សារបច្ចុប្បន្ននោះទេ។ យ៉ាងណាមិញ ជំនាញដែលជាតម្រូវការទីផ្សារបច្ចុប្បន្ន ក៏ប្រហែលជាប្រែប្រួល ក្នុងរយៈពេល៣ទៅ៤ ឆ្នាំទៀតដែរ។ ហេតុនេះ សំខាន់ យើងត្រូវចេះសម្លឹងមើលទៅមុខ និងចេះសម្របខ្លួនទៅតាមបម្រែបម្រួលរបស់សង្គមជាដរាប។ ជំពូកចុងក្រោយនេះ នឹងផ្តោតលើការពង្រឹងនូវចំណេះដឹង ជំនាញទាំងនេះ។

### តើធ្វើយ៉ាងដូចម្តេច ទើបអាចបង្កើត ឬពង្រឹងជំនាញផ្សេងក្រៅពីការសិក្សាក្នុងសាលា?

អ្នកអាចបង្កើនជំនាញនេះតាមរយៈ ការអនុវត្តផ្ទាល់ចេញពីការងារ ក៏ដូចជាការប្រាស្រ័យទាក់ទង ជាមួយអ្នកដទៃនាពេលធ្វើការស្ម័គ្រចិត្ត ឬការចូលរួមសិក្សាសិក្ខាសាលា ឬកម្មវិធីហ្វឹកហ្វឺនផ្សេងៗ។ ខាងក្រោមនេះជាជំនាញCognitive និងNon-Cognitive សំខាន់ៗ ដែលពុំមានបង្រៀនក្នុងសាលា និងដែលអ្នកគួរអភិវឌ្ឍបន្ថែម។

**ជំនាញ Critical thinking**
**(ការគិតសមហេតុសមផល)**
នេះគឺជាសមត្ថភាពក្នុងការចង្អុលបង្ហាញចំណុចល្អ ចំណុចមិនល្អ
នៃបញ្ហាណាមួយ ការចេះវិភាគសម្រេចចិត្តដោយពឹងផ្អែកលើការគិត រកមុលហេតុសមហេតុសមផល អំណះអំណាងច្បាស់លាស់ ពុំមែនចេះតែយល់ស្រប ឬតាមតែអ្នកដ៏ទៃខុសទំនងនោះទេ។

**Leadership**
**(ភាពជាអ្នកដឹកនាំ)**
សំដៅលើការចេះមើលលើតម្រូវការការងារ ការចេះប្រើប្រាស់មនុស្សទៅតាមការងារ ការចេះប្រើ និងបញ្ចុះបញ្ចូលពន្យល់សមាជិកក្រុម ដើម្បីឈានទៅសម្រេចការងារមួយ ដែលទទួលបានជោគជ័យ និងទទួលបានលទ្ធផលដែលចង់បាន។

**ជំនាញដោះស្រាយបញ្ហា**
សំដៅលើជំនាញដែលតម្រូវអោយបុគ្គលម្នាក់ៗចេះមើលឃើញវិធីសាស្ត្រផ្សេងៗ ដើម្បីដោះស្រាយបញ្ហា។ នៅពេលធ្វើការបុគ្គលម្នាក់ៗ នឹងជួបបញ្ហា និងឧបសគ្គជាច្រើន។ អ្នកដែលជោគជ័យចេះវិភាគរកមើលមូលហេតុដែលបង្កើតអោយមានបញ្ហា និងចេះស្រាយចំណាងដោយខ្លួនឯង។ ដើម្បីអាចអភិវឌ្ឍខ្លួនឯង បុគ្គលម្នាក់ៗត្រូវមានផ្នត់គំនិត ជឿជាក់ និងស្វែងរកវិធីសាស្ត្រ ដោយខ្លួនឯងមុនឹង ស្វែងរកជំនួយពីថ្នាក់លើ។ ជាទូទៅបុគ្គលដែលទទួលបានជោគជ័យ ពេលជួបបញ្ហា បុគ្គលនោះនឹងស្វែងរកមូលហេតុ បន្ទាប់មកគូសវាសនូវវិធី និងផ្លូវផ្សេងៗ ដែលអាចយកឈ្នះ បញ្ហានោះបាន។ ពួកគេមើលឃើញថាការជួបប្រទះឧបសគ្គជារឿងធម្មតា និងចេះកែប្រែឧបសគ្គមកជាឱកាស ក្នុងការអភិវឌ្ឍខ្លួន និងទទួលយកជោគជ័យទៅវិញ។

**ការធ្វើការងារជាក្រុម**
សំដៅលើការចេះសហការ ធ្វើការជាមួយសមាជិកដ៏ទៃទៀត ដើម្បីសម្រេចគោលដៅ និងកិច្ចការដែលខ្លួនត្រូវធ្វើ។ ជាការបិតណាស់ការងារធំពុំអាចសម្រេចបានអាស្រ័យតែលើមនុស្សខ្លាំងម្នាក់នោះទេ ពោលគឺត្រូវអោយសមាជិកម្នាក់ៗចេះធ្វើការជាមួយអ្នកដ៏ទៃ បំពេញភាពខ្លាំងភាពខ្សោយរបស់ក្រុមដើម្បីអាចសហការគ្នាប្រកបដោយជោគជ័យ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

ជំនាញទាំងអស់នេះពុំមានបង្រៀននៅក្នុងសាលាទេ តែយើងអាចអភិវឌ្ឍជំនាញទាំងនោះតាមរយៈការធ្វើការងារដោយផ្ទាល់ ដូចជាការចុះធ្វើការងារស្ម័គ្រចិត្ត។ ការធ្វើការងារស្ម័គ្រចិត្ត អាចជួយឲ្យអ្នកយល់ដឹង និងបង្កើនសមត្ថភាពរបស់ខ្លួន។ ការងារស្ម័គ្រចិត្តក៏អាចជួយ អោយមនុស្សបើកទូលាយជាងមុន និងអត់ធ្មត់ក្នុងរៀនពីកំហុសនានា។ មិនត្រឹមតែប៉ុណ្ណោះការសាកល្បងធ្វើការងារស្ម័គ្រចិត្តអាចឲ្យអ្នកសាកល្បងដឹងថា តើអ្វីដែលអ្នកគិតថាអ្នកចូលចិត្ត តើពិតប្រាកដមែនដែរឬទេ? ឧ. ប្រសិនបើអ្នកគិតថាខ្លួនចង់ធ្វើជាគ្រូពេទ្យ អ្នកអាចស្ម័គ្រចិត្តធ្វើការ នៅមន្ទីរពេទ្យដើម្បីស្វែងយល់ ពីកិច្ចការប្រចាំថ្ងៃដែលគ្រូពេទ្យធ្វើ។ នៅទីនោះអ្នក នឹងមានឱកាសសង្កេតមើល ពីកិច្ចការប្រចាំថ្ងៃរបស់គ្រូពេទ្យ តើអ្នកចង់ក្លាយជាគ្រូពេទ្យដែរឬទេ? អ្នកក៏គួរព្យាយាមស្ម័គ្រចិត្ត ធ្វើកិច្ចការផ្សេងៗ រួមទាំងការងារដែលអ្នកពុំសូវជឿជាក់ថាខ្លួនឯងអាចធ្វើបាន។ ឧ. ប្រសិនបើអ្នកជាមនុស្សពុំសូវពូកែខាងគិតលេខ អ្នកប្រហែលជាអាចចំណាយពេលសាកធ្វើខាងហិរញ្ញវត្ថុក្នុងគម្រោងតូចណាមួយជាដើម។ល។ គោលបំណង គឺដើម្បីស្វែងយល់ពីអ្វី ដែលអ្នកអាចធ្វើបាន និងអ្វីដែលអ្នកពុំអាច។

ការចុះអនុវត្តដោយផ្ទាល់តាមរយៈការធ្វើការងារស្ម័គ្រចិត្ត ពុំត្រឹមតែផ្តល់បទពិសោធន៍ និងបង្កើតបណ្តាញសម្រាប់ការងាររបស់អ្នកនាពេលអនាគតប៉ុណ្ណោះទេ ប៉ុន្តែវានឹងជួយឲ្យអ្នកស្គាល់ពីសក្តានុពល ភាពខ្លាំង ភាពខ្សោយ និងចំណង់ចំណូលចិត្តរបស់ខ្លួនកាន់តែច្បាស់ថែមទៀត។ ប្រសិនបើពុំមានស្ថាប័ន ឬកន្លែងណាអាចធ្វើការស្ម័គ្រចិត្តបានទេ អ្នកក៏អាចប្រមែប្រមូលមិត្តភក្តិមកធ្វើការ និងរៀបចំដើម្បីធ្វើគម្រោងកម្មវិធីដែលអាចជួយដោះស្រាយបញ្ហាបានដែរ។

## ការធ្វើកំណត់ត្រារក្សាតារាងបទពិសោធន៍ស្ម័គ្រចិត្ត

នៅពេលដែលអ្នកធ្វើការងារស្ម័គ្រចិត្ត អ្នកគួរកត់ត្រាពីអ្វីដែលអ្នកបានរៀន ពីកិច្ចការនីមួយៗ។ ការធ្វើកំណត់ត្រាបែបនេះ អ្នកអាចឆ្លុះបញ្ចាំងពីអ្វីដែលខ្លួនបានរៀន បានធ្វើ និងអាចជួយអោយអ្នកអាចសម្រេចចិត្តថា តើជំនាញណាដែលអ្នកខ្វះនិងត្រូវបំពេញបន្ថែមបន្តទៀត ។ ម្យ៉ាងទៀតពេលអ្នកកំណត់ត្រាការងារវាបង្កភាពងាយស្រួល ក្នុងការងារប្រមូលព័ត៌មាន សម្រាប់ដាក់ពាក្យសុំធ្វើការ។ ខាងក្រោមនេះជាគំរូតារាងដែលអ្នកអាចយកទៅប្រើប្រាស់

| កិច្ចការងារដែលបានបំពេញមុខងារ | ការងារស្ម័គ្រចិត្តដំបូងរបស់អ្នក | | | |
|---|---|---|---|---|
| ស្ថាប័ន និងអ្នកដឹកនាំ (Supervisor) | | | | |
| រយៈពេលគ្រប់គ្រង | | | | |
| ការរៀបរាប់ពីជំនាញដែលរៀនចេះនិងមេរៀន | | | | |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

**បណ្តុះផ្នត់គំនិត និតឥរិយាបថល្អៗសម្រាប់អភិវឌ្ឍខ្លួនឯង**

មនុស្សដែលមានផ្នត់គំនិត និងឥរិយាបថល្អៗមានឱកាសទទួលបានជោគជ័យក្នុងជីវិតច្រើន ដោយសារពួកគេនិងមិនចុះញ៉មចំពោះមុខបញ្ហា ឬឧបសគ្គមួយគ្រានោះទេ។ ផ្នត់គំនិតពុំមែនកើតឡើង ដោយឯកឯងនោះទេ វាអាចបណ្តុះដោយដឹងខ្លួន ឬពុំដឹងខ្លួនចេញពីបរិស្ថាន និងទំនាក់ទំនងជាមួយអ្នក ដទៃជុំវិញខ្លួនអ្នក។ ហេតុនេះហើយបានជាវាមានសារៈសំខាន់ ដែលអ្នកត្រូវដឹង និងចេះបណ្តុះផ្នត់គំនិត ណាដែលមានសារៈប្រយោជន៍ចំពោះអ្នក។ ផ្នត់គំនិតដែលបុគ្គល បាននិងកំពុងអភិវឌ្ឍសម្រាប់ខ្លួនឯង មានដូចជាការព្យាយាម (perseverance) រៀនធ្វើកិច្ចការដោយឯករាជ្យ (independent) ការគិតសម្លឹងទៅ មុខ (forward thinking) ការមានសុទិដ្ឋិនិយមលើរាល់កិច្ចការងារនិងឧបសគ្គទាំងឡាយ ការព្យាយាមឈប់ រកពាក្យដោះសារ (ឧ. រវល់គ្មានពេល ពុំចេះធ្វើ) ដើម្បីគេចចេញពីទំនួលខុសត្រូវ និងការលុតដំធ្វើការងារ អោយចប់ចុងចប់ដើមមុននឹងលេងសប្បាយជាដើម។ល។

បញ្ជាក់ មនុស្សម្នាក់ៗមានគុណតម្លៃផ្សេងៗគ្នា។ ផ្នត់គំនិតដែលល្អសម្រាប់មនុស្សម្នាក់ ពុំបាន ន័យដូចគ្នាសម្រាប់មនុស្សម្នាក់ទៀតនោះទេ។ ដូច្នេះអ្នកត្រូវរកអ្វីដែលសមស្របជាមួយនឹងស្ថានភាព របស់អ្នក។

**តើខ្ញុំអាចដឹងច្បាស់ពីខ្លួនខ្ញុំច្បាស់ប៉ុណ្ណាដែរ?**

**រឿងដើមឬស្សីចិន**

ដើមឬស្សីចិន លូតលាស់ខុសពីដើមឬស្សីទូទៅ។ ជាទូទៅរុក្ខជាតិនានា ដុះលូតលាស់ពីមួយ ឆ្នាំទៅមួយឆ្នាំ។ រីឯទំពាំងរបស់ដើមឬស្សីចិនវិញ កប់ក្នុងដីរយៈពេល៤ឆ្នាំមុន វានឹងផុសចេញ។ នៅឆ្នាំទី៥ ដើមឬស្សីចិន នឹងលូតលាស់យ៉ាងខ្លាំងក្លាគួរអោយស្ញប់ស្ញែង។ ក្នុងរយៈពេលតែ៥សប្តាហ៍តែប៉ុណ្ណោះឬស្សីចិនអាចលូតដល់កម្ពស់ជិត៣០ម៉ែត្រ វាហាក់ដូចជាយើងឃើញដើមឬស្សីកំពុងតែលូតកម្ពស់ នៅនឹង មុខយ៉ាងដូច្នោះដែរ។

ដំណើរជិវិតក៏វាស្រដៀងទៅនឹងដើមឬស្សីចិនដែរ។ អ្នកប្រហែលជាខិតខំធ្វើការយ៉ាងសស្រាក់ សស្រាំ។ អ្នកប្រហែលជាព្យាយាមបណ្តុះជំនាញសមត្ថភាពរបស់អ្នកជាប្រចាំ។ អ្នកក៏ប្រហែលជាព្យាយាម ដាក់ចិត្តរៀនដើម្បីសម្រេចគោលបំណងណាមួយរបស់អ្នកដែរ។ មេរៀនដែលយើងអាចរៀនពីដើមឬស្សី ចិន គឺជួនកាលកិច្ចការទាំងឡាយត្រូវការដើម្បីបង្ហាញលទ្ធផល។ ប្រសិនបើថ្ងៃនេះអ្នកពុំទាន់ឃើញលទ្ធផលចេញពីកិច្ចខំប្រឹងរបស់អ្នក វាប្រហែលដូចជាដើមឬស្សីចិនអញ្ចឹងដែរ។ វាកំពុងតែលូតលាស់នៅក្នុងដី ដែលអ្នកពុំទាន់មើលឃើញវានៅឡើយ។ កុំទាន់អាក់អន់ចិត្ត និងឆាប់បោះបង់ចោល ពេលអ្នកពុំទាន់មើល ឃើញលទ្ធផលអ្វី។ ហេតុដូចនេះអ្នកគួរមានជំនឿចិត្តលើខ្លួនអ្នក និងបន្តស្រោចទឹកដាក់ជីលើកិច្ចការរបស់ អ្នកឲ្យដូចកសិករដែលដាំដើមឬស្សីចិនអញ្ចឹងដែរ។ មិនយូរមិនឆាប់អ្នកនឹងឃើញសមិទ្ធផលដែលចេញពី ការខិតខំប្រឹងប្រែងរបស់អ្នកជាពុំខាន។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ៣
# ព័ត៌មានស្ដីពីការសិក្សា
# គ្រឹះស្ថានសិក្សា និងមុខរបរ

**សូមស្កេននៅទីនេះដើម្បីទទួលព័ត៌មានបន្ថែម**
**ស្ដីពីការជ្រើសរើសមុខជំនាញ**

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

# ក. ព័ត៌មានស្តីពីគ្រឹះស្ថានឧត្តមសិក្សា

## ១. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

### ❁ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យភូមិន្ទភ្នំពេញ** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងនៅមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ៨៨៣ ៦៤០, ០៩២ ៨៩៨ ៩៩៨
- Fax : 023 880 116, 023 884 154
- E-mail : lceav@camnet.com.kh, IFL@everyday.com.kh
- គេហទំព័រ : http://www.rupp.edu.kh

### ❁ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានមហាវិទ្យាល័យ ០៤ និងវិទ្យាស្ថាន ០១ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យវិទ្យាសាស្ត្រ | គណិតវិទ្យា |
| | | ព័ត៌មានវិទ្យា |
| | | ជីវវិទ្យា |
| | | គីមីវិទ្យា |
| | | រូបវិទ្យា |
| | | បរិស្ថាន |
| ២ | មហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ | អក្សរសាស្ត្រខ្មែរ |
| | | ទស្សនវិជ្ជា |
| | | សង្គមវិទ្យា |
| | | ទេសចរណ៍ |
| | | ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ |
| | | ប្រវត្តិវិទ្យា |
| | | ភូមិវិទ្យា |
| | | ចិត្តវិទ្យា |
| | | សង្គមកិច្ចវិទ្យា |
| ៣ | មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍ | អភិវឌ្ឍន៍សេដ្ឋកិច្ច |
| | | គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | អភិវឌ្ឍន៍សហគមន៍ |
| ៤ | មហាវិទ្យាល័យវិស្វកម្ម | វិស្វកម្មទូរគមនាគមន៍ និងអេឡិចត្រូនិច |
| | | វិស្វកម្មជីវសាស្ត្រ |
| | | វិស្វកម្មបច្ចេកវិទ្យាព័ត៌មាន |
| ៥ | វិទ្យាស្ថានភាសាបរទេស | ភាសាអង់គ្លេស |
| | | ភាសាបារាំង |
| | | ភាសាជប៉ុន |
| | | ភាសាកូរ៉េ |
| | | ភាសាចិន |
| | | សិក្សាអន្តរជាតិ |

## ២. សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

### ❖ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងនៅឡូត៍លេខ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ៤៣០ ៥៥៩, ០២៣ ៤៣០ ៥៦១
- E-mail : uhsc@univ-sante.edu.kh
- គេហទំព័រ : www.univ-sante.edu.kh

### ❖ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មានមហាវិទ្យាល័យ ០៤ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យវេជ្ជសាស្ត្រ | វេជ្ជសាស្ត្រ |
| ២ | មហាវិទ្យាល័យឱសថសាស្ត្រ | ឱសថសាស្ត្រ |
| ៣ | មហាវិទ្យាល័យទន្តវេទនសាស្ត្រ | ទន្តវេទនសាស្ត្រ |
| ៤ | មហាវិទ្យាល័យបច្ចេកទេសថែទាំវេជ្ជសាស្ត្រ | គិលានុបដ្ឋាក |
| | | ឆ្មប |
| | | បច្ចេកទេសមន្ទីរពិសោធន៍ |
| | | ព្យាបាលដោយចលនា |
| | | បច្ចេកទេសវិទ្យុសាស្ត្រ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ៣. សាកលវិទ្យាល័យជាតិគ្រប់គ្រង

### ❖ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យជាតិគ្រប់គ្រង** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងនៅតាម មហាវិថីព្រះមុនីវង្ស កែងនឹងផ្លូវគ្រីស្តូហ្វ័រហូស្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ៤២៨ ១២០
- E-mail : num@yahoo.com
- គេហទំព័រ : www.num.edu.kh

### ❖ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យជាតិគ្រប់គ្រង មានមហាវិទ្យាល័យ ០៦ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យ គ្រប់គ្រង និងម៉ាឃីតធីង | គ្រប់គ្រង |
| | | ម៉ាឃីតធីង |
| ២ | មហាវិទ្យាល័យ គណនេយ្យ និងហិរញ្ញវត្ថុ-ធនាគារ | គណនេយ្យ |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| ៣ | មហាវិទ្យាល័យ ទេសចរណ៍ និងបដិសណ្ឋារកិច្ច | ទេសចរណ៍ |
| | | សេវាបដិសណ្ឋារកិច្ច |
| ៤ | មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច | សេដ្ឋកិច្ចពាណិជ្ជសាស្ត្រ |
| | | សេដ្ឋកិច្ចអភិវឌ្ឍន៍ |
| ៥ | មហាវិទ្យាល័យនីតិសាស្ត្រ | ច្បាប់ពាណិជ្ជកម្ម |
| | | ច្បាប់រដ្ឋបាលសាធារណៈ |
| ៦ | មហាវិទ្យាល័យព័ត៌មានវិទ្យា | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា |
| | | ប្លង់ និងរចនា |

## ៤. សាកលវិទ្យាល័យភូមិន្ទកសិកម្ម

### ❖ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យភូមិន្ទកសិកម្ម** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងស្ថិតនៅចំការដូង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ២១៩ ៧៥៣, ០១២ ៨៥៨ ១២០
- ទូរសារលេខ៖ ០២៣ ២១៩ ៧៥៣
- E-mail : rua@camnet.com.kh

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

– គេហទំព័រ : www.rua.edu.kh

❁ **មហាវិទ្យាល័យ និងមុខជំនាញ**

សាកលវិទ្យាល័យភូមិន្ទកសិកម្ម មានមហាវិទ្យាល័យ ០៨ ដែលមានមុខជំនាញៈ

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យ វិទ្យាសាស្ត្រកសិកម្ម | វិទ្យាសាស្ត្រកៅស៊ូ |
| | | ផលិតកម្មដំណាំ |
| | | ការការពារដំណាំ |
| ២ | មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ | វិទ្យាសាស្ត្រសត្វ |
| | | វេជ្ជសាស្ត្រសត្វ |
| ៣ | មហាវិទ្យាល័យ វិទ្យាសាស្ត្រព្រៃឈើ | ធនធានព្រៃឈើ |
| | | អភិរក្សព្រៃឈើ |
| ៤ | មហាវិទ្យាល័យវិទ្យាសាស្ត្រជលផល | វារីជីវសាស្ត្រ |
| | | វារីវប្បកម្ម |
| | | អាជីវកម្ម និងផលិតផលជលផល |
| ៥ | មហាវិទ្យាល័យ បច្ចេកវិទ្យា និងគ្រប់គ្រងកសិកម្ម | វិស្វកម្មប្រព័ន្ធកសិកម្ម |
| | | ម៉ាស៊ីនកសិកម្ម |
| | | អភិរក្ស និងគ្រប់គ្រងធនធាន |
| ៦ | មហាវិទ្យាល័យ សេដ្ឋកិច្ច និងអភិវឌ្ឍន៍ជនបទ | សេដ្ឋកិច្ចកសិកម្ម |
| | | កសិ-ពាណិជ្ជកម្ម |
| | | អភិវឌ្ឍន៍ជនបទ |
| ៧ | មហាវិទ្យាល័យ កសិ-ឧស្សាហកម្ម | វិទ្យាសាស្ត្រអាហារ |
| | | បច្ចេកវិទ្យាជីវៈអាហារ |
| | | បច្ចេកវិទ្យាក្រោយពេលប្រមូលផល |
| ៨ | មហាវិទ្យាល័យ រៀបចំដី និងរដ្ឋបាលដីធ្លី | គោលនយោបាយដីធ្លី និងរដ្ឋបាលដីធ្លី |
| | | រៀបចំដី |
| | | ព័ត៌មានភូមិសាស្ត្រ វាស់វែង និងការធ្វើផែនទី |

**៩. សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**➢ អាសយដ្ឋានទំនាក់ទំនង**

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងស្ថិតនៅតាមមហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។
- ប្រអប់សំបុត្រ PO Box: ៨៤២
- ទូរស័ព្ទលេខ៖ ០២៣ ៣៦២ ៦០៧
- ទូរសារលេខ៖ ០២៣ ២១៤ ៩៥៣
- E-mail : ruleusokha@yahoo.com
- គេហទំព័រ : http://www.rule.edu.kh

**❖ មហាវិទ្យាល័យ និងមុខជំនាញ**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានមហាវិទ្យាល័យ ០៤ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យនីតិសាស្ត្រ | នីតិសាស្ត្រសិក្សាជាភាសាខ្មែរ |
| | | នីតិសាស្ត្រសិក្សាជាភាសាបារាំង |
| | | នីតិសាស្ត្រសិក្សាជាភាសាអង់គ្លេស |
| | | នីតិសាស្ត្រសិក្សាជាភាសាជប៉ុន |
| ២ | មហាវិទ្យាល័យរដ្ឋបាលសារធារណៈ | រដ្ឋបាលសាធារណៈ |
| | | ទំនាក់ទំនងអន្តរជាតិ |
| ៣ | មហាវិទ្យាល័យ សេដ្ឋកិច្ច និងគ្រប់គ្រង | សេដ្ឋកិច្ចសិក្សាជាភាសាខ្មែរ |
| | | សេដ្ឋកិច្ចសិក្សាជាភាសាបារាំង |
| | | ធនាគារ និងហិរញ្ញវត្ថុ |
| | | គណនេយ្យ |
| ៤ | មហាវិទ្យាល័យសេដ្ឋកិច្ចព័ត៌មាន | សេដ្ឋកិច្ចព័ត៌មាន |

**១. សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ**

**❖ អាសយដ្ឋានទំនាក់ទំនង**

- **សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងស្ថិតនៅអគារលេខ៧២ កាច់ជ្រុងផ្លូវព្រះអង្គយុគន្ធរ (លេខ១១៩) និងផ្លូវមគ្គវ័ន (លេខ១៧៨) សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ៩៨៦ ៤១៧
- ទូរសារលេខ៖ ០២៣ ៩៨៦ ៤១៧

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- E-mail : rufa@camnet.com.kh
- គេហទំព័រ : http://www.rufa.edu.kh/

**❖ មហាវិទ្យាល័យ និងមុខជំនាញ**

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានមហាវិទ្យាល័យ ០៥ ដែលមានមុខជំនាញៈ

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យបុរាណវិទ្យា | បុរាណវិទ្យា |
| | | មគ្គុទ្ទេសក៍បេតិកភណ្ឌវប្បធម៌ |
| ២ | មហាវិទ្យាល័យ ស្ថាបត្យកម្ម និងនគរោបនីយវិទ្យា | ស្ថាបត្យកម្ម |
| | | នគរោបនីយកម្ម និងការរៀបចំក្រុង |
| ៣ | មហាវិទ្យាល័យសិល្បៈសូនរូប | តុបតែងលម្អ |
| | | គំនូរវិចិត្រកម្ម |
| | | ចម្លាក់ទំនើប |
| | | គំនូរសារគមនាគមន៍ |
| ៤ | មហាវិទ្យាល័យតូរ្យតន្ត្រី | និពន្ធបទភ្លេង |
| | | ដឹកនាំក្រុមភ្លេង |
| | | អ្នកចម្រៀង និងតន្ត្រីករ |
| | | តូរ្យតន្ត្រី |
| ៥ | មហាវិទ្យាល័យនាដសាស្ត្រ | សម្តែង ដឹកនាំរឿង តម្លើងរបាំ ល្ខោនបុរាណ សម័យ និងសៀក |

## ៧. សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ

**❖ អាសយដ្ឋានទំនាក់ទំនង**

- **សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងស្ថិតនៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។
- ទូរស័ព្ទលេខៈ ០១២ ៨៧៨ ៩០១
- E-mail : uk_thaun@yahoo.com
- គេហទំព័រ : www.CSUK.edu.kh

**❖ មហាវិទ្យាល័យ និងមុខជំនាញ**

សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ មានមហាវិទ្យាល័យ ០២ ដែលមានមុខជំនាញៈ

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យគ្រប់គ្រង | ម៉ាឃីតធីង |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | គ្រប់គ្រងធនធានមនុស្ស |
| | | គណនេយ្យ |
| ២ | មហាវិទ្យាល័យកសិកម្ម | អភិវឌ្ឍន៍ជនបទ |
| | | ក្សេត្រសាស្ត្រ |
| | | គ្រប់គ្រងធនធានធម្មជាតិ |
| | | ភាសាអង់គ្លេស |

## ៨. សាកលវិទ្យាល័យស្វាយរៀង

### ❁ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យស្វាយរៀង** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ១ ភូមិចំបក់ សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង។
- ទូរស័ព្ទលេខ៖ ០៤៤ ៣៩៥ ៥៣៩, ០៤៤ ៧១៥ ៧៧៦, ០១១ ៩១១ ៧៧៨
- ទូរសារលេខ៖ ០៤៤ ៧១៥ ៧៧៨
- E-mail : info@sru.edu.kh
- គេហទំព័រ : www.sru.edu.kh

### ❖ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យស្វាយរៀង មានមហាវិទ្យាល័យ ០៥ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស | ភាសាអង់គ្លេស |
| ២ | មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | វិទ្យាសាស្ត្រកុំព្យូទ័រ |
| | | គណិតវិទ្យា |
| ៣ | មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម | គណនេយ្យ |
| | | គ្រប់គ្រង |
| | | ទីផ្សារ |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| ៤ | មហាវិទ្យាល័យកសិកម្ម | ក្សេត្រសាស្ត្រ |
| | | អភិវឌ្ឍន៍ជនបទ |
| | | វិទ្យាសាស្ត្រវេជ្ជសាស្ត្រសត្វ |
| ៥ | មហាវិទ្យាល័យសង្គមសាស្ត្រ | រដ្ឋបាលសាធារណៈ |

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

## ៩. សាកលវិទ្យាល័យមានជ័យ

### ❁ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យមានជ័យ** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៥ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។
- ទូរស័ព្ទលេខ៖ ០១២ ៩០១ ២២៤, ០៩៧ ៧៣៥ ៩៩៨៨, ០១២ ៩២១ ៩៧៦
- E-mail : choeuntauch@yahoo.com
- គេហទំព័រ : www.mcu.edu.kh

### ❁ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យមានជ័យ មានមហាវិទ្យាល័យ ០៥ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសា | អក្សរសាស្ត្រខ្មែរ |
| | | អក្សរសាស្ត្រអង់គ្លេស |
| | | អក្សរសាស្ត្រកូរ៉េ |
| ២ | មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ព័ត៌មានវិទ្យា |
| ៣ | មហាវិទ្យាល័យ សង្គមសាស្ត្រ និងអភិវឌ្ឍន៍សហគមន៍ | អភិវឌ្ឍន៍សហគមន៍ |
| ៤ | មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ | គ្រប់គ្រងពាណិជ្ជកម្ម |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| ៥ | មហាវិទ្យាល័យ កសិកម្ម និងកែច្នៃម្ហូបអាហារ | កសិឧស្សាហកម្ម |
| | | ក្សេត្រសាស្ត្រ |
| | | បសុពេទ្យ |
| | | គ្រឿងយន្តកសិកម្ម |

## ១០. សាកលវិទ្យាល័យបាត់ដំបង

### ❁ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យបាត់ដំបង** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៥ ទល់មុខព្រលានយន្តហោះវាលបែកចាន ភូមិអូរខ្ចាយ សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង។
- ទូរស័ព្ទលេខ៖ ០៥៣ ៩៥២ ៩០៥

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

– E-mail : info@ubb.edu.kh
– គេហទំព័រ : www.ubb.edu.kh

## ❁ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យបាត់ដំបង មានមហាវិទ្យាល័យ ០៦ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យ កសិកម្ម និងកែច្នៃអាហារ | ក្សេត្រសាស្ត្រ |
| | | បសុពេទ្យ និងវិទ្យាសាស្ត្រសត្វ |
| | | កែច្នៃអាហារ |
| ២ | មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ | គ្រប់គ្រង |
| | | គណនេយ្យ |
| | | ធនាគារ និងហិរញ្ញវត្ថុ |
| | | ទេសចរណ៍ |
| | | ទីផ្សារ |
| ៣ | មហាវិទ្យាល័យ សង្គមសាស្ត្រ និងអភិវឌ្ឍន៍សហគមន៍ | វិទ្យាសាស្ត្រសេដ្ឋកិច្ច |
| | | កសិពាណិជ្ជកម្ម |
| | | នីតិសាស្ត្រ |
| | | អភិវឌ្ឍន៍ជនបទ |
| ៤ | មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | បច្ចេកវិទ្យាព័ត៌មានវិទ្យា |
| | | វិស្វកម្មសំណង់ស៊ីវិល |
| | | វិស្វកម្មនុយក្លេអ៊ែរ |
| ៥ | មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងអប់រំ | គណិតវិទ្យា |
| | | គីមីវិទ្យា |
| | | រូបវិទ្យា |
| | | ជីវវិទ្យា |
| | | អក្សរសាស្ត្រខ្មែរ |
| ៦ | វិទ្យាស្ថានភាសាបរទេស | ភាសាអង់គ្លេស |
| | | ភាសាកូរ៉េ |
| | | ភាសាចិន |
| | | ភាសាជប៉ុន |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ១១. វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

### ❁ អាសយដ្ឋានទំនាក់ទំនង

- **វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា** ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលមានទីតាំងស្ថិតនៅមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ។
- ប្រអប់សំបុត្រលេខ ៨៦ រាជធានីភ្នំពេញ
- ទូរស័ព្ទលេខ៖ ០២៣ ៨៨០ ៣៧០
- ទូរសារលេខ៖ ០២៣ ៨៨០ ៣៦៩
- គេហទំព័រ : www.itc.edu.kh

### ❁ មុខជំនាញ

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានមុខជំនាញ៖

| ល.រ | មុខជំនាញ |
|---|---|
| ១ | គីមី និងចំណីអាហារ |
| ២ | សំណង់ស៊ីវិល |
| ៣ | អគ្គិសនី ថាមពល និងទូរគមនាគមន៍ |
| ៤ | ព័ត៌មានវិទ្យា និងទំនាក់ទំនង |
| ៥ | ឧស្សាហកម្ម និងមេកានិច |
| ៦ | ជនបទ (វិស្វកម្មធនធានទឹក និងភូគព្ភសាស្ត្រ) |

## ១២. សាកលវិទ្យាល័យមេគង្គកម្ពុជា

### ❁ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យមេគង្គកម្ពុជា** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងស្ថិតនៅអគារលេខ៩B ផ្លូវលេខ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ (មុំអូរបែកក្អម)។
- ទូរស័ព្ទលេខ៖ ០២៣ ៨៨២ ២១១, ០៩២ ២៩៧ ៧២២
- ទូរសារលេខ៖ ០១២ ៨០៩ ១៩១
- E-mail : info@mekong.edu.kh
- គេហទំព័រ : www.mekong.edu.kh

### ❁ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យមេគង្គកម្ពុជា មានមហាវិទ្យាល័យ ០៦ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យ | អប់រំភាសាអង់គ្លេស |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | សិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស | ភាសាជប៉ុន |
| ២ | មហាវិទ្យាល័យគ្រប់គ្រង និងទេសចរណ៍ | គ្រប់គ្រងពាណិជ្ជកម្ម និងសហគ្រាស |
| | | គ្រប់គ្រងអចលនទ្រព្យ |
| ៣ | មហាវិទ្យាល័យនីតិសាស្ត្រ | ច្បាប់ពាណិជ្ជកម្ម |
| ៤ | មហាវិទ្យាល័យសេដ្ឋកិច្ច | អភិវឌ្ឍន៍ជនបទ |
| | | វិភាគហិរញ្ញវត្ថុ និងការវិនិយោគ |
| ៥ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | វិស្វកម្មសំណង់ស៊ីវិល |
| | | ស្ថាបត្យកម្ម និងនគរូបនីយកម្ម |
| | | វិទ្យាសាស្ត្រផ្នែកអនុវត្តពាណិជ្ជកម្ម |
| ៦ | មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម | គ្រប់គ្រងអង្គភាព |
| | | ទំនាក់ទំនងអន្តរជាតិ |
| | | ទំនាក់ទំនងសាធារណៈ |
| | | ភាពជាអ្នកដឹកនាំ |

## ១៣. សាកលវិទ្យាល័យបៀលប្រាយ

### ❖ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យបៀលប្រាយ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងស្ថិតនៅអគារភ្នំពេញសិនធ័រ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ៩៨៧ ៧០០
- គេហទំព័រ : www.bbu.edu.kh

### ❖ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យបៀលប្រាយ មានមហាវិទ្យាល័យ ០៦ ដែលមានដេប៉ាតឺម៉ង់៖

| ល.រ | មហាវិទ្យាល័យ | ដេប៉ាតឺម៉ង់ |
|---|---|---|
| ១ | មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម | គណនេយ្យ និងហិរញ្ញវត្ថុ |
| | | ធនាគារ និងហិរញ្ញវត្ថុ |
| ២ | មហាវិទ្យាល័យ ទេសចរណ៍ និងបដិសណ្ឋារកិច្ច | ការគ្រប់គ្រងទេសចរណ៍ |
| | | ការគ្រប់គ្រងឧស្សាហកម្មម្ហូបអាហារ |
| | | ការគ្រប់គ្រងសណ្ឋាគារ |
| ៣ | មហាវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | នីតិសាស្ត្រ |
| | | វិទ្យាសាស្ត្រនយោបាយ |
| | | សង្គមវិទ្យា |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| ៤ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | វិទ្យាសាស្ត្រកុំព្យូទ័រ |
| | | បច្ចេកវិទ្យាព័ត៌មាន |
| | | បច្ចេកវិទ្យាទូរគមនាគមន៍ |
| | | ទីផ្សារ |
| | | ការគ្រប់គ្រង |
| ៥ | មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ និងភាសា | អក្សរសាស្ត្រអង់គ្លេស |
| | | ភាសាបរទេសសម្រាប់អាជីវកម្ម |
| | | អប់រំ |
| ៦ | មហាវិទ្យាល័យវិស្វកម្ម និងស្ថាបត្យកម្ម | វិស្វកម្មសំណង់ស៊ីវិល |
| | | វិស្វកម្មអគ្គិសនី និងអេឡិចត្រូនិច |
| | | វិស្វកម្មអេឡិចត្រូនិច និងទូរគមនាគមន៍ |
| | | ស្ថាបត្យកម្ម |

## ១៤. សាកលវិទ្យាល័យអន្តរជាតិ

### ➢ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យអន្តរជាតិ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងស្ថិតនៅ អគារលេខ៨៩-៩១-៩៣ និង៩៥ ផ្លូវលេខ១០១១-១៩៨៤ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ៨៨១ ៦២៣, ០១៧ ២២០ ០០៧
- ទូរសារលេខ៖ ០២៣ ៨៨១ ៦២៣

### ➢ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យអន្តរជាតិ មានមហាវិទ្យាល័យ ១០ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យវេជ្ជសាស្ត្រ និងរោគកុមារ | វេជ្ជសាស្ត្រទូទៅ |
| | | រោគកុមារ |
| ២ | មហាវិទ្យាល័យឱសថសាស្ត្រ | ឱសថសាស្ត្រ |
| ៣ | មហាវិទ្យាល័យទន្តវេទនសាស្ត្រ | ទន្តសាស្ត្រ |
| ៤ | មហាវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ | ស្ថាបត្យកម្ម |
| | | សំណង់ស៊ីវិល |
| | | ព័ត៌មានសំណង់ |
| | | អេឡិចត្រូនិច-ទូរគមនាគមន៍ |

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

| | | |
|---|---|---|
| | | វិស្វកម្មអេឡិចត្រូនិច និងអគ្គិសនី |
| | | គណិតវិទ្យាអនុវត្តន៍ |
| | | បច្ចេកវិទ្យាព័ត៌មាន |
| | | បច្ចេកវិទ្យាបរិស្ថាន |
| | | វិស្វកម្មបរិស្ថាន |
| | | ជីវគីមីសាស្ត្រ |
| | | មីក្រូជីវសាស្ត្រ |
| | | ជីវបច្ចេកវិទ្យា |
| | | ជីវវិទ្យា |
| | | គីមីចំណីអាហារ |
| | | សុរិយោដី |
| | | ព័ត៌មានវិទ្យា និងគ្រប់គ្រង |
| ៥ | មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម និងសារព័ត៌មាន | សង្គមវិទ្យា |
| | | វិទ្យាសាស្ត្រនយោបាយ |
| | | សារព័ត៌មាន |
| ៦ | មហាវិទ្យាល័យនីតិសាស្ត្រ | ច្បាប់សាធារណៈ |
| | | ច្បាប់ពាណិជ្ជកម្ម |
| | | ច្បាប់អន្តរជាតិ |
| ៧ | មហាវិទ្យាល័យ វិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ | ជលផល |
| | | ក្សេត្រសាស្ត្រ |
| | | បសុពេទ្យ |
| ៨ | មហាវិទ្យាល័យមនុស្សសាស្ត្រ និងភាសា | ភាសាអង់គ្លេស |
| | | ភាសាបារាំង |
| | | វិទ្យាសាស្ត្រអប់រំ |
| ៩ | មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងសេដ្ឋកិច្ច | ទីផ្សារ |
| | | គ្រប់គ្រង |
| | | គណនេយ្យ |
| | | គ្រប់គ្រង និងទេសចរណ៍ |
| | | សេដ្ឋកិច្ច |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| ១០ | មហាវិទ្យាល័យវិទ្យាសាស្ត្រថែទាំវេជ្ជសាស្ត្រ | គិលានុបដ្ឋាក |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | ឆ្មប |
| | | វិទ្យុសាស្ត្រ |
| | | មន្ទីរពិសោធន៍ |
| | | ព្យាបាលដោយចលនា |

## ១៥. សាកលវិទ្យាល័យឯកទេសនៃកម្ពុជា

### ❁ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យឯកទេសនៃកម្ពុជា** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងស្ថិតនៅអគារF ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ៣៥០ ៨២៨, ០១២ ៦៣៦ ២០៧
- E-mail : info@cus.edu.kh
- គេហទំព័រ៖ http://www.cus.edu.kh

### ❁ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យអន្តរជាតិ មានមហាវិទ្យាល័យ ០៥ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសា | ភូមិវិទ្យា |
| | | ប្រវត្តិវិទ្យា |
| | | អក្សរសាស្ត្រខ្មែរ |
| | | អក្សរសាស្ត្រអង់គ្លេស |
| ២ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | គណិតវិទ្យា |
| | | រូបវិទ្យា |
| | | គីមីវិទ្យា |
| | | ជីវវិទ្យា |
| | | វិទ្យាសាស្ត្រកុំព្យូទ័រ |
| ៣ | មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងសេដ្ឋកិច្ច | គ្រប់គ្រង |
| | | ម៉ាឃីតធីង (ទីផ្សារ) |
| | | គណនេយ្យ |
| | | គ្រប់គ្រងសណ្ឋាគារ-ទេសចរណ៍ |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| ៤ | មហាវិទ្យាល័យវិស្វកម្ម | វិស្វកម្មសំណង់ស៊ីវិល |
| ៥ | មហាវិទ្យាល័យ | នីតិឯកជន |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | វិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ | នីតិសាធារណៈ |

## ១៦. សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ

### ❁ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងស្ថិតនៅអគារលេខ៣៦ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ៩៨៦ ៩៣២, ០២៣ ៩៩៩ ៩០៨, ០១៦ ៩០១ ១២៣
- E-mail : info@ppiu.edu.kh
- គេហទំព័រ៖ http://www.ppiu.edu.kh

### ❁ មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ មានមហាវិទ្យាល័យ ០៤ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច | អភិវឌ្ឍសេដ្ឋកិច្ច |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| | | ច្បាប់ |
| | | រដ្ឋបាលសាធារណៈ |
| ២ | មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ និងទេសចរណ៍ | គ្រប់គ្រង |
| | | គណនេយ្យ |
| | | ទីផ្សារ |
| | | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ |
| ៣ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា | គណិតសាស្ត្រ |
| | | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា |
| | | វិទ្យាសាស្ត្រកុំព្យូទ័រ |
| ៤ | មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ | អក្សរសាស្ត្រអង់គ្លេសអប់រំ |
| | | ភាសាអង់គ្លេសពាណិជ្ជកម្ម |

## ១៧. សាកលវិទ្យាល័យអាយអាយស៊ីនៃកម្ពុជា

### ❁ អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យអាយអាយស៊ីនៃកម្ពុជា** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងស្ថិតនៅអគារលេខ៦៥០ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ខាងត្បូងវត្តចាក់អង្រែក្រោម ប្រហែល២០០ម៉ែត្រ។

facebook.com/moeyscambodia YouTube youtube.com/moeyscambodia moeys.gov.kh

– ទូរស័ព្ទលេខ៖ ០២៣ ៤២៥ ១៩៨, ០១១/០១៦/០៩២ ៣៩០ ៦២៦
– E-mail : infor@iic.edu.kh
– គេហទំព័រ៖ www.iic.edu.kh

❀ **មហាវិទ្យាល័យ និងមុខជំនាញ**

សាកលវិទ្យាល័យអាយអាយស៊ីនៃកម្ពុជា មានមហាវិទ្យាល័យ ០៥ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យពាណិជ្ជសាស្ត្រ | គ្រប់គ្រង |
| | | ទីផ្សារ |
| | | គណនេយ្យ |
| | | គ្រប់គ្រងអាជីវកម្មធុនតូច |
| | | គ្រប់គ្រងធនធានមនុស្ស |
| | | គ្រប់គ្រងសណ្ឋាគារ |
| | | គ្រប់គ្រងទេសចរណ៍ |
| | | គ្រប់គ្រងរដ្ឋបាល |
| | | គ្រប់គ្រងការលក់ |
| | | គ្រប់គ្រងភស្តុភា |
| | | គ្រប់គ្រងហានិភ័យ |
| | | ទំនាក់ទំនងឧស្សាហកម្ម |
| | | អាជីវកម្មអន្តរជាតិ |
| | | យុទ្ធសាស្ត្រលទ្ធកម្ម |
| ២ | មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច | សេដ្ឋកិច្ចវិទ្យា |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| | | ហិរញ្ញវត្ថុ និងអចលនទ្រព្យ |
| | | ហិរញ្ញវត្ថុ និងវិនិយោគ |
| | | ហិរញ្ញវត្ថុ និងធានារ៉ាប់រង |
| | | ហិរញ្ញវត្ថុ និងពន្ធដារ |
| | | ស្ថិតិ និងព្យាករណ៍អាជីវកម្ម |
| | | គ្រប់គ្រងមីក្រូហិរញ្ញវត្ថុ |
| ៣ | មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម | រដ្ឋបាលសាធារណៈ |
| | | វិទ្យាសាស្ត្រនយោបាយ |
| | | ច្បាប់ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | ប្រវត្តិសាស្ត្រសង្គមវិទ្យា |
| | | នរវិទ្យា |
| ៤ | មហាវិទ្យាល័យ<br>គណិតសាស្ត្រ និងវិទ្យាសាស្ត្រ | វិទ្យាសាស្ត្រកុំព្យូទ័រ |
| | | ព័ត៌មានវិទ្យា |
| | | វិស្វកម្មផ្នែកទន់ |
| | | គណិតវិទ្យា |
| | | វិទ្យាសាស្ត្របរិស្ថាន និង<br>វិទ្យាសាស្ត្រអនុវត្តន៍ |
| ៥ | មហាវិទ្យាល័យ<br>សិល្បៈ មនុស្សសាស្ត្រ និងភាសា | ការអប់រំភាសាអង់គ្លេស |
| | | អក្សរសាស្ត្រអង់គ្លេស |
| | | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម |
| | | ភាសាចិន |
| | | ភាសាជប៉ុន |
| | | ភាសាកូរ៉េ |

## ១៨. សាកលវិទ្យាល័យវេស្ទើន

### អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យវេស្ទើន** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងស្ថិតនៅអគារលេខ១៥ ផ្លូវលេខ៥២៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ៖ ០២៣ ៩៩៨ ២៣៣, ០១២ ២០០ ៩៨៨
- E-mail : info_kc@western.edu.kh
- គេហទំព័រ៖ www.western.edu.kh

### មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យវេស្ទើន មានមហាវិទ្យាល័យ ០៤ ដែលមានមុខជំនាញ៖

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យ<br>គ្រប់គ្រង និងសណ្ឋាគារ-ទេសចរណ៍ | គ្រប់គ្រងទីផ្សារ |
| | | គ្រប់គ្រង និងសហគ្រាស |
| | | គណនេយ្យ |
| | | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ |
| ២ | មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម | ធនាគារ និងហិរញ្ញវត្ថុ |
| | | អភិវឌ្ឍន៍សេដ្ឋកិច្ច |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | នីតិសាធារណៈ |
| | | នីតិឯកជន |
| ៣ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | វិទ្យាសាស្ត្រកុំព្យូទ័រ |
| | | អេឡិចត្រូនិច និងអគ្គិសនី |
| | | ទូរគមនាគមន៍ |
| ៤ | មហាវិទ្យាល័យ<br>សិល្បៈ មនុស្សសាស្ត្រ និងភាសា | អប់រំភាសាអង់គ្លេស |

## ១៩. សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច

*__អាសយដ្ឋានទំនាក់ទំនង__

- **សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅភូមិព្រែកព្រះស្តេច សង្កាត់ព្រែកព្រះស្តេច ក្រុងព្រែកព្រះស្តេច ខេត្តបាត់ដំបង ។
- ទូរស័ព្ទលេខ: ១៥៣ ៩៥២ ១៦០
- ទូរស័ព្ទលេខ: ១៥៣ ៩៥៣ ១៦០ P.O box ៣០៣

*__មហាវិទ្យាល័យ និងមុខជំនាញ__

សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ចមានមហាវិទ្យាល័យ ០៥ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យាល័យ<br>គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ | គណនេយ្យ និងហិរញ្ញវត្ថុ |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| | | គ្រប់គ្រងធនធានមនុស្ស |
| | | គ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ |
| | | គ្រប់គ្រងទីផ្សារ |
| | | គ្រប់គ្រងទេសចរណ៍ |
| ០២ | មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច | នីតិសាស្ត្រ |
| | | សេដ្ឋកិច្ច |
| ០៣ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកទេស | ព័ត៌មានវិទ្យា |
| ០៤ | មហាវិទ្យាល័យសិល្បៈមនុស្សសាស្ត្រ និងភាសាបរទេស | បង្រៀនភាសាអង់គ្លេស |
| | | ភាសាអង់គ្លេស |
| ០៥ | មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ | ក្សេត្រសាស្ត្រ |
| | | អភិវឌ្ឍន៍ជនបទ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ២០. សាកលវិទ្យាល័យចេនឡា

### *អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យចេនឡា** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅអាគារលេខ៤៣ ផ្លូវលេខ២៣១ សង្កាត់ផ្សារដើមគ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងលិចសណ្ឋាគាររ៉ូយ៉ាល់ប៉ាឡែស ខាងកើតមហោស្រពចេនឡា ផ្សារដើមគ) ។
- ទូរស័ព្ទលេខ: ០២៣ ៨៨៣ ២៦៩/ ០១២ ៥៣៥ ០៨០
- អ៊ីម៉ែល: Khandysin@yahoo.com

### *មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យចេនឡា មានមហាវិទ្យាល័យ ០៥ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រនិង ភាសា | អក្សរសាស្ត្រខ្មែរ |
| | | ប្រវត្តិវិទ្យា |
| | | អក្សរសាស្ត្រអង់គ្លេស |
| ០២ | មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម | គ្រប់គ្រង |
| | | ពាណិកម្ម |
| | | សេដ្ឋកិច្ច |
| | | ទីផ្សារ |
| | | ធនាគារ-ហិរញ្ញវត្ថុ |
| | | គណនេយ្យ |
| | | នីតិសាធារណៈ |
| | | នីតិឯកជន |
| ០៣ | មហាវិទ្យាល័យ គណិតសាស្ត្រ និងវិទ្យាសាស្ត្រកុំព្យូទ័រ | គណិតវិទ្យា |
| | | គីមីវិទ្យា |
| | | ជីវវិទ្យា |
| | | រូបវិទ្យា |
| | | វិទ្យាសាស្ត្រកុំព្យូទ័រ |
| ០៤ | មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម | វិទ្យាសាស្ត្រអប់រំ |
| ០៥ | មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម | គិលានុបដ្ឋាក |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ២១. សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ

### *អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅទល់មុខវិទ្យាល័យអង្គរ ក្រុងសៀមរាប ខេត្តសៀមរាប ។
- ទូរស័ព្ទលេខ: ០៦៣ ៩៦៣ ៨៥៣ / ០១២ ៩២៨ ៨៨៩ / ០១២ ៨៨៦ ៦៧៦
- អ៊ីម៉ែល: info@usea.edu.kh
- គេហទំព័រ: www.usea.edu.kh

### *មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ មានមហាវិទ្យាល័យ០៥ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យាល័យ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ | គ្រប់គ្រង |
| | | ទីផ្សារ |
| | | សេដ្ឋកិច្ច |
| | | គណនេយ្យ |
| | | គ្រប់គ្រងទេសចរណ៍ |
| | | គ្រប់គ្រងបដិសណ្ឋារកិច្ច |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| | | ពាណិជ្ជកម្មអន្តរជាតិ |
| ០២ | មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្រ្ត និងភាសា | ការអប់រំភាសាអង់គ្លេស |
| | | អក្សរសាស្រ្តខ្មែរ |
| | | ទស្សនវិទ្យា |
| | | ប្រវត្តិវិទ្យា |
| ០៣ | មហាវិទ្យាល័យ វិទ្យាសាស្រ្តសង្គម និងបច្ចេកវិទ្យា | ព័ត៌មានវិទ្យា |
| | | គណិតវិទ្យា |
| | | វិស្វកម្មសំណង់ស៊ីវិល |
| | | ស្ថាបត្យកម្ម |
| ០៤ | មហាវិទ្យាល័យ វិទ្យាសាស្រ្តសង្គម និងនីតិសាស្រ្ត | នីតិឯកជន |
| | | ទំនាក់ទំនងអន្តរជាតិ និងការទូត |
| | | នីតិសាធារណៈ |
| | | នីតិអន្តរជាតិ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | វិទ្យាសាស្ត្រនយោបាយ |
| | | រដ្ឋបាលសាធារណៈ |
| ០៥ | មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ | សេដ្ឋកិច្ចកសិកម្ម |
| | | កសិពាណិជ្ជកម្ម |
| | | ទីផ្សារ-កសិកម្ម |
| | | គ្រប់គ្រងកសិដ្ឋាន-ពាណិជ្ជកម្ម |
| | | អភិវឌ្ឍជនបទ |
| | | អភិវឌ្ឍសង្គម-ជនបទ |

## ២២. សាកលវិទ្យាល័យអាស៊ីអឺរ៉ុប

*អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យអាស៊ីអឺរ៉ុប** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន មានទីតាំងនៅអាគារលេខ ៨៣២ABCD មហាវិថីកម្ពុជាក្រោម សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ: ០២៣ ៩៩៨ ១២៤/ ០១២ ៤៨១ ៧៣៨
- ទូរសារលេខ: ០២៣ ៩៩៨ ១២៤
- អ៊ីម៉ែល: info@aeu.edu.kh
- គេហទំព័រ: www.aeu.edu.kh

*មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យអាស៊ីអឺរ៉ុបមានមហាវិទ្យាល័យ ០៣ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យាល័យ មនុស្សសាស្ត្រ និងភាសាបរទេស | ភាសាអង់គ្លេស |
| ០២ | មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាន | វិទ្យាសាស្ត្រកុំព្យូទ័រ |
| ០៣ | មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ | ទីផ្សារ |
| | | គ្រប់គ្រង |
| | | គណនេយ្យ |
| | | ធនាគារ និងហិរញ្ញវត្ថុ |
| | | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| ០៤ | មហាវិទ្យាល័យ<br>នីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ | នីតិសាស្ត្រ |
| | | រដ្ឋបាលសាធារណៈ |
| | | ទំនាក់ទំនងអន្តរជាតិ |
| | | វិទ្យាសាស្ត្រនយោបាយ |

## ២៣. សាកលវិទ្យាល័យអង្គរ

*អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យអង្គរ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ។
- ទូរស័ព្ទលេខ: ០៦៣ ៩៦៩ ៥០៧ / ០៩២ ២៥៦ ០៨៦
- អ៊ីម៉ែល: info@angkor.edu.kh
- គេហទំព័រ: www.angkor.edu.kh

*មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យអង្គរ មានមហាវិទ្យាល័យ ០៦ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យាល័យ ពាណិជ្ជកម្ម និងទេសចរណ៍ | គណនេយ្យ |
| | | ធនាគារ និងហិរញ្ញវត្ថុ |
| | | ទីផ្សារ |
| | | កុំព្យូទ័រពាណិជ្ជកម្ម |
| | | គ្រប់គ្រងពាណិជ្ជកម្ម |
| | | គ្រប់គ្រងធនធានមនុស្ស |
| | | គ្រប់គ្រងប្រព័ន្ធព័ត៌មាន |
| | | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ |
| ០២ | មហាវិទ្យាល័យ<br>មនុស្សសាស្ត្រ និងភាសាបរទេស | ភាសាអង់គ្លេស |
| | | ភាសាកូរ៉េ |
| ០៣ | មហាវិទ្យាល័យ<br>វិទ្យាសាស្ត្រសង្គម និងបច្ចេកវិទ្យា | ព័ត៌មានវិទ្យា |
| | | វិទ្យាសាស្ត្រកុំព្យូទ័រ |
| ០៤ | មហាវិទ្យាល័យ សង្គមសាស្ត្រ និងនីតិសាស្ត្រ | នីតិឯកជន |
| | | ទំនាក់ទំនងអន្តរជាតិ |
| | | នីតិសាធារណៈ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | វិទ្យាសាស្ត្រនយោបាយ |
| | | សេដ្ឋកិច្ច |
| ០៥ | មហាវិទ្យាល័យកសិកម្ម | ក្សេត្រសាស្ត្រ |
| | | អភិវឌ្ឍជនបទ |
| ០៦ | មហាវិទ្យាល័យសុខភាពសាធារណៈ | ផ្នែកវេជ្ជបណ្ឌិតទូទៅ |
| | | ផ្នែកគិលានុបដ្ឋាក-ឆ្មប |
| | | ផ្នែកគិលានុបដ្ឋាក |
| | | កម្រិតទន្តបណ្ឌិតទូទៅ |
| | | ផ្នែកឱសថ |
| | | ផ្នែកព្យាបាលដោយចលនា |
| | | ផ្នែកបច្ចេកទេសវិទ្យាសាស្ត្រ |
| | | ផ្នែកបច្ចេកទេស មន្ទីរពិសោធន៍ |

## ៦៤. សាកលវិទ្យាល័យបញ្ញាជាតិ

**អាសយដ្ឋានទំនាក់ទំនង:**

- **សាកលវិទ្យាល័យបញ្ញាជាតិ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅអាគារលេខ២០-២៤-១៣ ផ្លូវលេខ២១០ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ: ០២៣ ៨៨១ ៥៦៣ / ០៩២ ៧៧៧ ៧០៨ / ០៩៧ ៧៨៨ ៨៩០៨
- អ៊ីម៉ែល: info@pcur.edu.kh
- គេហទំព័រ: www.aeu.edu.kh

**មហាវិទ្យាល័យ និងមុខជំនាញ**

សាកលវិទ្យាល័យបញ្ញាជាតិ មានមហាវិទ្យាល័យ០៥ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រនិង ភាសា | អក្សរសាស្ត្រខ្មែរ |
| | | ទស្សនវិជ្ជា |
| | | ការអប់រំភាសាអង់គ្លេស |
| | | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម |
| ០២ | មហាវិទ្យាល័យគណិតវិទ្យា និងវិទ្យាសាស្ត្រ | គណិតវិទ្យា |
| | | រូបវិទ្យា |
| | | ជីវវិទ្យា |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | សំណេរកម្មវិធីកុំព្យូទ័រ |
| | | បណ្តាញកម្មវិធីកុំព្យូទ័រ |
| ០៣ | មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម | ភូមិវិទ្យា |
| | | វិទ្យាសាស្ត្រនយោបាយ |
| | | ច្បាប់ឯកជន |
| | | ច្បាប់អន្តរជាតិ |
| | | ច្បាប់សាធារណៈ |
| | | រដ្ឋបាលសាធារណៈ |
| ០៤ | មហាវិទ្យាល័យ ធុរកិច្ច និងសេដ្ឋកិច្ច | វិទ្យាសាស្ត្រអប់រំ |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| | | សេដ្ឋកិច្ចអភិវឌ្ឍន៍ |
| | | គណនេយ្យ |
| | | ទីផ្សារ |
| | | គ្រប់គ្រង |
| | | ទេសចរណ៍ |
| | | រដ្ឋបាលធុរអន្តរជាតិ |
| | | គ្រប់គ្រងសណ្ឋាគារ |
| ០៥ | មហាវិទ្យាល័យអប់រំ | វិទ្យាសាស្ត្រអប់រំ |
| | | គីមីវិទ្យា |
| | | ប្រវត្តិវិទ្យា |

## ១៥. សាកលវិទ្យាល័យខ្មែរបច្ចេកទេស និងគ្រប់គ្រង

### ‘អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យខ្មែរបច្ចេកទេស និងគ្រប់គ្រង** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅផ្លូវបូរីកម្មករ ក្រុមទី៨ ភូមិ៣ សង្កាត់លេខ៣ ខេត្តព្រះសីហនុ ។
- ទូរស័ព្ទលេខ: ០៣៤ ៩៣៣ ៧១៨ / ០១៦ ៨០៤ ៥៩៥ /០១៥ ៥៥៥៦៥០ / ០១៦ ៨៩១ ៩១៤
- អ៊ីម៉ែល: infor@kutmr.shv.kh
- គេហទំព័រ: www.kutmr.shv.kh

### ‘មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យខ្មែរបច្ចេកវិទ្យានិងគ្រប់គ្រង មានមហាវិទ្យាល័យ ០៥ មានមុខជំនាញ:

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យាល័យ នីតិសាស្ត្រនិង វិទ្យាសាស្ត្រសង្គម | នីតិសាធារណៈ |
| | | សង្គមវិជ្ជា |
| | | វិទ្យាសាស្ត្រនយោបាយ |
| | | ការសិក្សាអំពីការអភិវឌ្ឍ |
| | | ប្រវត្តិវិទ្យា |
| | | ទំនាក់ទំនងអន្តរជាតិ |
| | | រដ្ឋបាលសាធារណៈ |
| | | ចិត្តវិទ្យា |
| | | នរវិទ្យា |
| | | នីតិឯកជន |
| ០២ | មហាវិទ្យាល័យ គ្រប់គ្រងពាណិកម្ម និងទេសចរណ៍ | គណនេយ្យ |
| | | ការទិញលក់ផ្ទះ និងដី |
| | | ពាណិជ្ជកម្មអន្តរជាតិ |
| | | គ្រប់គ្រង និងបដិសណ្ឋារកិច្ច |
| | | កសិពាណិកម្ម |
| | | គ្រប់គ្រងឧស្សាហកម្ម |
| | | គ្រប់គ្រងទេសចរណ៍ |
| | | គ្រប់គ្រងធនធានមនុស្ស |
| | | កុំព្យូទ័រពាណិជ្ជកម្ម |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| | | គ្រប់គ្រងអាជីវកម្ម |
| | | សេដ្ឋកិច្ចពាណិជ្ជកម្ម |
| | | ទីផ្សារ |
| | | គ្រប់គ្រងទូទៅ |
| | | ការធានារ៉ាប់រង |
| | | សេដ្ឋកិច្ច |
| ០៣ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកទេស | ព័ត៌មានវិទ្យា |
| | | វិទ្យាសាស្ត្រទូរគមនាគមន៍ |
| | | កុំព្យូទ័រអនុវត្តន៍ |
| | | វិទ្យាសាស្ត្រកុំព្យូទ័រ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | ស្ថិតិអនុវត្ត |
| | | គណិតសាស្ត្រ |
| ០៤ | មហាវិទ្យាល័យ ធុរកិច្ច និងសេដ្ឋកិច្ច | ភាសាអង់គ្លេសសម្រាប់អាជីវកម្ម |
| | | ភាសាអង់គ្លេសសម្រាប់ការគ្រប់គ្រងទេសចរណ៍ និង បដិសណ្ឋារកិច្ច |
| | | អក្សរសាស្ត្រអង់គ្លេស |
| | | រដ្ឋបាលអប់រំ |
| | | ការអប់រំ |
| ០៥ | មហាវិទ្យាល័យ វិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ | កសិកម្ម និងអភិវឌ្ឍន៍ជនបទ |
| | | បសុព្យាបាល |
| | | ក្សេត្រសាស្ត្រ |
| | | រុក្ខសាស្ត្រ |

## ១៦. សាកលវិទ្យាល័យកម្ពុជា

### អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យកម្ពុជា** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅផ្ទះលេខ ១៩៣-១៩៥ មហាវិថី ព្រះនរោត្តមសង្កាត់បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ: ០២៣ ៩៩៣ ២៧៤ /០២៣ ៩៩៣ ២៧៥ / ០២៣៩៩៣ ២៧៦
- ទូរសារលេខ: ០២៣ ៩៩៣២៨៤
- អ៊ីម៉ែល: info@uc.edu.kh
- គេហទំព័រ: www.uc.edu.kh

### មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យកម្ពុជាមានមហាវិទ្យាល័យ ០៦ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យាល័យ សិល្បៈ និងវិទ្យាសាស្ត្រ | ភាសាអង់គ្លេស |
| ០២ | មហាវិទ្យាល័យច្បាប់ | ច្បាប់ |
| ០៣ | មហាវិទ្យាល័យអប់រំ | អប់រំ |
| ០៤ | មហាវិទ្យាល័យគ្រប់គ្រង | សេដ្ឋកិច្ច |
| | | គណនេយ្យ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | ធនាគារ និងហិរញ្ញវត្ថុ |
| | | គ្រប់គ្រងបដិសណ្ឋារកិច្ច និងទេសចរណ៍ |
| ០៥ | មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម | សិក្សាពីការអភិវឌ្ឍន៍ |
| | | រដ្ឋបាលសាធារណៈ |
| | | ទំនាក់ទំនងអន្តរជាតិ |
| | | វិទ្យាសាស្ត្រនយោបាយ |
| ០៦ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកទេស | ព័ត៌មានវិទ្យា |
| | | វិទ្យាសាស្ត្រកុំព្យូទ័រ |

## ២៧. សាកលវិទ្យាល័យឡាយហ្វ

### *អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យឡាយហ្វ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅផ្លូវសាតេ ក្រុមទី១១ មណ្ឌល ០៣ សង្កាត់០២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។
- ទូរស័ព្ទលេខ: ០៣៤ ៩៣៤ ៩៩៨/ ០១៦ ៩១១ ៩២៣
- អ៊ីម៉ែល: admin@lifieun.edu.kh
- គេហទំព័រ: www.lifeun.edu.kh

### *មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យឡាយហ្វ មានមហាវិទ្យាល័យ ០៦ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស | អក្សរសាស្ត្រភាសាអង់គ្លេស |
| | | សាសនាវិទ្យា |
| | | អក្សរសាស្ត្រកូរ៉េ |
| ០២ | មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងវិស្វកម្ម | វិទ្យាសាស្ត្រកុំព្យូទ័រ |
| | | គណិតវិទ្យា |
| | | សំណង់ស៊ីវិល |
| ០៣ | មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម | ចិត្តវិទ្យា |
| | | នីតិសាស្ត្រ |
| | | សេដ្ឋកិច្ច |
| ០៤ | មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម | គ្រប់គ្រង |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | ទីផ្សារ |
| | | គណនេយ្យ |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| ០៥ | មហាវិទ្យាល័យ គិលានុបដ្ឋាក និងឆ្មប | គិលានុបដ្ឋាក |
| | | ឆ្មប |
| ០៦ | មហាវិទ្យាល័យស្ថាបត្យកម្ម និងនគររូបនីយកម្ម | ស្ថាបត្យកម្ម |
| | | រចនាខាងក្នុង |
| | | ស្ថាបត្យកម្មសួនឧទ្យាន |

## ២៨. សាកលវិទ្យាល័យធនធានមនុស្ស

*អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យធនធានមនុស្ស** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅ អាគារ លេខ២ ផ្លូវលេខ១៦៣ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ: ០២៣ ៩៨៧ ៨២៦/ ០២៣ ៩៩៩ ៩៣៩
- ទូរសារលេខ: ០២៣ ៩៨៧ ៨២៦
- អ៊ីម៉ែល: info@hru.edu.kh
- គេហទំព័រ: www.hru.edu.kh

*មហាវិទ្យាល័យ និងមុខជំនាញ

សាកលវិទ្យាល័យធនធានមានមហាវិទ្យាល័យ០៥ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | មុខជំនាញ |
|---|---|---|
| ០១ | មហាវិទ្យល័យ សិល្បៈ មនុស្សសាស្រ្ត និង ភាសា | ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង |
| | | ភាសាអង់គ្លេសសម្រាប់បង្រៀន |
| ០២ | មហាវិទ្យល័យ នីតិសាស្រ្ត និងវិទ្យាសាស្រ្ត នយោបាយ | នីតិសាធារណៈ |
| | | នីតិឯកជន |
| ០៣ | មហាវិទ្យាល័យវិទ្យាសាស្រ្តសង្គម និងសេដ្ឋកិច្ច | ធានាគារ |
| | | សេដ្ឋកិច្ច |
| ០៤ | មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និង ទេសចរណ៍ | គណនេយ្យ |
| | | គ្រប់គ្រង |
| | | ទីផ្សារ |
| | | ទេសចរណ៍ |
| ០៥ | | វិទ្យាសាស្រ្តកុំព្យូទ័រ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | មហាវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ | ព័ត៌មានវិទ្យា |

## ២៩. សាកលវិទ្យាល័យពុទ្ធិសាស្ត្រ

*អាសយដ្ឋានទំនាក់ទំនង

- **សាកលវិទ្យាល័យពុទ្ធិសាស្ត្រ** ជាគ្រឹះឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅអគារលេខ ៥៥ ផ្លូវលេខ១៨០ និង ១៨៤ (វិថីកែវជា) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ: ០២៣ ២២១ ៦២៤
- ទូរសារលេខ: ០២៣ ២២០ ៤៧៦
- អ៊ីម៉ែល: info@puhisastra.edu.kh
- គេហទំព័រ: www.putisastra.edu.kh

*មហាវិទ្យាល័យ និងមុខជំនាញ

មហាវិទ្យាល័យពុទ្ធិសាស្ត្រ មានមហាវិទ្យាល័យ ០៥ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | បណ្តាញកុំព្យូទ័រ |
| | | គ្រប់គ្រងទិន្នន័យកុំព្យូទ័រ |
| | | សរសេរកម្មវិធី |
| ២ | មហាវិទ្យាល័យសេដ្ឋកិច្ច និងធុរកិច្ច | គណនេយ្យ |
| | | សេដ្ឋកិច្ច |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| | | គ្រប់គ្រង |
| | | ទីផ្សារ |
| ៣ | មហាវិទ្យាល័យអភិវឌ្ឍន៍ជនបទ និងកសិកម្ម | ក្សេត្រសាស្ត្រ |
| | | វិទ្យាសាស្ត្រសត្វ |
| ៤ | មហាវិទ្យាល័យសិល្បៈភាសា | បង្រៀនភាសាអង់គ្លេស |
| | | បកប្រែភាសាអង់គ្លេស |
| ៥ | មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ | នីតិសាស្ត្រ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ៣០. វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ច:

*អាសយដ្ឋានទំនាក់ទំនង

- **វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ច:** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅអគារលេខ ៤៧Eo ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ! ខណ្ឌចំការមន រាជធានីភ្នំពេញ ខាងលិចផ្សារអូរឡាំពិក ឃៀងខាងកើតវិទ្យាល័យទួលស្វាយព្រៃ។
- ទូរស័ព្ទលេខ:០២៣ ៦៩០ ០៧៦៧ ០២៣ ៦៩២ ១៩១២
- អ៊ីម៉ែល: sadi@sadi.edu.kh
- គេហទំព័រ: wwwsadi.edu.kh

*មហាវិទ្យាល័យ និងមុខជំនាញ

វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ច: មានមហាវិទ្យាល័យ ០៣ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យព័ត៌មានវិទ្យា | គ្រប់គ្រងទិន្នន័យ |
| | | វិស្វកម្មកម្មវិធីកុំព្យូទ័រ |
| | | គ្រប់គ្រងបណ្ដាញកុំព្យូទ័រ |
| ២ | មហាវិទ្យាល័យពាណិជ្ជកម្ម | គ្រប់គ្រងអាជីកម្ម |
| | | គ្រប់គ្រងទីផ្សារ |
| | | គ្រប់គ្រងគណនេយ្យ |
| ៣ | មហាវិទ្យាល័យភាសាបរទេស | ភាសាអង់គ្លេសផ្នែកអប់រំ |

## ៣១. វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ

*អាសយដ្ឋានទំនាក់ទំនង

- **វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅអគារលេខ ៣៥១ មហាវិថីហ្សាដឺហ្គោលសង្កាត់អូរឬស្សី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ (ជិតរង្វង់មូលនាងគង្ហីងអូរឬស្សី)។
- ទូរស័ព្ទលេខ: ០២៣ ៩៩០ ០៨៩ ០១៧ ៧៩៩ ៩៨១
- អ៊ីម៉ែល: info@ibei.edu.kh
- គេហទំព័រ: www.ibe.edu.kh

*មហាវិទ្យាល័យ និងមុខជំនាញ

វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ មានមហាវិទ្យាល័យ ០២ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| ១ | មហាវិទ្យាល័យពាណិជ្ជសាស្ត្រ បណ្ដុះបណ្ដាលជំនាញ | គ្រប់គ្រង |
| | | ទីផ្សារ |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| | | គណនេយ្យ និងហិរញ្ញវត្ថុ |
| | | សណ្ឋាគារ និងទេសចរណ៍ |
| ២ | មហាវិទ្យាល័យភាសាបរទេស បណ្ដុះបណ្ដាលជំនាញ | អក្សរសាស្ត្រ |

## ៣២. វិទ្យាស្ថានក្រុងអង្គរ

***អាសយដ្ឋានទំនាក់ទំនង**

- **វិទ្យាស្ថានក្រុងអង្គរ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន មានទីតាំងនៅភូមិលេខ៥ សង្កាត់កំពង់លាវ ក្រុងកំពង់លាវ ខេត្តព្រៃវែង។
- ទូរស័ព្ទលេខ: ០១១ ២៦៣ ៣២៦ / ០១២ ៩៦៣ ៧០០
- អ៊ីម៉ែល: aci pv@yahoo.com
- គេហទំព័រ: www. pv@yahoo.com

***មហាវិទ្យាល័យ និងមុខជំនាញ:**

វិទ្យាស្ថានក្រុងអង្គរមានមហាវិទ្យាល័យ ០២ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម | គណនេយ្យ |
| | | ទីផ្សារ |
| | | ធនធានមនុស្ស |
| ២ | មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ | គណិតវិទ្យា |
| | | រូបវិទ្យា |
| | | អក្សរសាស្ត្រខ្មែរ |
| | | អក្សរសាស្ត្រអង់គ្លេស |

## ៣៣. វិទ្យាស្ថានខេមអេដ

***អាសយដ្ឋានទំនាក់ទំនង**

- **វិទ្យាស្ថានខេមអេដ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជនដែលមានទីតាំងនៅអគារលេខ ៦៤ ផ្លូវលេខ១០៨ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ: ០២៣ ៩៨៦ ៥២២
- អ៊ីម៉ែល: reception@cam-ed.com
- គេហទំព័រ: www.cam-ed.com

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

***ដេប៉ាតឺម៉ង់ និងមុខជំនាញ:**

វិទ្យាស្ថានខេមអេដ ដេប៉ាតឺម៉ង់ ០៣ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | ដេប៉ាតឺម៉ង់គ្រប់គ្រង | គ្រប់គ្រង |
| ២ | ដេប៉ាតឺម៉ង់គណនេយ្យ | គណនេយ្យ |
| ៣ | ដេប៉ាតឺម៉ង់ហិរញ្ញវត្ថុ | ហិរញ្ញវត្ថុ |

## ៣៤. វិទ្យាស្ថានសន្តប៉ូល

***អាសយដ្ឋានទំនាក់ទំនង**

- **វិទ្យាស្ថានសន្តប៉ូល** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅភូមិអង្គរគគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ (ខាងជើងផ្សារអង្គតាសោម)។
- ទូរស័ព្ទលេខ: ០២៣ ៦៣៩០ ០០៣
- អ៊ីម៉ែល: info@saintpaulinstitute.org

***មហាវិទ្យាល័យ និងមុខជំនាញ**

វិទ្យាស្ថានសន្តប៉ូល មានមហាវិទ្យាល័យ ០៤ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា | ទូរគមនាគមន៍ និង បណ្តាញ |
| | | វិស្វកម្មផ្នែកទន់ |
| ២ | ដេប៉ាតឺម៉ង់អក្សរសាស្រ្តអង់គ្លេស | ភាសាអង់គ្លេសសម្រាប់ការបង្រៀន |
| | | ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង |
| ៣ | ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍ | គ្រប់គ្រងទេសចរណ៍ |
| ៤ | ដេប៉ាតឺម៉ង់កេ្សត្រសាស្រ្ត | កេ្សត្រសាស្រ្ត |

## ៣៥. វិទ្យាស្ថានប្រាយហ្វូប

***អាសយដ្ឋានទំនាក់ទំនង**

- **វិទ្យាស្ថានប្រាយហ្វូប** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅភូមិធម្មយុត្តិ សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង។
- ទូរស័ព្ទលេខ: ០១២ ៥៧១ ៣៦២
- អ៊ីម៉ែល: seng.sintha@gmail.com

***មហាវិទ្យាល័យ និងមុខជំនាញ**

វិទ្យាស្ថានប្រាយហ្វូប មានមហាវិទ្យាល័យ ០៣ ដែលមានមុខជំនាញ:

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យ<br>វិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ | អភិវឌ្ឍន៍ជនបទ |
| | | ក្សេត្រសាស្ត្រ |
| ២ | មហាវិទ្យាល័យ<br>គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ | គ្រប់គ្រងទូទៅ |
| | | គណនេយ្យ |
| | | ធនាគារ រូបិយវត្ថុ |
| | | វិទ្យាសាស្ត្រសេដ្ឋកិច្ច |
| | | គ្រប់គ្រងរដ្ឋបាលសាធារណៈ |
| ៣ | មហាវិទ្យាល័យ<br>វិទ្យាសាស្ត្រអប់រំ និងភាសាបរទេស | គ្រប់គ្រងអប់រំ |
| | | ភាសាអង់គ្លេស |
| | | អប់រំអក្សរសាស្ត្រខ្មែរ |
| | | អប់រំគណិតវិទ្យា |

## ១៦. វិទ្យាស្ថានអប់រំកម្ពុជា

### អាសយដ្ឋានទំនាក់ទំនង:

- **វិទ្យាស្ថានអប់រំកម្ពុជា** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅផ្ទះលេខ៥ ផ្លូវលេខ២០០ សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- ទូរស័ព្ទលេខ: ០២៣ ៦៣៦ ៨៥២៩
- អ៊ីម៉ែល: tepvantha.rac@gmail.com

### មហាវិទ្យាល័យ និងមុខជំនាញ

វិទ្យាស្ថានអប់រំ មានមហាវិទ្យាល័យ ០២ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យភាសា | ភាសាអង់គ្លេស |
| ២ | មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម | ទីផ្សារ |
| | | ទេសចរណ៍ |
| | | គណនេយ្យ |
| | | គ្រប់គ្រង |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ៣៧. វិទ្យាស្ថានបូលីណូ

### *អាសយដ្ឋានទំនាក់ទំនង

- **វិទ្យាស្ថានបូលីណូ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅភូមិថ្មរូង ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។
- ទូរស័ព្ទលេខ: ០២៣ ៨៨ ១៦ ២៣ / ០១៧ ២២ ០០០៧
- ទូរសារលេខ: ០២៣ ៨៨ ១៦ ២៣

### *មហាវិទ្យាល័យ និងមុខជំនាញ

វិទ្យាស្ថានបូលីណូ មានមហាវិទ្យាល័យ ១០ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យវេជ្ជសាស្ត្រ និងរោគកុមារ | វេជ្ជសាស្ត្រទូទៅ |
| | | រោគកុមារ |
| ២ | មហាវិទ្យាល័យឱសថសាស្ត្រ | ឱសថសាស្ត្រ |
| ៣ | មហាវិទ្យាល័យទន្តសាស្ត្រ | ទន្តសាស្ត្រ |
| ៤ | មហាវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ | ស្ថាបត្យកម្ម |
| | | សំណង់ស៊ីវិល |
| | | ព័ត៌មានសំណង់ |
| | | អេឡិចត្រូនិច-ទូរគមនាគមន៍ |
| | | វិស្វកម្មអេឡិចត្រូនិច និងអគ្គិសនី |
| | | គណិតវិទ្យាអនុវត្តន៍ |
| | | បច្ចេកវិទ្យាព័ត៌មាន |
| | | បច្ចេកវិទ្យាបរិស្ថាន |
| | | វិស្វកម្មបរិស្ថាន |
| | | ជីវគីមីសាស្ត្រ |
| | | មីក្រូជីវសាស្ត្រ |
| | | ជីវបច្ចេកវិទ្យា |
| | | ជីវវិទ្យា |
| | | គីមីចំណីអាហារ |
| | | សុរិយោដី |
| | | ព័ត៌មានវិទ្យា និងគ្រប់គ្រង |
| ៥ | មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និង សារព័ត៌មាន | សង្គមវិទ្យា |
| | | វិទ្យាសាស្ត្រនយោបាយ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

| | | |
|---|---|---|
| | | សារព័ត៌មាន |
| ៦ | មហាវិទ្យាល័យនីតិសាស្ត្រ | ច្បាប់សាធារណៈ |
| | | ច្បាប់ពាណិជ្ជកម្ម |
| | | ច្បាប់អន្តរជាតិ |
| ៧ | មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ | ជលផល |
| | | ក្សេត្រសាស្ត្រ |
| | | បសុពេទ្យ |
| ៨ | ហាវិទ្យាល័យមនុសាស្ត្រ និងភាសា | ភាសាអង់គ្លេស |
| | | ភាសាបារាំង |
| | | វិទ្យាសាស្ត្រអប់រំ |
| ៩ | មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងសេដ្ឋកិច្ច | ទីផ្សារ |
| | | គ្រប់គ្រង |
| | | គណនេយ្យ |
| | | គ្រប់គ្រង និងទេសចរណ៍ |
| | | សេដ្ឋកិច្ច |
| | | ហិរញ្ញវត្ថុ និងធនាគារ |
| ១០ | មហាវិទ្យាល័យវិទ្យាសាស្ត្រថៃទាំវេជ្ជសាស្ត្រ | គិលាននុបដ្ឋាក |
| | | ឆ្មប |
| | | វិទ្យុសាស្ត្រ |
| | | មន្ទីរពិសោធន៍ |
| | | ព្យាបាលដោយចលនា |

## ១៨. វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍

### អាសយដ្ឋានទំនាក់ទំនង

- **វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិសាត់។
- ទូរស័ព្ទលេខៈ ០៥២ ៩៥១ ៥១៩
- អ៊ីម៉ែលៈ mensethy@camintel.com
- គេហទំព័រៈ www.imd.edu.kh

### មហាវិទ្យាល័យ និងមុខជំនាញ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានមហាវិទ្យាល័យ ០៤ ដែលមានមុខជំនាញ:

| ល.រ | មហាវិទ្យាល័យ | ជំនាញ |
|---|---|---|
| ១ | មហាវិទ្យាល័យគ្រប់គ្រង | គ្រប់គ្រងទូទៅ |
| | | គណនេយ្យ និងហិរញ្ញវត្ថុ |
| ២ | មហាវិទ្យាល័យភាសាបរទេស | អប់រំភាសាអង់គ្លេស |
| ៣ | មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន | វិទ្យាសាស្រ្តកុំព្យូទ័រ |
| ៤ | មហាវិទ្យាល័យនីតិសាស្រ្ត និងសេដ្ឋកិច្ច | ហិរញ្ញវត្ថុ និងធនាគារ |

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ខ. ព័ត៌មានស្តីពីវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស

ក្រសួងអប់រំ យុវជន និងកីឡា មានគោលនយោបាយបង្កើតវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស យ៉ាងហោចណាស់ ០១ក្នុង ០១ខេត្ត និងនៅតាមតំបន់សេដ្ឋកិច្ចពិសេស។ គិតត្រឹមឆ្នាំ ២០១៦ មានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសចំនួន ០៧ ដែលក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតឡើងដើម្បីផ្តល់ឱកាស និងជម្រើសដល់សិស្សានុសិស្សក្នុងការសិក្សា។ វិទ្យាល័យទាំងនេះ ផ្តល់សេវាផ្នែកអប់រំចំណេះទូទៅ និងផ្នែកអប់រំបច្ចេកទេស។ សិស្សដែលបញ្ចប់ការសិក្សាផ្នែកអប់រំ បច្ចេកទេសនឹងទទួលបានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត៣ ដែលសមមូលនឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ខាងក្រោមនេះ ជាបញ្ជីឈ្មោះវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស៖

១. វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសអនុវត្តកំពង់ឈើទាល ស្ថិតនៅភូមិសំបូរ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។
២. វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនរ៉ូតា ស្ថិតនៅ ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
៣. វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី ស្ថិតនៅភូមិសាលាលេខប្រាំ សង្កាត់អូឬស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
៤. វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសឯកជន សន្តប្រ៊ូង់ស្វ័រ ស្ថិតនៅភូមិចំការទៀង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ
៥. វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសហ៊ុន សែន ជម្ពូវ័ន រាជធានីភ្នំពេញ
៦. វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសពួក ស្ថិតនៅក្នុងស្រុកពួក ខេត្តសៀមរាប
៧. វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសបាវិត ស្ថិតនៅក្នុងក្រុងបាវិត ខេត្តស្វាយរៀង។











facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## គ. ព័ត៌មានទាក់ទងនឹងការសិក្សាតាមមុខជំនាញនៅឧត្តមសិក្សា

### ១-ជំនាញគណិតវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : គណិតវិទ្យា និងរូបវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល៤ ឆ្នាំ ស្មើនឹង ១៤០ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :
  - មូលដ្ឋានគ្រឹះនៃគណិតវិទ្យា
  - យល់ដឹងពីគណិតវិទ្យាអនុវត្តន៍ (ស្ថិតិ តូប៉ូឡូជី...)
  - យល់ដឹងពីការវិភាគចំនួនកុំផ្លិច និងចេះភាសាអង់គ្លេស ។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ**:
  - សាស្ត្រាចារ្យគណិតវិទ្យា នៅតាមគ្រឹះស្ថានសិក្សា
  - តាមបណ្តាក្រសួង ក្រុមហ៊ុន ធនាគារ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ។

### ២-ជំនាញរូបវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : រូបវិទ្យា និង គណិតវិទ្យា
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល៤ឆ្នាំ ស្មើនឹង ១៥៣ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :
  - មូលដ្ឋានគ្រឹះនៃរូបវិទ្យា ដឹងពីឧបករណ៍អេឡិចត្រូនិច និងសៀគ្វី និងថាមពលមេកានិច
  - យល់ដឹងពីរូបវិទ្យាបូរាណ រូបវិទ្យាស្ថិតិ រូបវិទ្យាសាគរ រូបវិទ្យាអាតូមិច
  - យល់ដឹងពីអេឡិចត្រូឌីណាមិច និងចេះភាសាអង់គ្លេស ។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ** :
  - ជាសាស្ត្រាចារ្យរូបវិទ្យា នៅតាមគ្រឹះស្ថានសិក្សា
  - តាមបណ្តាក្រសួង ក្រុមហ៊ុន ធនាគារ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ។

### ៣-ជំនាញគីមីវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : គីមីវិទ្យា និង គណិតវិទ្យា

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ឆ្នាំ ស្មើនឹង ១៥៥ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - យល់ដឹងពីការពិសោធគីមីវិភាគ គីមីសរីរាង្គ គីមីរូប គីមីជីវៈ គីមីបរិស្ថាន
  - យល់ដឹងពីការសំយោគអសរីរាង្គ និងភាសាអង់គ្លេស ។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ជាសាស្រ្តាចារ្យគីមី នៅតាមគ្រឹះស្ថានសិក្សា
  - ទីពិសោធន៍ផ្សេងៗក្នុងស្ថាប័នរដ្ឋ និងឯកជន (ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
  - រោងចក្រផលិតចំណីអាហារ ស៊ីម៉ង់ត៍ ក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ

## ៤-ជំនាញជីវវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ជីវវិទ្យា និង គីមីវិទ្យា
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - មូលដ្ឋានគ្រឹះនៃជីវវិទ្យា
  - យល់ដឹងពីសរីរវិទ្យា គីមីជីវៈ កាយវិភាគរុក្ខជាតិ និងសត្វ
  - យល់ដឹងពីមីក្រូបវិទ្យា និងយល់ដឹងពីអេកូឡូស៊ីទូទៅ និងភាសាអង់គ្លេស ។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ជាសាស្រ្តាចារ្យជីវវិទ្យា នៅតាមគ្រឹះស្ថានសិក្សា
  - តាមបណ្តាក្រុមហ៊ុន ស្ថាប័ននានា អង្គការក្រៅរដ្ឋាភិបាល និងនៅតាមមន្ទីរពិសោធន៍ផ្សេងៗ។

## ៥-ជំនាញព័ត៌មានវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងរូបវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ឆ្នាំ ស្មើនឹង ១៦៤ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- យល់ដឹងពីការវិភាគ និងធ្វើគម្រោងប្រព័ន្ធព័ត៌មានវិទ្យា សរសេរកម្មវិធីកុំព្យូទ័រ
- យល់ដឹងពីការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ទំនាក់ទំនងទិន្នន័យ
- យល់ដឹងពីវិស្វករ Soft Ware កុំព្យូទ័រ Client-Server និងដឹងពីកម្មវិធីសារព័ត៌មាន និងបញ្ញាសិប្បនិម្មិត
- យល់ដឹងពីការគ្រប់គ្រងគម្រោង ប្រព័ន្ធប្រតិបត្តិការ និងភាសាអង់គ្លេស ។ល។

• **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ជាសាស្ត្រាចារ្យកុំព្យូទ័រនៅតាមគ្រឹះស្ថានសិក្សា
  - តាមបណ្តាក្រុមហ៊ុន ធនាគារ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ។

## ៦-ជំនាញបរិស្ថាន

• **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ជីវវិទ្យា និងគីមីវិទ្យា។

• **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ឆ្នាំ ស្មើនឹង ១៥៣ ក្រេឌីត។

• **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - យល់ដឹងពីថាមពល និងបរិស្ថាន ការគ្រប់គ្រងកាកសំណល់រឹង
  - យល់ដឹងពីគីមីបរិស្ថាន ច្បាប់បរិស្ថាន អេកូស៊ីសស្តែម
  - យល់ដឹងពីការគ្រប់គ្រងកាកសំណល់បំពុលទឹក និងភាសាអង់គ្លេស ។ល។

• **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ជាសាស្ត្រាចារ្យផ្នែកជីវវិទ្យា នៅតាមគ្រឹះស្ថានសិក្សា ក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ។

## ៧-ជំនាញគីមីជីវៈ

• **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គីមីវិទ្យា និងជីវវិទ្យា

• **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ឆ្នាំ យ៉ាងតិច ១២០ ក្រេឌីត។

• **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - យល់ដឹងពីគីមីសរីរាង្គ គីមីអសរីរាង្គ គីមីជីវៈ គីមីជីវសរីរាង្គ
  - យល់ដឹងពីជីវថាមពល ជីវវិទ្យាទូទៅ សារធាតុពុល និងចេះភាសាអង់គ្លេស ។ល។

• **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ:**

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- ជាសាស្ត្រាចារ្យគីមី នៅតាមគ្រឹះស្ថានសិក្សា
- ទីពិសោធន៍ផ្សេងៗក្នុងស្ថាប័នរដ្ឋ និងឯកជន (ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
- រោងចក្រផលិតចំណីអាហារ ស៊ីម៉ង់ត៍ ភេសជ្ជៈ ក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ។

## ៨-ជំនាញវិស្វកម្មនុយក្លេអ៊ែរ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល០៤ឆ្នាំ ស្មើនឹង ១៤០ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - យល់ដឹងពីមូលដ្ឋានគ្រឹះនៃគណិតវិទ្យា និងរូបវិទ្យាដើម្បីវិស្វកម្ម
  - ចេះវិភាគ និងកំណត់បញ្ហាផ្សេងៗក្នុងធម្មជាតិ ព្រមទាំងទាញរកមូលហេតុ និងឥទ្ធិពលចេញពីការវិភាគ
  - យល់ដឹងពីវិធីសាស្ត្រស្ថិតិនៅក្នុងវិស្វកម្ម និងដឹងពីយន្តការនៃប្រព័ន្ធកំដៅ និងប្រព័ន្ធអង្គធាតុរាវ
  - យល់ដឹងពីប្រព័ន្ធថេរភាព និងប្រព័ន្ធរញ្ជួយរបស់ធម្មជាតិ
  - បកស្រាយពីដំណោះស្រាយបែបវិស្វកម្មយ៉ាងត្រឹមត្រូវចំពោះប្រព័ន្ធមិនប្រក្រតី
  - មានសមត្ថភាពធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងវិស្វករជាច្រើន នៅក្នុងតំបន់ផ្សេងៗ
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ក្រសួងឧស្សាហកម្មកម្ម រ៉ែ និងថាមពល និងក្រសួងដែលមានការពាក់ព័ន្ធ
  - សាកលវិទ្យាល័យបាត់ដំបង
  - ក្រុមហ៊ុននៅប្រទេសកូរ៉េ។

## ៩-ជំនាញទេពកោសល្យ គីមី និងចំណីអាហារ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល០៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- មូលដ្ឋានគ្រឹះនៃរូបធាតុកែច្នៃផលិតផលកសិឧស្សាហកម្ម និងមីក្រូជីវៈអតិសុខុមប្រាណ ដែលបង្កជំងឺក្នុងចំណីអាហារ
- យល់ដឹងពីស្តង់ដារ និងការវេចខ្ចប់ចំណីអាហារ
- យល់ដឹងពីប្រព្រឹត្តិកម្មនៃការសម្អាតទឹក និងផ្នែកកម្តៅឧស្សាហកម្ម
- យល់ដឹងពីការគ្រប់គ្រង និងការសិក្សាទីផ្សារ

• **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
- ក្រសួងឧស្សាហកម្មកម្ម រ៉ែ និងថាមពល និងវិទ្យាស្ថានប៉ាស្ទ័រ
- ក្រុមហ៊ុន ឬរោងចក្រផលិតភេសជ្ជៈ សុរា និងចំណីអាហារនានា
- ក្រុមហ៊ុនថ្នាំជក់ និងមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា។

## ១០~ជំនាញវិស្វករសំណង់ស៊ីវិល

• **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។

• **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល០៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត។

• **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**
- ដឹងពីភាពធន់នៃសម្ភារ ការវិភាគ និងគណនាគ្រឿងបង្គុំ (អំពីដែក បេតុងអាម៉េ ឈើ បេតុងប្រេ៉កុងត្រាំង)
- យល់ដឹងពីការគណនាគ្រឹះសំណង់
- យល់ដឹងពីការសិក្សា និងគណនា ស្ពាននិងថ្នល់
- ការគ្រប់គ្រងការដ្ឋានសំណង់ និងសំណង់សិល្បៈការណ៍។

• **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
- ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមហ៊ុនសំណង់នានា
- ក្រុមហ៊ុនផលិតស៊ីម៉ង់ត៍ និងតាមស្ថាប័នផ្សេងៗ។

## ១១~ជំនាញវិស្វករអគ្គិសនី ថាមពល និងទូរគមនាគមន៍

• **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។

• **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត។

• **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**

facebook.com/moeyscambodia YouTube youtube.com/moeyscambodia

- យល់ដឹងពីអគ្គិសនីក្នុងអាគារ និងឧស្សាហកម្ម
- យល់ដឹងពីការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងផ្នែកឧស្សាហកម្ម និងការចែកចាយថាមពលអគ្គិសនី
- ដឹងពីរោងចក្រអគ្គិសនី និងអនុស្ថានីយ៍អគ្គិសនី បណ្តាញអគ្គិសនី
- យល់ដឹងពីស្វ័យប្រវត្តិកម្មទំនើបក្នុងសហគ្រាសឧស្សាហកម្ម
- យល់ដឹងពីប្រព័ន្ធទូរគមនាគមន៍ចល័ត និងអចល័ត។

- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - រោងចក្រ ឬក្រុមហ៊ុនអគ្គិសនី ក្រសួងឧស្សាហកម្មកម្ម រ៉ែ និងថាមពល
  - ក្រុមហ៊ុនផលិតថ្នាំជក់ ក្រុមហ៊ុនទូរសព្ទចល័ត និងអចល័ត និងតាមស្ថាប័នផ្សេងៗ។

## ១២-ជំនាញទេពកោសល្យព័ត៌មានវិទ្យា និងទំនាក់ទំនង

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**
  - យល់ដឹងពីវិធីសាស្ត្រក្នុងការសរសេរកម្មវិធីកុំព្យូទ័រ
  - យល់ដឹងពីប្រព័ន្ធប្រតិបត្តិការម៉ាស៊ីនកុំព្យូទ័រ
  - យល់ដឹងពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ បណ្តាញកុំព្យូទ័រ តក្កវិទ្យា
  - យល់ដឹងពីកម្មវិធី Internet និងកម្មវិធីពហុព័ត៌មាន និងបញ្ញាសិប្បនិម្មិត។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រាចារ្យតាមគ្រឹះស្ថានសិក្សា
  - ក្រុមហ៊ុនទូរសព្ទចល័ត និងអចល័ត ក្រុមហ៊ុន អង្គការ និងតាមស្ថាប័នផ្សេងៗ។

## ១៣-ជំនាញទេពកោសល្យឧស្សាហកម្ម និងមេកានិច

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**
  - យល់ដឹងពីមេកានិចនៃអង្គធាតុរឹង និងអង្គធាតុរាវ ទែរម៉ូឌីណាមិច និងទែរម៉ូឌីណាមិច

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- យល់ដឹងពីវិទ្យាសាស្ត្រ និងភាពធន់នៃសម្ភារ
- យល់ដឹងពីការកែច្នៃសម្ភារ ផលិតកម្មមេកានិច មាត្រាសាស្ត្រ
- យល់ដឹងពីការសិក្សាគម្រោង និងប្លង់ម៉ូទ័រចំហេះក្នុង
- យល់ដឹងពីម៉ាស៊ីនបរិក្ខារត្រជាក់ស្វ័យប្រវត្តិកម្ម អេឡិចត្រូតិចនិច
- យល់ដឹងពីការរៀបចំ និងការគ្រប់គ្រងសហគ្រាស។

• **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រុមហ៊ុនផលិតថ្នាំជក់
  - តាមបណ្តាក្រុមហ៊ុន អង្គការ និងតាមស្ថាប័នផ្សេងៗ។

## ១៤-ជំនាញទេពកោសល្យជនបទ (វិស្វកម្មធនធានទឹក និងភូគព្ភសាស្ត្រ)

• **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។

• **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត។

• **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**

**ក. វិស្វកម្មធនធានទឹកៈ**
  - យល់ដឹងអំពីវារីអគ្គិសនី
  - យល់ដឹងពីសំណង់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសំណង់ធារាសាស្ត្រ
  - យល់ដឹងពីការវិភាគគុណភាពទឹក ប្រព័ន្ធទឹកស្អាត និងការរំដោះទឹកកខ្វក់។

**ខ. វិស្វកម្មភូគព្ភសាស្ត្រៈ**
  - យល់ដឹងពីឋានលេខា និងព័ត៌មានភូមិសាស្ត្រ
  - យល់ដឹងពីគ្រឹះសំណង់អគារ និងផ្លូវថ្នល់
  - យល់ដឹងពីអាជីវកម្មខ្សាច់ ដីឥដ្ឋ គ្រួស និងអាជីវកម្មស៊ីម៉ង់ត៍។

• **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារៈ**
  - ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ
  - អាជ្ញាធរពាក់ព័ន្ធនានា មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍វិស័យកសិកម្ម ក្រុមហ៊ុន អង្គការ និងតាមស្ថាប័នផ្សេងៗ។

## ១៥-ជំនាញអក្សរសាស្ត្រខ្មែរ

• **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាខ្មែរ និង ប្រវត្តិវិទ្យា។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ឆ្នាំ ស្មើនឹង ១៦៥ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - មូលដ្ឋានគ្រឹះនៃអក្សរសាស្ត្រខ្មែរ និងអក្សរសិល្ប៍ខ្មែរ អាស៊ី បស្ចឹម ចិន និងឥណ្ឌា
  - យល់ដឹងពីទ្រឹស្តីអក្សរសិល្ប៍ វប្បធម៌ វេយ្យាករណ៍ ភាសាវិទ្យា វិធីសាស្ត្រស្រាវជ្រាវ
  - យល់ដឹងពីបាលីសំស្ក្រឹត សិល្បវិទ្យា សិលាចារិក និងភាសាអង់គ្លេស ។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រាចារ្យភាសាខ្មែរ នៅតាមគ្រឹះស្ថានសិក្សា
  - ជំនាញវិជ្ជានិពន្ធ ជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ ការងាររដ្ឋបាល តាមអង្គការក្រៅរដ្ឋាភិបាល និងតាមស្ថាប័នផ្សេងៗ។

## ១៦-ជំនាញទស្សនវិជ្ជា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាខ្មែរ និង ពលរដ្ឋវិជ្ជា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល០៤ឆ្នាំ ស្មើនឹង ១៦៤ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជា និងដឹងពីទស្សនវិជ្ជាប្រវត្តិសាស្ត្រ សាសនា និងទស្សនវិជ្ជា វិទ្យាសាស្ត្រសង្គម
  - យល់ដឹងពីប្រវត្តិគំនិតនយោបាយកម្ពុជា តក្កវិជ្ជា មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនយោបាយ
  - យល់ដឹងពីរូបធាតុនិយម បដិសំយោគ ផែនការយុទ្ធសាស្ត្រ និងភាសាអង់គ្លេស ។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រាចារ្យទស្សនវិជ្ជា នៅតាមគ្រឹះស្ថានសិក្សា
  - ការងាររដ្ឋបាល តាមក្រសួង ក្រុមហ៊ុន តាមបណ្តាអង្គការ ស្ថាប័នផ្សេងៗ។

## ១៧-ជំនាញប្រវត្តិវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និង ភាសាខ្មែរ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល០៤ឆ្នាំ ស្មើនឹង ១៤៨ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- មូលដ្ឋានគ្រឹះនៃប្រវត្តិវិទ្យា និងដឹងពីប្រវត្តិស្រាវជ្រាវនិពន្ធ ប្រវត្តិសាស្ត្រសកលលោក
- យល់ដឹងពីសិលាចារិកមុនអង្គរ និងសម័យអង្គរ ប្រវត្តិសិល្បៈខ្មែរ
- យល់ដឹងពីមគ្គុទ្ទេសក៍ទេសចរណ៍ ប្រវត្តិឧស្សាហកម្មទេសចរណ៍ និងភាសាអង់គ្លេស ។ល។

• **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រាចារ្យប្រវត្តិវិទ្យា នៅតាមគ្រឹះស្ថានសិក្សា
  - ការងាររដ្ឋបាល តាមក្រសួង តាមបណ្តាអង្គការ ស្ថាប័នផ្សេងៗ ការងារក្រុមហ៊ុននានា។

## ១៨-ជំនាញភូមិវិទ្យា និងរៀបចំដែនដី

• **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភូមិវិទ្យា និងគណិតវិទ្យា។

• **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល០៤ឆ្នាំ ស្មើនឹង ១៦០ ក្រេឌីត។

• **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - មូលដ្ឋានគ្រឹះនៃភូមិវិទ្យា និងដឹងពីភូមិវិទ្យារូបកម្ពុជា ឧស្សាហកម្ម ផែនដីវិទ្យា ភូមិវិទ្យានយោបាយ
  - យល់ដឹងពីការដឹកជញ្ជូនអន្តរជាតិ ការរៀបចំដែនដី
  - យល់ដឹងពីកំណើនប្រជាជន និងការអភិវឌ្ឍ និងភាសាអង់គ្លេស ។ល។

• **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រាចារ្យភូមិវិទ្យា សាស្ត្រាចារ្យផែនដីវិទ្យា សាស្ត្រាចារ្យបរិស្ថាន នៅតាមគ្រឹះស្ថានសិក្សា
  - ក្រសួងបរិស្ថាន ការងារក្រុមហ៊ុន និងជាអ្នកស្រាវជ្រាវជាមួយអង្គការក្រៅរដ្ឋាភិបាល។

## ១៩-ជំនាញចិត្តវិទ្យា

• **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងជីវវិទ្យា។

• **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ:** មានរយៈពេល០៤ឆ្នាំ ស្មើនឹង ១៦៣ ក្រេឌីត។

• **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - មូលដ្ឋានគ្រឹះនៃចិត្តវិទ្យា និងដឹងពីចិត្តវិទ្យាអន្តរវប្បធម៌ ការព្យាបាលលក្ខណៈគ្រួសារ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- យល់ដឹងពីទ្រឹស្តីបុគ្គលិកលក្ខណៈ នរចិត្តវិទ្យា ចិត្តវិទ្យាអប់រំ
- យល់ដឹងពីវិធីសាស្ត្រស្រាវជ្រាវ និងស្ថិតិក្នុងចិត្តវិទ្យា និងភាសាអង់គ្លេស ។ល។

- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រចារ្យចិត្តវិទ្យា នៅតាមគ្រឹះស្ថានសិក្សា និងជាអ្នកជំនាញ ជាអ្នកស្រាវជ្រាវរបស់ក្រុមហ៊ុន
  - បណ្តាអង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុន និងស្ថាប័នផ្សេងៗ។

## ២០~ជំនាញសង្គមវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាខ្មែរ និងគណិតវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល០៤ឆ្នាំ ស្មើនឹង ១៥៨ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - យល់ដឹងពីវិទ្យាសាស្ត្រនយោបាយ ស្រាវជ្រាវវិភាគទិន្នន័យសង្គមវិទ្យា
  - យល់ដឹងពីសង្គមវិទ្យាវប្បធម៌ សាសនា បរិស្ថាន សេដ្ឋកិច្ច
  - យល់ដឹងពីការស្រាវជ្រាវ និងនិពន្ធក្នុងសង្គមវិទ្យា និងភាសាអង់គ្លេស ។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រចារ្យសង្គមវិទ្យា នៅតាមគ្រឹះស្ថានសិក្សា
  - តាមបណ្តាអង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុន និងស្ថាប័ននានា។

## ២១~ជំនាញសង្គមកិច្ចវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាខ្មែរ និងគណិតវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល០៤ឆ្នាំ ស្មើនឹង ១៦០ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - យល់ដឹងពីប្រវត្តិគំនិតនយោបាយ អភិវឌ្ឍន៍គម្រោង
  - យល់ដឹងពីសង្គមវិទ្យាសាសនា សង្គមវិទ្យាច្បាប់ និងសង្គមវិទ្យាប្រជាធិបតេយ្យ
  - យល់ដឹងពីសង្គមវិទ្យាទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ និងភាសាអង់គ្លេស ។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រចារ្យសង្គមវិទ្យា នៅតាមគ្រឹះស្ថានឧត្តមសិក្សា

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- តាមបណ្ដាអង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុន និងស្ថាប័ននានា។

## ២២-ជំនាញប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាអង់គ្លេស និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពីភាសាអង់គ្លេស និងវប្បធម៌ទូទៅ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល០៤ឆ្នាំ យ៉ាងតិច ១២០ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - យល់ដឹងពីភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង និងមូលដ្ឋានសារព័ត៌មាន
  - យល់ដឹងពីច្បាប់ និងសីលធម៌ប្រព័ន្ធផ្សព្វផ្សាយ
  - យល់ដឹងពីការស្រាវជ្រាវ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ
  - យល់ដឹងពីទំនាក់ទំនងសាធារណៈ និងពាណិជ្ជកម្ម
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ស្ថាប័នរដ្ឋ (ក្រសួងព័ត៌មាន ស្ថានីយទូរទស្សន៍)
  - អ្នកយកព័ត៌មានក្នុងប្រទេស-ក្រៅប្រទេស និងធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល។

## ២៣-ជំនាញគ្រប់គ្រង

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និង ពលរដ្ឋវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ឆ្នាំ ស្មើនឹង ១២៩ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - យល់ដឹងពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង
  - ចេះធ្វើផែនការយុទ្ធសាស្ត្រ និងគ្រប់គ្រងធនធានមនុស្ស។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - គ្រប់ស្ថាប័នរដ្ឋ ភ្នាក់ងាររដ្ឋាភិបាលជាតិ/អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល
  - អង្គភាពអាជីវកម្មផ្ទាល់ខ្លួន និងឯកជន។

## ២៤-ជំនាញទីផ្សារ ឬម៉ាឃីតធីង

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និង ពលរដ្ឋវិទ្យា។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល៤ឆ្នាំ ស្មើនឹង ១២៩ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :
  - យល់ដឹងពីមូលដ្ឋានគ្រឹះនៃទីផ្សារ និងការស្រាវជ្រាវទីផ្សារ
  - យល់ដឹងពីការគ្រប់គ្រងទីផ្សារ និងរៀបចំផែនការយុទ្ធសាស្ត្រ
  - យល់ដឹងពីយុទ្ធសាស្ត្រនៃការកំណត់ថ្លៃ
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ** :
  - គ្រប់ស្ថាប័នរដ្ឋ ភ្នាក់ងាររដ្ឋាភិបាលជាតិ/អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល
  - អង្គភាពអាជីវកម្មផ្ទាល់ខ្លួន និងឯកជន។

## ២៥-ជំនាញទេសចរណ៍

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : ប្រវត្តិវិទ្យា និង ភូមិវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល៤ឆ្នាំ ស្មើនឹង ១២៩ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :
  - ចំណេះដឹងទូទៅអំពីសេដ្ឋកិច្ចទេសចរណ៍ជាតិ និងអន្តរជាតិ
  - យល់ដឹងពីការបង្កើន និងវិភាគសក្តានុពលទេសចរណ៍
  - យល់ដឹងពីជំនាញក្នុងផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ច និងដឹងពីវិធីជាមគ្គុទ្ទេសក៍ទេសចរណ៍ដ៏ចំណាន។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ** :
  - នៅតាមក្រសួង និងមន្ទីរទេសចរណ៍ តាមសណ្ឋាគារ ភោជនីយដ្ឋាន ក្រុមហ៊ុនដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍
  - បើកក្រុមហ៊ុនទេសចរណ៍ខ្លួនឯង។

## ២៦-ជំនាញសេដ្ឋកិច្ច-ពាណិជ្ជកម្ម

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : គណិតវិទ្យា និង សីលធម៌ពលរដ្ឋ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល៤ឆ្នាំ ស្មើនឹង ១២៩ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- ចំណេះដឹងទូទៅអំពីទ្រឹស្តីសេដ្ឋកិច្ច
- យល់ដឹងពីគោលនយោបាយរដ្ឋាភិបាលលើបញ្ហាសេដ្ឋកិច្ច ពាណិជ្ជកម្មអន្តរជាតិ និងអត្ថប្រយោជន៍
- ចំណេះដឹងមូលដ្ឋានរបស់អាជីវកម្ម កិច្ចការគណនេយ្យ និងធនាគារ

- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារបាន :**
  - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាស្ត្រាចារ្យនៅតាមគ្រឹះស្ថានសិក្សា
  - អ្នកកត់ត្រាបញ្ជីរបស់ក្រុមហ៊ុនឯកជននានា ជាអ្នកវិភាគសេដ្ឋកិច្ច វិភាគគម្រោង
  - អង្គការសង្គមស៊ីវិល និងអន្តរជាតិនានា ។ល។

## ២៧-ជំនាញនីតិសាស្ត្រ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ឆ្នាំ ស្មើនឹង ១៤៦.៥ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - ចំណេះដឹងទូទៅអំពីច្បាប់
  - យល់ដឹងពីទ្រឹស្តីច្បាប់ជាមូលដ្ឋាន ទ្រឹស្តីជំនាញ
  - យល់ដឹងពីការងារប្រតិបត្តិ និងសីលធម៌ និងអាចពិគ្រោះយោបល់ផ្នែកច្បាប់។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - គ្រប់ក្រសួងជំនាញ ស្ថាប័នតុលាការ (ចៅក្រម មេធាវី ក្រឡាបញ្ជី សារការី)
  - ក្រុមហ៊ុនមេធាវីឯកជន អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិនានា ក្រុមហ៊ុនឯកជន និងអន្តរជាតិ។

## ២៨-ជំនាញរដ្ឋបាលសាធារណៈ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ឆ្នាំ ស្មើនឹង ១៣៧ ក្រេឌីត។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - ចំណេះដឹងពីទ្រឹស្តីជាមូលដ្ឋាន ទ្រឹស្តីឯកទេសខាងច្បាប់នយោបាយ និងសីលធម៌
  - ចំណេះដឹងពីការពិគ្រោះយោបល់ផ្នែកច្បាប់។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - គ្រប់ស្ថាប័នរដ្ឋបាលសាធារណៈ និងគ្រប់ក្រសួងជំនាញ
  - ស្ថាប័នតុលាការ (ចៅក្រម មេធាវី ក្រឡាបញ្ជី សាការី) ក្រុមហ៊ុនមេធាវីឯកជន និងអន្តរជាតិ
  - អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិនានា ក្រុមហ៊ុនឯកជនជាតិ និងអន្តរជាតិ។

## ២៩-ជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ**:គណិតវិទ្យា និងសីលធម៌ពលរដ្ឋ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល៤ឆ្នាំ ស្មើនឹង ១៣១ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយបញ្ចប់ការសិក្សារយៈពេល ៤ឆ្នាំ :**
  - ចំណេះទូទៅអំពីទ្រឹស្តីសេដ្ឋកិច្ច និងការគ្រប់គ្រង
  - យល់ដឹងពីការអភិវឌ្ឍសេដ្ឋកិច្ច និងការព្យាករណ៍សេដ្ឋកិច្ច។
- **អង្គភាព ឬមូលដ្ឋានដែលសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធ
  - ធនាគារជាតិ និងធនាគារឯកជន ស្ថាប័នមីក្រូហិរញ្ញវត្ថុ អង្គការអន្តរជាតិ និងក្រុមហ៊ុនឯកជននានា។

## ៣០. ជំនាញធនាគារ និងហិរញ្ញវត្ថុ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : គណិតវិទ្យា និងសីលធម៌ពលរដ្ឋ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល ៤ឆ្នាំ ស្មើនឹង១២៩ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - ចំណេះដឹងទូទៅអំពីទ្រឹស្តីធនាគារ និងហិរញ្ញវត្ថុ
  - ដឹងពីផ្នែកធនាគារ និងហិរញ្ញវត្ថុ និងយល់ដឹងពីហានិភ័យធនាគារ និងហិរញ្ញវត្ថុ
  - យល់ដឹងពីស្ថាប័នហិរញ្ញវត្ថុជាតិ និងអន្តរជាតិ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាក់ព័ន្ធ ធនាគារជាតិ និងធនាគារឯកជន ស្ថាប័នមីក្រូហិរញ្ញវត្ថុ

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

– អង្គការអន្តរជាតិ និងក្រុមហ៊ុនឯកជននានា ទីផ្សារហ៊ុន ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនមូលបត្រ។

## ៣១. ជំនាញគណនេយ្យ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងសីលធម៌ពលរដ្ឋ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១៣២ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - ចំណេះដឹងទូទៅអំពីទ្រឹស្តីគណនេយ្យ និងហិរញ្ញវត្ថុ
  - យល់ដឹងពីការងារពន្ធដារ សវនកម្ម និងការងារពាក់ព័ន្ធ
  - យល់ដឹងពីការគ្រប់គ្រងទីផ្សារហិរញ្ញវត្ថុ និងស្តង់ដាគណនេយ្យ ការវិភាគ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុ
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ៖**
  - ក្រសួងពាក់ព័ន្ធ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) នៅធនាគារឯកជន
  - ស្ថាប័នមីក្រូហិរញ្ញវត្ថុ អង្គការ ក្រុមហ៊ុនសវនកម្ម និងក្រុមហ៊ុនផ្តល់សេវាកម្មគណនេយ្យ និងក្រុមហ៊ុននានា។

## ៣២. ជំនាញសេដ្ឋកិច្ចព័ត៌មានវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងសីលធម៌ពលរដ្ឋ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១៣៧ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - ចំណេះដឹងទូទៅអំពីទ្រឹស្តីវិទ្យាសាស្ត្រកុំព្យូទ័រ និងសេដ្ឋកិច្ច
  - ចេះប្រើប្រាស់ និងអនុវត្តជាក់ស្តែងផ្នែកបច្ចេកវិទ្យាកុំព្យូទ័រ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ៖**
  - ក្រសួងពាក់ព័ន្ធ នៅធនាគារជាតិ និងធនាគារឯកជន ស្ថាប័នមីក្រូហិរញ្ញវត្ថុ អង្គការ និងក្រុមហ៊ុនឯកជននានា។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

## ១៣. ជំនាញបុរាណវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : ប្រវត្តិសាស្ត្រ និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពីប្រវត្តិប្រាសាទ និងបុរាណដ្ឋាននៅកម្ពុជា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១៤៤ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :
  - មូលដ្ឋានគ្រឹះនៃវប្បធម៌ អារ្យធម៌ ជំនឿទំនៀមទម្លាប់ខ្មែរ អាស៊ីអាគ្នេយ៍ និងអារ្យធម៌ធំៗក្នុងលោក
  - យល់ដឹងពីឯកទេសបុរាណវិទូ នរវិទូ ឯកទេសផ្នែកជួសជុល និងថែទាំបេតិកភណ្ឌ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ៖**
  - ក្រសួង មន្ទីរ ស្ថាប័នរដ្ឋ និងអាជ្ញាធរជាតិដែលពាក់ព័ន្ធផ្នែកវប្បធម៌ (អាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ)
  - អង្គការអន្តរជាតិ ដែលកំពុងប្រតិបត្តិជួសជុលប្រាសាទ និងស្រាវជ្រាវអំពីសង្គមវប្បធម៌។

## ១៤. ជំនាញស្ថាបត្យកម្ម និងនគររូបនីយវិទ្យា

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : រូបវិទ្យា និងគណិតវិទ្យា និងត្រូវឆ្លងកាត់ការប្រឡងអំពីគំនូរមើលឃើញ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល ៥ឆ្នាំកន្លះ ស្មើនឹង ១៤៤ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :
  - មូលដ្ឋានចំណេះដឹងអំពីការថែទាំអភិរក្សស្ថាបត្យកម្មបុរាណ
  - យល់ដឹងពីការសិក្សាគម្រោងស្ថាបត្យកម្ម និងសំណង់។
  - យល់ដឹងពីការបង្កើតផែនការមេ សម្រាប់ការរៀបចំក្រុង និងរៀបចំដែនដី។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ៖**
  - តាមស្ថាប័នរដ្ឋ និងឯកជន អង្គការនានា ការងារជួសជុលនិងថែទាំប្រាសាទបុរាណនានា
  - ក្លាយជាស្ថាបត្យករ និងអ្នកមៅការសាងសង់ តាមរយៈការបើកក្រុមហ៊ុនសាងសង់ផ្ទាល់ខ្លួន។

## ១៥. ជំនាញតុបតែងលំអនៃស្ថាបត្យកម្ម

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : ប្រវត្តិវិទ្យា និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពីគំនូរមើលឃើញ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៥០ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - មូលដ្ឋានគ្រឹះអំពីរបៀបតុបតែងលំអខាងក្នុង និងខាងក្រៅគេហដ្ឋាន ឬអគារគ្រប់ប្រភេទ
  - ដឹងពីក្បាច់ និងសោភ័ណភាព អំពីស្ថាបត្យកម្មខ្មែរ និងចេះបកស្រាយអត្ថន័យនៃតម្លៃសិល្បៈខ្មែរ
  - ស្គាល់ពីតម្លៃសិល្បៈបែបប្រពៃណីបុរាណ និងតាមបែបសម័យទំនើប។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ក្រុមហ៊ុនសំណង់ ឬក្រុមហ៊ុនតុបតែង និងអាចមានលទ្ធភាពប្រកបអាជីវកម្មផ្ទាល់ខ្លួន។

## ៣៦. ជំនាញគំនូរវិចិត្រកម្ម

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពីគំនូរមើលឃើញ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៥០ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - ស្គាល់ទីតាំងបុរាណដ្ឋានប្រវត្តិសាស្ត្រ ដើម្បីសិក្សាពីមូលដ្ឋានក្បាច់ និងសោភ័ណភាពស្ថាបត្យកម្មខ្មែរ
  - ចេះថតរូប រោងជាងឯកទេសនីមួយៗ និងដឹងពីប្រវត្តិសិល្បៈខ្មែរ សិល្បៈអាស៊ីអាគ្នេយ៍ និងបស្ចឹមប្រទេស
  - ចេះរៀបចំពណ៌ ក្បាច់ខ្មែរ គំនូរទេសភាព សោភ័ណវិទ្យា។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - តាមស្ថាប័នរដ្ឋ ឬក្រុមហ៊ុន ដែលធ្វើការពាក់ព័ន្ធក្រាហ្វិក និងតុបតែង
  - តាមសារមន្ទីរ និងស្ថាប័នដែលថែរក្សាគំនូរបុរាណដែលមានតម្លៃប្រវត្តិសាស្ត្រ និងអាចបើកអាជីវកម្មផ្ទាល់ខ្លួន

## ១៧. ជំនាញចម្លាក់ទំនើប

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពីគំនូរមើលឃើញ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៥០ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - មូលដ្ឋានគ្រឹះនៃក្បាច់ និងសោភ័ណភាពស្ថាបត្យកម្មខ្មែរ
  - ដឹងពីក្បួនខ្នាតខ្មែរ និងនិន្នាការសិល្បៈសហសម័យ និងសិល្បៈដែលឆ្លុះបញ្ចាំងតាមគំនិត
  - ចេះប្រៀបធៀបប្រវត្តិសិល្បៈខ្មែរ នឹងសិល្បៈបស្ចឹមប្រទេស និងចេះបកស្រាយពីតម្លៃនៃសិល្បៈខ្មែរ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - តាមស្ថាប័នរដ្ឋ ឬក្រុមហ៊ុន ដែលធ្វើការពាក់ព័ន្ធក្រាហ្វិក និងតុបតែង
  - តាមសារមន្ទីរ និងស្ថានប័នដែលធ្វើការថែរក្សាប្រាសាទ និងរូបចម្លាក់
  - ក្លាយជាសិល្បៈករចម្លាក់ និងអាចបើកអាជីវកម្មផ្ទាល់ខ្លួន។

## ១៨. ជំនាញគំនូរសារគមនាគមន៍

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពីគំនូរមើលឃើញ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៥០ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - ចំណេះដឹងពីរបៀបច្នៃបង្កើតគំរូផលិតផល ការវេចខ្ចប់ទំនិញ រូបភាពឡូហ្គោ
  - ដឹងពីក្បួនខ្នាតខ្មែរ និន្នាការសិល្បៈសហសម័យ និងសិល្បៈដែលឆ្លុះបញ្ចាំងតាមគំនិត
  - ដឹងមូលដ្ឋានគ្រឹះនៃក្បាច់ និងសោភ័ណភាពស្ថាបត្យកម្មខ្មែរ និងចេះបកស្រាយពីតម្លៃនៃសិល្បៈខ្មែរ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - តាមស្ថាប័ន ឬក្រុមហ៊ុន ដែលធ្វើការពាក់ព័ន្ធក្រាហ្វិក និងតុបតែង
  - តាមបណ្ដាគ្រឹះស្ថានបោះពុម្ពផ្សព្វផ្សាយ និងរោងពុម្ព អាចមានលទ្ធភាពប្រកបអាជីវកម្មផ្ទាល់ខ្លួន។

## ១៩. ជំនាញគ្រប់គ្រងធនធានមនុស្ស

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ៖** ពលរដ្ឋវិជ្ជា និងគណិតវិទ្យា។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ យ៉ាងតិច ស្មើនឹង ១២០ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - ចំណេះដឹងក្នុងការគ្រប់គ្រងមនុស្សនៅក្នុងអង្គភាព និងការរៀបចំផែនការយុទ្ធសាស្ត្រ
  - ដឹងពីការធ្វើផែនការបណ្តុះបណ្តាលបុគ្គលិក និងរៀបចំធនធានមនុស្ស
  - យល់ដឹងពីការវាយតម្លៃគុណភាពបុគ្គលិក ទំនាក់ទំនងក្នុងអង្គភាព និងបណ្តាក្រុមហ៊ុននានា
  - ចេះរៀបចំលក្ខខណ្ឌការងារ សុវត្ថិភាពការងារ និងសុខមាលភាពការងារ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - គ្រប់ក្រសួង ស្ថាប័ន ក្រុមហ៊ុននានា អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិនានា។

## ៤០. ជំនាញពាណិជ្ជកម្មអន្តរជាតិ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាខ្មែរ និង គណិតវិទ្យា។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១២០ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - ចំណេះដឹងមូលដ្ឋាននៃការគ្រប់គ្រងពាណិជ្ជកម្ម និងពាណិជ្ជកម្មអន្តរជាតិ
  - ចំណេះដឹងអំពីបរិស្ថានពាណិជ្ជកម្មអន្តរជាតិ និងភាពជាអ្នកដឹកនាំ
  - យល់ដឹងពីក្រមសីលធម៌នៃការធ្វើជំនួញប្រកបដោយភាពជោគជ័យ
  - យល់ដឹងពីវិធីសាស្ត្រនៃការកាត់បន្ថយហានិភ័យក្នុងការធ្វើពាណិជ្ជកម្ម។
- **នៅពេលដែលបញ្ចប់ការសិក្សាមុខជំនាញនេះនិស្សិតអាចទៅបម្រើការងារ :**
  - ក្រសួងស្ថាប័ននានា (ក្រសួងពាណិជ្ជកម្ម) ក្រុមហ៊ុននីហរ័ណ អាហរ័ណ និងតាមអង្គការជាតិ និងអន្តរជាតិ
  - ការងារផ្នែកអភិវឌ្ឍន៍ជំនួញ និងអាចបើកអាជីវកម្មដោយខ្លួនឯង។

## ៤១. ជំនាញគ្រប់គ្រងសណ្ឋាគារ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និង សីលធម៌ពលរដ្ឋ។

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៣២ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :
  - ចំណេះដឹងទូទៅផ្នែកគ្រប់គ្រងសណ្ឋាគារ និងការគ្រប់គ្រង និងបណ្តុះបណ្តាលបុគ្គលិក
  - ចំណេះដឹងផ្នែកជំនាញវិភាគ និងព្យាករណ៍ស្ថានភាពសង្គម និងសេដ្ឋកិច្ច។
- **ក្រោយពេលបញ្ចប់ការសិក្សាមុខជំនាញនេះ និស្សិតអាចទៅបម្រើការងារ** :
  - តាមស្ថាប័នរដ្ឋ និងស្ថាប័នឯកជន សណ្ឋាគារ ភោជនីយដ្ឋាន និងក្រុមហ៊ុននានា
  - ក្លាយជាម្ចាស់ជំនួញខ្លួនឯងបាន។

## ៤២. ជំនាញភាសាអង់គ្លេស

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : សីលធម៌ពលរដ្ឋ និងភាសាអង់គ្លេស និងត្រូវឆ្លងកាត់ការប្រឡងវិញ្ញាសាសរសេរភាសាអង់គ្លេស។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល ០៤ឆ្នាំ យ៉ាងតិច ស្មើនឹង ១២០ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :
  - ចំណេះដឹងជំនាញ ការសរសេរ ស្តាប់ អាន និងនិយាយ
  - ចំណេះដឹងទូទៅផ្នែកភាសា ជំនាញបកប្រែភាសា និងជំនាញមគ្គុទ្ទេសក៍ទេសចរណ៍។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ** :
  - គ្រប់ក្រសួងស្ថាប័ន ក្រុមហ៊ុន អង្គការជាតិ និងអន្តរជាតិ
  - សាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងក្លាយជាមគ្គុទ្ទេសក៍ទេសចរណ៍ដ៏ចំណាន។

## ៤៣. ជំនាញភាសាកូរ៉េ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ** : សីលធម៌ពលរដ្ឋ និងត្រូវឆ្លងកាត់ការប្រឡងវិញ្ញាសាភាសាខ្មែរ និងភាសាអង់គ្លេស។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ** : មានរយៈពេល ០៤ឆ្នាំ យ៉ាងតិច ស្មើនឹង ១៣០ ក្រេឌីត។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ** :
  - ចំណេះដឹងពីជំនាញប្រាស្រ័យទាក់ទងទាំងបួនគឺ សរសេរ អាន ស្តាប់ និងនិយាយ
  - ចេះសរសេរគម្រោងស្រាវជ្រាវ និងចំណេះដឹងខាងវប្បធម៌ និងអក្សរសាស្ត្រកូរ៉េ
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ** :

facebook.com/moeys.gov.kh YouTube youtube.com/moeyscambodia

- តាមក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ (ក្រសួងទេសចរណ៍)
- ស្ថានទូតកូរ៉េ ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាលមកពីកូរ៉េ
